# ដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ

"ករណីប្រទេសកម្ពុជា និងចំណេះដឹងពីតំបន់អាស៊ាន"



Australian Aid

ពន្លក ចំណេះ

The Asia Foundation

# ដំណើរការគោលនយោបាយ
# និងការប្រើប្រាស់ទិន្នន័យ

## ករណីប្រទេសកម្ពុជា
## និងចំណេះដឹងពីតំបន់អាស៊ាន

ឆ្នាំ២០២១

បណ្ឌិត ប៉ក់ គឹមជឿន



**អំណះអំណាង**

ការសិក្សានេះ ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈ "កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា" របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលលើកឡើងក្នុងការសិក្សានេះ គឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ីឡើយ។

©អង្គការមូលនិធិអាស៊ី ២០២១

# មាតិកា


**បញ្ជីប្រអប់ រូបភាព និងតារាង** ..... i
**ពាក្យកាត់** ..... iii
**សេចក្តីសង្ខេប** ..... ១
**១. សេចក្តីផ្តើម** ..... ៨
១.១ សារតារ និងសនិទានភាព ..... ៨
១.២ គោលបំណងនៃការស្រាវជ្រាវ និងសំណួរក្នុងការស្រាវជ្រាវ ..... ១១
១.៣ វិធីសាស្ត្រ ..... ១៣
១.៤ រចនាសម្ព័ន្ធនៃរបាយការណ៍នេះ ..... ១៤
**២. និន្នាការធំៗក្រោយវិបត្តិកូវីដ-១៩៖ អាទិភាពរបស់កម្ពុជា និងតំបន់អាស៊ាន** ..... ១៦
២.១ និន្នាការធំៗក្រោយវិបត្តិកូវីដ-១៩ ..... ១៦
២.២ អាទិភាពអភិវឌ្ឍន៍របស់កម្ពុជា ..... ១៩
២.៣ ផែនការស្តារឡើងវិញរបស់អាស៊ាន និងកម្ពុជាក្នុងនាមជាប្រធានប្តូរវេនអាស៊ាន នៅឆ្នាំ ២០២២ ..... ២៤
**៣. ដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា** ..... ២៩
៣.១ ការកំណត់និយមន័យនៃគោលនយោបាយសាធារណៈនៅកម្ពុជា ..... ២៩
៣.២ ភាគីពាក់ព័ន្ធ និងយន្តការ ..... ៣៧
៣.៣ ដំណាក់កាលសំខាន់ៗក្នុងដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ ..... ៣៩
៣.៣.១ ដំណាក់កាលតាក់តែងគោលនយោបាយ ..... ៤៣
៣.៣.២ ការអនុវត្តគោលនយោបាយ ..... ៤៧
៣.៣.៣ ដំណាក់កាលពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ ..... ៤៩
៣.៣.៤ លក្ខណៈសំខាន់ៗនៃដំណើរការគោលនយោបាយនៅកម្ពុជា ..... ៥៣
**៤. អភិបាលកិច្ចទិន្នន័យសម្រាប់គោលបំណងគោលនយោបាយនៅកម្ពុជា** ..... ៥៦
៤.១ ក្របខ័ណ្ឌទស្សនាទាន និងក្របខ័ណ្ឌគោលនយោបាយ ..... ៥៦
៤.១.១ ក្របខ័ណ្ឌទស្សនាទាន ..... ៥៦
៤.១.២ ក្របខ័ណ្ឌគោលនយោបាយ ..... ៦០
៤.២ រដ្ឋាភិបាលក្នុងនាមជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យ ..... ៦៣
៤.២.១ ការអនុវត្ត និងវឌ្ឍនភាពនាពេលបច្ចុប្បន្ន ..... ៦៣
៤.២.២ បញ្ហាប្រឈមដែលនៅសេសសល់ ..... ៦៥
៤.៣ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងនាមជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យ ..... ៦៦
៤.៣.១ វឌ្ឍនភាពថ្មីៗ និងបញ្ហាទំនុកចិត្ត ..... ៦៧

៤.៣.២ លទ្ធភាពទទួលបានទិន្នន័យ និងការប្រើប្រាស់ទិន្នន័យ ..... ៧១
៤.៣.៣ ការជំរុញការចូលរួមរបស់វិស័យឯកជន និងទិន្នន័យសម្រាប់គោលបំណងឯកជន ..... ៧៣
៤.៤ ទិន្នន័យ និងរដ្ឋាភិបាលឌីជីថល ..... ៧៥
៤.៥ អភិបាលកិច្ចទិន្នន័យ និងភាពជាដៃគូនៅកម្រិតអាស៊ាន ..... ៧៩
**៥. ករណីសិក្សាចំនួន ៤ ស្តីពីការប្រើប្រាស់ទិន្នន័យ និងដំណើរការគោលនយោបាយ** ..... ៨៥
៥.១ ករណីសិក្សាទី១៖ កិច្ចគាំពារសង្គមក្នុងអំឡុងពេលឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ..... ៨៦
៥.១.១ កិច្ចគាំពារសង្គម និងការប្តេជ្ញាចិត្តផ្នែកនយោបាយ ..... ៨៦
៥.១.២ ការប្រើប្រាស់ទិន្នន័យ និងកំណែទម្រង់បន្ថែម ..... ៨៧
៥.១.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន ..... ៩១
៥.២ ករណីសិក្សាទី២៖ កំណែទម្រង់វិមជ្ឈការ ..... ៩១
៥.២.១ វិមជ្ឈការ និងបញ្ហាប្រឈមក្នុងការសម្របសម្រួល ..... ៩១
៥.២.២ បញ្ហាប្រឈមសម្រាប់ការប្រើប្រាស់ទិន្នន័យក្នុងវិមជ្ឈការ ..... ៩៣
៥.២.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន ..... ៩៦
៥.៣ ករណីសិក្សាទី៣៖ ការជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍នៅអំឡុងវិបត្តិកូវីដ-១៩ ..... ៩៦
៥.៣.១ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ និងជំនួយរបស់រដ្ឋាភិបាលក្នុងអំឡុងវិបត្តិកូវីដ-១៩ ..... ៩៧
៥.៣.២ គោលនយោបាយ និងការប្រើប្រាស់ទិន្នន័យដើម្បីជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ ..... ១០១
៥.៣.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន ..... ១០៣
៥.៤ ករណីសិក្សាទី៤៖ ការជំរុញការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសហគមន៍ ..... ១០៤
៥.៤.១ គោលនយោបាយ និងការប្រើប្រាស់ទិន្នន័យស្តីពីការអភិវឌ្ឍយុវជនសហគមន៍ ..... ១០៤
៥.៤.២ កម្មវិធីថ្មីមួយស្តីពីការស្ម័គ្រចិត្តរបស់យុវជន និងការអភិវឌ្ឍសហគមន៍ ..... ១០៦
៥.៤.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន ..... ១០៧
**៦. សេចក្តីសន្និដ្ឋានសំខាន់ៗ និងអនុសាសន៍សម្រាប់កម្មវិធី** ..... ១០៨
៦.១ សេចក្តីសន្និដ្ឋានសំខាន់ៗ ..... ១០៨
៦.២ អនុសាសន៍សម្រាប់ការពិចារណាក្នុងការរៀបចំកម្មវិធី ..... ១១១
**ឯកសារយោង** ..... ១១៦
**ឧបសម្ព័ន្ធ** ..... ១១៩
ឧបសម្ព័ន្ធ១៖ ស្ថាប័នរបស់អ្នកផ្តល់ព័ត៌មានសំខាន់ ..... ១១៩
ឧបសម្ព័ន្ធ២៖ ឧទាហរណ៍នៃគេហទំព័រផ្លូវការដែលមានទិន្នន័យ និង/ឬមូលដ្ឋានទិន្នន័យល្អៗ ..... ១២០

# បញ្ជីប្រអប់ រូបភាព និងតារាង


ប្រអប់ទី១៖ ចំណុចសំខាន់ៗនៃផែនការស្តារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោយវិបត្តិកូវីដ-១៩.... ២០
ប្រអប់ទី២៖ តួនាទីរបស់ក្រសួងហិរញ្ញវត្ថុ៖ ការអនុវត្តជាអន្តរជាតិ និងការអនុវត្តនៅកម្ពុជា.................. ២២
ប្រអប់ទី៣៖ ភាគីពាក់ព័ន្ធសំខាន់ៗ និងដំណើរការនៃការរៀបចំ និងអនុម័តឯកសារច្បាប់ .................. ៣៦
ប្រអប់ទី៤៖ ចំណុចសំខាន់ៗនៃគោលការណ៍ណែនាំស្តីពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ........................................................................................ ៥០
ប្រអប់ទី៥៖ CamStat–ការសាកល្បងដែលអាចធ្វើឡើង ប៉ុន្តែមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ ........................................................................................ ៥២
ប្រអប់ទី៦៖ ចំណេះដឹងជាសកលស្តីពីទិន្នន័យ វិស័យឯកជន និងការអភិវឌ្ឍ .................................. ៥៨
ប្រអប់ទី៧៖ បណ្តាញស្រ្តីក្នុងវិស័យស្រាវជ្រាវ (SheThinks) ដែលគាំទ្រដោយអង្គការមូលនិធិអាស៊ី..... ៦៨
ប្រអប់ទី៨៖ ភាពចាំបាច់ និងតួនាទីរបស់អន្តរការីទិន្នន័យ........................................................... ៧១
ប្រអប់ទី៩៖ Mekong Data និង DataU ក្នុងនាមជាប្រតិបត្តិករថ្មីក្នុងវិទ្យាសាស្រ្តទិន្នន័យនៅកម្ពុជា ...... ៧៤
ប្រអប់ទី១០៖ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)............................................................. ៧៧

រូបភាពទី១៖ ឋានានុក្រម និងទំនាក់ទំនងរវាងគោលនយោបាយ និងផែនការសំខាន់ៗនៅកម្ពុជា .......... ៣១
រូបភាពទី២៖ ក្របខ័ណ្ឌលទ្ធផលរបស់រដ្ឋាភិបាលសម្រាប់ការអនុវត្តគោលនយោបាយ........................ ៤៨
រូបភាពទី៣៖ មធ្យោបាយចំនួន៣ សម្រាប់ពង្រឹងការអភិវឌ្ឍទិន្នន័យ ............................................... ៥៧
រូបភាពទី៤៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា ................................................. ៦១
រូបភាពទី៥៖ អាទិភាព និងគំនិតផ្តួចផ្តើមនានា៖ ក្របខ័ណ្ឌអាស៊ានស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល........................................................................................ ៨៣

តារាងទី១៖ ក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF) – ចំណុចសំខាន់ៗមួយចំនួន ........................................................................................ ២៤
តារាងទី២៖ ឋានានុក្រមនៃឯកសារគោលនយោបាយនៅកម្ពុជា.................................................. ៣៣
តារាងទី៣៖ ដំណើរការ និងការប្រើប្រាស់ទិន្នន័យក្នុងដំណើរការគោលនយោបាយផ្សេងៗ.................. ៤០
តារាងទី៤៖ ឧទាហរណ៍នៃទិន្នន័យដែលត្រូវបានផលិត និងប្រើប្រាស់ក្នុងវិស័យសាធារណៈនៅកម្ពុជា .... ៦៣
តារាងទី៥៖ វិធានការគោលនយោបាយសំខាន់ៗស្តីពីអភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងក្របខ័ណ្ឌគោលនយោបាយឌីជីថល........................................................................................ ៧៦

តារាងទី៦៖ ព័ត៌មានសំខាន់ៗស្តីពី ASEANstats ........................................................................ ៨០
តារាងទី៧៖ ស្ថាប័ន និងប្រភពទិន្នន័យក្នុងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកិច្ចគាំពារសង្គម....... ៨៩
តារាងទី៨៖ ការកំណត់និយមន័យសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា .................. ៩៨
តារាងទី៩៖ ពិន្ទុឆ្នាំ២០១៨ របស់កម្ពុជា ក្នុងសន្ទស្សន៍គោលនយោបាយស្តីពីសហគ្រាសខ្នាតតូច និង
មធ្យម ធៀបនឹងពិន្ទុសម្រាប់តំបន់អាស៊ាន ............................................................ ១០៣

# ពាក្យកាត់

| | |
|---|---|
| ACRF | ក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន |
| ACSS | ប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន |
| ACSS-SCPC | ប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន-អនុគណៈកម្មាធិការរៀបចំផែនការ និងសម្របសម្រួល |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADGSOM | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ឌីជីថលអាស៊ី |
| AFCS | ក្របខ័ណ្ឌអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកស្ថិតិ |
| AI | បញ្ញាសិប្បនិម្មិត |
| AIMD | អគ្គនាយកដ្ឋានតាមដានសមាហរណកម្មអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEANStats | ផ្នែកស្ថិតិរបស់អាស៊ាន |
| AVI | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| AWPB | ផែនការការងារ និងថវិកាប្រចាំឆ្នាំ |
| BSP | ផែនការយុទ្ធសាស្ត្រថវិកា |
| BSRS | យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| CDB | មូលដ្ឋានទិន្នន័យឃុំ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CICP | វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| CKS | មជ្ឈមណ្ឌលខេមរសិក្សា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា |
| CoM | គណៈរដ្ឋមន្ត្រី |
| CPP | គណបក្សប្រជាជនកម្ពុជា |
| CPS | មជ្ឈមណ្ឌលសិក្សាគោលនយោបាយ |
| CRDB | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| CSDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| CSF | មូលនិធិឃុំ/សង្កាត់ |
| CSOs | អង្គការសង្គមស៊ីវិល |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| DBMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមូលដ្ឋានទិន្នន័យ |
| DBMS | ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ |
| DCPS | យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ |
| DFAT | ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| DMF | ក្របខ័ណ្ឌគ្រប់គ្រងទិន្នន័យ |
| DMK | ស្រុក ក្រុង និងខណ្ឌ |
| DP | ដៃគូអភិវឌ្ឍន៍ |
| DSBB | ផ្ទាំងផ្សព្វផ្សាយព័ត៌មានស្តង់ដារ |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |

| | |
|---|---|
| FF | ស្ថាប័នស្រាវជ្រាវវេទិកាអនាគត |
| FMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| GDP | អគ្គនាយកដ្ឋានគោលនយោបាយ |
| GDSNAF | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GI | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ |
| GS-NSPC | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម |
| HIV | វីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ (វីរុសហ៊ីវ) |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| ILO | អង្គការអន្តរជាតិខាងការងារ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| INASP | បណ្ដាញអន្តរជាតិសម្រាប់ជំរុញការបោះពុម្ពផ្សាយឯកសារវិទ្យាសាស្ត្រ |
| IP | កម្មសិទ្ធិបញ្ញា |
| KAS | មូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ |
| LMs | ក្រសួងសាម៊ី |
| M&E | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MCS | ក្រសួងមុខងារសាធារណៈ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFIs | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MOP | ក្រសួងផែនការ |
| MOSVY | ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា |
| MOT | ក្រសួងទេសចរណ៍ |
| MSMEs | សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម |
| MTBF | ក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| MTFF | ក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម |
| NAD | មូលដ្ឋានទិន្នន័យ ផ.ស.ថ ជាតិ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) |
| NCDD-S | លេខាធិការដ្ឋាន គ.ជ.អ.ប |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NP-SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSDS | យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ |
| NSPC | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| NSPPF | ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| NSS | ប្រព័ន្ធស្ថិតិជាតិ |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| ODC | អង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| OD4D | បណ្ដាញទិន្នន័យបើកទូលាយសម្រាប់ការអភិវឌ្ឍ |

| | |
|---|---|
| OECD | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| OWSU | អង្គភាពច្រកចេញចូលតែមួយ |
| PAEs | សហគ្រាសរដ្ឋបាលសាធារណៈ |
| PER | ការពិនិត្យចំណាយសាធារណៈ |
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMRP | កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PIM | ការគ្រប់គ្រងការវិនិយោគសាធារណៈ |
| PPP | ភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| RCEP | ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RSPPS | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ |
| SAC | ក្រុមប្រឹក្សាស្ថិតិ |
| SAP SMEF | ផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម |
| SCC | គណៈកម្មាធិការសម្របសម្រួលស្ថិតិ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានការផ្តល់សេវា |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SMEs | សហគ្រាសខ្នាតតូច និងមធ្យម |
| The Foundation | អង្គការមូលនិធិអាស៊ី |
| TFP | កត្តាផលិតភាពសរុប |
| TTCSP | កម្មវិធីស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ និងសង្គមស៊ីវិល |
| UHC | ការគ្របដណ្តប់សុខភាពជាសកល |
| UIS | វិទ្យាស្ថានស្ថិតិនៃអង្គការ UNESCO |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| UNV | អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ |
| VMC | កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ |
| WB | ធនាគារពិភពលោក |
| WDR | របាយការណ៍អភិវឌ្ឍន៍ពិភពលោក |
| WEF | វេទិកាសេដ្ឋកិច្ចពិភពលោក |
| WGDSA | ក្រុមការងារចែករំលែក និងវិភាគទិន្នន័យ |
| WGIIS | ក្រុមការងារស្ថិតិវិនិយោគអន្តរជាតិ |
| WGIMTS | ក្រុមការងារស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ |
| WGSDGI | ក្រុមការងារសូចនាករគោលដៅអភិវឌ្ឍន៍សង្គម |
| WGSITS | ក្រុមការងារស្ថិតិពាណិជ្ជកម្មអន្តរជាតិផ្នែកសេវាកម្ម |
| WGSNA | ក្រុមការងារប្រព័ន្ធគណនីជាតិ |
| WHO | អង្គការសុខភាពពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| YDI | សន្ទស្សន៍អភិវឌ្ឍន៍យុវជន |

# សេចក្តីសង្ខេប

**កម្ពុជាជិតឈានដល់ដំណាក់កាលអភិវឌ្ឍន៍ថ្មីមួយទៅហើយ ប៉ុន្តែត្រូវរាក់ខានទៅវិញ មួយផ្នែកគឺដោយសារវិបត្តិកូវីដ-១៩។** ក្រោយការស្រុតចុះសេដ្ឋកិច្ចក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ប៉ុន្តែមានស្ថិរភាពក្នុងផ្នែកជាច្រើន កម្ពុជាបានងាកទៅផ្តោតអាទិភាពលើការស្តារសេដ្ឋកិច្ច ដែលទាមទារនូវកំណែទម្រង់យ៉ាងហ្មត់ចត់នៅក្នុងប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ដែលមានប្រសិទ្ធភាពជាងមុន ជាពិសេសនៅកម្រិតអាស៊ាន។ ក្រៅពីនេះ ភាពស្មុគស្មាញនៃនិន្នាការអភិវឌ្ឍន៍បច្ចុប្បន្ន ទាំងក្នុងស្រុក និងក្នុងតំបន់ ទាមទារឱ្យមានដំណើរការគោលនយោបាយសាធារណៈដែលកាន់តែមានប្រសិទ្ធភាព ក៏ដូចជាទិន្នន័យ និងភស្តុតាងល្អប្រសើរជាងមុន។

ទោះបីជាមានការស្រាវជ្រាវ និងរបាយការណ៍ជាច្រើនក៏ដោយ ប៉ុន្តែមិនសូវមានការយល់ដឹងពីដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជានោះទេ ហើយក៏មិនសូវមានឯកសារស្តីពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជាផលិត និងប្រើប្រាស់ទិន្នន័យដើម្បីតម្រឹមតម្រង់ដំណើរការគោលនយោបាយនោះដែរ។ ការស្រាវជ្រាវនេះ មានគោលបំណងលុបបំបាត់គម្លាតនេះតាមរយៈការផ្តល់ការយល់ដឹងបច្ចុប្បន្នភាពនិងគ្រប់ជ្រុងជ្រោយស្តី ពីដំណើរការគោលនយោបាយសាធារណៈ ការប្រើប្រាស់ទិន្នន័យ និងអភិបាលកិច្ចទិន្នន័យនៅកម្ពុជា និងអាស៊ាន ក្នុងបរិបទនៃការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។លទ្ធផលរកឃើញពីការសិក្សានេះគឺ សម្រាប់ជាប្រយោជន៍ដល់ដៃគូបច្ចុប្បន្ន និងអ្នកដែលអាចក្លាយជាដៃគូរបស់កម្មវិធីពន្លកចំណេះ និងក្រុមគោលដៅនានា ដូចជា អ្នកស្រាវជ្រាវគោលនយោបាយសាធារណៈ សិស្សនិស្សិត និងភាគីពាក់ព័ន្ធផ្សេងទៀតដែលមានចំណាប់អារម្មណ៍។ ទោះជាយ៉ាងណា ការស្រាវជ្រាវនេះមិនមែនជាការប៉ាន់ប្រមាណជាប្រព័ន្ធលើដំណើរការគោលនយោបាយបច្ចុប្បន្ន និងអភិបាលកិច្ចទិន្នន័យ ឬការវាយតម្លៃកម្មវិធីពន្លកចំណេះនោះទេ។ កន្លងមក មានការងារស្រាវជ្រាវផ្សេងទៀតដែលផ្តោតលើវិធានការចាំបាច់របស់រដ្ឋាភិបាលក្នុងការបន្តកែទម្រង់ប្រព័ន្ធស្ថិតិជាតិបច្ចុប្បន្ន។

## លទ្ធផលរកឃើញ

**និន្នាការ និងអាទិភាពអភិវឌ្ឍន៍ក្រោយវិបត្តិកូវីដ-១៩៖** ផ្នែកដំបូងនៃការស្រាវជ្រាវនេះពិភាក្សាពីនិន្នាការធំៗក្រោយវិបត្តិកូវីដ-១៩ ក៏ដូចជាផែនការស្តារឡើងវិញរបស់រដ្ឋាភិបាលកម្ពុជានៅក្រោយវិបត្តិកូវីដ-១៩។ និន្នាការធំៗត្រូវបានកំណត់ជាចលករចម្បងសម្រាប់ការអភិវឌ្ឍសង្គម ដែលនឹងជះឥទ្ធិពលខ្លាំងបំផុតលើគ្រប់វិស័យនៅរយៈពេល ១០-១៥ ឆ្នាំខាងមុខ។ សម្រាប់កម្ពុជានិន្នាការធំៗក្នុងសេដ្ឋកិច្ចដែលត្រូវផ្តោតការយកចិត្តទុកដាក់ រួមមាននិន្នាការនៃការវិនិយោគពីបរទេស សេដ្ឋកិច្ចឌីជីថល អភិបាលកិច្ចទិន្នន័យកិច្ចគាំពារសង្គមនិងការងារ និងការប្រែប្រួលអាកាសធាតុ។ រដ្ឋាភិបាលកម្ពុជាបានរំលេចនិន្នាការទាំងនេះក្នុងផែនការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដែលផ្តោតសំខាន់លើការលើកស្ទួយវិស័យសំខាន់ៗ (ឧ. កសិកម្ម ទេសចរណ៍) ពិពិធកម្មសេដ្ឋកិច្ច កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការបង្កើនភាពធន់ (ឧ. ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ឌីជីថលូបនីយកម្ម និងកិច្ចគាំពារសង្គម)។ បរិយាបន្នសង្គម និងការជួយដល់ក្រុមងាយរងគ្រោះក៏ត្រូវបានរំលេចជាពិសេសក្នុងគោលនយោបាយនេះផងដែរ។ អាទិភាពទាំងនេះបន្សុីគ្នានឹងអាទិភាពដែលបានកំណត់នៅកម្រិតអាស៊ាន ដែលនេះក៏ជាផលប្រយោជន៍សម្រាប់កម្ពុជាផងដែរ ព្រោះកម្ពុជានឹងធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២។

**ដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជា៖** ភាពស្មុគស្មាញនៃនិន្នាការអភិវឌ្ឍន៍ដែលកំពុងលេចឡើងទាមទារនូវដំណើរការគោលនយោបាយដែលកាន់តែមានប្រសិទ្ធភាព ដែលតម្រូវឱ្យមានទិន្នន័យ និងភស្តុតាងល្អប្រសើរជាងមុន។ កម្ពុជាមានទាំងគោលនយោបាយរយៈពេលវែង (៣-៥ឆ្នាំ) និងគោលនយោបាយរយៈពេលមធ្យម (៣ឆ្នាំ) ដែលគោលនយោបាយនីមួយៗចែកចេញជា ៣ដំណាក់កាល៖ ការតាក់តែងគោលនយោបាយ ការអនុវត្តគោលនយោបាយ និងការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ។ ការសិក្សានេះរកឃើញថា ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ កម្ពុជាបានអនុវត្តដំណើរការគោលនយោបាយស្តង់ដារ និងធ្វើការកែលម្អជាបន្តបន្ទាប់ និងមានការប្រើប្រាស់ទិន្នន័យកាន់តែច្រើន។

ទោះជាយ៉ាងណា មិនសូវមានភាពពាក់ព័ន្ធគ្នារវាងគោលនយោបាយនិងថវិកា និងការពិនិត្យតាមដាននិងវាយតម្លៃ (ជាពិសេសនៅកម្រិតផលប៉ះពាល់) នោះទេ។ កត្តាជាក់ស្តែងផ្សេងទៀតដែលជះឥទ្ធិពលលើដំណើរការគោលនយោបាយ រួមមាន ចំណាប់អារម្មណ៍ផ្នែកនយោបាយការសម្របសម្រួលឆ្លងវិស័យ និងកត្តាមនុស្ស (ឧ. ការដឹកនាំ អ្នកជំនាញការវ័យក្មេង ទំនុកចិត្ត)។ ខណៈដែលដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា មានដំណើរការនិងលក្ខណៈដូចគ្នាមួយចំនួន ការអនុវត្តនេះប្រែប្រួលតាមវិស័យ និងបញ្ហា។ តាមរយៈការប្រើ

ប្រាស់ករណីផ្សេងៗគ្នាចំនួន៤ (កិច្ចគាំពារសង្គមនៅអំឡុងនិងក្រោយការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ កំណែទម្រង់វិមជ្ឈការ ការផ្តល់ជំនួយដល់សហគ្រាសខ្នាតតូចនិងមធ្យមក្នុងវិស័យទេសចរណ៍ និងការអភិវឌ្ឍនិងការជំរុញការចូលរួមរបស់យុវជន) ការសិក្សានេះបង្ហាញថា ភាពខុសគ្នាទាំងនេះ អាចបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន ដូចជា កម្រិតនៃចំណាប់អារម្មណ៍ផ្នែកនយោបាយ ភាពចាំបាច់នៃការសម្របសម្រួលអន្តរក្រសួង គុណភាពនៃការគ្រប់គ្រង និងអ្នកជំនាញការក្នុងទីភ្នាក់ងារដឹកនាំការអនុវត្ត និងគុណភាពនៃក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃរបស់វិស័យ ឬបញ្ហានោះ។ ទោះជាមានភាពខុសគ្នាក៏ដោយ ប៉ុន្តែគំរូជារួមមួយគឺមានការផលិតទិន្នន័យច្រើនគួរសម ហើយអ្វីដែលជាបញ្ហាចោទគឺការប្រើប្រាស់ និងការចែករំលែកទិន្នន័យ។

**អភិបាលកិច្ចទិន្នន័យ និងការប្រើប្រាស់ទិន្នន័យ៖** អភិបាលកិច្ចទិន្នន័យប្រកបដោយប្រសិទ្ធភាពជាកត្តាសំខាន់សម្រាប់ការផ្តល់មូលដ្ឋានព័ត៌មានដល់ដំណើរការគោលនយោបាយ។ មិនខុសពីប្រទេសដទៃទៀតនោះទេ រដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យចម្បងជាងគេ។ ក្នុងរយៈពេល ១ ទសវត្សរ៍កន្លងមកនេះ ភាគីពាក់ព័ន្ធសំខាន់ៗបានផលិតទិន្នន័យយ៉ាងច្រើននៅក្នុងប្រព័ន្ធស្ថិតិជាតិ ដូចជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាក់ព័ន្ធ និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ រដ្ឋាភិបាលបានលើកទឹកចិត្តឱ្យមានការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរ តាមរយៈយុទ្ធសាស្ត្រកំណែទម្រង់ផ្សេងៗ ដូចជា យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតាមរយៈកំណែទម្រង់វិមជ្ឈការ។ ទន្ទឹមនឹងនេះ មានការបង្កើតភាពជាដៃគូនៅកម្រិតអាស៊ាន ដើម្បីបន្តកែលម្អប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហការក្នុងតំបន់លើផ្នែកទិន្នន័យ រួមទាំង Big Data។

ទោះបីជាមានវឌ្ឍនភាពក្តី ប៉ុន្តែនៅមានចំណុចសំខាន់ៗដែលត្រូវកែលម្អ ដូចជា ភាពចាំបាច់ក្នុងការបង្កើនគុណភាពទិន្នន័យសម្រាប់ការប៉ាន់ស្មានសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ (ដូចជា ផសស) និងទិន្នន័យស្តីពីយេនឌ័រ និងក្រុមងាយរងគ្រោះមួយចំនួន ជាពិសេសពាក់ព័ន្ធនឹងផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើក្រុមទាំងនោះ។ ក្នុងបរិបទឌីជីថលូបនីយកម្ម ការបង្កើនការផលិតនិងប្រើប្រាស់ទិន្នន័យ ទាមទារទាំងការផ្តោតការយកចិត្តទុកដាក់លើការពង្រឹងមុខងារសំខាន់ៗរបស់ប្រព័ន្ធស្ថិតិជាតិ និងការតាមឱ្យទាន់សន្ទុះនៃបច្ចេកវិទ្យាឌីជីថលថ្មីៗ ដូចជា Big Data។

**បញ្ហាប្រឈមពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ៖** ការចែករំលែកទិន្នន័យក៏ជាបញ្ហាប្រឈមមួយសម្រាប់រដ្ឋាភិបាលផងដែរ។ ទោះបីជាមានក្របខ័ណ្ឌស្ថាប័នច្បាស់លាស់សម្រាប់ប្រព័ន្ធស្ថិតិជាតិក៏ដោយ ប៉ុន្តែក្នុងការអនុវត្ត នៅតែមិនសូវមានការយល់ដឹងពីតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៅតាមក្រសួង និងទីភ្នាក់ងារពាក់ព័ន្ធ។ រដ្ឋាភិបាលបានខិតខំដោះស្រាយបញ្ហាទាំងនេះតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ។ នៅតាមប្រទេសមួយចំនួន ដំណោះស្រាយសម្រាប់បញ្ហាដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ គឺការប្រើប្រាស់អន្តរការីទិន្នន័យ ហើយកម្ពុជាអាចរៀនសូត្រពីបទពិសោធន៍របស់ប្រទេសទាំងនោះបាន។ រដ្ឋាភិបាលកម្ពុជាគ្រោងនឹងបង្កើនការចូលរួមរបស់វិស័យឯកជន និងតភ្ជាប់ប្រព័ន្ធស្ថិតិជាតិទៅនឹងទិន្នន័យ Big Data។

**ការជំរុញការចូលរួមរបស់តួអង្គមិនមែនរដ្ឋ៖** មកទល់បច្ចុប្បន្ន មានការចូលរួមតិចតួចប៉ុណ្ណោះពីសំណាក់តួអង្គមិនមែនរដ្ឋ ដែលជាចម្បងគឺដោយសារបញ្ហាទំនុកចិត្ត។ ខ្សែរយៈផ្ទាល់ខ្លួន មិត្តភាព និងការយល់ឃើញពីនិន្នាការនយោបាយ នៅតែមានសារៈសំខាន់សម្រាប់ការកសាងទំនុកចិត្តរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ប៉ុន្តែតាមការសង្កេត ហាក់មានភាពងាយស្រួលជាងក្នុងការកសាងទំនុកចិត្ត និងទំនាក់ទំនងក្នុងចំណោមអ្នកធ្វើការក្នុងការិយាល័យ និងអ្នកជំនាញវ័យក្មេងនៅក្នុងអង្គការសង្គមស៊ីវិល ដែលមួយផ្នែកគឺដោយសារពួកគេច្រើនតែមានសាវតារអប់រំ និងវិជ្ជាជីវៈដូចគ្នា (ឧ. រៀនសាលាជាមួយគ្នា ទទួលបានអាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលដូចគ្នា។ល។)។ ការសិក្សានេះក៏បានកត់សម្គាល់ពីនិន្នាការវិជ្ជមានមួយចំនួនផ្សេងទៀតផងដែរ។ ទីមួយ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ អ្នកស្រាវជ្រាវកម្ពុជាបានដើរតួនាទីកាន់តែសំខាន់ក្នុងស្ថាប័នសិក្សាស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់។ ទីពីរ មានការបង្កើតក្រុមអ្នកស្រាវជ្រាវវ័យក្មេងកាន់តែច្រើនដែលទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិល។ និន្នាការវិជ្ជមានទាំងនេះបង្ហាញពីសក្តានុពលខ្ពស់សម្រាប់ការកសាងវិស័យស្រាវជ្រាវស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។

មានកើនឡើងនៃការចែករំលែកទិន្នន័យ និងលទ្ធផលរកឃើញពីការស្រាវជ្រាវតាមបែបជាប្រព័ន្ធក្នុងគេហទំព័រ និងបណ្តាញសង្គម ជាពិសេសចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិកូវីដ-១៩។ ទោះជាយ៉ាងណា ការទទួលបាន និងការប្រើប្រាស់ទិន្នន័យបែបបរិមាណជាមួយនឹងសំណាកធំៗ នៅតែជាឧបសគ្គសម្រាប់អ្នកស្រាវជ្រាវជាច្រើននៅកម្ពុជា។ ឧបសគ្គទាំងនេះធ្វើឱ្យអ្នកស្រាវជ្រាវទាំងនោះពិបាកទាក់ទាញចំណាប់អារម្មណ៍របស់អ្នកតាក់តែងគោលនយោបាយ ដែលច្រើនតែមិនសូវឱ្យតម្លៃដល់ការស្រាវជ្រាវបែបគុណភាព និងការស្រាវជ្រាវបែបបរិមាណដែលមានទំហំសំណាកតូចៗ។ ប៉ុន្តែក្នុងករណីមួយចំនួន អ្នកតាក់តែងគោលនយោបាយក៏ទទួលយកលទ្ធផលរកឃើញ

ពីការស្រាវជ្រាវបែបគុណភាពផងដែរ ប្រសិនបើការស្រាវជ្រាវទាំងនោះផ្តល់ព័ត៌មាន និងដំណោះស្រាយកាន់តែច្រើនដោយផ្អែកតាមបទពិសោធន៍អន្តរជាតិ និងបទពិសោធន៍ក្នុងតំបន់។

**ឱកាសថ្មីៗសម្រាប់ការទទួលបានទិន្នន័យ៖** លទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានទិន្នន័យជាគន្លឹះក្នុងការកែលម្អការងារស្រាវជ្រាវសម្រាប់គោលបំណងគោលនយោបាយនៅកម្ពុជា។ មានការរំពឹងថា អ្នកស្រាវជ្រាវនៅក្រៅរដ្ឋាភិបាល នឹងមានលទ្ធភាពច្រើនជាងមុនក្នុងការទទួលបានទិន្នន័យរដ្ឋាភិបាលដោយសារការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យដែលដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ។ ក្រៅពីលទ្ធភាពទទួលបានទិន្នន័យ ការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ ក៏សំខាន់ផងដែរ។ មកទល់បច្ចុប្បន្ន មានការផលិតទិន្នន័យយ៉ាងច្រើនក្នុងបណ្តាញអ៊ីនធឺណិត ប៉ុន្តែអ្នកស្រាវជ្រាវក្នុងស្រុក និងអង្គការសង្គមស៊ីវិលមួយចំនួន ប្រហែលជាមិនបានប្រើប្រាស់ទិន្នន័យទាំងនោះឱ្យអស់សក្តានុពលនៅឡើយទេ។ ផ្នែកមួយទៀតដែលត្រូវសិក្សាស្វែងយល់គឺការប្រមូលនិងទាញយកទិន្នន័យដោយប្រើប្រាស់ថ្នាលឌីជីថលដូចជាកម្មវិធីប្រភពបើកទូលាយ (ឧ. Kobo Toolbox, Google forms, chatbot) ប្រភពទិន្នន័យបើកទូលាយ (ឧ. ប្រភពទិន្នន័យដែលផ្តល់ដោយធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នផ្សេងទៀត) និងទិន្នន័យដែលផលិតដោយប្រជាពលរដ្ឋ។ ក្រៅពីនេះ អ្នកស្រាវជ្រាវកម្ពុជាក៏អាចទទួលបានសំណុំទិន្នន័យអភិវឌ្ឍន៍ជាច្រើនស្តីពីអាស៊ាន តាមរយៈគេហទំព័រផ្លូវការរបស់អាស៊ានផងដែរ។

**ភាពជាដៃគូនៅកម្រិតតំបន់៖** ភាពជាដៃគូនៅកម្រិតអាស៊ាន អាចផ្តល់ឱកាសថ្មីៗដល់កម្ពុជាសម្រាប់អភិបាលកិច្ចទិន្នន័យ។ បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាតែងបានផ្តល់ទិន្នន័យផ្សេងៗដល់ផ្នែកស្ថិតិរបស់អាស៊ាន (ASEANstats) ដូចជា ពាណិជ្ជកម្មអន្តរជាតិ និងជញ្ជីងទូទាត់។ ASEANstats មានគោលបំណងប្រែក្លាយទៅជាប្រភពចម្បងដែលផ្តល់ស្ថិតិស្តីពីអាស៊ានប្រកបដោយភាពពាក់ព័ន្ធ ភាពអាចប្រៀបធៀបបាន និងភាពទាន់ពេលវេលា ដើម្បីសម្រួលដល់ការកសាងចំណេះដឹងនៅក្នុងសហគមន៍អាស៊ានដែលមានភាពរឹងមាំ ប្រកបដោយទំនុកចិត្ត និងទទួលបានការគោរព។ Big Data និងការជំរុញការចូលរួមរបស់វិស័យឯកជន គឺជាសមាសភាគសំខាន់ៗក្នុងរបៀបវារៈនៃកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០២២។

**ការជំរុញការចូលរួមរបស់វិស័យឯកជន៖** ភាពជាដៃគូជាមួយវិស័យឯកជនជាកត្តាសំខាន់សម្រាប់ការលើកកម្ពស់ការប្រើប្រាស់ទិន្នន័យសម្រាប់គោលបំណងឯកជន ដើម្បីជាប្រយោជន៍ដល់គោលនយោបាយសាធារណៈ ប៉ុន្តែនេះជាគំនិតថ្មីស្រឡាងនៅកម្ពុជា ទោះបីជាមានការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក

និងអាជីវកម្មថ្នាលបច្ចេកវិទ្យាក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះក៏ដោយ។ ការត្រៀមខ្លួនរួចរាល់នៃប្រព័ន្ធស្ថិតិជាតិ ជាគន្លឹះសម្រាប់ការទាញប្រយោជន៍ពីទិន្នន័យសម្រាប់គោលបំណងឯកជន ហើយការត្រៀមខ្លួននោះផ្អែកលើគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ ( hardware និង software ) សម្រាប់ការរក្សាទុក ការពិនិត្យ និងការប៉ាន់ប្រមាណទិន្នន័យ និងសមត្ថភាពរបស់ស្ថិតិវិទូផ្លូវការ និងអ្នកវិទ្យាសាស្ត្រផ្នែកទិន្នន័យ។ ដើម្បីដើរតាមទិសដៅនេះ កម្ពុជាគួរផ្អែកតាមបទពិសោធន៍ពីប្រទេសសមាជិកអាស៊ានផ្សេងទៀត ដូចជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន និងធ្វើការដកពិសោធន៍មួយចំនួនជាមួយ Big Data ដើម្បីផ្តល់ស្ថិតិឱ្យបានញឹកញាប់ និងពិស្តារ។

## អនុសាសន៍សម្រាប់ការពិចារណាក្នុងការរៀបចំកម្មវិធី

**អនុសាសន៍ទាំងនេះគឺសម្រាប់កម្មវិធីពន្លកចំណេះ និងកម្មវិធីស្រដៀងគ្នាផ្សេងទៀតដែលខិតខំផ្តល់ការគាំទ្រដល់សមត្ថភាពស្រាវជ្រាវគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា។** កម្មវិធីពន្លកចំណេះ មានគោលបំណងគាំទ្រ និងពង្រឹងសមត្ថភាពនៃវិស័យស្រាវជ្រាវ ក៏ដូចជាផ្តល់មូលដ្ឋានព័ត៌មានដល់ការវិភាគគោលនយោបាយសាធារណៈនៅកម្ពុជា។ ដើម្បីបង្កើនប្រសិទ្ធភាព និងផលប៉ះពាល់នៃកម្មវិធីនេះនៅកម្រិតជាយុទ្ធសាស្ត្រ កម្មវិធីពន្លកចំណេះគួរពិចារណាអភិវឌ្ឍខ្លួនឱ្យក្លាយជា "អន្តរការីទិន្នន័យ" រវាងរដ្ឋាភិបាលនិងតួអង្គមិនមែនរដ្ឋ ក្នុងចំណោមតួអង្គមិនមែនរដ្ឋ និងរវាងអ្នកស្រាវជ្រាវកម្ពុជានិងភាគីពាក់ព័ន្ធនៅកម្រិតតំបន់ ដូចជាស្ថាប័នសិក្សាស្រាវជ្រាវក្នុងអាស៊ាន និងក្នុងប្រទេសអូស្ត្រាលី។ គោលបំណងចម្បងគឺដើម្បីលើកកម្ពស់ ១) ទំនុកចិត្តនិងកិច្ចសហការក្នុងការរៀបចំ ការអនុវត្តការស្រាវជ្រាវ ការចែករំលែកទិន្នន័យ ការប្រើប្រាស់ទិន្នន័យ និងការផ្សព្វផ្សាយការស្រាវជ្រាវក្នុងចំណោមតួអង្គទាំងនេះ និង ២) ចក្ខុវិស័យក្នុងតំបន់ស្តីពីការវិភាគទិន្នន័យ និងការអនុវត្តគំនិតផ្តួចផ្តើមទិន្នន័យថ្មីៗ ដូចជា ទិន្នន័យ Big Data និងការប្រើប្រាស់ទិន្នន័យសម្រាប់គោលបំណងឯកជនដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ។

ផ្អែកតាមទិសដៅយុទ្ធសាស្ត្រខាងលើ កម្មវិធីពន្លកចំណេះអាចពិចារណាពីគំនិតប្រតិបត្តិការមួយចំនួន ដូចខាងក្រោម ៖

- **ការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវ៖** ជាពិសេសអ្នកស្រាវជ្រាវមកពីទីភ្នាក់ងាររដ្ឋាភិបាល និង ដៃគូរបស់កម្មវិធីពន្លកចំណេះ។ បណ្តុះបណ្តាលគួរផ្តោតលើប្រធានបទទូទៅស្តីពីដំណើរការស្រាវជ្រាវ និងជំនាញថ្មីៗជុំវិញការប្រមូលទិន្នន័យ (ឧ. កម្មវិធីតាមអនឡាញ ប្រភពទិន្នន័យបើកទូលាយ ទិន្នន័យដែលផលិតដោយប្រជាពលរដ្ឋ) និងរបៀបទាញប្រយោជន៍ពីទិន្នន័យដែលមានស្រាប់ ទាំងក្នុងប្រទេស និងក្នុងតំបន់។

- **ការសម្របសម្រួលការប្រមូល ការចែករំលែក និងការប្រើប្រាស់ទិន្នន័យ៖** កម្មវិធីពន្លកចំណេះគួរដើរតួនាទីជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំ រក្សាទុក និងធ្វើបច្ចុប្បន្នភាពទិន្នន័យពីទីភ្នាក់ងាររដ្ឋាភិបាល និងប្រភពផ្សេងៗ ទាំងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ ក្រៅពីនេះ គួរផ្សព្វផ្សាយទិន្នន័យដែលប្រមូលបាន ដល់ដៃគូស្រាវជ្រាវរបស់កម្មវិធី និងសាធារណជន ក៏ដូចជាអនុវត្តតាមវិធាន និងនីតិវិធីសមស្រប។ ក្នុងករណីអាចអនុវត្តបាន កម្មវិធីនេះគួរផ្តល់ការបណ្តុះបណ្តាលស្តីពីការយល់ដឹង និងការប្រើប្រាស់ទិន្នន័យ។
- **ការលើកស្ទួយអ្នកស្រាវជ្រាវវ័យក្មេង៖** កម្មវិធីពន្លកចំណេះគួរលើកទឹកចិត្តឱ្យដៃគូកម្មវិធីជំរុញការចូលរួមរបស់អ្នកស្រាវជ្រាវ និងអ្នកហាត់ការវ័យក្មេង ក្នុងគម្រោងស្រាវជ្រាវដែលទទួលបានការឧបត្ថម្ភ និងរៀបចំកម្មវិធីបណ្តុះបណ្តាលការស្រាវជ្រាវ ដែលកែសម្រួលទៅតាមតម្រូវការរបស់អ្នកស្រាវជ្រាវវ័យក្មេង ជាពិសេសអ្នកស្រាវជ្រាវជាស្ត្រី និងអ្នកស្រាវជ្រាវដែលមកពីតាមបណ្តាខេត្ត។ ក្រៅពីនេះ កម្មវិធីពន្លកចំណេះគួរពិចារណាផ្តល់ការណែនាំដល់គំនិតផ្តួចផ្តើម និងកម្មវិធីយុវជនថ្មីៗ ដូចជា កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំជាដើម។
- **ការផ្តួចផ្តើមប្រធានបទស្រាវជ្រាវដែលថ្មី និងសម្លឹងឆ្ពោះទៅមុខ៖** ប្រធានបទជាឧទាហរណ៍ រួមមានទិន្នន័យ Big Data និងការជំរុញការចូលរួមរបស់វិស័យឯកជនក្នុងវិស័យសំខាន់ៗដូចជា ទេសចរណ៍ កសិកម្ម និងសហគ្រាសខ្នាតតូច និងមធ្យម។ ក្នុងការផ្តួចផ្តើមប្រធានបទថ្មីៗ កម្មវិធីពន្លកចំណេះគួរ ពាំនាំចក្ខុវិស័យកាន់តែច្រើនពីកម្រិតតំបន់ ជាពិសេសកម្រិតអាស៊ាន។
- **ការបង្កើតភាពជាដៃគូជាមួយស្ថាប័នស្រាវជ្រាវក្នុងតំបន់៖** អង្គការមូលនិធិអាស៊ី និងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី រួមជាមួយនឹងបណ្តាញយ៉ាងច្រើនរបស់ខ្លួននៅកម្រិតអាស៊ាន និងក្រៅពីនេះ គួរតភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នស្រាវជ្រាវក្នុងស្រុក និងកម្រិតតំបន់ និងផ្តួចផ្តើមគម្រោងស្រាវជ្រាវថ្នាក់តំបន់ ជាពិសេសប្រធានបទស្រាវជ្រាវថ្មីៗដូចបានលើកឡើងខាងលើ។ ភាពជាដៃគូនេះមានសារៈសំខាន់ណាស់សម្រាប់ការកសាងសមត្ថភាពបច្ចេកទេស និងការលើកទឹកចិត្ត ការបង្កើនភាពអាចជឿទុកចិត្តបាន និងការកសាងទំនុកចិត្ត ជាពិសេសរវាងស្ថាប័នក្នុងស្រុក និងទីភ្នាក់ងាររដ្ឋាភិបាល។

# ១. សេចក្តីផ្តើម

## ១.១ សាវតារ និងសនិទានភាព

**កម្ពុជាជិតឈានដល់ដំណាក់កាលអភិវឌ្ឍន៍ថ្មីមួយទៅហើយ ប៉ុន្តែត្រូវរាក់ខានទៅវិញ មួយផ្នែកគឺដោយសារវិបត្តិកូវីដ-១៩។** កាលពីរយៈពេលមួយទសវត្សរ៍មុនការផ្ទុះឡើងនៃវិបត្តិកូវីដ-១៩ កម្ពុជាសម្រេចបានកំណើនប្រចាំឆ្នាំជាមធ្យម ៧% ប៉ុន្តែក្នុងឆ្នាំ២០២០ អត្រាកំណើនរបស់កម្ពុជាមានការថយចុះដូចបណ្តាប្រទេសជាច្រើនផ្សេងទៀតនៅក្នុងពិភពលោកដែរ ពោលគឺអត្រាកំណើនរបស់កម្ពុជាបានធ្លាក់ដល់ -៣,១% ដោយសារតែវិស័យ និងឧស្សាហកម្មសំខាន់ៗ ដូចជា ទេសចរណ៍ ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ នៅពេលដែលកម្ពុជាអាចគ្រប់គ្រងវិបត្តិនេះបាន ប្រទេសនេះបានងាកទៅផ្តោតសំខាន់លើការស្តារសេដ្ឋកិច្ច ដែលទាមទារកំណែទម្រង់កាន់តែគ្រប់ជ្រុងជ្រោយ ក៏ដូចជាកិច្ចសហប្រតិបត្តិការដែលកាន់តែមានប្រសិទ្ធភាពនៅថ្នាក់តំបន់ជាពិសេសនៅកម្រិតតំបន់អាស៊ាន។ អាស៊ានកាន់តែមានភាពពាក់ព័ន្ធសម្រាប់កម្ពុជា ព្រោះកម្ពុជានឹងធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០២២។

ភាពស្មុគស្មាញនៃនិន្នាការអភិវឌ្ឍន៍បច្ចុប្បន្ន ទាំងក្នុងស្រុក និងក្នុងតំបន់ ទាមទារឱ្យមានដំណើរការគោលនយោបាយសាធារណៈដែលកាន់តែមានប្រសិទ្ធភាព ក៏ដូចជាទិន្នន័យ និងភស្តុតាងល្អប្រសើរជាងមុន។ មិនខុសពីបណ្តាប្រទេសផ្សេងទៀតនោះទេ ដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជារួមមានការតាក់តែងគោលនយោបាយ ការអនុវត្តគោលនយោបាយ និងការពិនិត្យតាមដាននិងវាយតម្លៃគោលនយោបាយ។ ក្នុងដំណាក់កាលទាំងនេះ ទិន្នន័យនិងភស្តុតាងគឺ ជាសមាសភាគសំខាន់សម្រាប់ការធានាប្រសិទ្ធភាពនៃដំណើរការគោលនយោបាយសាធារណៈ។ ទោះជាយ៉ាងណា ការទាញប្រយោជន៍ពីទិន្នន័យនិងភស្តុតាងសម្រាប់គោលបំណងទាំងនេះទាមទារការយល់ដឹងច្បាស់ពីដំណើរការគោលនយោបាយសាធារណៈ និងរបៀបផលិត ប្រើប្រាស់ និងប្រើប្រាស់ឡើងវិញនូវទិន្នន័យ ឬភស្តុតាងទាំងនោះ។ ក្នុងបរិបទនៃឌីជីថលូបនីយកម្ម ការបង្កើនការផលិត និងប្រើប្រាស់ទិន្នន័យ ក៏ទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងផងដែរលើសក្តានុពលបច្ចេកវិទ្យា ដូចជា ទិន្នន័យ Big Data។

**ទោះបីជាមានការស្រាវជ្រាវ និងរបាយការណ៍ជាច្រើនក៏ដោយ ប៉ុន្តែមិនសូវមានការយល់ដឹងពីដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជានោះទេ។** កន្លងមកមានការស្រាវជ្រាវ និងបោះពុម្ពផ្សាយឯកសារជាច្រើនស្តីពីនយោបាយ និងរដ្ឋសហសម័យរបស់កម្ពុជា[1] ។

[1] សម្រាប់អត្ថបទមួយចំនួនក្នុងចំណោមនោះ សូមមើល ឧ. Luo, Jing Jing, and Kheang Un. "China's Role in the Cambodian People's Party's Quest for Legitimacy." Contemporary Southeast Asia 43, no. 2 (2021): 395-419; Un, Kheang. Cambodia: Return to Authoritarianism. Cambridge University Press, 2019.

ក្រៅពីនេះ មានការសិក្សាគ្រប់ជ្រុងជ្រោយតិចតួចប៉ុណ្ណោះស្តីពីប្រព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា[2] ប៉ុន្តែបើនិយាយពីដំណើរការគោលនយោបាយសាធារណៈរបស់កម្ពុជា គឺមិនសូវមានឯកសារពាក់ព័ន្ធនោះទេ។ ភាពមានកម្រិតនេះគឺមួយផ្នែកបណ្តាលមកពីកង្វះគោលការណ៍ណែនាំផ្លូវការស្តីពីដំណើរការគោលនយោបាយសាធារណៈ និងកង្វះលទ្ធភាពរបស់អ្នកស្រាវជ្រាវឯករាជ្យក្នុងការទទួលបានគោលការណ៍ណែនាំដែលមានស្រាប់។ ស្ថានភាពនេះមានភាពប្រសើរឡើង ជាពិសេសក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ ដោយមានការអនុម័តគោលការណ៍ណែនាំកាន់តែច្រើនស្តីពីការតាក់តែង ការអនុវត្ត និងការពិនិត្យតាមដាននិងវាយតម្លៃគោលនយោបាយ។ ក្នុងនោះ គោលការណ៍ណែនាំជាច្រើនត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ដែលមួយផ្នែកធំគឺបណ្តាលមកពីការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតទាំងនៅក្នុង និងក្រៅរដ្ឋាភិបាល។

មួយទសវត្សរ៍កន្លងមកនេះ មានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើតួនាទីរបស់ទិន្នន័យសម្រាប់ការអភិវឌ្ឍ ទាំងនៅកម្រិតអន្តរជាតិ និងក្នុងប្រទេសកម្ពុជា។ នៅកម្រិតអន្តរជាតិ ទិន្នន័យដើរតួនាទីយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍ ដោយបានក្លាយជាប្រធានបទក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១ "ទិន្នន័យដើម្បីជីវិតកាន់តែប្រសើរ"។ នៅកម្ពុជា កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងវិបត្តិកូវីដ-១៩ នាពេលថ្មីៗនេះ បានធ្វើឱ្យទីភ្នាក់ងាររដ្ឋាភិបាលត្រូវការទិន្នន័យដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងងាយស្រួលទទួលបាន ជាងពេលណាទាំងអស់ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ដំណើរការតាក់តែងគោលនយោបាយ និងការពិនិត្យតាមដាន។ ទោះជាយ៉ាងណា គេមិនអាចទទួលបានទិន្នន័យទាំងនេះដោយស្វ័យប្រវត្តិនោះទេ ហើយដើម្បីទទួលបានទិន្នន័យ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ ចំណុចដែលកាន់តែពាក់ព័ន្ធជាងនេះ គឺរដ្ឋាភិបាលត្រូវស្វែងរក និងប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តន៍ទិន្នន័យថ្មីៗ ដើម្បីកសាងប្រព័ន្ធទិន្នន័យជាតិដែលកាន់តែសម្បូរបែប និងបន្ស៊ីគ្នានឹងនិន្នាការអភិវឌ្ឍន៍នាពេលថ្មីៗនេះ។

ដោយសារតែភាពជាសកល និងភាពប្រទាក់ក្រឡាគ្នានៃពិភពលោកសម័យទំនើប ចក្ខុវិស័យដែលអាចប្រៀបធៀបគ្នាបាន កាន់តែមានសារៈសំខាន់សម្រាប់ការតាក់តែងគោលនយោបាយ។ អ្វីដែលសំខាន់គឺអ្នកតាក់តែងគោលនយោបាយ និងអ្នកស្រាវជ្រាវគោលនយោបាយសាធារណៈ ត្រូវមានទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីកម្ពុជា ក៏ដូចជាទិន្នន័យពាក់ព័ន្ធនឹងប្រទេសផ្សេងទៀត ជាពិសេសទិន្នន័យស្តីពីស្ថានភាព និងបរិបទអភិវឌ្ឍន៍ដែលអាចប្រៀបធៀបបាន។ សម្រាប់ផ្នែកប្រតិបត្តិការ ចាំបាច់ត្រូវមានចក្ខុវិស័យអាចអាចប្រៀបធៀបបាននៅកម្រិតតំបន់ ជាពិសេសក្នុងតំបន់អាស៊ី និងតំបន់អាស៊ានតែម្តង។

[2] ឧទាហរណ៍មួយនាពេលថ្មីៗនេះគឺ the Hang, C. (2015) Cambodia's economy: Toward a brighter future – Progress, challenges, and future prospects.

**របៀបនៃការប្រើប្រាស់ទិន្នន័យ ឬភស្តុតាងក្នុងដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជា គឺជាប្រធានបទថ្មីស្រឡាងមួយ។** គេអាចរកបានព័ត៌មានសំខាន់ៗស្តីពីរបៀបបង្កើតប្រព័ន្ធស្ថិតិជាតិ របៀបតាក់តែង និងពិនិត្យតាមដានគោលនយោបាយអភិវឌ្ឍន៍ជាតិ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងរបៀបរៀបចំថវិកា ដោយអានឯកសារគោលនយោបាយ ឯកសារច្បាប់ និងឯកសាររដ្ឋបាលផ្សេងៗ។ ទោះជាយ៉ាងណា ចំណេះដឹងពីធនធានទាំងនោះហាក់ប៉ាត់ប៉ាយ និងមានលក្ខណៈបច្ចេកទេស។ ចំណុចខ្វះខាតគឺ ការវិភាគបែបសំយោគស្តីពីរបៀបអនុវត្តគោលនយោបាយសាធារណៈ និងការប្រើប្រាស់ទិន្នន័យ ឬភស្តុតាង កត្តាសំខាន់ៗដែលជះឥទ្ធិពលលើការអនុវត្តនោះ និងរបៀបដែលការអនុវត្តនោះប្រែប្រួលតាមវិស័យ ឬស្ថានភាព។ តាមការលើកឡើងក្នុងរបាយការណ៍នេះ ចំណេះដឹងទាំងអស់នេះមានសារៈសំខាន់ណាស់សម្រាប់ការលើកកម្ពស់ការប្រើប្រាស់ទិន្នន័យ ឬភស្តុតាងក្នុងដំណើរការគោលនយោបាយ។

ក្នុងរបាយការណ៍នេះ ពាក្យ "ទិន្នន័យ" សំដៅលើ "ភស្តុតាង" "ព័ត៌មាន" "ស្ថិតិ" ឬ "លទ្ធផលរកឃើញពីការស្រាវជ្រាវ" ទាំងការស្រាវជ្រាវបែបបរិមាណ និងការស្រាវជ្រាវបែបគុណភាព។ និយមន័យនេះ ផ្អែកតាមមូលហេតុដូចតទៅ។ ទីមួយ ពាក្យ "ទិន្នន័យ" ស្រដៀងគ្នា និងមានន័យចំគ្រប់គ្រាន់ទៅនឹងនិយមន័យនៃពាក្យ "ភស្តុតាង" ក្នុងឯកសារពាក់ព័ន្ធស្តីពីគោលនយោបាយសាធារណៈ។ យោងតាមរបាយការណ៍របស់បណ្តាញអន្តរជាតិសម្រាប់ជំរុញការបោះពុម្ពផ្សាយឯកសារវិទ្យាសាស្ត្រ (INASP) ឆ្នាំ២០១៦ "ភស្តុតាង" សំដៅលើ "ព័ត៌មានទាំងឡាយណាដែលជួយឱ្យអ្នកតាក់តែងគោលនយោបាយធ្វើសេចក្តីសម្រេចចិត្ត និងទទួលបានលទ្ធផលដែលជាក់លាក់ អាចគ្រប់គ្រងបាន និងអាចសម្រេចបាន[3]"។ ក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១ "ទិន្នន័យ" សំដៅលើ "ព័ត៌មានស្តីពីមនុស្ស វត្ថុ និងប្រព័ន្ធនានា"។ របាយការណ៍នោះក៏បញ្ជាក់ផងដែរថា ទិន្នន័យអាចជាទិន្នន័យបែបបរិមាណ ឬជាទិន្នន័យបែបគុណភាព និងអាចសម្រាប់គោលបំណងសាធារណៈ ឬគោលបំណងឯកជន[4]។ ទីពីរ នៅពេលបកប្រែជាភាសាខ្មែរ (ទិន្នន័យ) ពាក្យនេះកាន់តែងាយស្រួលយល់ និងងាយស្រួលលើកឡើងក្នុងដំណើរការគោលនយោបាយរដ្ឋាភិបាល។ ទីបី តាមរយៈការប្រើប្រាស់ពាក្យ "ទិន្នន័យ" ការស្រាវជ្រាវនេះ មានគោលបំណងផ្សារភ្ជាប់កាន់តែខ្លាំងទៅនឹងការជជែកដេញដោលជាអន្តរជាតិ ស្តីពីការប្រើប្រាស់ទិន្នន័យក្នុងការអភិវឌ្ឍ និងកិច្ចខិតខំប្រឹងប្រែងធ្វើទំនើបកម្មប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា[5] ។

---

[3] INASP (2016) Evidence-informed policy making toolkit,
[4] World Bank (2021) WDR on Data for Better Lives (p. 24)
[5] NIS (2018) National Strategy for the Development of Statistics (2019-2023)

## ១.២ គោលបំណងនៃការស្រាវជ្រាវ និងសំណួរក្នុងការស្រាវជ្រាវ

**ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងបរិបទនៃ "កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា"។** កម្មវិធីនេះ ត្រូវបានអនុវត្តដោយអង្គការមូលនិធិអាស៊ី ក្រោមជំនួយពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី (DFAT)។ កម្មវិធីពន្លកចំណេះ ខិតខំពង្រឹងសមត្ថភាពរបស់ស្ថាប័នស្រាវជ្រាវនៅកម្ពុជាដើម្បី ផលិតការស្រាវជ្រាវប្រកបដោយគុណភាពដែលគាំទ្រដល់ការវិភាគ និងពិភាក្សាអំពីគោលនយោបាយនៅកម្ពុជា។

ការស្រាវជ្រាវនេះមានគោលបំណងផ្តល់ការយល់ដឹងថ្មីៗ និងគ្រប់ជ្រុងជ្រោយបំផុតស្តីពីដំណើរការគោលនយោបាយសាធារណៈ ការប្រើប្រាស់ទិន្នន័យ និងអភិបាលកិច្ចទិន្នន័យនៅកម្ពុជានិងអាស៊ាន ក្នុងបរិបទនៃការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។ លទ្ធផលរកឃើញពីការសិក្សានេះគឺសម្រាប់ជាប្រយោជន៍ដល់ដៃគូបច្ចុប្បន្ន និងអ្នកដែលអាចក្លាយជាដៃគូក្នុងកម្មវិធីពន្លចំណេះ និងក្រុមគោលដៅនានា ដូចជា អ្នកស្រាវជ្រាវគោលនយោបាយសាធារណៈ សិស្សនិស្សិត និងភាគីពាក់ព័ន្ធផ្សេងទៀតដែលមានចំណាប់អារម្មណ៍។ ពាក់ព័ន្ធនឹងកម្មវិធីពន្លកចំណេះ ការស្រាវជ្រាវនេះមិនមែនជាការវាយតម្លៃលើសមិទ្ធកម្មរបស់កម្មវិធីនេះនោះទេ ប៉ុន្តែជាលំហាត់បង្កើតទស្សនីកណ៍ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់យុទ្ធសាស្រ្ត និងអភិក្រមនៃការរៀបចំកម្មវិធីនាពេលអនាគត។

ដើម្បីសម្រេចគោលបំណងដែលបានកំណត់ ការស្រាវជ្រាវនេះខិតខំឆ្លើយសំណួរខាងក្រោម៖

- **តើអ្វីជានិន្នាការ និងអាទិភាពអភិវឌ្ឍន៍សំខាន់ៗនៅកម្ពុជា ក្រោយវិបត្តិកូវីដ-១៩?** តើអ្វីជាភាពពាក់ព័ន្ធនៅកម្រិតអាស៊ាន ដូចជា កម្ពុជាក្នុងនាមជាប្រធានប្តូរវេនអាស៊ាន ឆ្នាំ២០២២? ចម្លើយសម្រាប់សំណួរទាំងពីរនេះ មានបង្ហាញក្នុងផ្នែកទី២ ដែលផ្តល់បរិបទសម្រាប់ផ្នែកបន្តបន្ទាប់។
- **តើអ្វីជាដំណើរការ និងលក្ខណៈសំខាន់ៗនៃដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា?** ចម្លើយសំណួរនេះមានបង្ហាញក្នុងផ្នែកទី៣។
- **តើអភិបាលកិច្ចទិន្នន័យសម្រាប់គោលបំណងគោលនយោបាយនៅកម្ពុជាមានដំណើរការដូចម្តេច?** ចម្លើយលម្អិតសម្រាប់សំណួរនេះមានបង្ហាញក្នុងផ្នែកទី៤ ដែលលើកឡើងពីតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ និងផ្សារភ្ជាប់កិច្ចពិភាក្សានេះទៅនឹងឌីជីថលូបនីយកម្ម និងគំនិតផ្តួចផ្តើមជាបន្តបន្ទាប់នៅកម្រិតអាស៊ាន។
- **តើដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ មានភាពខុសគ្នាដូចម្តេចតាមវិស័យនិងអនុវិស័យមួយចំនួន?** ដើម្បីរំលេចភាពខុសគ្នា ផ្នែកទី៥ នឹងលើកឡើងពីករណីសិក្សាចំនួន៤ មានដូចជា កិច្ចគាំពារសង្គម វិមជ្ឈការ ការផ្តល់ជំនួយដល់សហគ្រាសខ្នាតតូចនិងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ និងការអភិវឌ្ឍយុវជន។ ក្នុងករណីសិក្សានីមួយៗ មានការបង្ហាញ

ពីភាពពាក់ព័ន្ធ និងចំណេះដឹងពីកម្រិតអាស៊ាន។

- ផ្អែកតាមលទ្ធផលរកឃើញ តើមានសេចក្ដីសន្និដ្ឋាន និងអនុសាសន៍សំខាន់ៗអ្វីខ្លះសម្រាប់កម្មវិធីពន្លកចំណេះ ឬកម្មវិធីស្រដៀងគ្នាផ្សេងទៀត ដែលខិតខំលើកកម្ពស់វិស័យស្រាវជ្រាវនៅកម្ពុជា? សំណួរទាំងនេះត្រូវបានលើកមកពិភាក្សាក្នុងជំពូកចុងក្រោយនៃរបាយការណ៍នេះ។

ដើម្បីផ្ដល់ព័ត៌មានបច្ចេកទេសលម្អិតដល់អ្នកអាន របាយការណ៍នេះក៏មានបញ្ចូលប្រអប់ តារាង និងឧបសម្ព័ន្ធផងដែរ។ ព័ត៌មានបន្ថែមទាំងនេះ ដែលភាគច្រើនផ្អែកតាមប្រភពអនឡាញ គឺសម្រាប់ជាប្រយោជន៍ដល់អ្នកដែលចង់ស្វែងយល់បន្ថែមអំពីប្រធានបទជាក់លាក់ ដូចជា តួនាទីរបស់ក្រសួងហិរញ្ញវត្ថុក្នុងដំណើរការគោលនយោបាយ អភិបាលកិច្ចទិន្នន័យ និងគោលនយោបាយឌីជីថលូបនីយកម្ម ប្រព័ន្ធស្ថិតិជាតិបច្ចុប្បន្នរបស់កម្ពុជា ក៏ដូចជាគោលនយោបាយនិងគំនិតផ្ដួចផ្ដើមដែលពាក់ព័ន្ធនៅកម្រិតអាស៊ាន។

គួរកត់សម្គាល់ថា ការស្រាវជ្រាវនេះមិនមែនជាការវាយតម្លៃជាប្រព័ន្ធលើដំណើរការគោលនយោបាយសាធារណៈ និងការប្រើប្រាស់ទិន្នន័យនាពេលបច្ចុប្បន្ននោះទេ និងមិនមានគោលបំណងផ្ដល់អនុសាសន៍គោលនយោបាយដល់រដ្ឋាភិបាលស្ដីពីរបៀបកែលម្អប្រព័ន្ធស្ថិតិជាតិឡើយ។ មានស្នាដៃស្រាវជ្រាវផ្សេងទៀតដែលផ្ដោតលើប្រធានបទទាំងនេះ ហើយការសិក្សានេះយោងតាមស្នាដៃទាំងនោះក្នុងករណីដែលអាចអនុវត្តបាន[6]។ ផ្ទុយទៅវិញ ការស្រាវជ្រាវនេះជាការសិក្សាបែបវិភាគ និងមានគោលបំណងប្រមូល សំយោគ និងវិភាគព័ត៌មាន និងទិន្នន័យដែលមានថ្មីបំផុតស្ដីពីប្រធានបទនេះ ដើម្បីផ្ដល់ទិដ្ឋភាពកាន់តែច្បាស់ថាតើដំណើរការគោលនយោបាយសាធារណៈដំណើរការដោយរបៀបណា តើដំណើរការនេះអាចទាញប្រយោជន៍ពីទិន្នន័យដោយរបៀបណា បញ្ហាប្រឈម និងតើដំណើរការនេះដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា។ ការស្រាវជ្រាវនេះ យោងតាមឯកសារពាក់ព័ន្ធពីបណ្ដាប្រទេសផ្សេងទៀត និងចំណេះដឹងពីតំបន់អាស៊ាន ដើម្បីឱ្យអ្នកអានអាចទទួលបានការយល់ដឹងប្រហាក់ប្រហែលគ្នា ស្ដីពីស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា និងម៉ាគាឆ្ពោះទៅមុខ។

6 សូមមើល ឧ. RGC (2021) Report on the assessment of the Implemetnation of National Strategy for the Development of Statistics 2019-2023 and Statistics 2030: Towards Reform Agenda. Phnom Penh.

## ១.៣ វិធីសាស្ត្រ

ដើម្បីឆ្លើយសំណួរខាងលើ ការស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម ៖

- នៅដំណាក់កាលដំបូង អ្នកស្រាវជ្រាវខិតខំសិក្សាស្វែងយល់ ផ្ទៀងផ្ទាត់ និងសំយោគក្តីរំពឹងទុករបស់ក្រុមការងារកម្មវិធីពន្លកចំណេះ និងដៃគូរបស់កម្មវិធី ស្តីពីចំណុចផ្តោតសំខាន់ និងការបន្ថែមតម្លៃរំពឹងទុកក្នុងការស្រាវជ្រាវនេះ។ ជំហាននេះ មានសារៈសំខាន់ណាស់ សម្រាប់តម្រឹមតម្រង់រចនាសម្ព័ន្ធជារួម និងក្របខ័ណ្ឌវិភាគនៃការសិក្សានេះ។
- អ្នកស្រាវជ្រាវប្រើប្រាស់ អភិក្រមច្រំដែលសម្រាប់ការអានឯកសារពាក់ព័ន្ធ បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងកិច្ចប្រជុំផ្ទៀងផ្ទាត់។ ក្នុងការស្រាវជ្រាវនេះ មានការអានឯកសារពាក់ព័ន្ធយ៉ាងច្រើន រួមមាន ឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀត (ដូចជា អភិបាលកិច្ចទិន្នន័យ ដំណើរការគោលនយោបាយ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩) ឯកសារគោលនយោបាយ និងគោលការណ៍ណែនាំផ្នែកបច្ចេកទេសនៅកម្ពុជា គោលនយោបាយ និងគំនិតផ្តួចផ្តើមនៅកម្រិតអាស៊ាន និងមូលដ្ឋានទិន្នន័យដែលមានស្រាប់។ ការអានឯកសារពាក់ព័ន្ធ ផ្តល់ចំណេះដឹងបឋម និងសម្មតិកម្ម ដែលក្រោយមកទៀត ត្រូវបានប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ដើម្បីស្វែងយល់បន្ថែម និង/ឬបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់។
- ក្រៅពីនេះ អ្នកស្រាវជ្រាវទទួលបានអត្ថប្រយោជន៍ពីចំណេះដឹងដែលត្រូវបានចែករំលែក និងជជែកដេញដោលក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះស្តីពី "ម៉ាគាឆ្ពោះទៅរកការស្តារឡើងវិញពីវិបត្តិកូវីដ-១៩នៅកម្ពុជា" កាលពីខែវិច្ឆិកា ឆ្នាំ២០២១។ ចំណេះដឹងដែលបានចែករំលែកដោយវាគ្មិនមកពីវិស័យរដ្ឋាភិបាល និងវិស័យមិនមែនរដ្ឋាភិបាលត្រូវបានចងក្រងជាសៀវភៅព័ត៌មាន[7] និងត្រូវបានដកស្រង់ក្នុងរបាយការណ៍នេះ។
- ក្រៅពីនេះ អ្នកស្រាវជ្រាវផ្អែកលើចំណេះដឹងផ្ទាល់ខ្លួន និងការសង្កេតមើលក្នុងការងារជាអ្នកស្រាវជ្រាវរយៈពេល ១៨ឆ្នាំកន្លងមកនេះ ជាពិសេសពាក់ព័ន្ធនឹងដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា។ ទោះបីជាបណ្តុំចំណេះដឹងទាំងនេះបានផ្តល់ជាប្រយោជន៍មែន ប៉ុន្តែក៏មានការកត់សម្គាល់ពីព្រំដែនកំណត់ និងភាពលម្អៀងរបស់វាផងដែរ។

**ការសិក្សានេះផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការយោងតាមគោលនយោបាយ និងឯកសារច្បាប់នានា។** ក្នុងករណីខ្លះ ដំណើរការគោលនយោបាយនៅកម្ពុជា (ក៏ដូចជាក្នុងប្រទេសផ្សេងទៀតដែរ) យកលំនាំតាមវិធាន និងបទបញ្ញត្តិផ្លូវការ។ ដូច្នេះហើយទើបរបាយការណ៍នេះផ្តោតកាន់តែខ្លាំងលើការយោងតាមច្បាប់ជាធរមាន អនុក្រឹត្យ ប្រកាស សារាចរ និង

[7] The Asia Foundation (2021) Ponlok Chomnes National Policy Forum Booklet, Phnom Penh, Cambodia.

គោលការណ៍នានា។ ពោលគឺមានទាំងទិដ្ឋភាពជាក់ស្តែង និងទិដ្ឋភាពតាមផ្លូវច្បាប់ក្នុងការអនុវត្ត គោលនយោបាយមួយ។ ការស្រាវជ្រាវនេះ ពិភាក្សាពីទិដ្ឋភាពទាំងពីរនេះ។

**ការស្រាវជ្រាវនេះប្រើប្រាស់ករណីសិក្សា ដើម្បីផ្តល់ទិដ្ឋភាពចម្រុះនៃដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា។** ខណៈដែលដំណើរការគោលនយោបាយនៅកម្ពុជាអនុវត្តតាមកម្រងវិធាន និងបទដ្ឋានទូទៅ អ្នកស្រាវជ្រាវត្រូវបង្ហាញថាតើកម្រងវិធាន និងបទដ្ឋាននោះ មានការប្រែប្រួលដូចម្តេចទៅតាមករណីនានា និងបង្ហាញពីកត្តាដែលអាចពន្យល់ពីការប្រែប្រួលទាំងនោះបាន។ នេះជាមូលហេតុចម្បងក្នុងផ្នែកវិធីសាស្ត្រ ដែលនាំឱ្យមានការបញ្ចូលផ្នែកទី៥ (ករណីសិក្សា) ក្នុងរបាយការណ៍នេះ។

## ១.៤ រចនាសម្ព័ន្ធនៃរបាយការណ៍នេះ

របាយការណ៍នេះត្រូវបានចែកចេញជាផ្នែកដូចខាងក្រោម៖

- ផ្នែកទី២ ពិភាក្សាពីនិន្នាការធំៗក្រោយវិបត្តិកូវីដ-១៩ ទាំងនៅកម្រិតសកល និងកម្រិតតំបន់។ បន្ទាប់មកគឺការរៀបរាប់ពីករណីរបស់ប្រទេសកម្ពុជា ជាពិសេសផែនការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។ ចុងក្រោយគឺការពិភាក្សាពីអ្វីដែលត្រូវបានគ្រោងឡើង និងអនុវត្តនៅកម្រិតអាស៊ាន ដូចជា កម្ពុជាក្នុងនាមជាប្រធានកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២។
- ផ្អែកលើទិដ្ឋភាពទូលំទូលាយដែលបានលើកមកបង្ហាញក្នុងផ្នែកទី២ ផ្នែកទី៣ គឺផ្តោតលើប្រធានបទសំខាន់ៗស្តីពីដំណើរការគោលនយោបាយសាធារណៈរបស់កម្ពុជា ភាគីពាក់ព័ន្ធសំខាន់ៗ យន្តការ និងការប្រើប្រាស់ទិន្នន័យក្នុងដំណាក់កាលនីមួយៗនៃដំណើរការគោលនយោបាយ។
- ផ្នែកទី៤ ពិនិត្យមើលលម្អិតលើសំណួរដែលពាក់ព័ន្ធនឹងអភិបាលកិច្ចទិន្នន័យសម្រាប់ដំណើរការគោលនយោបាយនៅកម្ពុជា ដោយមានការពិភាក្សាពីក្របខ័ណ្ឌទស្សនាទានសំខាន់ៗ (ដោយផ្អែកចម្បងលើរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១) ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយ ការផលិត និងការចែករំលែកទិន្នន័យដោយរដ្ឋាភិបាល និងការជំរុញការចូលរួមរបស់តួអង្គមិនមែនរដ្ឋ ដូចជា ស្ថាប័នស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល (NGO) និងវិស័យឯកជន។ ក្រៅពីនេះ ក៏មានការពិភាក្សាពីអភិបាលកិច្ចទិន្នន័យក្នុងបរិបទនៃឌីជីថលូបនីយកម្ម និងភាពជាដៃគូនៅកម្រិតអាស៊ានផងដែរ។
- ផ្នែកទី៥ បំពេញបន្ថែមលើផ្នែកមុនៗ ដោយលើកឡើងពីករណីសិក្សាចំនួន៤ ដើម្បីបង្ហាញពីភាពខុសគ្នាក្នុងដំណើរការគោលនយោបាយសាធារណៈ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា (ទោះបីជាមានដំណើរការ និងលក្ខណៈដូចគ្នាមួយចំនួនក៏ដោយ)។ ករណីសិក្សាទាំង៤ មានជាអាទិ៍ ១) កិច្ចគាំពារសង្គមក្នុងអំឡុងពេលនៃការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ២)

កំណែទម្រង់វិមជ្ឈការ ៣) ការផ្តល់ជំនួយដល់សហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យទេសចរណ៍ក្នុងអំឡុងវិបត្តិកូវីដ-១៩ និង ៤) ការជំរុញការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសហគមន៍។ ក្នុងករណីសិក្សានីមួយៗ ក៏មានបង្ហាញពីចំណេះដឹងពាក់ព័ន្ធពីកម្រិតអាស៊ានផងដែរ។

- ផ្នែកទី៦ ផ្តល់សេចក្តីសន្និដ្ឋាន និងអនុសាសន៍ដល់កម្មវិធីពន្លកចំណេះសម្រាប់ការរៀបចំ និងអនុវត្តកម្មវិធីនាពេលអនាគត។

## ២. និន្នាការធំៗក្រោយវិបត្តិកូវីដ-១៩៖ អាទិភាពរបស់កម្ពុជា និងតំបន់អាស៊ាន

### ២.១ និន្នាការធំៗក្រោយវិបត្តិកូវីដ-១៩

និន្នាការធំៗត្រូវបានកំណត់ជាចលករចម្បងក្នុងការអភិវឌ្ឍសង្គម ដែលនឹងបង្កផលប៉ះពាល់លើគ្រប់វិស័យទាំងអស់ក្នុងរយៈពេល ១០-១៥ ឆ្នាំខាងមុខ។ និន្នាការធំៗអាចពាក់ព័ន្ធនឹងសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន ឬបច្ចេកវិទ្យា។ ចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិកូវីដ-១៩ ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ និងទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគីជាច្រើន ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារពិភពលោក ទីភ្នាក់ងារអង្គការសហប្រជាជាតិ វេទិកាសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចវិទូ បានចេញផ្សាយកម្រងឯកសារជាច្រើនស្តីពីនិន្នាការធំៗ និងការជះឥទ្ធិពលរបស់និន្នាការទាំងនោះលើពិភពលោកទាំងមូល[8]។

**ក្នុងនាមជាប្រទេសសេដ្ឋកិច្ចបើកចំហ កម្ពុជាបានប្រឈមនឹងនិន្នាការធំៗ ដែលលេចឡើងទាំងនៅកម្រិតតំបន់ និងកម្រិតសកល។** ក្នុងផែនការស្តារឡើងវិញ និងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់និន្នាការធំៗទាំងនោះ ក៏ដូចជាឱកាស និងហានិភ័យដែលអាចកើតចេញពីនិន្នាការទាំងនោះផងដែរ ដូចជា ហានិភ័យជាបន្តបន្ទាប់ និងមិនច្បាស់លាស់នៃជំងឺរាតត្បាតនាពេលអនាគត ភាពតានតឹងក្នុងចំណោមប្រទេសមហាអំណាច សង្គ្រាមពាណិជ្ជកម្ម ការបង្អាក់សង្វាក់ភស្តុភារ និងពាណិជ្ជកម្មក្នុងតំបន់ ហានិភ័យដែលអាចកើតមានក្នុងវិស័យហិរញ្ញវត្ថុ និងការប្រែប្រួលអាកាសធាតុ។ និន្នាការធំៗដែលពាក់ព័ន្ធនឹងបញ្ហាមួយចំនួន ដូចជា ការវិនិយោគពីបរទេស សេដ្ឋកិច្ចឌីជីថល អភិបាលកិច្ចទិន្នន័យ កិច្ចគាំពារសង្គមនិងការងារ និងការប្រែប្រួលអាកាសធាតុ ត្រូវបានលើកមកពិភាក្សាដោយសង្ខេបក្នុងផ្នែកខាងក្រោម។

**និន្នាការធំដំបូងគេពាក់ព័ន្ធនឹងការវិនិយោគពីបរទេស (កម្រិតសកល និងកម្រិតតំបន់)។** នៅលើពិភពលោក ការវិនិយោគផ្ទាល់ពីបរទេសបានធ្លាក់ចុះយ៉ាងគំហុកដោយសារវិបត្តិកូវីដ-១៩ ប៉ុន្តែភាពជ្រាលជ្រៅនៃការធ្លាក់ចុះនៅតាមតំបន់ គឺមានកម្រិតខុសគ្នា។ ប្រទេសអភិវឌ្ឍន៍ និងប្រទេសក្នុងទ្វីបអាហ្វ្រិក រងផលប៉ះពាល់យ៉ាងដំណំ ខណៈដែលតំបន់អាស៊ីរងផលប៉ះពាល់តិចតួចជាង[9]។ សម្រាប់តំបន់អាស៊ាន ទោះបីជាមានការថយចុះការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសការវិនិយោគលើវិស័យកម្មន្តសាល និងទេសចរណ៍ក្នុងឆ្នាំ២០២០ ក៏ដោយ ក៏និន្នាការរយៈពេលវែងនៅតែមានសញ្ញាវិជ្ជមាន ហើយក្នុងអំឡុងវិបត្តិកូវីដ-១៩ តំបន់អាស៊ានមានការកើនឡើងនៃការ

---

[8] សូមមើល ឧ. the Economist's the World Ahead 2022 (https://www.economist.com/the-world-ahead-2022/) and WEF's Strategic Foresights (https://reports.weforum.org/global-strategic-foresight/)

[9] UNCTAD (2021) World Investment Report 2021: Investing in sustainable recovery. New York, USA.

វិនិយោគលើឧស្សាហកម្មដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជា អគ្គិសនី បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ការដឹកជញ្ជូននិងការស្តុកទុក ដែលគូសបញ្ជាក់ពីភាពធន់នៃឧស្សាហកម្មទាំងនេះ ក្នុងអំឡុងពេលមានការលំបាកផ្នែកសេដ្ឋកិច្ច[10]។

**សេដ្ឋកិច្ចឌីជីថលដែលជាចលកររយៈពេលវែង ត្រូវបានពង្រីក និងពង្រឹងដោយវិបត្តិកូវីដ-១៩។** នេះជាការពិតសម្រាប់កម្រិតសកល និងជាតថភាពនៅកម្រិតអាស៊ាន។ យោងតាមរបាយការណ៍ឆ្នាំ២០២១ របស់ក្រុមហ៊ុន Google, Temasek, and Bain & Company ដែលមានចំណងជើងថា 'Roaring 20's: The SEA Digital Decade' តំបន់អាស៊ានកំពុងឈានទៅសម្រេចបានសេដ្ឋកិច្ចឌីជីថលដែលមានទំហំ ១ពាន់ទ្រីលានដុល្លារនៅឆ្នាំ២០៣០។ របាយការណ៍នេះកត់សម្គាល់ថា កំណើននេះត្រូវបានជំរុញជាចម្បងដោយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអាជីវកម្មដឹកជញ្ជូនអាហារ អមជាមួយនឹងបណ្តាញផ្សព្វផ្សាយអនឡាញ សេវាហិរញ្ញវត្ថុ និងសេវាធ្វើដំណើរតាមអនឡាញ។ បច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងសុខភាព និងការអប់រំ ក៏កំពុងមានការកើនឡើងផងដែរ។ របាយការណ៍នេះលើកឡើងថា សេដ្ឋកិច្ចឌីជីថលនឹងជះឥទ្ធិពលលើនិន្នាការរយៈពេលវែងនៅក្នុងតំបន់ ហើយរដ្ឋសមាជិកអាស៊ាននីមួយៗបានលើកឡើងពីភាពចាំបាច់ក្នុងការបង្កើនកិច្ចខិតខំប្រឹងប្រែងទាញប្រយោជន៍ពីសក្តានុពលនៃសេដ្ឋកិច្ចឌីជីថល[11]។ និន្នាការជំមួយនៅកម្រិតតំបន់អាស៊ានគឺ សហគ្រាសខ្នាតតូចនិងមធ្យម កាន់តែច្រើននឹងបន្សុំខ្លួនទៅនឹងសេដ្ឋកិច្ចឌីជីថលដើម្បីអាចឈរជើងនិងរីកចម្រើនបាន[12]។

**ទិន្នន័យកំពុងក្លាយជាធាតុផ្សំកាន់តែសំខាន់សម្រាប់ការជះឥទ្ធិពលលើសេដ្ឋកិច្ចឌីជីថល។** សារៈសំខាន់នៃទិន្នន័យត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ក្នុងរបាយការណ៍សំខាន់ៗ ដូចជា "របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១" របស់ធនាគារពិភពលោក និង "របាយការណ៍សេដ្ឋកិច្ចឌីជីថលឆ្នាំ២០២១" របស់ UNCTAD។ របាយការណ៍របស់ UNCTAD ផ្តោតសំខាន់លើបញ្ហាលំហូរទិន្នន័យឆ្លងដែន និងឥទ្ធិពលរបស់វាលើការអភិវឌ្ឍ[13]។ នៅកម្រិតអាស៊ាន ក៏មានចំណុចផ្តោតស្រដៀងគ្នាផងដែរ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការវិនិយោគលើបច្ចេកវិទ្យា និងឧស្សាហកម្មឌីជីថល[14]។ ជាមួយនឹងភាពជឿនលឿននៃទិន្នន័យ Big Data និន្នាការរយៈពេលវែងដែលកំពុងលេចឡើង គឺរបៀបដែលរដ្ឋាភិបាលអាចប្រើប្រាស់ទិន្នន័យទាន់ពេលវេលា ដើម្បីកំណត់រកឱកាសបញ្ហាប្រឈម និងនិន្នាការសំខាន់ៗក្នុងវិស័យនានា ដូចជា ម៉ាក្រូសេដ្ឋកិច្ច ការអប់រំ ការគ្រប់គ្រងជំងឺរាតត្បាត។ល[15]។

[10] ASEAN and UNCTAD (2021) ASEAN investment report (2020-2021): Investing in Industry 4.0. Jakarta, Indonesia.
[11] Google, Temasek and Bain & Company (2021) E-Conomy SEA 2021: Roaring 20s: The SEA digital decade. USA.
[12] UOB (2021) ASEAN SME transformation study 2020. Singapore.
[13] UNCTAD (2021) Digital economy report 2021: Cross-border data flows and development: For whom the data flow. New York, USA.
[14] ASEAN and UNCTAD (2021) ASEAN investment report (2020-2021): Investing in Industry 4.0. Jakarta, Indonesia.
[15] The Economist (2021) Instant economics – A real time revolution will up-end the practice macro-economics (23rd Oct 2021 Edition).

និន្នាការធំៗ ចំនួន២ ផ្សេងទៀតដែលពាក់ព័ន្ធគ្នា គឺរបៀបដែលប្រទេសនានាកំណត់ និងកែទម្រង់ប្រព័ន្ធគាំពារសង្គម និងគោលនយោបាយការងាររបស់ខ្លួន។ យោងតាមរបាយការណ៍ស្តីពីកិច្ចគាំពារសង្គមពិភពលោករបស់អង្គការILO(២០២០-២០២២)វិបត្តិកូវីដ-១៩បានរំលេចវិសមភាពដែលចាក់ឫសជ្រៅ និងគម្លាតធំៗក្នុងការគ្របដណ្តប់ ភាពគ្រប់ជ្រុងជ្រោយ និងភាពគ្រប់គ្រាន់នៃកិច្ចគាំពារសង្គមក្នុងប្រទេសទាំងអស់ ប៉ុន្តែវិបត្តិនេះក៏ជំរុញឱ្យមានការឆ្លើយតបខុសៗគ្នាក្នុងទម្រង់ជាគោលនយោបាយគាំពារសង្គមផងដែរ និងបានបំផុសឱ្យរដ្ឋាភិបាលជាច្រើនប្តេជ្ញាកសាងប្រព័ន្ធគាំពារសង្គមក្នុងរយៈពេលវែង[16]។ អ្វីដែលពាក់ព័ន្ធនឹងកិច្ចគាំពារសង្គមគឺ ភាពចាំបាច់ក្នុងការពិនិត្យឡើងវិញលើគោលនយោបាយការងារ និងគោលនយោបាយការពាររបស់រដ្ឋាភិបាល ជាពិសេសក្នុងចំណោមយុវជន និងអ្នកដែលស្ថិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ[17]។

**ចុងបញ្ចប់ ការប្រែប្រួលអាកាសធាតុគឺ ជានិន្នាការដ៏ធំមួយក្នុងជីវិតរស់នៅរបស់យើង។** កន្លងមកមានការអនុវត្តគំនិតផ្តួចផ្តើមជាសកលជាច្រើនដើម្បីដោះស្រាយបញ្ហានេះ ដោយមានការចេញរបាយការណ៍ និងព័ត៌មានបច្ចុប្បន្នភាពជាទៀងទាត់[18]។ ប្រទេសកាន់តែច្រើនបាន និងកំពុងអនុវត្តអភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការប្រែប្រួលអាកាសធាតុ តាមរយៈការដាក់បញ្ចូលបញ្ហានេះទៅក្នុងវិស័យផ្សេងៗ។ ឧទាហរណ៍ល្អមួយគឺ ប្រទេសអូស្ត្រាលីបានអនុម័តផែនការកាត់បន្ថយការបំភាយឧស្ម័នរយៈពេលវែង ក្នុងឆ្នាំ២០២១។ ផែនការនេះមានគោលបំណងផ្សារភ្ជាប់ដំណោះស្រាយបច្ចេកវិទ្យា និងដំណោះស្រាយសេដ្ឋកិច្ច ដើម្បីកាត់បន្ថយចំណាយលើបច្ចេកវិទ្យា ជំរុញការពង្រីកក្នុងទ្រង់ទ្រាយធំ ក្តាប់ឱកាសទាំងក្នុងទីផ្សារបែបប្រពៃណីនិងទីផ្សារថ្មីៗ និងជំរុញកិច្ចសហប្រតិបត្តិការកម្រិតសកល[19]។ ខណៈដែលបច្ចុប្បន្ន មានការលើកឡើងខុសៗគ្នាអំពីភាពល្អប្រសើរនៃផែនការនេះ គេរំពឹងថា ប្រទេសនានានឹងដាក់បញ្ចូលការប្រែប្រួលអាកាសធាតុដែលជានិន្នាការដ៏ធំមួយ ឱ្យកាន់តែស៊ីជម្រៅទៅក្នុងផ្នែកផ្សេងៗនៃគន្លងអភិវឌ្ឍន៍របស់ខ្លួន។

## ២.២ អាទិភាពអភិវឌ្ឍន៍របស់កម្ពុជា

**ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ បាននាំឱ្យមានការកែប្រែអាទិភាពអភិវឌ្ឍន៍ទាំងសម្រាប់កម្ពុជា និងតំបន់អាស៊ានទាំងមូល។** ចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍សំខាន់ៗបានធ្វើការស្រាវជ្រាវគោលនយោបាយផ្សេងៗដើម្បីតាមដានការវិវត្ត និងផលប៉ះពាល់នៃវិបត្តិនេះលើសេដ្ឋកិច្ច-សង្គមកិច្ច។ នៅចុងឆ្នាំ២០២១ រដ្ឋាភិបាលបានចេញក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា

16 ILO (2021) World Social Protection Report (2020-2022). Geneva.
17 ILO (2021) World employment and social outlook trends (2022). Geneva.
18 ឧ. សូមមើល https://www.un.org/en/climatechange/reports
19 Australian Government (2021) Australia with its Australia's Long-Term Emissions Reduction Plan adopted in 2021, Canberra.

(២០២១-២០២៣)[20]។ ក្រៅពីនេះ ដៃគូអភិវឌ្ឍន៍បានចេញផ្សាយរបាយការណ៍ស្រាវជ្រាវ និងអនុសាសន៍គោលនយោបាយស្តីពីវិធានការស្តារឡើងវិញមួយចំនួន។ នៅកម្រិតអាស៊ាន ក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF) ត្រូវបានអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ កាលពីខែវិច្ឆិកា ឆ្នាំ២០២០។

ជារួម ការសិក្សាថ្មីៗបំផុត និងឯកសារគោលនយោបាយស្តីពីស្ថានភាពវិបត្តិកូវីដ-១៩ និងផលប៉ះពាល់នៃវិបត្តិនេះលើសេដ្ឋកិច្ចកម្ពុជា បានផ្តល់សេចក្តីសន្និដ្ឋាន និងអនុសាសន៍ស្រដៀងគ្នា។ ទីមួយ បើធៀបនឹងប្រទេសជាច្រើនផ្សេងទៀតនៅក្នុងពិភពលោក និងក្នុងតំបន់អាស៊ាន កម្ពុជាធ្វើបានល្អក្នុងការគ្រប់គ្រងវិបត្តិនេះ។ គិតត្រឹមខែធ្នូឆ្នាំ២០២១ កម្ពុជាមានករណីឆ្លងសរុប ១២០.០០០ ករណី និងករណីស្លាប់ប្រមាណ ៣.០០០ ករណី។ ទោះជាយ៉ាងណា សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់បំផុតគឺ អត្រាខ្ពស់នៃការចាក់វ៉ាក់សាំង ដែលគិតត្រឹមខែធ្នូឆ្នាំ២០២១ ប្រជាជនជិត ៩០% នៃចំនួនប្រជាជនសរុប ១៦លាននាក់ ត្រូវបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។ ការណ៍នេះបានផ្តល់លទ្ធភាពឱ្យកម្ពុជាអនុវត្តការបើកសេដ្ឋកិច្ចឡើងវិញដោយសន្សឹមៗ និងការសម្របខ្លួនក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី[21]។

**ទាំងរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ សុទ្ធតែបានធ្វើការស្រាវជ្រាវស្តីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩លើសេដ្ឋកិច្ចកម្ពុជា។** រដ្ឋាភិបាល និងម្ចាស់ជំនួយពហុភាគីសំខាន់ៗ ដូចជា ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី តែងបានចេញផ្សាយ និងកែសម្រួលព័ត៌មានបច្ចុប្បន្នភាពរបស់ខ្លួន ដើម្បីឃ្លាំមើលយកចក្ខុវិស័យសេដ្ឋកិច្ចរបស់កម្ពុជា ក៏ដូចជាតំបន់ និងពិភពលោកទាំងមូល។ ការសិក្សាទាំងនេះច្រើនតែប្រើប្រាស់សំណុំទិន្នន័យម៉ាក្រូសេដ្ឋកិច្ចស្រដៀងគ្នា និងការយោងតាមទិន្នន័យគ្នាទៅវិញទៅមក។ ដូច្នេះ ការសិក្សាទាំងនេះគឺមួយភាគធំផ្តល់លទ្ធផលរកឃើញប្រហាក់ប្រហែលគ្នា។ ក្រៅពីនេះ ការសិក្សាមួយចំនួនផ្តោតលើវិស័យ ឬអនុវិស័យជាក់លាក់។ ឧ. អង្គការមូលនិធិអាស៊ីបានសហការជាមួយអង្គការស្រាវជ្រាវក្នុងស្រុកឱ្យធ្វើការសិក្សាចំនួន២ ដោយឡែកពីគ្នាស្តីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម (MSMEs) ក្នុងវិស័យទេសចរណ៍ និងគ្រួសារនៅកម្ពុជា[22]។ ការសិក្សាមួយចំនួនផ្សេងទៀត ផ្តោតលើលំហសារពើពន្ធ កិច្ចគាំពារសង្គម និងជំនាញឌីជីថល[23]។

[20] RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023)

[21] RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023), World Bank (2020) Cambodia Economic Update: Restrained recovery, AMRO (2021) AMRO annual consultation report – Cambodia 2021.

[22] The Asia Foundation (2021) Revisiting the Pandemic: Rapid survey on the impact of COVID-19 on MSMEs in the tourism sector and households in Cambodia, available here: https://asiafoundation.org/publication/revisiting-the-pandemic-rapid-survey-on-the-impact-of-covid-19-on-msmes-in-the-tourism-sector-and-households-in-cambodia/

[23] ឧទាហរណ៍រួមមាន World Bank (2020) Cambodia Economic Update: Restrained recovery; UNDP (2020) Meeting the costs and maximizing the impact of social protection in Cambodia; UNDP (2021) How Industry 4.0 can boost Cambodia's economy after COVID-19: Opportunities for industrial upgrading and equitable development; CADT, CDRI, et al (2021) Demand for and supply of digital skills in Cambodia.

ជារួម ផែនការស្តារឡើងវិញរបស់រដ្ឋាភិបាលកម្ពុជា បានរួមបញ្ចូលចំណុចសំខាន់ៗជាច្រើនស្តីពីមេរៀន ហានិភ័យដែលកំពុងលេចឡើង និងឱកាសក្រោយវិបត្តិកូវីដ-១៩។ ផែនការស្តារសេដ្ឋកិច្ចឡើងវិញរបស់កម្ពុជា (២០២១-២០២៣) កំណត់មេរៀនចំនួន៦ និង ៨ចំណុចស្តីពីភាពធន់នៃសេដ្ឋកិច្ចកម្ពុជានៅក្រោយវិបត្តិកូវីដ-១៩។ ផែនការនេះក៏ផ្តល់យុទ្ធសាស្ត្ររួមចំនួន ៧ចំណុចដើម្បីជួយដល់ការស្តារសេដ្ឋកិច្ចឡើងវិញផងដែរ។ ចំណុចទាំងនេះ (សង្ខេបក្នុងប្រអប់ខាងក្រោម) ស្រដៀងគ្នានឹងចំណុចដែលបានកំណត់ក្នុងការសិក្សាដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍។

### ប្រអប់ទី១៖ ចំណុចសំខាន់ៗនៃផែនការស្តារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោយវិបត្តិកូវីដ-១៩[24]

ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា (២០២១-២០២៣) កត់សម្គាល់ពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិកូវីដ-១៩ ប៉ុន្តែក៏មើលឃើញឱកាសសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុង "គន្លងប្រក្រតីភាពថ្មី" ផងដែរ។ ក្របខ័ណ្ឌនេះរៀបរាប់ពីផែនការស្តារសេដ្ឋកិច្ចឡើងវិញ ដោយផ្អែកលើមេរៀនសំខាន់ៗខាងក្រោម៖

- ភាពងាយរងគ្រោះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាពីការប្រែប្រួលនៃស្ថានភាព និងតម្រូវការខាងក្រៅប្រទេស
- សំណាញ់សុវត្ថិភាពសង្គមជាឧបករណ៍អន្តរាគមន៍ដ៏មានប្រសិទ្ធភាពក្នុងការទ្រទ្រង់សុខុមាលភាពសង្គមក្នុងពេលមានវិបត្តិ
- ភាពចាំបាច់ក្នុងការរៀបចំឱ្យមានឧបករណ៍គោលនយោបាយហិរញ្ញវត្ថុ និងហិរញ្ញវត្ថុសាធារណៈបន្ថែមទៀត
- សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួនច្រើន ដែលបង្កផលវិបាកកាន់តែខ្លាំងក្នុងពេលមានវិបត្តិ
- ប្រាក់សន្សំរាជរដ្ឋាភិបាល ជាប្រភពហិរញ្ញប្បទានដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានានា ក្នុងអំឡុងពេលមានវិបត្តិ
- ប្រព័ន្ធពន្ធត្រូវតែបន្តអភិវឌ្ឍឱ្យមានលក្ខណៈទំនើប រឹងមាំ និងឆ្លើយតបខ្ពស់ទៅនឹងស្ថានភាពសង្គមសេដ្ឋកិច្ច។

[24] RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023)

យុទ្ធសាស្ត្រនេះក៏មើលឃើញភាពខ្លាំង និងឱកាសសម្រាប់សេដ្ឋកិច្ចផងដែរ៖

- កម្ពុជាអាចកសាងសមត្ថភាពក្នុងវិស័យសុខាភិបាលបាន ដោយឆ្លើយតបបានរហ័សទៅនឹងស្ថានភាពនៃវិបត្តិនេះ
- ស្ថានភាពជញ្ជីងទូទាត់ បន្តស្ថិតក្នុងស្ថានភាពល្អប្រសើរ
- លទ្ធផលនៃការប្រមូលចំណូល មានកម្រិតប្រសើរជាងអ្វីដែលធ្លាប់បានប៉ាន់ស្មាន
- ស្ថានភាពបំណុលសាធារណៈមានភាពល្អប្រសើរ ខណៈដែលកម្ពុជានៅតែមានលំហសម្រាប់កៀរគរហិរញ្ញប្បទាន
- វិស័យហិរញ្ញវត្ថុនៅកម្ពុជា មិនបានបង្ហាញនូវសញ្ញាណាមួយនៃហានិភ័យខ្ពស់នោះឡើយ
- វិស័យកសិកម្មនៅតែមានសក្តានុពលខ្ពស់ក្នុងការជួយទ្រទ្រង់សន្តិសុខស្បៀង ជាពិសេសការគាំទ្រកំណើន និងការស្រូបយកអ្នកអត់ការងារធ្វើ
- កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងទីផ្សារសកល តំបន់ និងទ្វេភាគី
- អត្រាចាប់យកបច្ចេកវិទ្យាឌីជីថល (Digital Adoption) ក៏មាននិន្នាការកើនឡើងយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ មានគោលបំណងស្តារកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យម ឱ្យត្រឡប់ទៅរកកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្នក្នុងរយៈពេលវែង។ គោលបំណងនេះត្រូវបានសម្រេចបានដោយផ្អែកលើសសរស្តម្ភទាំង៣ (ការស្តារឡើងវិញ ការកែទម្រង់ និងការកសាងភាពធន់)។ សម្រាប់អំឡុងឆ្នាំ ២០២១-២០២៣ អាទិភាពជាយុទ្ធសាស្ត្ររួមមាន៖

- ការស្តារសេដ្ឋកិច្ចឡើងវិញ ដោយផ្តោតសំខាន់លើវិស័យកសិកម្ម កសិឧស្សាហកម្ម ទេសចរណ៍ កាត់ដេរ និងឧស្សាហកម្មមិនមែនកាត់ដេរ
- កំណែទម្រង់ដើម្បីបង្កើនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែងដោយផ្តោតលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ ការអនុវត្តច្បាប់ស្តីពីការវិនិយោគ (ថ្មី) វិស័យថាមពល និងការកែលម្អបរិយាកាសធុរកិច្ច ការដឹកជញ្ជូន និងភស្តុភារ
- ការពង្រឹងភាពធន់តាមរយៈការកែលម្អវិស័យឌីជីថល ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ការអភិវឌ្ឍជំនាញ វិស័យអប់រំ កិច្ចគាំពារសង្គម វិស័យសុខាភិបាល ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាស្ថាប័នដឹកនាំការតាក់តែង និងក្នុងករណីខ្លះ ដឹកនាំការអនុវត្ត និងការពិនិត្យតាមដានគោលនយោបាយផ្សេងៗដែលពាក់ព័ន្ធនឹងវិបត្តិកូវីដ-១៩។ ក្រៅពីការចូលរួមជាសមាជិកគណៈកម្មាធិការសំខាន់ៗ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដើរតួនាទីជាក់ស្តែងក្នុងការព្រាងវិធានការគោលនយោបាយផ្សេងៗផងដែរ ដូចជា គោលនយោបាយស្តីពីការផ្តល់ជំនួយដល់សហគ្រាសខ្នាតតូចនិងមធ្យម ការពង្រឹងការប្រមូលចំណូលរដ្ឋ និងការកំណត់អាទិភាពឡើងវិញសម្រាប់វិភាជថវិការដ្ឋ។ ដូចអ្វីដែលនឹងបង្ហាញឱ្យដឹងក្នុងរបាយការណ៍នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើរតួនាទីកាន់តែសំខាន់ក្នុងដំណើរការគោលនយោបាយនៅកម្ពុជា រួមទាំងអភិបាលកិច្ចទិន្នន័យ។ សមត្ថកិច្ច និងឥទ្ធិពលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមការលើកឡើងដោយរបាយការណ៍នេះ) មានភាពទូលំទូលាយ និងសំខាន់ ពោលគឺគោលនយោបាយ និងកំណែទម្រង់នានាត្រូវមានការទទួលយក និងការគាំទ្រពីក្រសួង ទើបអាចមានឱកាសខ្ពស់ក្នុងការសម្រេចបានជោគជ័យ។ ហេតុនេះ គួរផ្តល់ព័ត៌មានកាន់តែច្រើនស្តីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាំងពីដំបូង ដូចការបង្ហាញក្នុងប្រអប់ខាងក្រោម។

### ប្រអប់ទី២៖ តួនាទីរបស់ក្រសួងហិរញ្ញវត្ថុ៖ ការអនុវត្តជាអន្តរជាតិ និងការអនុវត្តនៅកម្ពុជា

ឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀតបង្ហាញថា ការមានទីភ្នាក់ងារហិរញ្ញវត្ថុស្នូលមួយដែលរឹងមាំ (ពោលគឺក្រសួងហិរញ្ញវត្ថុ) គឺជាកត្តាសំខាន់ និងអំណោយផលសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចរបស់ប្រទេសមួយ ព្រោះថាក្រសួងនេះទទួលខុសត្រូវលើការរៀបចំគោលនយោបាយ និងការអនុវត្តមុខងារហិរញ្ញវត្ថុសំខាន់ៗរបស់រដ្ឋ ដែលនឹងជួយកំណត់ពីសណ្ឋាន និងគន្លងនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ឯកសារទាំងនោះក៏លើកឡើងផងដែរថា ប្រទេសអភិវឌ្ឍន៍ ដូចជា បារាំង អាល្លឺម៉ង់ និងចក្រភពអង់គ្លេស មានក្រសួងហិរញ្ញវត្ថុដែលរឹងមាំជាងក្រសួងហិរញ្ញវត្ថុរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងណា ក៏មានករណីលើកលែងផងដែរ។ ឧ. ផ្អែកតាមហេតុផលនយោបាយ ក្រសួងហិរញ្ញវត្ថុនៅអូស្ត្រាលីត្រូវបានកាត់បន្ថយដែនសមត្ថកិច្ចតាមរយៈការបំបែកជាក្រសួងពីរផ្សេងគ្នា (ក្រសួងហិរញ្ញវត្ថុ និងក្រសួងរតនាគារ[25])។

**សម្រាប់ជាឧទាហរណ៍មួយនៃការអនុវត្តជាអន្តរជាតិ ក្រសួងហិរញ្ញវត្ថុបំពេញមុខងារសំខាន់ៗ ចំនួន ៣៖** ១) មុខងារគោលនយោបាយ (ការព្យាករណ៍និងវិភាគម៉ាក្រូសារពើពន្ធ ការតាក់តែងគោលនយោបាយសារពើពន្ធ ការវិភាគហានិភ័យសារពើពន្ធ ភាពប្រទាក់ក្រឡាគ្នារវាងគោលនយោបាយរូបិយវត្ថុនិងគោលនយោបាយសារពើពន្ធ ទំនាក់ទំនងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិ គោលនយោបាយពន្ធ ការរៀបចំ និងអនុវត្តថវិកា) ២) មុខងារប្រតិបត្តិការ (រតនាគារ និងការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងបំណុល លទ្ធកម្មសាធារណៈ ការប្រមូលពន្ធអាករ និងពន្ធគយ) និង

[25] Allen et al (2013) The international handbook of public financial management, Washington DC.

៣) មុខងារតាក់តែង ពិភាក្សា និងឯកភាពលើគោលនយោបាយ និងនីតិវិធីថ្មីៗ ដើម្បីធ្វើទំនើបកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧ. គណនេយ្យ ការអភិវឌ្ឍភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកំណែទម្រង់ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)[26] ។

នៅកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏មានតួនាទី និងដែនសមត្ថកិច្ចប្រហាក់ប្រហែលគ្នានឹងការគូសបញ្ជាក់ក្នុងការអនុវត្តជាអន្តរជាតិខាងលើដែរ។ បេសកកម្ម និងតួនាទីផ្លូវការរបស់ក្រសួងនេះត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ៤៨៨ ឆ្នាំ២០១៣។ ក្រសួងមានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពប្រជាជនដោយផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌។ ក្រសួងមានតួនាទីសំខាន់ៗចំនួន២៥ ដែលសុទ្ធតែស្រដៀងគ្នានឹងប្រភេទមុខងារសំខាន់ៗ ដែលមានលើកឡើងក្នុងឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀត។ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធស្ថាប័ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានចំនួន១៣ នៅកម្រិតកណ្តាល មន្ទីរពាក់ព័ន្ធ និងរតនាគារខេត្តក្នុង២៥រាជធានីខេត្ត សាខាពន្ធដារនៅតាមស្រុកក្រុងនិងខណ្ឌ និងសាខាគយនៅតាមខេត្ត[27]។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចជាក្រសួងល្អជាងគេ ដែលអាចកៀរគរនិស្សិតវ័យក្មេងដែលបញ្ចប់ការសិក្សា និងផ្តល់គ្រឿងលើកទឹកចិត្តល្អប្រសើរដល់ពួកគេផងដែរ។ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ គេសង្កេតឃើញថា ក្រសួងបានជ្រើសរើសមន្ត្រីវ័យក្មេងជាច្រើន(វ័យ ៣០ និង ៤០ ឆ្នាំ) ដែលមន្ត្រីជាច្រើនបានបញ្ចប់ការសិក្សាពីបរទេស ឬមានបទពិសោធន៍ក្នុងវិស័យឯកជន។ អ្នកជំនាញការវ័យក្មេងទាំងនេះទទួលខុសត្រូវលើការងារបច្ចេកទេសផ្សេងៗ ចាប់ពីការវិភាគទិន្នន័យ ការព្រាងគោលការណ៍ណែនាំនិងគោលនយោបាយ ការពិនិត្យសំណើថវិកា និងការដំណើរការនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ ក្រៅពីនេះ ក្រសួងបានផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ក៏ដូចជាឱកាសចូលរួមក្នុងព្រឹត្តិការណ៍ និងការបណ្តុះបណ្តាលកសាងសមត្ថភាពផ្សេងៗ។ ក្នុងការបំពេញការងារប្រចាំថ្ងៃ អ្នកជំនាញការវ័យក្មេងទាំងនេះតែងបានចូលរួមកិច្ចប្រជុំបច្ចេកទេស ដែលពួកគេអាចរៀនសូត្រពីមន្ត្រីជាន់ខ្ពស់ និងទីប្រឹក្សាបច្ចេកទេសរបស់ម្ចាស់ជំនួយអន្តរជាតិ។

**អ្វីដែលចាំបាច់គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចំណាប់អារម្មណ៍ខ្លាំងទាំងលើការតាក់តែងគោលនយោបាយ ក៏ដូចជាការពិនិត្យតាមដាននិងវាយតម្លៃ ការប្រើប្រាស់ទិន្នន័យ និងអភិបាលកិច្ចឌីជីថល។** ការចេញគោលនយោបាយ និងគោលការណ៍ណែនាំថ្មីៗស្ទើរតែក្លាយជាការងារជាប់លាប់សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប៉ុន្តែក្រៅពីនេះ ក្រសួងក៏ពិនិត្យតាម

26 Allen, R., and P. Kohnert. 2012. "Anatomy of a Finance Minister," Mimeo. Washington, DC: IMF.
27 RGC (2013) Sub-decree #488 on the organizational structure and functioning of MEF.

ជានការអនុវត្តគោលនយោបាយជាច្រើនដែលបានដាក់ចេញផងដែរ។ សម្រាប់កិច្ចការខាងលើ ការស្រាវជ្រាវនេះរកឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងទិន្នន័យកាន់តែប្រសើរជាងមុន ហើយផ្អែកតាមទំហំ និងភាពស្មុគស្មាញនៃការងាររបស់ខ្លួន ក្រសួងត្រូវបន្តបង្កើនប្រសិទ្ធភាពផ្ទៃក្នុង ដើម្បីបញ្ចៀសការរាំងស្ទះក្នុងប្រព័ន្ធនេះ។ ការស្រាវជ្រាវនេះរកឃើញថា អ្វីដែលជាកត្តាចាំបាច់ផងដែរនោះគឺក្រសួងបានផ្តល់ការគាំទ្រយ៉ាងផុសផុលដល់ការអនុវត្តដំណោះស្រាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីទ្រទ្រង់មុខងាររបស់ខ្លួន។

## ២.៣ ផែនការស្តារឡើងវិញរបស់អាស៊ាន និងកម្ពុជាក្នុងនាមជាប្រធានប្តូរវេនអាស៊ាន នៅឆ្នាំ២០២២

**កិច្ចសហប្រតិបត្តិការនៅកម្រិតអាស៊ាន មានសារៈសំខាន់ណាស់សម្រាប់កម្ពុជា**បន្ថែមលើកិច្ចសហប្រតិបត្តិការក្រៅប្រទេសផ្សេងទៀត ដូចជា កិច្ចសហប្រតិបត្តិការជាមួយចិន សាធារណរដ្ឋកូរ៉េ និងប្រទេសដែលពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)[28]។ ការចូលរួមថ្នាក់តំបន់នៅកម្រិតអាស៊ាន បង្កប់ទាំងទិដ្ឋភាពសេដ្ឋកិច្ច និងទិដ្ឋភាពនយោបាយ។ ទិដ្ឋភាពនយោបាយមានដូចជា របៀបដែលអាស៊ានប្រឈមនឹងការប្រកួតប្រជែងរបស់ប្រទេសមហាអំណាច និងដោះស្រាយបញ្ហានយោបាយក្នុងប្រទេសមីយ៉ាន់ម៉ា។ អាទិភាពសេដ្ឋកិច្ច ពាក់ព័ន្ធជាចម្បងនឹងរបៀបដែលអាស៊ានអាចស្តារសេដ្ឋកិច្ចចេញពីវិបត្តិកូវីដ-១៩[29]។ ផ្នែកនេះនឹងផ្តោតសំខាន់លើទិដ្ឋភាពសេដ្ឋកិច្ច។

សមាហរណកម្មសេដ្ឋកិច្ច និងភាពជាដៃគូអាស៊ានក្នុងអំឡុងវិបត្តិកូវីដ-១៩ ត្រូវបានគូសបញ្ជាក់ដោយរដ្ឋាភិបាលកម្ពុជា និងលេខាធិការដ្ឋានអាស៊ាន។ មានអាទិភាពដូចគ្នាជាច្រើនរវាងផែនការស្តារសេដ្ឋកិច្ចរបស់រដ្ឋាភិបាលកម្ពុជា និងក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF)។ ACRF ផ្តោតសំខាន់លើយុទ្ធសាស្ត្រធំៗចំនួន៥ រួមមាន ១) ការពង្រីកប្រព័ន្ធសុខាភិបាល ២) ការពង្រឹងសន្តិសុខមនុស្ស ៣) ការបង្កើនជាអតិបរមានូវសក្តានុពលទីផ្សារក្នុងតំបន់អាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ចទូលំទូលាយ ៤) ការពន្លឿនបរិវត្តកម្មឌីជីថលបែបបរិយាបន្ន និង ៥) ការឈានទៅសម្រេចបានអនាគតដែលកាន់តែមានចីរភាព និងភាពធន់។ តារាងខាងក្រោមសង្ខេបពីអាទិភាព គំនិតផ្តួចផ្តើម និងកម្មវិធីមួយចំនួនក្រោមយុទ្ធសាស្ត្រនីមួយៗ។

---

28 Lim H,. (2021) ASEAN's contribution to regional peace and stability: A Cambodian perspective in Cambodia's ASEAN Chairmanship in 2022: Priorities and challenges.

29 ASEAN (2020) ASEAN Comprehensive Recovery Framework (ACRF) – Implementation Plan.

តារាងទី១៖ ក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF) – ចំណុចសំខាន់ៗមួយចំនួន

| យុទ្ធសាស្ត្រ | អាទិភាព គំនិតផ្តួចផ្តើម និងកម្មវិធីមួយចំនួន |
|---|---|
| ការពង្រីកប្រព័ន្ធសុខាភិបាល | - គ្រប់គ្រងការវិភាគ និងការប៉ាន់ប្រមាណទិន្នន័យ Big Data ដើម្បីវាយតម្លៃហានិភ័យនៃជំងឺឆ្លង ការងើបឡើង ឬការងើបឡើងវិញនៃជំងឺឆ្លង<br>- ពង្រឹងការផ្សព្វផ្សាយព័ត៌មានបានទាន់ពេលវេលា និងការចែករំលែកទិន្នន័យពាក់ព័ន្ធនៅតាមប្រទេសនានាសម្រាប់ការរៀបចំផែនការថ្នាក់តំបន់<br>- រៀបចំបញ្ចប់យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់សន្តិសុខ និងភាពម្ចាស់ការលើវ៉ាក់សាំងក្នុងតំបន់អាស៊ាន (២០២១-២០២៥)<br>- ផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិតមកពីរដ្ឋសមាជិកអាស៊ាន ដើម្បីសិក្សាផ្នែកសុខាភិបាល និងផ្នែកដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ។ |
| ការពង្រឹងសន្តិសុខមនុស្ស | - បង្កើនការពង្រឹង និងពង្រីកកិច្ចគាំពារសង្គម និងសុខុមាលភាពសង្គម ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ សហគ្រាសខ្នាតតូចនិងមធ្យម វិស័យក្រៅផ្លូវការ និងពលករទេសន្តរប្រវេសន៍<br>- ពិនិត្យតាមដានផលប៉ះពាល់ និងប្រមូលទិន្នន័យស្តីពីកិច្ចគាំពារសង្គមដោយប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលកិច្ចគាំពារសង្គមអាស៊ាន<br>- លើកកម្ពស់កិច្ចសន្ទនាថ្នាក់តំបន់ និងការវិភាគរួមគ្នាលើការឆ្លើយតបបន្ទាន់ផ្នែកកិច្ចគាំពារសង្គម តាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក និងការផ្សព្វផ្សាយ |

| | |
|---|---|
| | - លើកកម្ពស់ការអភិវឌ្ឍជំនាញ ជាពិសេសសម្រាប់ស្ត្រី និងយុវជនដែលមកពីជនបទ ដោយផ្តោតសំខាន់លើជំនាញឌីជីថល និងជំនាញសតវត្សរ៍ទី២១ (ដោយអនុវត្តតាមអនុសាសន៍ពី "ការវាយតម្លៃរហ័សលើវិបត្តិកូវីដ-១៩ ក្នុងតំបន់អាស៊ានៈ ផលប៉ះពាល់លើកិច្ចគាំពារសង្គម ការងារ និងការអប់រំ" ដែលធ្វើឡើងដោយអង្គការមូលនិធិអាស៊ី<br>- បង្កើនទិន្នន័យយេនឌ័រ និងភស្តុតាងស្តីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើស្ត្រី និងក្មេងស្រី<br>- លើកកម្ពស់អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងអក្ខរកម្មព័ត៌មានដើម្បីប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត[30]។ |
| ការបង្កើនជាអតិបរមានូវសក្តានុពលទីផ្សារក្នុងតំបន់អាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ចទូលំទូលាយ | - ពង្រឹងការតភ្ជាប់សង្វាក់ផ្គត់ផ្គង់ និងភាពធន់<br>- រិះរកលទ្ធភាពបង្កើនមូលដ្ឋានទិន្នន័យអាស៊ានស្តីពីក្រុមហ៊ុនផលិត និងក្រុមហ៊ុននាំចេញទំនិញសំខាន់ៗ ដើម្បីបង្កើនភាពធន់នៃសង្វាក់ផ្គត់ផ្គង់ ក្នុងពេលមានវិបត្តិ<br>- ពន្លឿនការស្តារវិស័យឡើងវិញ (ទេសចរណ៍ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម) និងការធានាសុវត្ថិភាពការងារក្នុងវិស័យដែលរងផលប៉ះពាល់ខ្លាំងបំផុត<br>- បន្តចែករំលែក/ផ្លាស់ប្តូរព័ត៌មានស្តីពីគោលនយោបាយ និងវិធានការពាក់ព័ន្ធនឹងអាជីវកម្ម ដែលដាក់ចេញដោយរដ្ឋសមាជិកអាស៊ានក្នុងការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ (ដូចមានបង្ហាញក្នុងចំណេះដឹងផ្នែកគោលនយោបាយស្តីពីការឆ្លើយតបនៃគោលនយោបាយសហគ្រាសទៅនឹងវិបត្តិកូវីដ-១៩ នៅអាស៊ានៈ វិធានការបង្កើនភាពធន់របស់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម)។ |

[30] ចំណុចនេះស៊ីសង្វាក់គ្នានឹងក្របខ័ណ្ឌ AMRI និងសេចក្តីប្រកាសរួមគ្នាដើម្បីកាត់បន្ថយផលជះអវិជ្ជមាននៃព័ត៌មានមិនពិត។

| | |
|---|---|
| ការពន្លឿនបរិវត្តកម្មឌីជីថលបែបបរិយាបន្ន | - លើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសេដ្ឋកិច្ចឌីជីថល តាមរយៈការផ្តល់ថ្នាលឌីជីថល និងគោលនយោបាយពាក់ព័ន្ធសម្រាប់លើកកម្ពស់ការបង្កើនជំនាញឌីជីថលក្នុងសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម និងការផ្តល់បច្ចេកវិទ្យាឌីជីថល និង fintech ដើម្បីជ្រៀតចូលទីផ្សារ<br>- អនុវត្ត Go Digital ASEAN ក្រោមការគាំទ្រពីអង្គការមូលនិធិអាស៊ី និង Google ដើម្បីពង្រីកឱកាសសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន<br>- បង្កើតក្របខ័ណ្ឌគ្រប់គ្រងទិន្នន័យអាស៊ាន (DMF) ក្រោមក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យឌីជីថលអាស៊ាន។ |
| ការឈានទៅសម្រេចបានអនាគតដែលកាន់តែមានចីរភាព និងភាពធន់ | - លើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពលើគ្រប់វិស័យ<br>- សម្របសម្រួលអន្តរកាលឆ្ពោះទៅរកថាមពលដែលមានចីរភាព<br>- កសាងហេដ្ឋារចនាសម្ព័ន្ធបៃតង និងដោះស្រាយគម្លាតហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ<br>- បង្កើតគោលការណ៍ណែនាំអាស៊ាន ស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់វិស័យចំណីអាហារ និងកសិកម្មនៅអាស៊ាន។ |

**ក្នុងឆ្នាំ២០២២ កម្ពុជានឹងធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ានជាលើកទី៣។** កម្ពុជាបានចូលជាសមាជិកអាស៊ានកាលពីខែមេសាឆ្នាំ១៩៩៩។ ចាប់ពីពេលនោះមក កម្ពុជាបានធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ាន ២លើក ដែលលើកទី១ គឺនៅឆ្នាំ២០០២ និងលើកទី២ គឺនៅឆ្នាំ២០១២។ តួនាទីជាប្រធានអាស៊ាននេះ ត្រូវបានកំណត់វិលជុំក្នុងមួយឆ្នាំៗទៅតាមលំដាប់អក្ខរក្រមភាសាអង់គ្លេសនៃឈ្មោះរបស់រដ្ឋសមាជិក។ រដ្ឋសមាជិកមួយដែលត្រូវធ្វើជាប្រធានអាស៊ាន ត្រូវធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ដូចជា កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍អាស៊ានទាំង ៣សា្ថប័ន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាននិងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់និងកិច្ចប្រជុំគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍[31]។ ក្នុងឆ្នាំ២០២២

កម្ពុជានឹងធ្វើជាប្រធានអាស៊ានជាលើកទី៣ ក្រោមមូលបទ "អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា"[32]។

**យោងតាមគេហទំព័រអាស៊ាន កិច្ចប្រជុំកំពូលនេះនឹងមានរបៀបវារៈជាក់លាក់មួយ។** ក្នុងនាមជាប្រធានអាស៊ាន កម្ពុជាខិតខំពង្រឹងការចូលរួមរបស់អាស៊ានក្នុងការឆ្លើយតបទាំងក្នុង និងក្រៅតំបន់អាស៊ាន ទៅនឹងផលប៉ះពាល់ និងភាពមិនប្រាកដប្រជាដែលបង្កឡើងដោយបញ្ហាក្នុងតំបន់ និងបញ្ហាជាសកល ដូចជា វិបត្តិកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព ការប្រកួតប្រជែងរវាងប្រទេសមហាអំណាច ការការពារនិយម ជម្លោះដែនដី សង្គ្រាមពាណិជ្ជកម្មនិងការប្រកួតប្រជែងបច្ចេកវិទ្យា និងការគំរាមកំហែងសន្តិសុខបែបប្រពៃណីនិងការគំរាមកំហែងសន្តិសុខថ្មីៗ[33]។

**ថ្មីៗនេះ មានការរៀបរៀងសៀវភៅ អត្ថបទ និងបទវិចារណកថាជាច្រើនស្តីពីកម្ពុជា ក្នុងនាមជាប្រធានប្តូរវេនអាស៊ាននៅឆ្នាំ២០២២** ដូចជា សៀវភៅរបស់មូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ និងវិទ្យាស្ថានចក្ខុវិស័យអាស៊ីស្តីពីកម្ពុជាក្នុងនាមជាប្រធានប្តូរវេនអាស៊ានក្នុងឆ្នាំ២០២១៖ អាទិភាព និងបញ្ហាប្រឈម (២០២១)[34] និងសៀវភៅរបស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពស្តីពីកម្ពុជាក្នុងនាមជាប្រធានប្តូរវេនអាស៊ាន៖ ការឆ្លើយតបនឹងទស្សនៈប្រឈម និងការពង្រឹងប្រសិទ្ធភាពកិច្ចការតំបន់ (២០២១)[35] ។ ក្រៅពីនេះ មានការរៀបរៀង និងបោះពុម្ពផ្សាយអត្ថបទ និងបទវិចារណកថាផ្សេងៗក្នុងគេហទំព័ររបស់បណ្តាញផ្សព្វផ្សាយក្នុងស្រុក និងក្រៅស្រុក។ ឯកសារទាំងនោះផ្តោតទាំងលើទិដ្ឋភាពនយោបាយ និងទិដ្ឋភាពសេដ្ឋកិច្ច ប៉ុន្តែការសិក្សានេះនឹងផ្តោតចម្បងលើទិដ្ឋភាពសេដ្ឋកិច្ច ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងទិន្នន័យ។

---

31 https://asean.org/category/chairmanship/
32 https://asean.org/asean-chairmanship-2022-cambodia/
33 https://asean.org/asean-chairmanship-2022-cambodia/
34 KAS and AVI (2021) Cambodia's ASEAN Chairmanship 2021: Priorities and Challenges
35 CICP (2021) Cambodia's Chairmanship of ASEAN: Challenging Perceptions, Concretizing Consolidations

## ៣. ដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា

ការយល់ពីលក្ខណៈសំខាន់ៗនៃដំណើរការគោលនយោបាយនៅកម្ពុជា ជាជំហានដំបូងឆ្ពោះទៅរកការបង្ហាញពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរ។ អត្ថប្រយោជន៍មានដូចជា ការកំណត់គោលនយោបាយសាធារណៈក្នុងបរិបទកម្ពុជា ដំណើរការនៃការតាក់តែង ការផ្តល់ហិរញ្ញប្បទាន ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយសាធារណៈ ភាគីពាក់ព័ន្ធសំខាន់ៗ និងកត្តាសំខាន់ៗដែលជះឥទ្ធិពលលើគុណភាព និងលទ្ធផលនៃគោលនយោបាយទាំងនោះ។ ផ្នែកនេះនឹងបង្ហាញពីចំណុចមួយចំនួនខាងលើ ដោយផ្តោតសំខាន់លើវិធាន គោលការណ៍ណែនាំ និងកត្តាសំខាន់ៗដែលពាក់ព័ន្ធនឹងដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា។

### ៣.១ ការកំណត់និយមន័យនៃគោលនយោបាយសាធារណៈនៅកម្ពុជា

**មុននឹងកំណត់និយមន័យនៃគោលនយោបាយសាធារណៈ ដំបូងគួរយល់ពីសាវតារនៅវិស័យសាធារណៈរបស់កម្ពុជាជាមុនសិន ដើម្បីយល់ពីបរិបទរបស់ប្រទេសនេះ។** កម្ពុជាជាប្រទេសប្រជាធិបតេយ្យក្រោមប្រព័ន្ធនយោបាយបែបសភា។ វិស័យសាធារណៈរបស់កម្ពុជាចែកចេញជារដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិរួមមានក្រសួង (រួមទាំងមន្ទីរតាមខេត្ត) សហគ្រាសរដ្ឋបាលសាធារណៈ (PAE) និងសហគ្រាសរដ្ឋ។ រដ្ឋបាលថ្នាក់ក្រោមជាតិចែកជា ៣ ថ្នាក់៖ ថ្នាក់រាជធានី ខេត្ត ថ្នាក់ស្រុក ក្រុង ខណ្ឌ និងថ្នាក់ឃុំ/សង្កាត់[36]។

**ពាក្យ "គោលនយោបាយសាធារណៈ" មិនត្រូវបានកំណត់និយមន័យច្បាស់នៅក្នុងប្រទេសកម្ពុជា ឬក្នុងឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀតឡើយ។** ក្នុងបរិបទអន្តរជាតិ គោលនយោបាយសាធារណៈសំដៅលើ "របៀប ឬមធ្យោបាយជាក់លាក់នៃការធ្វើសកម្មភាពដែលត្រូវបានជ្រើសរើស (ដោយរដ្ឋាភិបាល ស្ថាប័ន ក្រុម ឬបុគ្គល) ពីក្នុងចំណោមជម្រើសនានា និងផ្អែកតាមស្ថានភាព/លក្ខខណ្ឌកំណត់ និងជាទូទៅ កំណត់ពីសេចក្តីសម្រេចនាពេលបច្ចុប្បន្ន និងនាពេលអនាគត"[37]។ នៅកម្ពុជា និយមន័យនៃគោលនយោបាយសាធារណៈមានបង្ហាញក្នុងសេចក្តីប្រកាសរបស់គណៈរដ្ឋមន្ត្រី ក្នុងឆ្នាំ២០១១ ដោយបានកំណត់គោលនយោបាយសាធារណៈជា "ដំណើរការ ឬគោលការណ៍សកម្មភាពដែលត្រូវបានអនុម័ត ឬស្នើឡើងដោយស្ថាប័នមួយ គណបក្សនយោបាយមួយ ក្រុមហ៊ុនមួយ ឬបុគ្គល"[38] ។

---

36 របៀបកំណត់និយមន័យនៃវិស័យសាធារណៈនៅកម្ពុជា គឺមួយភាគធំបន្សុីគ្នានឹងនិយមន័យអន្តរជាតិ។ សូមមើល IMF (2011) ស្តីពីប្រព័ន្ធគណនីជាតិ (SNA) សម្រាប់និយមន័យនៃវិស័យសាធារណៈ។

37 INASP (2016), Evidence-informed policy making toolkit (p. 18)

38 CoM (2011) Notification on the preparation of policy, strategy, and workplan document.

ការសិក្សានេះកំណត់និយមន័យនៃគោលនយោបាយសាធារណៈ និងដំណើរការពាក់ព័ន្ធដោយសំយោគចំណុចពាក់ព័ន្ធពីឯកសារផ្លូវការផ្សេងៗ។ ការសិក្សារកមិនឃើញគោលការណ៍ណែនាំផ្លូវការណាមួយដែលផ្តោតសំខាន់លើប្រធានបទនេះឡើយ ប៉ុន្តែដោយសារការវិវត្តឥតឈប់ឈរនៃដំណើរការគោលនយោបាយនៅកម្ពុជា មានការរៀបចំគោលការណ៍ណែនាំផ្លូវការផ្សេងៗដើម្បីរំលេចគោលបំណងជាក់លាក់ និងប្រភេទគោលនយោបាយ។ ទោះជាយ៉ាងណា ឯកសារផ្លូវការមួយចំនួនត្រូវបានកំណត់ និងប្រើប្រាស់ជាឯកសារយោងក្នុងរបាយការណ៍ពីការស្រាវជ្រាវនេះ៖

- សេចក្តីប្រកាសរបស់គណៈរដ្ឋមន្ត្រីស្តីពីការរៀបចំឯកសារគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការការងារ (២០១១)
- គោលការណ៍ណែនាំរបស់រដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP)[39]
- គោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពី ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា (BSP) (២០១១)[40] និង
- សារាចរប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា (BSP)។[41]

ផ្អែកតាមឯកសារផ្លូវការ និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ការសិក្សានេះកំណត់និយមន័យ និងបែងចែកប្រភេទគោលនយោបាយ ដូចខាងក្រោម៖

- គោលនយោបាយជាឯកសារដែលកំណត់ពីទិសដៅគោលនយោបាយរយៈពេលវែង (៣-៥ឆ្នាំ) និងរយៈពេលមធ្យម (៣ ឆ្នាំ) និងអាទិភាពសម្រាប់រដ្ឋាភិបាល និងទីភ្នាក់ងាររដ្ឋាភិបាល។
- ឯកសារគោលនយោបាយយកលំនាំតាមមាតិកាស្តង់ដារ ដែលបានកំណត់ក្នុងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា។ មាតិកាស្តង់ដាររួមមានចក្ខុវិស័យ គោលដៅ គោលបំណង យុទ្ធសាស្រ្ត ភាគីពាក់ព័ន្ធ សកម្មភាពសំខាន់ៗ ក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃ និងធនធានហិរញ្ញវត្ថុ។
- គេអាចហៅឯកសារគោលនយោបាយជាគោលនយោបាយ យុទ្ធសាស្រ្ត កម្មវិធី ឬក្របខ័ណ្ឌ ឱ្យតែឯកសារនោះយកលំនាំតាមក្របខ័ណ្ឌពេលវេលា និងមាតិកាស្តង់ដារដែលមានរៀបរាប់ពីខាងដើម។

**គោលនយោបាយមួយមានចរិតលក្ខណៈផ្សេងៗ អាស្រ័យលើថាតើវាជាគោលនយោបាយរយៈពេលវែង ឬជាគោលនយោបាយរយៈពេលមធ្យម។** គោលនយោបាយរយៈពេលវែងរួមមានគោលនយោបាយអភិវឌ្ឍន៍ជាតិ គោលនយោបាយឆ្លងវិស័យ និងគោលនយោបាយក្រសួង ដែលមានរយៈពេល ៥ឆ្នាំឡើងទៅ និងត្រូវចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ គោលនយោបាយ

[39] RGC (2013) Guideline on preparing the NSDP (2014-2018)
[40] MEF (2011) Guideline on preparing Budget Strategic Plan (BSP)
[41] MEF (2020) Circular on preparing Budget Strategic Plan (BSP) for 2021.

រយៈពេលមធ្យមមានរយៈពេល ៣ឆ្នាំ និងចែកចេញជា ២ប្រភេទ៖ ១) ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌសារពើពន្ធច្រើនឆ្នាំ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ២) ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិលដែលរៀបចំឡើងដោយក្រសួងពាក់ព័ន្ធ និងទីភ្នាក់ងារដែលត្រូវបានចាត់ទុកជា "អង្គភាពថវិកា"[42]។ ផែនការយុទ្ធសាស្ត្រថវិកាត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬប្រធានអង្គភាពថវិកា។

**មានឋានានុក្រម និងទំនាក់ទំនងរវាងគោលនយោបាយរយៈពេលវែង គោលនយោបាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ។** គោលបំណងចម្បងនៃគោលនយោបាយរយៈពេលវែង គឺការកំណត់ទិសដៅ និងអាទិភាពអភិវឌ្ឍន៍រយៈពេលវែង សម្រាប់រដ្ឋាភិបាលទាំងមូល ក្រសួងលើសពីមួយ ឬក្រសួងតែមួយ។ ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល មានគោលបំណងផ្សារភ្ជាប់អាទិភាពគោលនយោបាយរយៈពេលវែងទៅនឹងវិភាជថវិកាកម្មវិធីប្រចាំឆ្នាំ (ដូចការបង្ហាញក្នុងដ្យាក្រាមខាងក្រោម)។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺមួយផ្នែកជាគោលនយោបាយ និងមួយផ្នែកជាផែនការប្រតិបត្តិរបស់គោលនយោបាយមួយ។ ទោះជាយ៉ាងណា ក្នុងរបាយការណ៍នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានកំណត់ជាគោលនយោបាយ ព្រោះវាបំពេញលក្ខខណ្ឌនៃក្របខ័ណ្ឌពេលវេលា និងមាតិកាស្តង់ដារដែលមានរៀបរាប់ខាងលើ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាយកលំនាំតាមគោលការណ៍ណែនាំស្តង់ដារដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ២០១១ ដែលបច្ចុប្បន្នកំពុងត្រូវបានកែសម្រួលឡើងវិញ។

រូបភាពទី ១ ៖ ឋានានុក្រម និងទំនាក់ទំនងរវាងគោលនយោបាយ និងផែនការសំខាន់ៗនៅកម្ពុជា




[42] អង្គភាពថវិកាត្រូវបានកំណត់និយមន័យជាអង្គភាពកាន់ថវិកា ពោលគឺទីភ្នាក់ងារដែលទទួលបានថវិកាពីរដ្ឋាភិបាល និងទទួលខុសត្រូវលើការប្រើប្រាស់ថវិកាទាំងនោះ។

គេអាចយល់ពីគោលនយោបាយមួយតាមរយៈការគ្របដណ្តប់ និងដំណើរការរបស់វា ក៏ដូចជាការចូលរួមពីភាគីពាក់ព័ន្ធ។ តាមការបង្ហាញក្នុងតារាងខាងក្រោម ជាទូទៅ គោលនយោបាយរយៈពេលវែងគ្របដណ្តប់លើអាណត្តិរបស់រដ្ឋាភិបាលទាំងមូល ក្រសួងចម្រុះ ឬក្រសួងតែមួយ។ គោលនយោបាយនេះត្រូវបានអនុម័តតែម្តងប៉ុណ្ណោះ ប៉ុន្តែត្រូវឆ្លងកាត់ការពិនិត្យតាមដាន និងវាយតម្លៃ ២ដង៖ ពាក់កណ្តាលអាណត្តិ (ក្រោយរយៈពេល ២,៥ឆ្នាំ) និងចុងអាណត្តិ (ក្រោយពេលអនុវត្តបាន ៥ឆ្នាំ)។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌសារពើពន្ធច្រើនឆ្នាំជាឯកសារគោលនយោបាយ ៣ឆ្នាំរំកិលដែលត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់រដ្ឋាភិបាលទាំងមូល ខណៈដែលផែនការយុទ្ធសាស្រ្តថវិកាគឺសម្រាប់ទីភ្នាក់ងារជាក់លាក់ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ គោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏គូសបញ្ជាក់ផងដែរពីភាពចាំបាច់ក្នុងការពិនិត្យតាមដាន និងវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តផែនការយុទ្ធសាស្រ្តថវិកា ប៉ុន្តែភាគច្រើនគឺនៅកម្រិតលទ្ធផលរំពឹងទុក។ គេរំពឹងថានឹងមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងក្នុងដំណើរការគោលនយោបាយរយៈពេលវែង និងដំណើរការគោលនយោបាយរយៈពេលមធ្យម។ ទោះជាយ៉ាងណាកម្រិតនៃការចូលរួមជាក់ស្តែងគឺមិនដូចគ្នានោះទេ (សូមមើលផ្នែកបន្ទាប់)។

តារាងទី២៖ ឋានានុក្រមនៃឯកសារគោលនយោបាយនៅកម្ពុជា

| ចំណុចសំខាន់ៗ | គោលនយោបាយរយៈពេលវែង | ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| រយៈពេល | - ៣-៥ឆ្នាំ | - ៣ ឆ្នាំ |
| គោលនយោបាយសំខាន់ៗ | - គោលនយោបាយអភិវឌ្ឍន៍ជាតិ ( ឧ. យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ )<br>- គោលនយោបាយឆ្លងវិស័យ ( ឧ. កិច្ចគាំពារសង្គម កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ភស្តុភារ ថាមពល )<br>- គោលនយោបាយក្រសួង ( ឧ. ការអប់រំ សុខភាព យុទ្ធសាស្ត្រវិស័យកសិកម្ម ) | - ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌសារពើពន្ធច្រើនឆ្នាំ<br>- ផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការ ៣ឆ្នាំរំកិល |
| គោលបំណងសំខាន់ៗ | - ដើម្បីកំណត់ទិសដៅ និងអាទិភាព<br>- អភិវឌ្ឍន៍រយៈពេលវែង | - ដើម្បីផ្សារភ្ជាប់អាទិភាពគោលនយោបាយរយៈពេលវែងទៅនឹងវិភាជថវិកាកម្មវិធីប្រចាំឆ្នាំ |
| មាតិកាសំខាន់ៗ | - សាវតារ ចក្ខុវិស័យ គោលដៅ គោលបំណង យុទ្ធសាស្ត្រ ភាគីពាក់ព័ន្ធ សកម្មភាពសំខាន់ៗ ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ធនធានហិរញ្ញវត្ថុ | - សាវតារ ចក្ខុវិស័យ គោលដៅ គោលបំណង យុទ្ធសាស្ត្រ ភាគីពាក់ព័ន្ធ សកម្មភាពសំខាន់ៗ ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ធនធានហិរញ្ញវត្ថុ |
| ការធ្វើបច្ចុប្បន្នភាព | - ត្រូវបានអនុម័តតែម្តង | - ធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ |

| | | |
|---|---|---|
| គោលការណ៍ណែនាំ | - គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៣) | - គោលការណ៍ណែនាំរបស់ក្រសួង<br>- សេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីផែនការយុទ្ធសាស្ត្រថវិកា (២០១១) |
| កម្រិតទីភ្នាក់ងារ | - កម្រិតរដ្ឋាភិបាល (ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី)<br>- កម្រិតក្រសួង (ចុះហត្ថលេខាដោយរដ្ឋមន្ត្រី) | - កម្រិតក្រសួង និងកម្រិតអង្គភាពថវិកា (ចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬប្រធានអង្គភាព) |
| ការចូលរួមរបស់តួអង្គមិនមែនរដ្ឋ | - ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយបច្ចេកទេស<br>- អង្គការមិនមែនរដ្ឋាភិបាលដែលចូលរួម និងផ្តល់ជាតុចូល | - ក្រសួង និងអង្គភាពថវិកាដែលអនុវត្តផែនការនេះនៅក្នុងអង្គភាពរបស់ខ្លួន<br>- ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅមានកម្រិត ប៉ុន្តែត្រូវបានរំពឹងថានឹងកាន់តែសកម្ម |
| ការតាក់តែង | - ដឹកនាំដោយក្រុមការងារបច្ចេកទេសដោយមានការចូលរួមពីក្រសួងសំខាន់ៗ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល | - ដឹកនាំដោយក្រុមការងារមួយ ដោយមានការចូលរួមពីនាយកដ្ឋានសំខាន់ៗរបស់ទីភ្នាក់ងារនានា និងតួអង្គមិនមែនរដ្ឋ |
| ការអនុវត្ត | - អនុវត្តដោយផ្អែកតាមផែនការយុទ្ធសាស្ត្រថវិកា ៣ ឆ្នាំរំកិល | - អនុវត្តដោយផ្អែកតាមថវិកាកម្មវិធីប្រចាំឆ្នាំ |
| ការពិនិត្យតាមដាន និង វាយតម្លៃ | - ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ | - ការពិនិត្យតាមដាន និងវាយតម្លៃជាចម្បងនៅកម្រិតលទ្ធផលរំពឹងទុក |

| | | |
|---|---|---|
| | - ការពិនិត្យតាមដាន និងវាយតម្លៃនៅពាក់កណ្តាលអាណត្តិ (២,៥ ឆ្នាំ) និងចុងអាណត្តិ | (ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីផែនការយុទ្ធសាស្ត្រថវិកា)<br>- ការពិនិត្យតាមដាន និងវាយតម្លៃត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ។ |

ក្នុងការបំពេញមុខងាររបស់វិស័យសាធារណៈ គោលនយោបាយនិងឯកសារច្បាប់បំពេញឱ្យគ្នាទៅវិញទៅមក ប៉ុន្តែគោលនយោបាយនិងឯកសារច្បាប់ គឺខុសគ្នា។ ភាពខុសគ្នានេះលេចឡើងក្នុងការអនុវត្តជាអន្តរជាតិ ក៏ដូចជាក្នុងប្រទេសកម្ពុជា។ គោលនយោបាយរៀបរាប់ពីអ្វីដែលរដ្ឋាភិបាលនឹងធ្វើ និងអ្វីដែលរដ្ឋាភិបាលអាចសម្រេចបានសម្រាប់សង្គមជាតិទាំងមូល។ គោលនយោបាយក៏លើកឡើងពីអ្វីដែលរដ្ឋាភិបាលមិនចង់ធ្វើផងដែរ។ គោលនយោបាយមិនមែនជាច្បាប់ទេ ប៉ុន្តែវាអាចគូសបញ្ជាក់ថាតើក្នុងការអនុវត្តគោលនយោបាយ ចាំបាច់ត្រូវមានច្បាប់ លិខិតុបករណ៍គតិយុត្តិ ឬគោលការណ៍ណែនាំថ្មី ឬទេ។ គោលនយោបាយមិនបង្ហាញពីភាពចាំបាច់ក្នុងការអនុលោមតាមនោះទេ ប៉ុន្តែឯកសារច្បាប់ ឬគោលការណ៍ណែនាំ ណែនាំប្រជាជនពីអ្វីដែលត្រូវធ្វើ។

**ឯកសារច្បាប់ និងគោលការណ៍ណែនាំបច្ចេកទេស ដើរតួនាទីសំខាន់ក្នុងដំណើរការគោលនយោបាយនៅកម្ពុជា។** ក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលកម្ពុជាបានចេញសារាចរស្តីពីការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត។ យោងតាមគោលការណ៍ណែនាំនេះ ឯកសារច្បាប់រួមបញ្ចូលច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងសារាចរ។ ច្បាប់ត្រូវអនុម័តដោយរដ្ឋសភា អនុក្រឹត្យត្រូវចេញដោយនាយករដ្ឋមន្ត្រី ហើយប្រកាសត្រូវចេញដោយក្រសួងមួយ ឬច្រើន។ សេចក្តីសម្រេច ឬសារាចរ អាចត្រូវបានអនុម័តនៅកម្រិតរដ្ឋាភិបាល ឬកម្រិតក្រសួង[43]។ ក្រោមឯកសារច្បាប់ទាំងនេះ ទីភ្នាក់ងាររដ្ឋាភិបាលអាចចេញគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ការប្រើប្រាស់ជាសាធារណៈ ឬសម្រាប់ក្រុមរងផលប៉ះពាល់មួយចំនួន។

[43] RGC (2013) Guideline on the Procedures and Measures for Developing Legal Documents.

### ប្រអប់ទី៣៖ ភាគីពាក់ព័ន្ធសំខាន់ៗ និងដំណើរការនៃការរៀបចំ និងអនុម័តឯកសារច្បាប់[44]

ផ្អែកតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលដែលបានចេញនៅឆ្នាំ២០១៣ ច្បាប់ និងឯកសារច្បាប់ទាំងអស់ត្រូវព្រាងឡើងទៅតាមដំណើរការស្តង់ដារដូចតទៅ។ ដំណើរការនេះចាប់ផ្តើមពីក្រសួងសាម៉ីមួយដែលផ្អែកលើធាតុចូលសំខាន់ៗពីភាគីរដ្ឋ និងភាគីមិនមែនរដ្ឋ ចាប់ផ្តើមព្រាងគោលនយោបាយណាមួយ។ ជារឿយៗ សេចក្តីព្រាងរៀបចំឡើងដោយនាយកដ្ឋានបច្ចេកទេស ១ ឬច្រើននៅក្នុងក្រសួង ដោយមានការគាំទ្រពីក្រុមការងារបច្ចេកទេស និងត្រូវពិនិត្យឡើងវិញដោយនាយកដ្ឋាននីតិកម្មរបស់ក្រសួង។

ក្រសួងសាម៉ីត្រូវពិគ្រោះសេចក្តីព្រាងច្បាប់ និង/ឬបទបញ្ញត្តិច្បាប់ជាមួយក្រសួងផ្សេងទៀត រដ្ឋបាលថ្នាក់ក្រោមជាតិ និងតួអង្គមិនមែនរដ្ឋ ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបញ្ហាដែលពាក់ព័ន្ធនឹងថវិកាជាតិ។ សេចក្តីព្រាងច្បាប់ និងឯកសារច្បាប់ទាំងអស់ត្រូវយកលំនាំតាមគំរូមាតិកាស្តង់ដារ អាស្រ័យលើប្រភេទ និងឋានានុក្រមរបស់វា (ឧ. ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ និងសេចក្តីសម្រេច)។

ក្រសួងត្រូវដាក់សេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងឯកសារច្បាប់ទៅគណៈរដ្ឋមន្ត្រី អមជាមួយនឹងសេចក្តីអធិប្បាយពន្យល់។ សេចក្តីអធិប្បាយត្រូវគូសបញ្ជាក់ពីលទ្ធផល និងមតិយោបល់ពីដំណើរការពិគ្រោះយោបល់។ អគ្គលេខាធិការដ្ឋានគណៈរដ្ឋមន្ត្រី ត្រូវពិនិត្យសេចក្តីព្រាងដែលបានដាក់ជូន មុននឹងបញ្ចូលសេចក្តីព្រាងនោះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំបច្ចេកទេសរបស់គណៈរដ្ឋមន្ត្រី កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំពិនិត្យចុងក្រោយ។

ខណៈដែលមានការកំណត់យ៉ាងទូលំទូលាយពីឋានានុក្រមនៃគោលនយោបាយ និងឯកសារច្បាប់ផ្នែកមួយចំនួននៅតែមានភាពមិនច្បាស់លាស់ និងស្ថិតក្រោមការបកស្រាយបែបបរានុម័តក្នុងពេលអនុម័ត។ ទីមួយគឺភាពមិនច្បាស់លាស់លើភាពខុសគ្នា និងសារៈសំខាន់រវាងគោលនយោបាយ និងឯកសារច្បាប់។ បញ្ហានេះច្រើនតែកើតឡើងចំពោះប្រជាជន នៅកម្រិតអនុវត្ត។ ក្នុងមួយឆ្នាំៗ គោលនយោបាយ និងសេចក្តីណែនាំថ្មីៗត្រូវបានដាក់ឱ្យអនុវត្ត ប៉ុន្តែច្រើនតែមានភាពមិនច្បាស់លាស់ថាតើមួយណាជាទិសដៅគោលនយោបាយ មួយណាជាសេចក្តីណែនាំផ្លូវច្បាប់ និងថាតើត្រូវអនុវត្តតាមឯកសារមួយណា នៅពេលដែលឯកសារទាំងនោះមិនបន្សុីគ្នា។ នេះជាស្ថានភាពមួយដែលកើតឡើងជាទូទៅក្នុងការអនុវត្ត។ ផ្អែកតាមបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ក្នុងស្ថានភាពនេះ គេគួរអនុវត្តតាមសេចក្តីណែនាំផ្លូវច្បាប់ ជាជាងទិសដៅគោលនយោបាយ ប៉ុន្តែក្នុងការអនុវត្ត អ្វីដែលជាបញ្ហាចោទគឺអ្នកដែលចេញឯកសារនោះ និងកម្រិតនៃអនុភាពរបស់វា។

[44] RGC (2013) Guideline on the Procedures and Measures for Developing Legal Documents.

**សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិបែបវិមជ្ឈការ មិនមានការកំណត់ច្បាស់ពីអ្វីដែលបង្កើតបានជាគោលនយោបាយនោះទេ។** រដ្ឋបាលថ្នាក់ក្រោមជាតិគួរអនុវត្តតាម និងរួមចំណែកដល់អាទិភាពអភិវឌ្ឍន៍ជាតិជារួម។ រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើប្រតិបត្តិការ និងផ្អែកតាមទិសដៅកំណែទម្រង់ដែលបានកំណត់ក្នុងគោលនយោបាយវិមជ្ឈការ។ ទោះជាយ៉ាងណា រដ្ឋបាលថ្នាក់ក្រោមជាតិគួរប្រមូល និងវិភាគព័ត៌មានស្តីពីតម្រូវការក្នុងមូលដ្ឋាន និងរំលេចតម្រូវការទាំងនោះក្នុងផែនការអភិវឌ្ឍន៍ ៣ឆ្នាំ និង ៥ឆ្នាំរបស់ខ្លួន។ ក្នុងរបាយការណ៍នេះ ផែនការរយៈពេល ៣ឆ្នាំ និងផែនការរយៈពេល ៥ឆ្នាំត្រូវបានចាត់ទុកជាទម្រង់មួយនៃគោលនយោបាយ។ ផែនការទាំងនេះមានសមាសភាគភាគច្រើននៃគោលនយោបាយ ដូចជា ចក្ខុវិស័យអភិវឌ្ឍន៍ និងគោលបំណងសម្រាប់បរិបទមូលដ្ឋាននីមួយៗ ការប៉ាន់ប្រមាណតម្រូវការ តម្រូវការធនធាន និងសូចនាករពិនិត្យតាមដាននិងវាយតម្លៃ។

## ៣.២ ភាគីពាក់ព័ន្ធ និងយន្តការ

តាមនិយមន័យ ដំណើរការគោលនយោបាយសាធារណៈក្នុងប្រទេសមួយពាក់ព័ន្ធនឹងភាគីជាច្រើន ហើយនេះក៏ជាការពិតសម្រាប់កម្ពុជាផងដែរ។ ក្រុមភាគីពាក់ព័ន្ធដំបូងគេគឺតួអង្គរដ្ឋដែលអាចបែងចែកជាស្ថាប័ននីតិប្រតិបត្តិនិងស្ថាប័ននីតិបញ្ញត្តិ និងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមទីពីរគឺតួអង្គមិនមែនរដ្ឋ ដូចជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងប្រជាពលរដ្ឋ។ ដើម្បីជួយសម្របសម្រួលតួអង្គទាំងនេះ មានការបង្កើតយន្តការជាច្រើននៅកម្រិតផ្សេងៗ និងសម្រាប់គោលបំណងខុសៗគ្នា។

ស្ថាប័ននីតិប្រតិបត្តិ ជាតួអង្គចម្បងក្នុងការតាក់តែង អនុវត្ត និងពិនិត្យតាមដាននិងវាយតម្លៃគោលនយោបាយ។ ទីភ្នាក់ងារនៅក្នុងស្ថាប័ននីតិប្រតិបត្តិចែកចេញជា ៣ក្រុម៖ ១) ក្រសួងសាមី ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ២) ក្រសួងស្នូល ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ និង ៣) គណៈរដ្ឋមន្ត្រី។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានចាត់ទុកជាផ្នែកមួយនៃស្ថាប័ននីតិប្រតិបត្តិផងដែរ។ គិតត្រឹមឆ្នាំ២០២០ កម្ពុជាមាន ៣៩ក្រសួង (រួមជាមួយនឹងមន្ទីរតាមខេត្ត) គ្រឹះស្ថានរដ្ឋបាលសាធារណៈចំនួន២៨ សហគ្រាសរដ្ឋចំនួន១៣ (ក្រៅពីធនាគារជាតិនៃកម្ពុជា) និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៣ថ្នាក់ (១ រាជធានី និង ២៤ ខេត្ត ២០៣ ស្រុក ក្រុង ខណ្ឌ និង ១.៦៥០ ឃុំ/សង្កាត់)។

**តាមគោលការណ៍ ការចូលរួម និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗជាលក្ខណៈចម្បងនៃដំណើរការគោលនយោបាយនៅកម្ពុជា។** ទោះជាយ៉ាងណា សមាសភាគ និងតួនាទីរបស់ភាគីពាក់ព័ន្ធទាំងនោះ គឺមិនដូចគ្នានោះទេ។ យោងតាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជា

ស្ថាប័នដឹកនាំការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយមានការចូលរួមពីក្រសួងផ្សេងទៀត។ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលមានតួនាទីផ្តល់ធាតុចូលតាមរយៈយន្តការក្រុមការងារបច្ចេកទេសផ្សេងៗ (សូមមើលខាងក្រោម)។ សម្រាប់ផែនការយុទ្ធសាស្ត្រថវិកា ក្រុមការងារថវិកាផ្ទៃក្នុងរបស់ទីភ្នាក់ងារនីមួយៗជាអ្នកដឹកនាំដំណើរការនេះ។ សម្រាប់ខ្លឹមសារលម្អិត សូមអានផ្នែកខាងក្រោម។

ក្រុមប្រឹក្សា គណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស ជួយដល់ការសម្របសម្រួល ប៉ុន្តែពេលខ្លះ ស្ថាប័នទាំងនេះក៏បង្កការលំបាកដល់ការសម្របសម្រួលផងដែរ។ តាមធម្មតា មានការបង្កើតក្រុមការងារបច្ចេកទេសនិងគណៈកម្មាធិការក្នុងវិស័យសាធារណៈ ដើម្បីធានាការចូលរួមគ្រប់គ្រាន់ពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗ និងប្រមូលធាតុចូលផ្នែកបច្ចេកទេស ដោយចាប់ផ្តើមពីភាគីដែលស្ថិតក្នុងជួររដ្ឋាភិបាល។ ការរៀបចំទាំងនេះផ្តល់ផលល្អ ជាពិសេសសម្រាប់បញ្ហាដែលប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណា មានការសង្កេតឃើញថា ការរៀបចំទាំងនេះក៏បង្កបញ្ហាកាន់តែច្រើនក្នុងការសម្របសម្រួល និងភាពមិនច្បាស់លាស់នៃដែនសមត្ថកិច្ចផងដែរ។ បញ្ហានេះមានភាពជ្រាលជ្រៅក្នុងករណីគោលនយោបាយឆ្លងវិស័យ ដូចជា ការអភិវឌ្ឍយុវជន វិមជ្ឈការ កិច្ចគាំពារសង្គម។ល។ ករណីសិក្សាក្នុងផ្នែកទី៥ នឹងបង្ហាញលម្អិតពីចំណុចនេះ។

គោលការណ៍និងយន្តការមួយចំនួនត្រូវ បានរៀបចំឡើងសម្រាប់ជាមគ្គុទេសក៍ដល់ការសម្របសម្រួលរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ ក្នុងដំណើរការគោលនយោបាយ។ ព័ត៌មានអាចរកបានក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (DCPS)។ យោងតាមឯកសារដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៩ ការជំរុញការចូលរួមត្រូវយកលំនាំតាមគោលការណ៍សំខាន់ៗ ដូចជា ភាពម្ចាស់ការ ភាពជាដៃគូ និងលទ្ធផល។ ក្រៅពីនេះ មានការបង្កើតយន្តការ និងឧបករណ៍មួយចំនួនសម្រាប់ការសម្របសម្រួល ដូចជា ក្រុមការងារបច្ចេកទេសតាមវិស័យ កិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល កិច្ចសន្ទនាភាពជាដៃគូថ្នាក់ខេត្ត សូចនាករតាមដានរួមគ្នា (JMI) និងជំនួយអភិវឌ្ឍន៍ផ្លូវការ និងមូលដ្ឋានទិន្នន័យអង្គការមិនមែនរដ្ឋាភិបាល[45]។

**ដៃគូអភិវឌ្ឍន៍ ជាពិសេសដៃគូពហុវិស័យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋា-ភិបាល។** ដៃគូអភិវឌ្ឍន៍ មានដូចជា ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (សម្រាប់បញ្ហាពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ ក៏ដូចជាគោលនយោបាយសារពើពន្ធ) និងធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារអង្គការសហប្រជាជាតិ (សម្រាប់បញ្ហាអភិវឌ្ឍន៍សង្គមជាច្រើន ដូចជា កិច្ចគាំពារសង្គម ការអភិវឌ្ឍយុវជន។ល។)។ ទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ

45 RGC (2019) Development Cooperation and Partnership Strategy (2019-2023)

ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូទាំងនេះ និងដាក់សំណើផ្លូវការដើម្បីស្នើសុំជំនួយបច្ចេកទេស។ បន្ទាប់ពីត្រូវបានឯកភាព ជំនួយការបច្ចេកទេស (ទាំងក្នុង និងក្រៅស្រុក) ត្រូវបានជ្រើសរើសឱ្យធ្វើការសិក្សា និងផ្ដល់អនុសាសន៍។ ក្រុមដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ (ផ្អែកតាមលក្ខខណ្ឌយោងផ្លូវការ) ទទួលបានទិន្នន័យចាំបាច់ និងឯកសារគោលនយោបាយថ្មីបំផុត។ តាមការសង្កេតកន្លងមក គឺមន្ត្រីរដ្ឋាភិបាលបានតម្រូវឱ្យមានការផ្ដោតទាំងលើករណីរបស់កម្ពុជា ក៏ដូចជាចំណេះដឹងពីការអនុវត្តជាអន្តរជាតិ និងការអនុវត្តថ្នាក់តំបន់ នៅក្នុងការសិក្សានានា។

ពាក់ព័ន្ធនឹងការផ្ទេរចំណេះដឹង អ្នកជំនាញការវ័យក្មេងដែលមានភារៈសម្របសម្រួល និងគាំទ្រដល់ការសិក្សានានា ទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីគម្រោងជំនួយបច្ចេកទេស។ តាមការសង្កេតរបាយក្រុមអ្នកជំនាញការវ័យក្មេងដែលមានទេពកោសល្យនៅតាមក្រសួងនានា ឬក្នុងក្រសួងតែមួយ គឺមិនដូចគ្នានោះទេ។ ដូចការលើកឡើងពីខាងដើម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាក្រសួងដែលមានចំនួនអ្នកជំនាញការវ័យក្មេងច្រើនជាងគេ ប៉ុន្តែក្នុងនាយកដ្ឋានមួយចំនួនរបស់ក្រសួងនេះ ហាក់មានចំនួនអ្នកជំនាញការវ័យក្មេងតិចជាងនាយកដ្ឋានផ្សេងទៀត។

## ៣.៣ ដំណាក់កាលសំខាន់ៗក្នុងដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ

**ដំណើរការគោលនយោបាយនៅកម្ពុជា ពាក់ព័ន្ធនឹងដំណាក់កាលសំខាន់ៗចំនួន ៣ ៖** ការតាក់តែងគោលនយោបាយ ការអនុវត្តគោលនយោបាយ និងការពិនិត្យតាមដាននិងវាយតម្លៃគោលនយោបាយ។ ទោះបីជាមានភាពខុសគ្នាខ្លះក៏ដោយ ប៉ុន្តែដំណាក់កាលទាំងនេះស៊ីសង្វាក់គ្នានឹងទស្សនាទាន និងការអនុវត្តជាអន្តរជាតិស្ដីពីគោលនយោបាយសាធារណៈ[46]។ គួរកត់សម្គាល់ផងដែរថា នៅក្នុងការអនុវត្ត ដំណើរការគោលនយោបាយ មិនមានភាពរលូននោះទេ ប៉ុន្តែគឺរញ៉េរញ៉ៃ និងច្រំដែល។ ក្រៅពីនេះ មានជំហានរាយរង និងកិច្ចការជាច្រើនក្នុងដំណាក់កាលនីមួយៗ បូករួមនឹងភាគីពាក់ព័ន្ធសំខាន់ៗ និងទិន្នន័យដែលត្រូវការចាំបាច់។ ខ្លឹមសារសង្ខេបមានបង្ហាញក្នុងតារាងខាងក្រោម។

[46] INASP (2016), Evidence-informed policy making toolkit

### តារាងទី៣៖ ដំណើរការ និងការប្រើប្រាស់ទិន្នន័យក្នុងដំណើរការគោលនយោបាយផ្សេងៗ

| | | គោលនយោបាយរយៈពេលវែង | ម៉ាក្រូសេដ្ឋកិច្ច/MTFF | ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសាមី/ទីភ្នាក់ងារ |
|---|---|---|---|---|
| ការតាក់តែងគោលនយោបាយ | ដំណើរការ | - ឆ្លងរដ្ឋាភិបាល៖ ចាប់ផ្តើមពីក្រសួងផែនការ ឬក្រុមការងារបច្ចេកទេសអន្តរក្រសួង ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី<br>- ក្រសួងសាមី៖ ចាប់ផ្តើមពីក្រុមការងារបច្ចេកទេសរបស់ក្រសួង ចុះហត្ថលេខាដោយរដ្ឋមន្ត្រី | - ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ<br>- ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី<br>- ធ្វើបច្ចុប្បន្នជារៀងរាល់ឆ្នាំ (នៅខែមីនា)<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | - ដឹកនាំដោយក្រសួងសាមី/ទីភ្នាក់ងារ អនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ (នៅខែឧសភា)<br>- ជាតុចូលមានកម្រិតពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល |
| | ទិន្នន័យ | - អង្កេតធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ទិន្នន័យរដ្ឋបាល ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល<br>- ផ្សព្វផ្សាយជាសាធារណៈ (មិនមែនទាំងអស់) | - គណនីជាតិ និងសូចនាករម៉ាក្រូសេដ្ឋកិច្ច<br>- ការព្យាករណ៍ចំណូល/ចំណាយ<br>- ផ្សព្វផ្សាយជាសាធារណៈ | - កម្មវិធី អនុកម្មវិធី និងគម្រោងថវិកា<br>- មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ |

| ការអនុវត្តគោលនយោបាយ | ដំណើរការ | - ឆ្លងរដ្ឋាភិបាលៈ ចាត់តាំងកិច្ចការ/សកម្មភាព ជាក់លាក់ ឱ្យក្រសួង/ទីភ្នាក់ងារនានា<br>- ក្រសួងសាម៉ីៈ ចាត់តាំងឱ្យនាយកដ្ឋានផ្សេងៗ<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | - ការពិនិត្យតាមដានជាប្រចាំលើម៉ាក្រូសមិទ្ធកម្ម<br>- ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | - ការពិនិត្យតាមដានជាប្រចាំ<br>- ដឹកនាំដោយក្រសួងសាម៉ី/ទីភ្នាក់ងារ អនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ជាតុចូលមានកម្រិតពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល |
|---|---|---|---|---|
| | ទិន្នន័យ | - ទិន្នន័យរដ្ឋបាល ជំរឿន/អង្កេត ធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល<br>- ផ្សព្វផ្សាយជាសាធារណៈ (មិនមែនទាំងអស់) | - ទិន្នន័យម៉ាក្រូសេដ្ឋកិច្ច និងទិន្នន័យសារពើពន្ធ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងផែនការ<br>- ផ្សព្វផ្សាយជាសាធារណៈ (មានកម្រិត) | - ទិន្នន័យរដ្ឋបាលរបស់ក្រសួងសាម៉ី FMIS (សម្រាប់ទិន្នន័យថវិកា)<br>- មិនផ្សព្វផ្សាយជាសាធារណៈ |

| | | | | |
|---|---|---|---|---|
| ការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ | ដំណើរការ | - ឆ្លងរដ្ឋាភិបាល ៖ ពាក់កណ្តាលអាណត្តិ ចុងអាណត្តិ<br>- ក្រសួង៖ ពាក់កណ្តាលអាណត្តិ ចុងអាណត្តិ (មិនធ្វើឡើងជាទៀងទាត់ដោយក្រសួងសាមីទាំងអស់នោះទេ)<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍ | - រៀងរាល់ឆ្នាំ ពាក់កណ្តាលអាណត្តិ ចុងអាណត្តិ (ផ្នែកមួយនៃ PFMRP)<br>- ដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ធនាគារជាតិនៃកម្ពុជា<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍ (ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ...) | - ធ្វើឡើងជារៀងរាល់ឆ្នាំ<br>- ទិន្នន័យរដ្ឋបាលរបស់ក្រសួងសាមី FMIS (សម្រាប់ទិន្នន័យថវិកា)<br>- ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល |
| | ទិន្នន័យ | - ឆ្លងរដ្ឋាភិបាល ៖ ជំរឿន/អង្កេតធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ទិន្នន័យរដ្ឋបាល ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | - ទិន្នន័យម៉ាក្រូសេដ្ឋកិច្ច/ទិន្នន័យសារពើពន្ធ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងផែនការ ជាតុចូលពីដៃគូអភិវឌ្ឍន៍<br>- ផ្សព្វផ្សាយជាសាធារណៈ (មានកម្រិត) | - ទិន្នន័យរដ្ឋបាលរបស់ក្រសួងសាមី FMIS (សម្រាប់ទិន្នន័យថវិកា)<br>- ផ្សព្វផ្សាយជាសាធារណៈ (ឧ. របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ) |

| | | | | |
|---|---|---|---|---|
| | | - ក្រសួង៖ ទិន្នន័យរដ្ឋបាល អង្កេតធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ជាតុចូលពីដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | | |

**ទីភ្នាក់ងាររដ្ឋាភិបាលប្រើប្រាស់ប្រភេទទិន្នន័យផ្សេងៗក្នុងដំណើរការគោលនយោបាយ។** ខ្លឹមសារលម្អិតស្តីពីការផលិត ការចែករំលែក និងការប្រើប្រាស់ទិន្នន័យ នឹងលើកមកពិភាក្សាក្នុងផ្នែកបន្ទាប់។ ក្នុងផ្នែកនេះ គួរកត់សម្គាល់ថា មានការប្រើប្រាស់ទិន្នន័យយ៉ាងតិច៣ប្រភេទ៖ ១) ជំរឿនថ្នាក់ជាតិ និងអង្កេតសំណាកដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ២) ទិន្នន័យរដ្ឋបាលដែលត្រូវបានផលិតឡើងក្នុងការបំពេញមុខងារជាប្រចាំរបស់ទីភ្នាក់ងាររដ្ឋាភិបាល និង ៣) ទិន្នន័យដែលប្រមូលបាន និងការស្រាវជ្រាវដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ តាមការរៀបរាប់លម្អិតក្នុងផ្នែកទី៤ វិទ្យាស្ថានជាតិស្ថិតិបានខិតខំប្រមូល និងរក្សាទុករាល់ប្រភពទិន្នន័យផ្សេងៗក្នុងគេហទំព័រ ឬហៅថា CamStat (ពីមុនហៅថា CamInfo)។ គំនិតផ្តួចផ្តើមនេះនឹងជួយបង្កើនលទ្ធភាពទទួលបាន និងការចែករំលែកទិន្នន័យសាធារណៈនាពេលអនាគត ទោះបីជាបច្ចុប្បន្ន នៅមានបញ្ហាប្រឈមជាច្រើនក្នុងផ្នែកបច្ចេកទេសក៏ដោយ។

### ៣.៣.១ ដំណាក់កាលតាក់តែងគោលនយោបាយ

**ដំណើរការ និងការប្រើប្រាស់ទិន្នន័យក្នុងការតាក់តែងគោលនយោបាយប្រែប្រួលទៅតាមករណី។** សម្រាប់ការអនុវត្តជាអន្តរជាតិ ដំណាក់កាលនេះអាចចែកចេញជាជំហានរាយរង ដូចជា ការកំណត់របៀបវារៈ ការកំណត់របញ្ហា ការពិភាក្សាពីជម្រើស និងការធ្វើសេចក្តីសម្រេចចិត្ត[47]។ នៅកម្ពុជា ដំណើរការលម្អិតប្រែប្រួលទៅតាមប្រភេទគោលនយោបាយ។ សម្រាប់គោលនយោបាយឆ្លងរដ្ឋាភិបាលរយៈពេលវែង ដូចជា យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដំណើរការនេះស្ថិតក្រោមការដឹកនាំភាគច្រើនដោយក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយនឹងទីភ្នាក់ងារផ្សេងទៀត ដូចជា ធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍

[47] INASP (2016), Evidence-informed policy making toolkit

កម្ពុជា ក្រសួងសាមី៉ ដៃគូអភិវឌ្ឍន៍ និងតួអង្គមិនមែនរដ្ឋផ្សេងទៀត។ សម្រាប់គោលនយោបាយទាំងនេះរដ្ឋាភិបាលពឹងផ្អែកចម្បងលើជំរឿនថ្នាក់ជាតិ និងអង្កេតដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងបំពេញបន្ថែមដោយទិន្នន័យរដ្ឋបាលពីក្រសួងសាមី៉ ក៏ដូចជាធាតុចូលពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។

គោលនយោបាយរយៈពេលវែងរបស់រដ្ឋាភិបាល (ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា) ផ្សារភ្ជាប់នឹងរបៀបវារៈអភិវឌ្ឍន៍ពិភពលោក។ យុទ្ធសាស្ត្រចតុកោណដើរតួនាទីជាវេទិកានយោបាយរបស់រដ្ឋាភិបាលពេញមួយអាណត្តិតែម្តង ចំណែកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានចាត់ទុកជាឧបករណ៍សម្រាប់ការដំណើរការវេទិកាគោលនយោបាយក្នុងរដ្ឋាភិបាលទាំងមូល។ ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបញ្ជាក់ពីតួអង្គ ផ្នែកគោលនយោបាយ ការប៉ាន់ស្មានតម្រូវការធនធាន និងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ។ គោលបំណង និងសូចនាករគោលនយោបាយជាច្រើនក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ យោងតាមរបាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ៤០% នៃសូចនាករក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា បន្សុីគ្នា និងត្រូវបានដាក់បញ្ចូលក្នុងកម្រងសូចនាករនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[48]។

**ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលវែង និងក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម** (MTFF) **ស្ថិតក្រោមការដឹកនាំភាគច្រើនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា។** ឯកសារនេះជាគោលនយោបាយ ៣ឆ្នាំរំកិលដែលគ្របដណ្តប់លើរដ្ឋាភិបាលទាំងមូល និងត្រូវបានប្រើប្រាស់ជាត្រីវិស័យសម្រាប់ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) និងផែនការយុទ្ធសាស្ត្រថវិកានៅកម្រិតក្រសួងសាមី៉ និងកម្រិតទីភ្នាក់ងារ។ ក្រោមជំនួយផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក រដ្ឋាភិបាលបានបង្កើតម៉ូដែលសម្រាប់ការធ្វើបច្ចុប្បន្នភាពគណនីជាតិ និងការព្យាករណ៍ចំណូលជាតិ (ទាំងពន្ធ និងមិនមែនពន្ធ) បំណុល និងចំណាយសរុប។ ទិន្នន័យបន្ថែមទៀតស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌសារពើពន្ធ អាចរកបានក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគោលនយោបាយ)[49] និងគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា[50]។

**ផែនការយុទ្ធសាស្ត្រថវិកា ជាផែនការ ៣ឆ្នាំរំកិលដែលត្រូវរៀបចំឡើងដោយអង្គភាពថវិកា។** បច្ចុប្បន្ន អង្គភាពថវិកាទាំងនោះរួមបញ្ចូលក្រសួងសាមី៉ទាំងអស់ នាយកដ្ឋានពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត។ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយខ្លួនឯង អង្គភាពថវិកាទទួលបាន

[48] RGC (2020) CSDG progress report
[49] សូមចូលទៅកាន់៖ https://gdp.mef.gov.kh/
[50] សូមចូលទៅកាន់៖ https://www.nbc.org.kh/english/publications/economic_and_monetary_statistics.php

សមត្ថកិច្ចកាន់តែច្រើនលើផែនការរបស់ខ្លួន និងមានចក្ខុវិស័យយុទ្ធសាស្ត្ររយៈពេលមធ្យម នៅពេលរៀបចំផែនការទាំងនោះ។ ក្រសួងសាមី និងទីភ្នាក់ងារពាក់ព័ន្ធ យោងតាមក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យមដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នៅខែមីនា) និងផ្អែកជាចម្បងលើទិន្នន័យរដ្ឋបាលរបស់ខ្លួននៅពេលរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ បច្ចុប្បន្នគឺមិនសូវមានធាតុចូលពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងនោះទេ មួយផ្នែកគឺដោយសារតែពេលវេលាខ្លី (រយៈពេលត្រឹមតែ២ខែ ចាប់ពីខែមេសា ដល់ខែឧសភា)។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងពិចារណាផ្តល់ពេលវេលាច្រើនជាងមុនសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ គួរកត់សម្គាល់ផងដែរថា មិនសូវមានការផ្សព្វផ្សាយជាសាធារណៈអំពីទិន្នន័យដែលពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រថវិកាឡើយ។

**ផែនការយុទ្ធសាស្ត្រថវិកា ជាឯកសារដែលមានភាពស្មុគស្មាញផ្នែកបច្ចេកទេស** ដែលរួមបញ្ចូលទាំងទិដ្ឋភាពជាយុទ្ធសាស្ត្រនៅរយៈពេល ៣ឆ្នាំបន្ទាប់ និងទិដ្ឋភាពប្រតិបត្តិការដែលផ្តោតសំខាន់លើផែនការការងារ និងចំណាយប្រចាំឆ្នាំ។ ៤. យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផែនការយុទ្ធសាស្ត្រថវិកាទាំងអស់ត្រូវបង្ហាញពី ១) គោលបំណងគោលនយោបាយ ២) ការប៉ាន់ប្រមាណបញ្ហា និងតម្រូវការ ៣) ជម្រើសគោលនយោបាយ ៤) ចំណាយ និង ៥) សូចនាករ និងចំណុចដៅក្នុងការពិនិត្យតាមដាននិងវាយតម្លៃ[51]។ ក្នុងករណីដែលអាចអនុវត្តបាន ចំណុចសំខាន់ៗទាំងនេះត្រូវបែងចែកទៅតាមកម្មវិធី អនុកម្មវិធី និងឆ្នាំ។ ទោះជាយ៉ាងណា នៅតែមានការអនុវត្តខុសៗគ្នាទៅតាមសមត្ថភាព និងធនធានរបស់ក្រសួងសាមី និងទីភ្នាក់ងារនីមួយៗ។ ផ្អែកតាមការសិក្សាដែលមានស្រាប់ ផែនការយុទ្ធសាស្ត្រថវិកាភាគច្រើនហាក់មានភាពខ្វះចន្លោះលើការគណនាចំណាយ និងការពិនិត្យតាមដាននិងវាយតម្លៃ (ជាពិសេសការជ្រើសរើសសូចនាករ និងចំណុចដៅ)[52]។

**ការសិក្សាដែលមានស្រាប់រកឃើញថា មិនសូវមានទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រថវិការយៈពេល ៣ឆ្នាំ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនោះទេ។** ដូចការលើកឡើងពីខាងដើម គួរមានឋានានុក្រម និងទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការសិក្សាមួយរបស់ក្រសួងផែនការ ក្នុងឆ្នាំ២០១៥ រកឃើញថា មានភាពបន្សុីគ្នាបានល្អរវាងឯកសារគោលនយោបាយ និងឯកសារផែនការ ពោលគឺរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងឯកសារយុទ្ធសាស្ត្រវិស័យសំខាន់ៗ ប៉ុន្តែមិនសូវមានភាពបន្សុីគ្នារវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រថវិកា (និងផែនការថវិកាប្រចាំឆ្នាំ)។ ការសិក្សានោះបានពន្យល់បន្ថែមទៀតថា ភាពមិនបន្សុីគ្នានេះអាចបណ្តាលមកពីរចនាសម្ព័ន្ធស្ថាប័ន ដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយវិស័យមានការ

[51] MEF (2011) Guideline on preparing Budget Strategic Plan (BSP)

[52] EU (2020) Assessment of the Budget Strategic Plan (BSP) of selected ministries

ចូលរួមកាន់តែច្រើនពីក្រសួងផែនការ ចំណែកផែនការយុទ្ធសាស្ត្រថវិកាស្ថិតក្រោមការដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមតិចតួចពីក្រសួងផែនការ[53]។

**ឯកសារគោលនយោបាយ និងឯកសារផែនការនៅថ្នាក់ក្រោមជាតិ ត្រូវបានកំណត់យ៉ាងច្បាស់ ប៉ុន្តែបញ្ហាប្រឈមចម្បងគឺវិភាជថវិកា។** ក្នុងរបាយការណ៍នេះ ផែនការរយៈពេល ៥ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចាត់ទុកជាទម្រង់មួយនៃគោលនយោបាយ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមដំណើរការរៀបចំផែនការដែលត្រូវបានកំណត់យ៉ាងច្បាស់ និងមានការចូលរួមពីថ្នាក់មូលដ្ឋាន ពោលគឺដំណើរការដែលប្រជាជនមូលដ្ឋាន (ជាពិសេសក្រុមងាយរងគ្រោះ) និងតួអង្គមិនមែនរដ្ឋអាចចូលរួមបាន។ ទោះបីជាមានព្រំដែនកំណត់មួយចំនួនក្តី ប៉ុន្តែការស្រាវជ្រាវបានបង្ហាញថា មួយភាគធំគឺរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមតាមលក្ខខណ្ឌតម្រូវនេះ។

ក្រៅពីនេះ ពួកគេបានប្រើប្រាស់ទិន្នន័យពីមូលដ្ឋានទិន្នន័យឃុំ នៅពេលរៀបចំផែនការរយៈពេល ៥ឆ្នាំ។ ទោះជាយ៉ាងណា បញ្ហាប្រឈមចម្បងគឺភាពមានកម្រិតនៃវិភាជថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ប៉ុន្តែចំណែកជារួមនៃចំណាយសាធារណៈសម្រាប់គណនីរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមានប្រមាណតែ ១០% ប៉ុណ្ណោះ បើធៀបនឹងចំណាយជាតិសរុប។ ភាគរយនេះគឺទាបបំផុត បើធៀបនឹងប្រទេសផ្សេងទៀត[54]។

**ក្រោមការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជំរុញឱ្យមានកំណែទម្រង់ភាគច្រើនលើការតាក់តែងគោលនយោបាយ។** សម្រាប់គោលនយោបាយរយៈពេលវែង ទោះបីជាតាមច្បាប់ ក្រសួងផែនការគួរជាស្ថាប័នដឹកនាំក៏ដោយ ប៉ុន្តែយូរៗទៅគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈអគ្គនាយកដ្ឋានគោលនយោបាយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) ជាស្ថាប័នដឹកនាំកិច្ចការនេះ។ ក្រៅពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានតាក់តែងគោលនយោបាយឆ្លងវិស័យនានា ដូចជា គោលនយោបាយដែលផ្តោតសំខាន់លើសេដ្ឋកិច្ចឌីជីថល កិច្ចគាំពារសង្គម ភស្តុភារ។ល។ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏មានតួនាទីកាន់តែជាក់លាក់ផងដែរក្នុងការតាក់តែងគោលនយោបាយរយៈពេលមធ្យម ដែលកាន់តែពាក់ព័ន្ធនឹងបញ្ហាថវិកា។

មកទល់បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដឹកនាំគោលនយោបាយសំខាន់ៗចំនួន៥ ដែលពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) រួមមាន ១) យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា (២០១៨-២០២៥) ២) យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៣) ៣) យុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ (២០១៩-២០២៥) ៤) យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ

53 MOP (2015) Summary assessment of the M&E system for NSDP implementation.

54 World Bank (2021) Intergovernmental fiscal architecture.

(២០១៩-២០២៥) និង ៥) យុទ្ធសាស្ត្រកៀរគរចំណូល (២០១៩-២០២៣)។ កំណែទម្រង់ទាំងនេះនឹងផ្លាស់ប្តូររបៀបរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌសារពើពន្ធ ក៏ដូចជាជំរុញឱ្យមានការផ្សព្វផ្សាយជាសាធារណៈស្តីពីទិន្នន័យដែលពាក់ព័ន្ធនឹងថវិកា។

### ៣.៣.២ ការអនុវត្តគោលនយោបាយ

**ព្រំដែន និងវិសាលភាពនៃដំណាក់កាលអនុវត្តគោលនយោបាយ មិនសុទ្ធតែត្រូវបានកំណត់ច្បាស់នោះទេ។** ទីមួយ អ្វីដែលត្រូវបានចាត់ទុកជាដំណាក់កាលតាក់តែងគោលនយោបាយរបស់ក្រសួងមួយ ឬផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមពិតជាការអនុវត្តគោលនយោបាយជាតិ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទីពីរ ការអនុវត្តគោលនយោបាយក៏ផ្តោតលើ "ការអនុវត្តជាក់ស្តែង" នូវអ្វីដែលត្រូវបានគ្រោងឡើងក្នុងឯកសារគោលនយោបាយផងដែរ មិនថាវាពាក់ព័ន្ធនឹងថ្នាក់ជាតិ ឬថ្នាក់ក្រសួង រយៈពេលវែង ឬរយៈពេលខ្លីនោះទេ។ ដូច្នេះតាមន័យបច្ចេកទេស ការអនុវត្តគោលនយោបាយគឺផ្តោតលើការរៀបចំផែនការសកម្មភាព ការរៀបចំថវិកា និងការផលិតលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ ដូចដែលបានចែងក្នុងឯកសារគោលនយោបាយ។

**សម្រាប់គោលនយោបាយរយៈពេលវែង និងគោលនយោបាយរយៈពេលមធ្យម កិច្ចការអនុវត្តជាតួនាទីរបស់ក្រសួង និងទីភ្នាក់ងារដែលទទួលខុសត្រូវ។** ជាទូទៅ គោលនយោបាយទាំងនោះមានផ្នែកបន្ថែមមួយ (តារាងផែនការសកម្មភាព) ដែលបញ្ជាក់ពីក្រសួង (សម្រាប់គោលនយោបាយជាតិ) ឬនាយកដ្ឋាន (សម្រាប់គោលនយោបាយក្រសួង) ដែលទទួលខុសត្រូវលើការបំពេញកិច្ចការជាក់លាក់។ ក្នុងករណីមួយចំនួន តារាងនេះក៏គូសបញ្ជាក់ពីសូចនាករ និងចំណុចដៅផងដែរ។ ក្នុងករណីមួយចំនួនតូច វាក៏បង្ហាញពីថវិកាដែលត្រូវការចាំបាច់ផងដែរ។ ក្នុងការអនុវត្តគោលនយោបាយទាំងនេះ ក្រសួង និងទីភ្នាក់ងារដែលមានភារៈទទួលខុសត្រូវ ពឹងផ្អែកចម្បងលើទិន្នន័យរដ្ឋបាលផ្ទៃក្នុង ដើម្បីត្រួតពិនិត្យ និងរាយការណ៍ពីវឌ្ឍនភាពនៃគោលនយោបាយ។ ក្នុងករណីខ្លះ ក្រសួងនិងទីភ្នាក់ងារទាំងនោះខិតខំប្រើប្រាស់ទិន្នន័យពីជំរឿនថ្នាក់ជាតិ និងអង្កេតដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក៏ដូចជាទិន្នន័យ និងធាតុចូលដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ទោះជាយ៉ាងណា ការប្រើប្រាស់ប្រភពទិន្នន័យទាំងនេះមិនមានរបាយដូចគ្នានោះទេ។

**នៅកម្រិតក្រសួង និងកម្រិតទីភ្នាក់ងារ ការអនុវត្តគោលនយោបាយមានន័យស្មើនឹងការអនុវត្តដំណើរការថវិកាតាមកម្មវិធី។** យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង និងទីភ្នាក់ងារទាំងអស់ចាំបាច់ត្រូវអនុវត្តគោលនយោបាយរបស់ខ្លួនដោយយកលំនាំតាម "ក្របខ័ណ្ឌលទ្ធផល" ដើម្បីបម្លែងធនធានដែលបានបែងចែក (ធាតុចូល) ទៅជាលទ្ធផលរំពឹង

ទុក និងផលប៉ះពាល់។ ដូចការបង្ហាញក្នុងដ្យាក្រាមខាងក្រោម ក្របខ័ណ្ឌនេះគឺដូចគ្នានឹងឡូកហ្វ្រេម (logical framework) ដែលត្រូវបានប្រើប្រាស់ក្នុងកម្មវិធី និងគម្រោងរបស់ម្ចាស់ជំនួយជាច្រើនដែរ។ "ក្របខ័ណ្ឌលទ្ធផល" ត្រូវបានរៀបចំ និងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័ត ដើម្បីធានាការអនុលោមតាមគោលបំណងអភិវឌ្ឍន៍ទូលំទូលាយ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងរំហូរការងារផ្ទៃក្នុង។

រូបភាពទី២៖ ក្របខ័ណ្ឌលទ្ធផលរបស់រដ្ឋាភិបាលសម្រាប់ការអនុវត្តគោលនយោបាយ




**គោលបំណងនៃផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី គឺការផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា។** ទោះបីជាមានវឌ្ឍនភាពក៏ដោយ ប៉ុន្តែមួយភាគធំគឺ វិភាជថវិកានៅកម្ពុជានៅតែកើនឡើង ប៉ុន្តែមិនទាន់ផ្សារភ្ជាប់ទៅនឹងលទ្ធផល និងគោលបំណងគោលនយោបាយឱ្យបានគ្រប់គ្រាន់នោះទេ។ នេះជាលទ្ធផលដែលរកឃើញដោយការសិក្សាឯករាជ្យផ្សេងៗ និងត្រូវបានបញ្ជាក់ក្នុងបទសម្ភាសន៍សម្រាប់ការសិក្សានេះ[55]។ ដូចការពិភាក្សាក្នុងផ្នែកមួយផ្សេងទៀត ព្រំដែនកំណត់នេះ បានកាត់បន្ថយការលើកទឹកចិត្តឱ្យមន្ត្រីក្រសួងសាមីខិតខំប្រើប្រាស់ទិន្នន័យ ដើម្បីកសាងករណីសម្រាប់កម្មវិធី និងគំនិតផ្តួចផ្តើមថ្មីៗរបស់ខ្លួន ព្រោះពួកគេដឹងថា ការប្រែងទាំងនោះនឹងមិននាំឱ្យមានការផ្តល់ថវិកា និងរង្វាន់លើកទឹកចិត្តកាន់តែច្រើននោះទេ។

វឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយក្នុងការអនុវត្តគោលនយោបាយគឺ ការប្រមូលទិន្នន័យជាប្រព័ន្ធស្តីពីវិភាជថវិកា និងការប្រើប្រាស់ថវិកា តាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដែលជាថ្នាលឌីជីថលសម្រាប់ជួយដល់ក្រសួង និងទីភ្នាក់ងារពាក់ព័ន្ធ (រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ) ក្នុងការប្រើប្រាស់ និងកត់ត្រាថវិការបស់ខ្លួន និងលើកកម្ពស់ការគ្រប់គ្រងថវិការដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ប្រព័ន្ធនេះចាប់ផ្តើមឡើងនៅក្នុងឆ្នាំ២០១៣ និងបច្ចុប្បន្នគ្របដណ្តប់លើក្រសួងសាមីទាំងអស់ និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។

ប្រព័ន្ធនេះត្រូវបានសំយោគជាមួយប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្សេងទៀត ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារពាណិជ្ជ ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គយ និងរដ្ឋាករ ប្រព័ន្ធគ្រប់គ្រងព័ត៌មានពន្ធដារ និងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនពន្ធប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គលិកសាធារណៈ[56]។ តាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធ

55 World Bank (2016) Program budgeting in Cambodia
56 សូមចូលទៅកាន់៖ https://fmis.mef.gov.kh/

គ្រប់គ្រងព័ត៌មានផ្សេងទៀត គេអាចទាញយកទិន្នន័យស្តីពីប្រធានបទផ្សេងៗបានយ៉ាងងាយស្រួល (ដូចជាវិភាជថវិកាការប្រើប្រាស់ថវិកា ការប្រមូលចំណូលមិនមែនពន្ធ។ល។)។ របាយការណ៍ដែលផលិតចេញពីមូលដ្ឋានទិន្នន័យទាំងនេះ អាចរកបានក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែរបាយការណ៍ភាគច្រើននៅតែមានទម្រង់ pdf មិនមែនទម្រង់ Excel ដែលងាយស្រួលប្រើប្រាស់នោះទេ[57] ។

## ៣.៣.៣ ដំណាក់កាលពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ

**ការពិនិត្យតាមដាននិងវាយតម្លៃ មានភាពពាក់ព័ន្ធគ្នាបំផុត ប៉ុន្តែមិនដូចគ្នានោះទេ។** ការពិនិត្យតាមដានពិពណ៌នាពីការប៉ាន់ប្រមាណក្នុងឆ្នាំ និងការប៉ាន់ប្រមាណប្រចាំឆ្នាំលើការអនុវត្តសកម្មភាពនានា និងការសម្រេចបានចំណុចដៅសមិទ្ធកម្មរយៈពេលខ្លី ដែលពាក់ព័ន្ធនឹងសូចនាករលទ្ធផលរំពឹងទុក។ ចំណែកការវាយតម្លៃសំដៅលើការប៉ាន់ប្រមាណស៊ីជម្រៅលើចំណុចដៅរយៈពេលវែងដែលពាក់ព័ន្ធនឹងសូចនាករលទ្ធផល។

ការពិនិត្យតាមដាន អាចជួយគូសបញ្ជាក់ថាតើយើងកំពុងដើរតាមទិសដៅត្រឹមត្រូវឈានទៅសម្រេចបានលទ្ធផលដែលចង់បានឬទេ ខណៈដែលគេអាចប្រើប្រាស់ការវាយតម្លៃដើម្បីស្វែងយល់ពី "មូលហេតុ" ដែលនាំឱ្យយើងដើរតាម ឬមិនដើរតាមទិសដៅត្រឹមត្រូវ[58] ។

**រដ្ឋាភិបាលកម្ពុជាកត់សម្គាល់ពីសារៈសំខាន់នៃការពិនិត្យតាមដាន និងវាយតម្លៃទាំងសម្រាប់គោលនយោបាយរយៈពេលវែង និងគោលនយោបាយរយៈពេលមធ្យម។** ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានទាំងការវាយតម្លៃពាក់កណ្តាលអាណត្តិ និងការវាយតម្លៃចុងអាណត្តិ និងផ្សារភ្ជាប់នឹងវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា[59]។

ក្នុងគោលនយោបាយកំណែទម្រង់ផ្សេងទៀត ដូចជា កិច្ចគាំពារសង្គមវិមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏មានការពិនិត្យតាមដានប្រចាំឆ្នាំ និងការវាយតម្លៃតាមដំណាក់កាលផងដែរ។ ក្រៅពីនេះ ការពិនិត្យតាមដានត្រូវបានធ្វើឡើងក្នុងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល របស់ក្រសួង និងទីភ្នាក់ងារពាក់ព័ន្ធ ក្នុងផ្នែកមួយនៃដំណើរការរៀបចំផែនការ និងថវិកាជាប្រចាំ[60]។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (ដូចជា UNICEF, UNFPA, WFP, World Bank, IMF) ក៏បានកត់សម្គាល់ពីព្រំដែនកំណត់ (សូមមើលខាងក្រោម) ក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃបច្ចុប្បន្ន និងខិតខំធ្វើការកែលម្អផងដែរ។

---

57 សូមចូលទៅកាន់៖ https://mef.gov.kh/documents-category/publication/

56 MOP (2015) Monitoring and evaluation for NSDP implementation system (MENI) orientation guideline.

59 RGC (2020) Progress report for 2019 on the CSDGs (2016-2030).

60 សូមមើល ឧ. MEF's Circular on BSP in 2021.

**សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានការប៉ាន់ប្រមាណលើប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃ និងមានការរៀបចំគោលការណ៍ណែនាំស្តីពីវិធីកែលម្អ។** ក្នុងឆ្នាំ២០១៥ មានការសិក្សាបែបវិភាគមួយដើម្បីប៉ាន់ប្រមាណប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមជាមួយនឹងលក្ខណៈវិនិច្ឆ័យចំនួន៦៖ ១) បុរេលក្ខខណ្ឌសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃដោយផ្អែកតាមលទ្ធផល ២) ក្របខ័ណ្ឌស្ថាប័នសម្រាប់ការពិនិត្យតាមដាន និង វាយតម្លៃ ៣) ផែនការ និងថវិកា ៤) ការពិនិត្យតាមដានជាប់លាប់ ៥) វដ្តនៃការវាយតម្លៃ និង ៦) ប្រព័ន្ធព័ត៌មានស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ។ ពិន្ទុជារួមគឺ ១,២៦ លើ៣។ ពិន្ទុសម្រាប់ការពិនិត្យតាមដានជាប់លាប់គឺខ្ពស់ជាងគេ (១,៨៨) បន្ទាប់មកគឺពិន្ទុសម្រាប់វដ្តនៃការវាយតម្លៃ (១,៥) ចំណែកពិន្ទុសម្រាប់ក្របខ័ណ្ឌស្ថាប័នគឺទាបជាងគេ (០,៥៦) និងជាកត្តាចម្បងដែលរាំងស្ទះដល់ការកែលម្អប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។

ក្រុមការងារថ្នាក់ជាតិទទួលបន្ទុកពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ប៉ុន្តែបញ្ហាចោទរបស់ក្រុមការងារនេះគឺសមត្ថភាពសម្របសម្រួល ជាពិសេសសមត្ថភាពសម្របសម្រួលរវាងក្រសួងផែនការ និងក្រសួងផ្សេងទៀត[61]។ លទ្ធផលនៃការប៉ាន់ប្រមាណត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំគោលការណ៍ណែនាំ ដែលចំណុចសំខាន់ៗមានបង្ហាញក្នុងប្រអប់ខាងក្រោម។

### ប្រអប់ទី ៤ ៖ ចំណុចសំខាន់ៗនៃគោលការណ៍ណែនាំស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ផ្អែកតាមការប៉ាន់ប្រមាណប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រសួងផែនការបានរៀបចំគោលការណ៍ណែនាំ (ក្រោមជំនួយបច្ចេកទេសពី UNICEF និង UNFPA)។ គោលការណ៍ណែនាំនោះមានសមាសភាគសំខាន់ៗចំនួន៣ ៖ ១) គោលបំណង និង គោលការណ៍ណែនាំ ២)សមាសភាគបច្ចេកទេស និង ៣) រចនាសម្ព័ន្ធស្ថាប័ន។

**គោលបំណង និងគោលការណ៍ណែនាំ៖** ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានគោលបំណងផ្តល់ព័ត៌មានល្អៗ និងប្រកបដោយគុណភាពសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងពង្រឹងគណនេយ្យភាពលើ ក) ការអនុវត្តកម្មវិធីជាតិធំៗ និង ខ) វឌ្ឍនភាពនៃការសម្រេចបានចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ គោលការណ៍ណែនាំរួមមាន ការបន្ថែមតម្លៃ ការផ្តោតលើលទ្ធផល ការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមភស្តុតាង ការរៀនសូត្រ និងប្រសិទ្ធិភាពចំណាយ។

[61] MOP (2015) Monitoring and evaluation for NSDP implementation system (MENI) orientation guideline.

**សមាសភាគបច្ចេកទេស៖** ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃរួមបញ្ចូលសមាសភាគជារួម និងសមាសភាគជាក់លាក់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ។ សមាសភាគជារួមមាន ៤៖ គោលនយោបាយស្តីពីការពិនិត្យតាមដាននិងវាយតម្លៃ ក្របខ័ណ្ឌវាស់វែងសមិទ្ធកម្ម ផែនការកសាងសមត្ថភាពពិនិត្យតាមដាននិងវាយតម្លៃ និងប្រព័ន្ធព័ត៌មានស្តីពីការពិនិត្យតាមដាននិងវាយតម្លៃ។ សមាសភាគការពិនិត្យតាមដានចែកចេញជា៣៖ សៀវភៅព័ត៌មានស្តីពីការពិនិត្យតាមដាន ផែនការពិនិត្យតាមដាននិងថវិកា និងតារាងសូចនាករសមិទ្ធកម្ម។ សមាសភាគការវាយតម្លៃរួមមានសៀវភៅព័ត៌មានស្តីពីការវាយតម្លៃ និងផែនការវាយតម្លៃនិងថវិកា។

**រចនាសម្ព័ន្ធស្ថាប័ន៖** ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃត្រូវមានរចនាសម្ព័ន្ធស្ថាប័នអចិន្ត្រៃយ៍អមជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ ក៏ដូចជាតួនាទី និងការទទួលខុសត្រូវចម្បង។ តួអង្គសំខាន់ៗរួមមានគណៈរដ្ឋមន្ត្រី ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសាមី ដៃគូអភិវឌ្ឍន៍ អ្នកវាយតម្លៃនិងទីប្រឹក្សាដែលមានគុណវុឌ្ឍិ និងតំណាងវិស័យឯកជននិងអង្គការមិនមែនរដ្ឋាភិបាល។ ក្រៅពីនេះ គួរមានការបង្កើតគណៈកម្មាធិការដឹកនាំការពិនិត្យតាមដាននិងវាយតម្លៃ ក្រុមការងារពិនិត្យតាមដាននិងវាយតម្លៃ និងលេខាធិការដ្ឋានបច្ចេកទេសផ្នែកការពិនិត្យតាមដាននិងវាយតម្លៃ។

**សម្រាប់ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាស្ថាប័នដឹកនាំកិច្ចខិតខំប្រឹងកែលម្អប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃរបស់ខ្លួន។** ក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា (២០១១)[62] និងគោលការណ៍ណែនាំថវិកាកម្មវិធី (២០១៥)[63] មានផ្នែកមួយស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ។ ទោះជាយ៉ាងណា តាមរយៈអភិក្រមតាមដំណាក់កាលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំណុចផ្តោតសំខាន់បច្ចុប្បន្នគឺការពិនិត្យតាមដានលទ្ធផលរំពឹងទុកក្នុងឆ្នាំ ប៉ុន្តែមិនទាន់មានការផ្តោតសំខាន់លើកម្រិតផលប៉ះពាល់លទ្ធផលចុងក្រោយនោះទេ។ ទិន្នន័យដែលត្រូវបានប្រើប្រាស់សម្រាប់ការពិនិត្យតាមដានជាប្រចាំលើការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាទទួលបានពីរបាយការណ៍ប្រចាំខែ របាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព/លទ្ធផលរំពឹងទុក និងការប្រើប្រាស់ថវិកា។ របាយការណ៍ស្តីពីសកម្មភាព/លទ្ធផលរំពឹងទុក ទទួលបានពីក្រសួងសាមី និងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ។ ទិន្នន័យស្តីពីការប្រើប្រាស់ថវិកាអាចស្រង់ចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ប៉ុន្តែមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ លើកលែងតែរបាយការណ៍សង្ខេប។

[62] MEF (2011) Guideline on preparing Budget Strategic Plan (BSP)
[63] MEF (2015) Guideline on preparing program-based budgets

**ទិន្នន័យជាធាតុផ្សំសំខាន់មួយសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃបានល្អ ប៉ុន្តែមិនមែនជាធាតុផ្សំតែមួយគត់នោះទេ។** ផ្អែកតាមការសិក្សាដែលមានស្រាប់ និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ការសិក្សានេះសន្និដ្ឋានថា មានទិន្នន័យច្រើនបង្គួរដែលត្រូវបានផលិតឡើងសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ទាំងសម្រាប់គោលនយោបាយរយៈពេលវែង ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬគោលនយោបាយរយៈពេលមធ្យម ដូចជា ផែនការយុទ្ធសាស្ត្រថវិកា។ ទោះជាយ៉ាងណាគម្លាតដែលនៅសេសសល់រួមមាន ការសម្របសម្រួលស្ថាប័នសម្រាប់ការចងក្រង និងចែករំលែកទិន្នន័យក្នុងទីភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាល សមត្ថភាពវិភាគទិន្នន័យ និងយន្តការស្ថាប័នដើម្បីកៀរគរលទ្ធផលរកឃើញសំខាន់ៗសម្រាប់អ្នកតាក់តែងគោលនយោបាយ[64]។

វិទ្យាស្ថានជាតិស្ថិតិដែលជាភាគីពាក់ព័ន្ធដ៏សំខាន់ក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិទាំងមូលយល់ច្បាស់ពីបញ្ហាទាំងនេះបាន និងកំពុងខិតខំធ្វើការដោះស្រាយ។ ឧ. ក្រោមការគាំទ្រផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ វិទ្យាស្ថានជាតិស្ថិតិបានបង្កើត និងដាក់ឱ្យប្រើប្រាស់ថ្នាលចែករំលែកទិន្នន័យឌីជីថល (CamStat) តាំងពីឆ្នាំ២០១៩។ CamStat បានផ្តល់ប្រយោជន៍ជាច្រើន ប៉ុន្តែមិនទាន់មានភាពរីកចម្រើននៅឡើយ ព្រោះនៅមានបញ្ហាបច្ចេកទេសជាច្រើនដែលត្រូវដោះស្រាយ (សូមមើលប្រអប់ខាងក្រោម)។ ឧទាហរណ៍មួយទៀតគឺផែនការអនុម័តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ ដើម្បីបង្កើនការផ្សព្វផ្សាយទិន្នន័យ និងទទួលបានយោបល់ត្រឡប់ពីអ្នកប្រើប្រាស់។ ផ្នែកបន្ទាប់ស្តីពីអភិបាលកិច្ចទិន្នន័យ នឹងពិភាក្សាលម្អិតពីចំណុចនេះ។

### ប្រអប់ទី៥៖ CamStat–ការសាកល្បងដែលអាចធ្វើឡើង ប៉ុន្តែមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ

ការចែករំលែក និងគ្រប់គ្រងទិន្នន័យ ជាសមាសភាគចម្បងមួយក្នុងការបង្កើតទំនាក់ទំនងរវាងទិន្នន័យនិងការតាក់តែង និងការពិនិត្យតាមដានគោលនយោបាយនិងផែនការអភិវឌ្ឍន៍។ បច្ចេកវិទ្យាឌីជីថលដើរតួនាទីសំខាន់ក្នុងការបង្កើតទំនាក់ទំនងទាំងនេះ តាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន។ CamStat ជាឧទាហរណ៍មួយដែលបង្ហាញពីដំណើរការខាងលើ។ CamStat ជាវេទិកាអនឡាញដែលប្រមែប្រមូល ទិន្នន័យពីក្រសួងផ្សេងៗ រួចផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ឱ្យសាធារណៈជនទាញយកទៅប្រើប្រាស់។ សូមចូលទៅកាន់៖ http://camstat.nis.gov.kh។

CamStat រួមបញ្ចូលវិស័យចំនួន១២ ដូចជា អប់រំ កសិកម្ម សុខាភិបាលនិងអាហារូបត្ថម្ភ ប្រជាសាស្ត្រ សេដ្ឋកិច្ច បរិស្ថាន អភិបាលកិច្ច គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទេសចរណ៍ ការងារ យេនឌ័រ និងហេដ្ឋារចនាសម្ព័ន្ធ។ ផ្អែកតាមការសាកល្បងដែលបានធ្វើឡើងសម្រាប់

[64] MOP (2015) Summary assessment of the M&E system for NSDP implementation.

ការស្រាវជ្រាវនេះ គឺមិនសូវមានការប្រើប្រាស់ទិន្នន័យស្ដីពីវិស័យទាំង១២ នេះសម្រាប់ការវិភាគនោះទេ។ មានការរកឃើញថា សំណុំទិន្នន័យដែលមានក្នុង CamStat គឺមិនពេញលេញ និងមិនគួរយកទៅប្រើប្រាស់នោះទេ។ CamStat មិនទាន់មានការអភិវឌ្ឍពេញលេញ និងមិនអាចជឿជាក់បានឡើយ។ ខ. នៅតែមានបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងទំហំ និងរចនាបទនៃតួអក្សរ។ សំណុំទិន្នន័យពីវិស័យនានាមិនមានបច្ចុប្បន្នភាព និងរប៉ាត់រប៉ាយ និងអាចមានកំហុសជាច្រើនក្នុងការវាយបញ្ចូល។

## ៣. ៣. ៤ លក្ខណៈសំខាន់ៗនៃដំណើរការគោលនយោបាយនៅកម្ពុជា

បន្ទាប់ពីបានពិពណ៌នាពីដំណើរការគោលនយោបាយនៅកម្ពុជា ផ្នែកនេះនឹងគូសបញ្ជាក់ពីលក្ខណៈសំខាន់ៗជាច្រើន ជាពិសេសលក្ខណៈដែលមិនត្រូវបានលើកឡើងជាលាយលក្ខណ៍អក្សរ។ លក្ខណៈសំខាន់ៗ រួមមានភាពប្រសើរឡើងនៃគុណភាពដំណើរការគោលនយោបាយ សមត្ថកិច្ចកាន់តែធំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ហាប្រឈមក្នុងការសម្របសម្រួលឆ្លងក្រសួង និងផលប៉ះពាល់របស់បណ្ដាញសង្គម និងយុវជនលើការតាក់តែង និងការឆ្លើយតបគោលនយោបាយ។ លក្ខណៈសំខាន់ៗទាំងនេះដែលលេចឡើងក្នុងប្រទេសផ្សេងទៀតផងដែរនោះ គឺជាលក្ខណៈចម្រុះសំខាន់ៗក្នុងការតាក់តែង ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ។ ដូចការបង្ហាញក្នុងផ្នែកទី៤ និងផ្នែកទី៥ លក្ខណៈសំខាន់ៗទាំងនេះក៏ជះឥទ្ធិពលលើរបៀបដែលទិន្នន័យត្រូវបានផលិត ចែករំលែក និងប្រើប្រាស់ក្នុងដំណើរការគោលនយោបាយផងដែរ។

លក្ខណៈសំខាន់ទី១ គឺចេតនាល្អរបស់រដ្ឋាភិបាលក្នុងការខិតខំសម្រេចបានគោលដៅអភិវឌ្ឍន៍ និងបំពេញចំណុចដៅដើម្បីធានាថា កម្ពុជានឹងក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ បើធៀបនឹងទសវត្សរ៍ឆ្នាំ៩០ និងឆ្នាំ២០០០ អាទិភាពគោលនយោបាយត្រូវផ្ដោតកាន់តែខ្លាំងលើការកសាងស្ថាប័នរឹងមាំ ការធ្វើឱ្យប្រព័ន្ធរដ្ឋមានលក្ខណៈផ្លូវការ និងការផ្ដល់គ្រឿងលើកទឹកចិត្តគ្រប់គ្រាន់សម្រាប់កំណែទម្រង់ក្រោមកិច្ចសហការជាមួយភាគីពាក់ព័ន្ធចម្រុះ ដូចជា សង្គមស៊ីវិល វិស័យឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ បញ្ញវន្ត និងដៃគូអភិវឌ្ឍន៍។

**ទីពីរ គុណភាពនៃដំណើរការគោលនយោបាយនៅកម្ពុជាតែងប្រែប្រួល ប៉ុន្តែមានភាពប្រសើរឡើង។** ភាពប្រសើរឡើងនេះគឺមួយផ្នែកកើតចេញពីកត្តាចម្បងចំនួន២៖ កំណែទម្រង់ជាច្រើនដែលត្រូវបានអនុវត្ត និងការកើនឡើងនៃចំនួនយុវជន និងអ្នកជំនាញដែលគ្រប់គ្រងដំណើរការនេះ។ កត្តាទាំងពីរនេះ ត្រូវបានកត់សម្គាល់ទូទាំងរដ្ឋាភិបាល ជាពិសេសក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានក្លាយជាមជ្ឈមណ្ឌលកំណែទម្រង់ និងដោយសារតែក្រសួងនេះអាចកៀរគរធនធានទាំងពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ដើម្បីទ្រទ្រង់

សកម្មភាពកំណែទម្រង់ និងជាពិសេសទាក់ទាញ និងផ្តល់ការលើកទឹកចិត្តដល់អ្នកជំនាញវ័យក្មេង ដែលភាគច្រើនបញ្ចប់ការសិក្សាពីបរទេស។

**លក្ខណៈសំខាន់ទី៣ គឺសមត្ថកិច្ចកាន់តែធំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងបញ្ហាគោលនយោបាយ។** បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាក្រសួងតែមួយគត់ដែលមានឥទ្ធិពលខ្លាំងជាងគេក្នុងប្រទេសកម្ពុជា ទាំងតាមការរៀបចំ និងការទុកឱ្យកើតឡើងតាមដំណើរ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានអាណត្តិដឹកនាំការតាក់តែងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ខណៈដែលក្រសួងផែនការមានតួនាទីសម្របសម្រួល។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏មានឥទ្ធិពលលើរបៀបវារៈគោលនយោបាយរបស់ក្រសួងសាមីផងដែរ មួយផ្នែកគឺដោយសារតែក្រសួងនេះមានតួនាទីត្រួតពិនិត្យគោលនយោបាយទាំងនោះ និងមួយផ្នែកទៀតគឺដោយសារតែក្រសួងនេះមានឥទ្ធិពលលើវិភាជ និងការចរចាថវិកា។ ដោយសារតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបានទំនុកចិត្តកាន់តែច្រើនឡើងពីរាជរដ្ឋាភិបាល ធ្វើឱ្យក្រសួងនេះមានឥទ្ធិពលជាងក្រសួងផ្សេងទៀត។ របាយការណ៍នេះនឹងបង្ហាញព័ត៌មានបន្ថែមស្តីពីឌីណាមិកអំណាចនេះ ក្នុងករណីដែលពាក់ព័ន្ធ។

**លក្ខណៈសំខាន់ទីបួន គឺបញ្ហានៃការសម្របសម្រួលឆ្លងក្រសួង។** នៅកម្ពុជា ការតាក់តែង ការអនុវត្ត និងការវាយតម្លៃគោលនយោបាយឆ្លងវិស័យគឺជាកិច្ចការដ៏លំបាក។ គោលនយោបាយទាំងនេះសំដៅលើគោលនយោបាយដែលពាក់ព័ន្ធនឹងអាណត្តិរបស់ក្រសួងលើសពី ១។ គោលនយោបាយតាមវិស័យមួយចំនួន ដូចជា វិមជ្ឈការ និងកិច្ចគាំពារសង្គម ត្រូវបានអនុម័តដោយប្រើប្រាស់យន្តការអន្តរក្រសួង ប៉ុន្តែការអភិវឌ្ឍគោលនយោបាយតាមវិស័យផ្សេងទៀត ដូចជា គោលនយោបាយស្តីពីអភិបាលកិច្ចភស្តុភារ ថាមពល និងទឹក គឺជាកិច្ចការកាន់តែលំបាក។ យោងតាមបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ បញ្ហានេះគឺបណ្តាលមកពីកង្វះការលើកទឹកចិត្តឱ្យក្រសួងនានាចូលរួមក្នុងក្នុងដំណើរការនេះ។ ទីមួយ គោលនយោបាយតាមវិស័យដែលខុសពីគោលនយោបាយរបស់ក្រសួង មិនមែនជាលក្ខខណ្ឌចម្បងមួយសម្រាប់ឱ្យក្រសួងទទួលបានថវិការបស់ខ្លួននោះទេ។ ទីពីរ ការចូលរួមក្នុងអាណត្តិឆ្លងក្រសួង អាចមានន័យស្មើនឹងក្រសួងនានាប្រជែងគ្នាលើអាណត្តិ និងធនធាន។ ទីបី ជារឿយៗ ទំនាក់ទំនងអំណាចក្នុងចំណោមក្រសួងសាមី នាំឱ្យមានភាពអសកម្ម លុះត្រាតែក្រសួងណាមួយមានសមត្ថកិច្ចលើសក្រសួងផ្សេងទៀត។

**ការប្រើប្រាស់បណ្តាញសង្គម និងការចូលរួមរបស់យុវជនក្នុងប្រព័ន្ធអ៊ីនធឺណិត ជាកត្តាមួយផ្សេងទៀតដែលជះឥទ្ធិពលលើលក្ខណៈនៃដំណើរការគោលនយោបាយនៅកម្ពុជា។** ការកើនឡើងយ៉ាងឆាប់រហ័សនៃអត្រាប្រើប្រាស់អ៊ីនធឺណិត គឺជាកាតាលីកររចម្បង។ គិតត្រឹមខែមករា ឆ្នាំ ២០២០ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា មានចំនួន ៩,៧លាននាក់ និងកើនដល់ ១៥,៥លាននាក់នៅខែមីនាឆ្នាំ២០២១ មួយផ្នែកគឺដោយសារតែវិបត្តិកូវីដ-១៩ និងការរឹតត្បិតការ

ធ្វើដំណើរ[65]។ យុវជនជាអ្នកចូលរួមដ៏សកម្មបំផុតក្នុងបណ្ដាញអ៊ីនធឺណិត និងជាអ្នកប្រើប្រាស់បណ្ដាញសង្គមយ៉ាងសកម្មផងដែរ។ ក្នុងចំណោមកត្តាផ្សេងទៀត ការបង្ហោះសារ/ព័ត៌មានក្នុងបណ្ដាញសង្គម បាននាំឱ្យមានការបង្ហាញពីព័ត៌មានសាធារណៈបច្ចុប្បន្នភាព និងយោបល់ត្រឡប់លើបញ្ហាសាធារណៈ។ អ្វីដែលសំខាន់ជាងនេះ គឺបណ្ដាញសង្គមអាចផ្សព្វផ្សាយព័ត៌មានភ្លាមៗដល់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល។ ដូច្នេះ បណ្ដាញសង្គមមានប្រសិទ្ធភាពបំផុតក្នុងការទាក់ទាញចំណាប់អារម្មណ៍ និងការឆ្លើយតបពីរដ្ឋាភិបាល។

65 https://www.phnompenhpost.com/national/kingdoms-internet-demands-amid-COVID-19-restrictions

# ៤. អភិបាលកិច្ចទិន្នន័យសម្រាប់គោលបំណងគោលនយោបាយនៅកម្ពុជា

**ក្នុងយុគសម័យឌីជីថល ទិន្នន័យបានក្លាយជាធាតុផ្សំកាន់តែសំខាន់សម្រាប់គោលបំណងគោលនយោបាយ។** ផ្អែកតាមកិច្ចពិភាក្សាក្នុងផ្នែកមុន ផ្នែកនេះនឹងបង្ហាញលម្អិតពីចម្ងល់ពាក់ព័ន្ធនឹងថាតើទិន្នន័យត្រូវបានផលិត ចែករំលែក និងប្រើប្រាស់ដោយរបៀបណាដោយតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ ផ្នែកនេះចាប់ផ្តើមពីទស្សនាទានសំខាន់ៗដែលពាក់ព័ន្ធនឹងទិន្នន័យ និងតួនាទីរបស់ទិន្នន័យក្នុងការអភិវឌ្ឍនិងក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនៅកម្ពុជា។ បន្ទាប់មក ផ្នែកនេះផ្តោតសំខាន់លើតួនាទី និងបញ្ហាប្រឈមរបស់តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក្នុងការផលិត និងប្រើប្រាស់ទិន្នន័យ។

## ៤.១ ក្របខ័ណ្ឌទស្សនាទាន និងក្របខ័ណ្ឌគោលនយោបាយ

### ៤.១.១ ក្របខ័ណ្ឌទស្សនាទាន

ការយល់ដឹងផ្នែកទស្សនាទានដំបូងបង្អស់ស្តីពីទិន្នន័យ គឺនិយមន័យ ប្រភេទ និងវដ្តជីវិតរបស់ទិន្នន័យ។ ផ្អែកតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១ ទិន្នន័យសំដៅលើ "ព័ត៌មានស្តីពីមនុស្ស វត្ថុ និងប្រព័ន្ធនានា"។ ទិន្នន័យមានទាំងបែបគុណភាព និងបែបបរិមាណ និងអាចរក្សាទុកក្នុងព័ត៌មានទម្រង់ឌីជីថល ឬទម្រង់អាណាឡូក។ គេអាចបែងចែកប្រភេទទិន្នន័យដោយប្រើប្រាស់ទិដ្ឋភាព២។

ទីមួយ ផ្អែកតាមគោលបំណងនៃទិន្នន័យ គេអាចចែកចេញជាទិន្នន័យសម្រាប់គោលបំណងសាធារណៈ ឬទិន្នន័យសម្រាប់គោលបំណងឯកជន (ឧ. សម្រាប់គោលបំណងពាណិជ្ជកម្ម)។ ក្នុងទិដ្ឋភាពមួយទៀត ទិន្នន័យត្រូវបានចែកជាប្រភេទទៅតាមការប្រើប្រាស់មធ្យោបាយប្រមូលបែបប្រពៃណី ឬមធ្យោបាយប្រមូលថ្មី។ ទិន្នន័យមានវដ្តជីវិត ដូចតទៅ៖ បង្កើត/ទទួលបាន ដំណើរការរក្សាទុក ផ្ទេរ/ចែករំលែក វិភាគ/ប្រើប្រាស់ សម្រេចបាន/រក្សាទុក (និងពេលខ្លះ បំផ្លាញចោល)។

## រូបភាពទី៣៖ មធ្យោបាយចំនួន៣ សម្រាប់ពង្រឹងការអភិវឌ្ឍទិន្នន័យ [66]




**ទិន្នន័យអាចទ្រទ្រង់ដល់ការអភិវឌ្ឍ តាមវិធី ៣យ៉ាង។** យោងតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១ (មានបង្ហាញក្នុងរូបភាពខាងក្រោម) វិធីកណ្តាលគឺទិន្នន័យដែលត្រូវបានផលិត ឬទទួលបានដោយរដ្ឋាភិបាល និងអង្គការអន្តរជាតិដើម្បីគាំទ្រដល់ការគ្រប់គ្រងទិន្នន័យការផ្តល់សេវានិងការតាក់តែងគោលនយោបាយផ្អែកតាមភស្តុតាង។វិធីផ្នែកខាងលើគឺទិន្នន័យដែលត្រូវបានផលិត និងប្រើប្រាស់ដោយសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវ ដើម្បីត្រួតពិនិត្យនិងវិភាគផលប៉ះពាល់នៃកម្មវិធី និងគោលនយោបាយរបស់រដ្ឋាភិបាល និងទិន្នន័យដែលត្រូវបានផលិត និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ដើម្បីបង្កើនសិទ្ធិអំណាចផ្ទាល់ខ្លួន និងអាចឱ្យពួកគេទទួលបានសេវាសាធារណៈ និងសេវាក្នុងទ្រង់ទ្រាយធំដែលត្រូវបានកែសម្រួលទៅតាមតម្រូវការរបស់ពួកគេ។

វិធីផ្នែកខាងក្រោមគឺទិន្នន័យដែលត្រូវបានផលិតដោយក្រុមហ៊ុនឯកជន។ ទិន្នន័យអាចត្រូវបានប្រើប្រាស់ឡើងវិញ ចែករំលែក និងកំណត់គោលបំណងឡើងវិញសម្រាប់វិធីទាំង៣ នេះ។ តួអង្គទាំងអស់ (ទាំងតួអង្គរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាល) ដែលចូលរួមក្នុងការផលិត និងប្រើប្រាស់ទិន្នន័យ និងទាញប្រយោជន៍ពីទិន្នន័យដែលមាន ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិភាគ និងដំណើរការទិន្នន័យ។

**ទិន្នន័យ ជាពិសេសទិន្នន័យសម្រាប់គោលបំណងសាធារណៈ បង្កផលប៉ះពាល់ដោយផ្ទាល់លើដំណើរការ និងការរៀបចំគោលនយោបាយ។** របាយការណ៍នេះផ្តោតចម្បងលើទិន្នន័យសម្រាប់គោលបំណងសាធារណៈ ទោះបីជាក្នុងករណីខ្លះ អាចមានការពិភាក្សាពីទិន្នន័យសម្រាប់គោលបំណងឯកជនក៏ដោយ។ យោងតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោក ទិន្នន័យសម្រាប់គោលបំណងសាធារណៈចែកចេញជា៦ប្រភេទ៖ ទិន្នន័យរដ្ឋបាល ជំរឿន អង្កេតសំណាក ទិន្នន័យដែល

[66] World Bank (2021) WDR 2021 – Data for better lives.

ផលិតដោយប្រជាពលរដ្ឋ ទិន្នន័យផលិតដោយកុំព្យូទ័រ និងទិន្នន័យភូមិសាស្ត្រ (geospatial)។ ទិន្នន័យសម្រាប់គោលបំណងសាធារណៈ អាចរួមចំណែកដល់ការអភិវឌ្ឍតាមវិធី ៣យ៉ាង ៖ ១) ការបង្កើនការផ្តល់សេវា ២) ការផ្តោតអាទិភាពលើធនធានកម្រ និង ៣) ការរក្សាការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងការបង្កើនសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ។

គេអាចដោះស្រាយបញ្ហាគម្លាតក្នុងទិន្នន័យសម្រាប់គោលបំណងសាធារណៈ និងមូលហេតុដែលនាំឱ្យមានគម្លាតទាំងនោះ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជា ការគ្របដណ្តប់ (កង្វះភាពទាន់ពេលវេលា ភាពញឹកញាប់ និងភាពពេញលេញ) គុណភាព (កង្វះភាពពិស្តារ សុក្រឹតភាព និងភាពអាចប្រៀបធៀបបាន) និងភាពងាយស្រួលក្នុងការប្រើប្រាស់ (កង្វះការបង្កភាពងាយស្រួល ភាពអាចយល់បាន និងអន្តរប្រតិបត្តិការ) និងសុវត្ថិភាពក្នុងការប្រើប្រាស់ (កង្វះភាពមិនលម្អៀង ការរក្សាការសម្ងាត់ និងភាពសមស្របសម្រាប់ការអភិវឌ្ឍ)។ ឫសគល់ទូទៅដែលបង្កឱ្យមានគម្លាតទិន្នន័យទាំងនេះ រួមមានកង្វះហិរញ្ញប្បទាន សមត្ថភាពផ្នែកបច្ចេកទេស អភិបាលកិច្ចទិន្នន័យ (ជាពិសេសការិយាល័យស្ថិតិជាតិដែលមានសមត្ថភាពខ្ពស់) និងកង្វះតម្រូវការទិន្នន័យ។

### ប្រអប់ទី៦៖ ចំណេះដឹងជាសកលស្តីពីទិន្នន័យ វិស័យឯកជន និងការអភិវឌ្ឍ[67]

**អាជីវកម្មនៅជុំវិញពិភពលោក បាន និងកំពុងប្រើប្រាស់ទិន្នន័យជាកត្តាផលិតកម្ម និង/ឬកត្តាបង្កើនផលិតភាព។** ទិន្នន័យគឺជាកត្តាផលិតកម្មដ៏សំខាន់សម្រាប់ក្រុមហ៊ុនបណ្តាញសង្គម ដូចជា Facebook និង Google ដូចកម្លាំងពលកម្ម មូលធន និងដីដែរ។ សម្រាប់ប្រភេទអាជីវកម្មផ្សេងទៀត ទិន្នន័យត្រូវបានចាត់ទុកជាចលករនៃកត្តាផលិតភាពសរុប (TFP)។ ក្នុងករណីនេះ ទិន្នន័យត្រូវបានប្រើប្រាស់ដើម្បីបង្កើនដំណើរការអាជីវកម្ម ស្វែងយល់កាន់តែច្បាស់ពីអតិថិជន និងក្រុមហ៊ុនផ្គត់ផ្គង់ អភិវឌ្ឍផលិតផលថ្មី និងធ្វើការសម្រេចចិត្តកាន់តែប្រសើរ។ ក្នុងករណីមួយចំនួនផ្សេងទៀត ទិន្នន័យត្រូវបានចាត់ទុកជាង អនុផលនៃសកម្មភាពសេដ្ឋកិច្ចឌីជីថល ដូចជា ព័ត៌មានទំនាក់ទំនងលម្អិត (call detail) គំរូនៃការបញ្ជាទិញ កំណត់ត្រាឥណទាន។ល។ វិស័យដែលទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីទិន្នន័យ (ជាពិសេសក្នុងទម្រង់ជាទិន្នន័យ Big Data) រួមមានហិរញ្ញវត្ថុ កសិកម្ម សុខាភិបាល អប់រំ ដឹកជញ្ជូន និងភស្តុភារ និងការធ្វើទីផ្សារតាមបណ្តាញសង្គម។

**ការប្រើប្រាស់ទិន្នន័យក្នុងក្រុមហ៊ុនឯកជន អាចជួយដល់ការអភិវឌ្ឍ ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនផងដែរ។** ចំណុចនេះអាចកើតឡើងតាម ៤វិធី៖ ១) ការបង្កើនគុណភាពនៃសេវាសាធារណៈដែលមានស្រាប់ ២) ការកាត់បន្ថយចំណាយលើការផ្តល់សេវាសាធារណៈទាំងនោះ

[67] World Bank (2021) WDR on Data for Better Lives

៣) ការផ្សព្វផ្សាយនវានុវត្តន៍សាធារណៈ និងសេវាថ្មីៗ និង ៤) អន្តរការីកម្មកាន់តែមានប្រសិទ្ធភាព និងការកាត់បន្ថយចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណា វាអាចបង្កើនវិសមភាពគ្រួសារ ក្នុងករណីដែលមិនសូវមានជំនាញជាមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងហិរញ្ញវត្ថុនៅក្នុងប្រទេស។ ការប្រើប្រាស់ទិន្នន័យដោយអាជីវកម្ម ក៏អាចធ្វើឱ្យប្រទេសក្រីក្រចាញ់ប្រៀបផងដែរ ដោយសហគ្រាសក្នុងស្រុកអាចមានការលំបាកក្នុងការប្រជែងជាមួយក្រុមហ៊ុនធំៗក្នុងពិភពលោក មួយផ្នែកគឺដោយសារតែសេដ្ឋកិច្ចវិមាត្រ និងវិសាលភាពពីទិន្នន័យ។

តួនាទីកាន់តែសំខាន់របស់ទិន្នន័យក្នុងគំរូអាជីវកម្មថ្នាលបច្ចេកវិទ្យា ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ កំពុងជះឥទ្ធិពលលើការប្រកួតប្រជែង ពាណិជ្ជកម្ម និងពន្ធដារក្នុងសេដ្ឋកិច្ចជាក់ស្តែង ដោយបានបង្កហានិភ័យធំៗសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ វិធីដែលប្រទេសនានារៀបចំវិធានការធានាសុវត្ថិភាព និងកត្តាអំណោយផលសម្រាប់ទិន្នន័យ នឹងបង្កផលប៉ះពាល់ដោយប្រយោលលើសេដ្ឋកិច្ចជាក់ស្តែង។ ឧ. ការជំរុញការចែករំលែកទិន្នន័យក្នុងចំណោមតួអង្គក្នុងទីផ្សារ អាចដើរតួនាទីយ៉ាងសំខាន់សម្រាប់ការបង្កើនការប្រកួតប្រជែង។ ទន្ទឹមនឹងនេះ ភាពតឹងរ៉ឹងនៃការធានាសុវត្ថិភាពទិន្នន័យ នឹងជះឥទ្ធិពលលើគំរូនៃការធ្វើពាណិជ្ជកម្មឆ្លងដែន សម្រាប់សេវាដែលទ្រទ្រង់ដោយទិន្នន័យ។ ដូចគ្នានេះដែរ ភាពអរូបីនៃសង្វាក់តម្លៃទិន្នន័យ កំពុងបង្កបញ្ហាប្រឈមធំៗសម្រាប់ការប្រមូលចំណូលពន្ធ។

ជាទូទៅ ប្រទេសកំពុងអភិវឌ្ឍន៍មិនសូវមានសមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រងបញ្ហាប្រឈមផ្នែកគោលនយោបាយសេដ្ឋកិច្ចដែលបង្កឡើងដោយសេដ្ឋកិច្ចដែលផ្អែកលើទិន្នន័យឡើយ។ ប្រឈមនឹងបញ្ហាទាំងនេះ ចាំបាច់ត្រូវមានការរៀបចំគោលនយោបាយប្រកួតប្រជែង និងការគ្រប់គ្រងពាណិជ្ជកម្ម និងពន្ធដារឱ្យបានឆាប់រហ័សបំផុត។

អ្វីដែលធ្វើឱ្យមានបញ្ហាកាន់តែស្មុគស្មាញគឺ គោលនយោបាយស្តីពីការប្រកួតប្រជែង ពាណិជ្ជកម្ម និងពន្ធដារ មានភាពប្រទាក់ក្រឡាគ្នាបំផុត។ វិធានការសម្របសម្រួលជាអន្តរជាតិ ដូចជា ការពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការប្រកួតប្រជែងមិនស្មើភាព បទបញ្ញត្តិសម្រាប់ក្រុមហ៊ុនថ្នាលបច្ចេកវិទ្យា ស្តង់ដារទិន្នន័យ កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងគោលនយោបាយពន្ធ ជាកត្តាសំខាន់សម្រាប់ការធានាបាននូវគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងសមធម៌សម្រាប់សេដ្ឋកិច្ចទិន្នន័យដែលឆ្លើយតបនឹងតម្រូវការ និងផលប្រយោជន៍របស់ប្រទេស។

### ៤.១.២ ក្របខ័ណ្ឌគោលនយោបាយ

គោលនយោបាយចំនួន៤ នៅកម្ពុជាគឺមានភាពពាក់ព័ន្ធ និងសំខាន់បំផុតសម្រាប់ការលើកកម្ពស់ការប្រើប្រាស់ទិន្នន័យក្នុងគោលនយោបាយសាធារណៈ។ គោលនយោបាយទាំងនោះរួមមាន ១) យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) ២) ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥) ៣) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ៤) កំណែទម្រង់វិមជ្ឈការ។ ក្រោមជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ គោលនយោបាយទាំងនេះត្រូវបានផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល និងត្រូវបានរៀបចំឡើងដោយយកលំនាំតាមការអនុវត្តជាអន្តរជាតិ។

**យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) ជាគោលនយោបាយពាក់ព័ន្ធនឹងទិន្នន័យ និងស្ថិតិជាតិ។** យុទ្ធសាស្ត្រនេះមានគោលបំណងកសាងប្រព័ន្ធស្ថិតិជាតិ (NSS) ដែលអាចសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការបែបសត្យានុម័ត និងមានគុណភាពខ្ពស់ដើម្បីជាជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ការជជែកដេញដោល និងកិច្ចពិភាក្សាក្នុងជួររដ្ឋាភិបាល (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) អាជីវកម្ម និងប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល និងសហគមន៍អន្តរជាតិ។ យុទ្ធសាស្ត្រនេះយកលំនាំតាមគោលការណ៍ណែនាំដែលចេញដោយលេខាធិការដ្ឋានប៉ារីស២១ របស់ OECD[68]។ ដៃគូអភិវឌ្ឍន៍ជាច្រើនបានគាំទ្រដល់កំណែទម្រង់ស្ថិតិនៅកម្ពុជា មានជាអាទិ៍ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងប៉ារីស២១ របស់ OECD។ យុទ្ធសាស្ត្រនេះក៏ពាក់ព័ន្ធនឹងការងារស្ថិតិរបស់អាស៊ានផងដែរ (នឹងលើកមកពិភាក្សាក្នុងផ្នែកបន្ទាប់)[69]។

មានការរៀបចំជាស្រេចនូវក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌស្ថាប័នជាក់លាក់មួយដើម្បីធានាថា ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជាមានប្រសិទ្ធភាព។ និយមន័យនៃប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា ត្រូវបានកំណត់ក្នុងច្បាប់ស្តីពីស្ថិតិ (២០១៥) និងអនុក្រឹត្យចំនួន២[70]។ ក្របខ័ណ្ឌគតិយុទ្ធនេះគូសបញ្ជាក់ពីតួអង្គសំខាន់ៗក្នុងប្រព័ន្ធស្ថិតិជាតិក្នុងនាមជាអ្នកផលិតទិន្នន័យ អ្នកជំរុញប្រព័ន្ធ និងអ្នកប្រើប្រាស់ទិន្នន័យ ចំណែកដៃគូអភិវឌ្ឍន៍ដើរតួនាទីជាអ្នកទ្រទ្រង់ទិន្នន័យ។ សូមមើលដ្យាក្រាមខាងក្រោម។ តួអង្គសំខាន់ៗក្នុងរដ្ឋាភិបាល រួមមានវិទ្យាស្ថានជាតិស្ថិតិ ក្រសួងសាមីុ និងទីភ្នាក់ងារ និងធនាគារជាតិនៃកម្ពុជា។ ទោះបីជាមានវឌ្ឍនភាពជាច្រើនក៏ដោយ ប៉ុន្តែនៅតែមានបញ្ហាប្រឈមធំៗដែលរារាំងដល់ការពន្លឿនប្រព័ន្ធស្ថិតិជាតិ ដូចជា កង្វះការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ កង្វះហិរញ្ញប្បទាន សមត្ថភាពបច្ចេកទេស និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍[71]។

---

68 សូមចូលទៅកាន់៖ https://paris21.org/about-paris21

69 RGC (2018) National Strategy for the Development of Statistics (NSDS) (2019-2023)

70 អនុក្រឹត្យទាំង២ នោះគឺ ១) អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធស្ថិតិជាតិ (២០០៧) និង ២) អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង (២០១០)។

71 RGC (2018) National Strategy for the Development of Statistics (NSDS) (2019-2023)

រូបភាពទី៤៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា[72]




**គោលនយោបាយដ៏សំខាន់មួយទៀតគឺក្របខ័ណ្ឌសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥)**។ គោលនយោបាយនេះត្រូវបានតាក់តែងឡើងក្នុងបរិបទនៃឌីជីថលូបនីយកម្មឆាប់រហ័ស និងវិបត្តិកូវីដ-១៩ និងការស្តារឡើងវិញ។ ចក្ខុវិស័យនៃគោលនយោបាយនេះគឺ "ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ ពលរដ្ឋ និងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លងប្រក្រតីភាពថ្មី"។ ទោះបីជាមានការលើកឡើងពីទិន្នន័យក្នុងឯកសារគោលនយោបាយនេះក៏ដោយ ប៉ុន្តែសារៈសំខាន់របស់ទិន្នន័យត្រូវបានគូសបញ្ជាក់ជាពិសេសក្នុងផ្នែក "រដ្ឋាភិបាលឌីជីថល" ជាមួយនឹងផ្នែកដោយឡែកមួយស្តីពី "អភិបាលកិច្ចផ្អែកលើទិន្នន័យ"។

ក្នុងគោលនយោបាយនេះ "អភិបាលកិច្ចផ្អែកលើទិន្នន័យ" ផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវការផលិតទិន្នន័យ ការចែករំលែកទិន្នន័យ និងទិន្នន័យ Big Data។ គោលនយោបាយនេះមានគោលបំណង ១) បង្កើតថ្នាលឌីជីថលសម្រាប់ការរក្សាទុក និងការចែករំលែកទិន្នន័យរដ្ឋាភិបាលប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ២) បង្កើតសេវា និងលើកកម្ពស់ការប្រើប្រាស់សេវាឌីជីថលក្នុងក្រសួងសាម៉ី វិស័យឯកជន និងក្នុងចំណោមប្រជាពលរដ្ឋ និង ៣) កសាងប្រព័ន្ធអភិបាលកិច្ចផ្អែកតាមទិន្នន័យដែលបង្កើនប្រសិទ្ធភាព និងតម្លាភាពក្នុងកិច្ចការសាធារណៈ។ សមាសភាគផ្អែកតាមទិន្នន័យ មានវិធានការគោលនយោបាយចំនួន១០ ដែលដឹកនាំជាចម្បងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រួមជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និង

[72] RGC (2018) National Strategy for the Development of Statistics (NSDS) (2019-2023)

ក្រសួងសាមីៗ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា និងគណៈកម្មាធិការផ្សេងៗត្រូវបានបង្កើតឡើងសម្រាប់ការអនុវត្តគោលនយោបាយនេះ ដោយមានការចូលរួមពីតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ[73]។

**កម្មវិធីកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈជាគោលនយោបាយទី៣ ដែលគូសបញ្ជាក់ពីភាពចាំបាច់នៃការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរក្នុងដំណើរការគោលនយោបាយ។** ដោយត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៤ កម្មវិធីកែទម្រង់នេះប្រើប្រាសអភិក្រមជាជំហានដើម្បីបង្កើន ១) ភាពអាចជឿទុកបាននៃថវិកា ២) គណនេយ្យភាពហិរញ្ញវត្ថុ ៣) ភាពពាក់ព័ន្ធរវាងគោលនយោបាយ និងថវិកា និង ៤) គណនេយ្យភាពសមិទ្ធកម្ម។ បច្ចុប្បន្ន កម្មវិធីនេះស្ថិតក្នុងជំហានទី៣ (ភាពពាក់ព័ន្ធរវាងគោលនយោបាយ និងថវិកា) ដែលផ្តោតសំខាន់លើការកែលម្អការរៀបចំផែនការការអនុវត្ត និងការពិនិត្យតាមដាននិងវាយតម្លៃថវិកា ដោយប្រើប្រាស់អភិក្រមរៀបចំថវិកាផ្អែកតាមកម្មវិធី។ អ្វីដែលសំខាន់គឺការរៀបចំថវិកាកម្មវិធី ទាមទារការប្រើប្រាស់ទិន្នន័យជាប្រព័ន្ធសម្រាប់ដំណើរការគោលនយោបាយទាំងមូល ដោយចាប់ផ្តើមពីការតាក់តែងរហូតដល់ការពិនិត្យតាមដាននិងវាយតម្លៃ[74]។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតួអង្គចម្បងក្នុងការអនុវត្តកម្មវិធីកែទម្រង់នេះ និងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងគោលនយោបាយ និងការគ្រប់គ្រងសារពើពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវលើការកំណត់វិធាន និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងការរៀបចំផែនការថវិការយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី ការអនុវត្តថវិកា និងការវាយតម្លៃផលប៉ះពាល់នៃការចំណាយថវិកា។ ផ្អែកតាមបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ រដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការពិនិត្យតាមដាន និងវាយតម្លៃ (ជាពិសេសការវាយតម្លៃ) ដូច្នេះ ទាមទារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រើប្រាស់ទិន្នន័យថវិកាដែលមានស្រាប់ឱ្យកាន់តែប្រសើរ ដែលទិន្នន័យទាំងនេះអាចទាញយកពីប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)[75] និងបង្កើតនាយកដ្ឋានមួយសម្រាប់ទទួលខុសត្រូវលើការពិនិត្យតាមដាន និងវាយតម្លៃ[76]។

កម្មវិធីកែទម្រង់ទី៤ គឺកម្មវិធីកែទម្រង់វិមជ្ឈការ។ ការលើកឡើងពីគោលនយោបាយនេះគឺដោយសារតែវាពាក់ព័ន្ធដោយផ្ទាល់នឹងតួនាទីរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដែលមានសមាសភាគយ៉ាងច្រើនក្នុងវិស័យសាធារណៈ។ យោងតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) កំណែទម្រង់នេះលើកកម្ពស់ការផលិត និងប្រើប្រាស់ប្រភេទទិន្នន័យផ្សេងៗ ដើម្បីជានាការរៀបចំផែនការដោយមានការចូលរួម និងចំគោលដៅ វិភាជថវិកា

[73] RGC (2021) Cambodia digital economy and society policy framework.
[74] សម្រាប់ព័ត៌មានបន្ថែមស្តីពី PFMRP សូមចូលទៅកាន់៖ http://www.pfm.gov.kh/index.php/km/about-pfm-kh/pfmback_ground-kh
[75] សម្រាប់ព័ត៌មានបន្ថែមស្តីពី FMIs សូមចូលទៅកាន់៖ https://fmis.mef.gov.kh/
[76] បទសម្ភាសន៍ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

តម្លាភាព និងដំណើរការគណនេយ្យភាព[77]។ ក្នុងផ្នែកទី៥ កំណែទម្រង់វិមជ្ឈការនឹងត្រូវបានបង្ហាញឡើងជាករណីសិក្សាមួយស្តីពីដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ។

## ៤.២ រដ្ឋាភិបាលក្នុងនាមជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យ

### ៤.២.១ ការអនុវត្ត និងវឌ្ឍនភាពនាពេលបច្ចុប្បន្ន

រដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិដែលចូលរួមសហការ សុទ្ធតែជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យធំបំផុតក្នុងដំណើរការគោលនយោបាយ។ ដូចប្រទេសផ្សេងទៀតដែរ ប្រភពចម្បងនៃទិន្នន័យសម្រាប់គោលបំណងសាធារណៈនៅកម្ពុជាគឺជំរឿន និងអង្កេតដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងទិន្នន័យរដ្ឋបាលដែលផលិតដោយក្រសួងសាម៉ី (ភាគច្រើនគឺត្រូវបានផលិតឡើងរៀងរាល់ឆ្នាំ ប៉ុន្តែពេលខ្លះ ក៏ត្រូវបានផលិតឡើងរៀងរាល់ត្រីមាស និងរៀងរាល់ខែផងដែរ)។

តារាងខាងក្រោមផ្តល់ឧទាហរណ៍នៃទិន្នន័យដែលកំពុងត្រូវបានផលិត ចែករំលែក និងប្រើប្រាស់ក្នុងប្រព័ន្ធស្ថិតិជាតិ។

តារាងទី៤៖ ឧទាហរណ៍នៃទិន្នន័យដែលត្រូវបានផលិត និងប្រើប្រាស់ក្នុងវិស័យសាធារណៈនៅកម្ពុជា[78]

| ប្រភេទ/ចំណងជើងនៃផលិតផលទិន្នន័យ | ឆ្នាំ/ប្រភព |
|---|---|
| ជំរឿន និងអង្កេត | |
| ជំរឿនប្រជាជនកម្ពុជា | ២០០៨ ២០១៩ |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) | រៀងរាល់ឆ្នាំ តាំងពីឆ្នាំ២០០៧ |
| អង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជា (CDHS) | ២០០៥ ២០១០ ២០១៥ (ជាមួយ MOH) |
| អំពើហិង្សាលើកុមារ | ២០១៣ (ជាមួយ MOH) |
| អង្កេតស្តីពីកម្លាំងពលកម្ម | ២០១៩ |
| អង្កេតស្តីពីការវិនិយោគផ្ទាល់ពីបរទេស | NBC |
| ទិន្នន័យរដ្ឋបាល | |
| ស្ថិតិ និងសូចនាករអប់រំប្រចាំឆ្នាំ | MOEYS |
| ស្ថិតិសុខភាពប្រចាំឆ្នាំ | MOH |

[77] RGC (2021) National Program for Sub-National Democratic Development (NP-SNDD) Phase 2.
[78] RGC (2018) National Strategy for the Development of Statistics (NSDS) (2019-2023)

| | |
|---|---|
| កុមារកំព្រា និងកុមាររងាយរងគ្រោះក្នុងមណ្ឌលថែទាំ | MOSVY |
| ទិន្នន័យស្តីពីការរៀបចំផែនការ និងការអនុវត្តថវិកា | លើក្រដាសស្នាម និងក្នុង FMIS |
| ទិន្នន័យទេសចរណ៍ | MOT |
| ប្រភេទទិន្នន័យផ្សេងទៀត | |
| មូលដ្ឋានទិន្នន័យឃុំ | MOP, NCDD-S |
| ទិន្នន័យគ្រួសារក្រីក្រ | MOP |

**ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើការផលិត និងប្រើប្រាស់ទិន្នន័យក្នុងវិស័យសាធារណៈនៅកម្ពុជា។** អ្នកផ្តល់ព័ត៌មានសំខាន់ទាំងអស់ដែលត្រូវបានសម្ភាសន៍ សុទ្ធតែឯកភាពនឹងលទ្ធផលរកឃើញនេះ។ វឌ្ឍនភាពដែលបានកត់សម្គាល់រួមមានជំរឿនជាប់លាប់និងកាន់តែមានគុណភាព ការអង្កេតទិន្នន័យរដ្ឋបាលនិងទិន្នន័យថវិកាដែលផលិតដោយតួអង្គរដ្ឋ និងការផ្សព្វផ្សាយកាន់តែប្រសើរស្តីពីទិន្នន័យផ្លូវការ (ទោះបីជាមានកម្រិត) ដោយរដ្ឋាភិបាល។

ឧទាហរណ៍រួមមានការកើនឡើងនៃចំនួនទិន្នន័យដែលបានបង្ហោះក្នុងគេហទំព័រ និងទំព័រ Facebook របស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាមី និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ មានគំនិតផ្តួចផ្តើមក្នុងការធ្វើឱ្យការប្រមូល និងការចែករំលែកទិន្នន័យមានលក្ខណៈឌីជីថល ដូចជា CamStat ដែលដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ (ត្រូវបានលើកមកពិភាក្សាក្នុងផ្នែកខាងដើម) និងថ្នាល់ផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ត្រូវបានលើកមកពិភាក្សាក្នុងផ្នែកស្តីពី "ទិន្នន័យ និងរដ្ឋាភិបាលឌីជីថល" ខាងក្រោម)។

វិទ្យាស្ថានជាតិស្ថិតិកំពុងរៀបចំយុទ្ធសាស្ត្រថ្មីមួយដើម្បីផ្សព្វផ្សាយទិន្នន័យឱ្យកាន់តែប្រសើរ និងជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ។ ផ្អែកតាមបទសម្ភាសន៍ជាមួយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ទីភ្នាក់ងារនេះកំពុងសម្រេចបញ្ចប់យុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ ដែលមានគោលបំណង ១) លើកទឹកចិត្តអ្នកប្រើប្រាស់ទិន្នន័យ (ទាំងក្នុង និងក្រៅរដ្ឋាភិបាល) ដើម្បីឱ្យពួកគេយល់កាន់តែច្បាស់ពីទិន្នន័យ និងរបៀបទាញយក និងទទួលបានទិន្នន័យស្ថិតិជាតិសម្រាប់ការស្រាវជ្រាវ និងការពិនិត្យតាមដាននិងវាយតម្លៃ និង ២)ទទួលបានយោបល់ត្រឡប់ពីអ្នកប្រើប្រាស់ទិន្នន័យស្តីពីរបៀបបង្កើនគុណភាព និងលទ្ធភាពទទួលបានទិន្នន័យ។ ក្នុងការបង្កើនលទ្ធភាពទទួលបានទិន្នន័យ វិទ្យាស្ថានជាតិស្ថិតិគ្រោងនឹងប្រើប្រាស់ថ្នាលឌីជីថល

កាន់តែច្រើន ដូចជា CamStat និងមធ្យោបាយផ្សព្វផ្សាយបែបប្រពៃណីផ្សេងទៀត (ខិតប័ណ្ណ គេហទំព័រ)[79]។

វត្តមានអ្នកគ្រប់គ្រង និងអ្នកជំនាញការវ័យក្មេង និងការកើនឡើងនៃការប្រើប្រាស់បណ្តាញសង្គម ក្នុងរដ្ឋាភិបាល ជាកត្តាចំនួន២ដែលពន្លឿនវឌ្ឍនភាពនេះ។ ដោយបានបញ្ចប់ការសិក្សាពីបរទេស មន្ត្រីរដ្ឋាភិបាលវ័យក្មេងឱ្យតម្លៃខ្ពស់លើដំណើរការគោលនយោបាយដែលផ្អែកតាមភស្តុតាង ជាងមន្ត្រីជំនាន់មុន។ កត្តាសំខាន់មួយទៀតគឺរបៀបដែលរដ្ឋាភិបាលមានឆន្ទៈក្នុងការប្រើប្រាស់ និងទទួលយកបណ្តាញសង្គមយ៉ាងពេញលេញសម្រាប់ការស្វែងរកព័ត៌មានស្តីពីមតិ និងបណ្តឹងរបស់ប្រជាពលរដ្ឋលើបញ្ហាសាធារណៈ។ ឧ. មន្ត្រីរដ្ឋាភិបាលទាំងអស់ហាក់តាមដានជាប្រចាំលើមតិយោបល់ និងបណ្តឹងដែលត្រូវបានបង្ហោះក្នុង Facebook និងក្រុម Telegram។

**ភាពប្រសើរឡើងនៃដំណើរការគោលនយោបាយសាធារណៈ បានជំរុញ និងសម្រួលមួយផ្នែកដល់ការប្រើប្រាស់ទិន្នន័យកាន់តែច្រើន។** ដូចការពិភាក្សាពីខាងដើម ដំណើរការគោលនយោបាយរបស់កម្ពុជា (ចាប់ពីការរៀបចំផែនការរហូតដល់ការអនុវត្ត និងការពិនិត្យតាមដាននិងវាយតម្លៃ) កាន់តែមានស្តង់ដារ និងមានភាពប្រសើរឡើងជាលំដាប់។ នីតិវិធី និងដំណើរការស្តង់ដារទាំងនោះទាមទារឱ្យទីភ្នាក់ងាររដ្ឋាភិបាលប្រើប្រាស់ទិន្នន័យដើម្បីសំអាង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់ខ្លួន។ ដូច្នេះ ការប្រើប្រាស់ទិន្នន័យបានក្លាយជាសមាសភាគចម្បងមួយក្នុងដំណើរការការិយាល័យទូទៅ។ ប៉ុន្តែផ្អែកតាមការពិភាក្សាខាងក្រោម ភាពប្រសើរឡើងទាំងនេះ គឺមិនទាន់គ្រប់គ្រាន់អាចបង្កើនគ្រឿងលើកទឹកចិត្តជាក់ស្តែងឱ្យមន្ត្រីរដ្ឋប្រើប្រាស់ទិន្នន័យសម្រាប់វិភាជថវិកា ការដំឡើងតំណែង ឬការដាក់ទណ្ឌកម្មឡើយ។

### ៤.២.២ បញ្ហាប្រឈមដែលនៅសេសសល់

**ក្រៅពីវឌ្ឍនភាពខាងលើ ក៏មានបញ្ហាប្រឈមធំៗផងដែរ។** បញ្ហាប្រឈមធំៗពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិតែម្តង។ ការប៉ាន់ស្មានកន្លងមក និងអ្នកជំនាញដែលត្រូវបានសម្ភាសន៍ គូសបញ្ជាក់ពីបញ្ហាប្រឈមចំនួន៤៖ ១)ភាពមានកម្រិត និងភាពមិនរលូននៃកិច្ចសហការនិងការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗក្នុងប្រព័ន្ធស្ថិតិជាតិ (សូមមើលផ្នែកខាងលើ) ជាពិសេសរវាងវិទ្យាស្ថានជាតិស្ថិតិ និងទីភ្នាក់ងារផ្សេងទៀត ២) ភាពមានកម្រិតនៃការផ្តល់ជំនួយមូលនិធិដល់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិក្នុងរដ្ឋាភិបាល ៣) សមត្ថភាពមានកម្រិតរបស់បុគ្គលិកក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលថ្មីៗ និង ៤) កង្វះក្របខ័ណ្ឌបច្ចុប្បន្នភាពសម្រាប់ការប៉ាន់ប្រមាណគុណភាពទិន្នន័យការចែករំលែក និងការផ្សព្វផ្សាយទិន្នន័យ និងគោលនយោបាយដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍[80]។

[79] បទសម្ភាសន៍ជាមួយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ (ថ្ងៃទី៤ ខែមករា ឆ្នាំ២០២២)

[80] បញ្ហាប្រឈមទាំងនេះត្រូវបានកត់សម្គាល់ក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) និងត្រូវបានបញ្ជាក់ផងដែរក្នុងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់។

ឧបសគ្គផ្នែករចនាសម្ព័ន្ធខាងលើ បានបង្កឱ្យមានបញ្ហាប្រឈមជាបន្តបន្ទាប់ក្នុងការចែករំលែកទិន្នន័យ។ ទីមួយ ទោះបីជាមានការកំណត់ច្បាស់នូវក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធស្ថិតិជាតិក៏ដោយ ក៏ក្នុងការអនុវត្ត នៅតែមិនសូវមានការយល់ដឹងពីតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួងសាមី និងទីភ្នាក់ងារ។ ទីពីរ ខណៈដែលមានការផលិតទិន្នន័យយ៉ាងច្រើន មិនសុទ្ធតែមានការផ្សព្វផ្សាយបានល្អពីការរក្សាទុក និងបញ្ជីសារពើភណ្ឌទិន្នន័យនោះទេ។ ក្នុងករណីមួយចំនួន សូម្បីតែមន្ត្រីក្នុងក្រសួងតែមួយក៏មិនបានដឹងពីបញ្ជីសារពើភណ្ឌទិន្នន័យទាំងនោះ និងរបៀបទាញយកទិន្នន័យដែរ។ លទ្ធផលរកឃើញនេះក៏ពន្យល់ផងដែរពីមូលហេតុដែលនាំឱ្យមានការលំបាកក្នុងការលើកកម្ពស់ការផ្សព្វផ្សាយទិន្នន័យរវាងទីភ្នាក់ងាររដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋ។

**មានមូលហេតុចំនួន៣ ដែលនាំឱ្យមានបញ្ហាប្រឈមជាបន្តបន្ទាប់សម្រាប់ការចែករំលែក និងប្រើប្រាស់ទិន្នន័យក្នុងរដ្ឋាភិបាល។** មូលហេតុទី១ ពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស ដូចជា ការបែងចែកប្រភេទទិន្នន័យដោយមិនស៊ីសង្វាក់គ្នា និងភាពមានកម្រិតនៃអន្តរប្រតិបត្តិការសម្រាប់ប្រព័ន្ធព័ត៌មានគ្រប់គ្រង (MIS) ក្នុងក្រសួងនានា។ មូលហេតុទី២ គឺដំណើរការការិយាល័យបច្ចុប្បន្នមានលក្ខណៈមជ្ឈការ ចំណាយពេលយូរ និងប្រើប្រាសក្រដាសស្នាម ដែលធ្វើឱ្យអ្នកធ្វើកិច្ចការការិយាល័យត្រូវផ្តោតចម្បងលើការអនុលោមតាមដំណើរការ ជាជាងការប្រើប្រាស់ទិន្នន័យដើម្បីកែលម្អដំណើរការនោះ។ មូលហេតុទី៣ គឺទោះបីជាការប្រើប្រាស់ទិន្នន័យជាតម្រូវការចាំបាច់ក៏ដោយ ប៉ុន្តែមិនមានការផ្តល់គ្រឿងលើកទឹកចិត្តនោះទេ។ ឧ. អ្នកផ្តល់ព័ត៌មានសំខាន់ក្នុងក្រសួងសាម៉ីនានាបានលើកឡើងថា ទីភ្នាក់ងាររបស់ពួកគេទំនងជាមិនទទួលបានថវិកាបន្ថែម ឬរង្វាន់លើកទឹកចិត្តណាមួយសម្រាប់ការប្រើប្រាស់ទិន្នន័យបានល្អ ដើម្បីទ្រទ្រង់សំណើថវិការបស់ពួកគេឡើយ[81]។

## ៤.៣ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងនាមជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យ

ការអនុវត្តជាអន្តរជាតិគូសបញ្ជាក់ពីសារៈសំខាន់របស់សង្គមស៊ីវិល ស្ថាប័នសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋក្នុងការផលិត និងប្រើប្រាស់ទិន្នន័យក្នុងបញ្ហាគោលនយោបាយសាធារណៈ។ ការមានទិន្នន័យសម្រាប់ការទាញយកដោយតួអង្គមិនមែនរដ្ឋ អាចជួយដល់ពួកគេក្នុងការរក្សាឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើជម្រើសគោលនយោបាយផ្សេងៗ។ ជាតុចូលពីសង្គមស៊ីវិលក៏អាចជាយោបល់ត្រឡប់សម្រាប់រដ្ឋាភិបាលក្នុងការកែលម្អ និងកែសម្រួលគោលនយោបាយរបស់ខ្លួនផងដែរ។ អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវ ផលិតទិន្នន័យតាមរយៈអង្កេត និងព័ត៌មានដែល

[81] មន្ត្រីរដ្ឋាភិបាល និងអ្នកនៅក្រៅរដ្ឋាភិបាលមួយចំនួនគូសបញ្ជាក់ថា ជាមួយនឹងការប្រើប្រាស់ Facebook យ៉ាងទូលំទូលាយក្នុងចំណោមមន្ត្រីរដ្ឋាភិបាល ការបង្ហោះសារក្នុង Facebook បានក្លាយជា "សូចនាករសមិទ្ធកម្ម" សំខាន់មួយដែលអាចទាក់ទាញចំណាប់អារម្មណ៍កាន់តែខ្លាំងពីថ្នាក់លើរបស់ពួកគេ។

ទទួលបានដោយផ្ទាល់ពីមហាជន ប៉ុន្តែស្ថាប័នទាំងនេះក៏ពឹងផ្អែកផងដែរលើទិន្នន័យរដ្ឋបាលពីរដ្ឋាភិបាលដើម្បីបង្កើនបរិមាណ និងគុណភាពនៃភស្តុតាងស្តីពីកម្មវិធី និងគោលនយោបាយនានា។ ទោះជាយ៉ាងណាអ្វីដែលនៅតែជាបញ្ហាចោទសម្រាប់ពួកគេគឺលទ្ធភាពទទួលបានទិន្នន័យរដ្ឋបាលទាំងនោះ សូម្បីតែក្នុងបណ្តាប្រទេសដែលមានប្រព័ន្ធស្ថិតិល្អប្រសើរក៏ដោយ[82]។

## ៤.៣.១ ខឿ្ងនភាពថ្មីៗ និងបញ្ហាទំនុកចិត្ត

ក្រុមដ៏សំខាន់មួយនៃតួអង្គមិនមែនរដ្ឋក្នុងការផលិត និងប្រើប្រាស់ទិន្នន័យ គឺវិទ្យាស្ថានស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់។ នៅចុងឆ្នាំ២០១៩ មានការសិក្សាបែបវិភាគមួយដោយកម្មវិធីពន្លកចំណេះស្តីពីវិទ្យាស្ថានស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ចំនួន៣០នៅកម្ពុជា។ ស្ថាប័នទាំងនោះមានចរិតលក្ខណៈពិសេស ចំណុចផ្តោតក្នុងការស្រាវជ្រាវ និងបញ្ហាប្រឈមខុសៗគ្នាក្នុងការផលិតការស្រាវជ្រាវ និងការប្រើប្រាស់លទ្ធផលរកឃើញរបស់ខ្លួនដើម្បីជះឥទ្ធិពលលើគោលនយោបាយ។ ក្នុងចំណោមបញ្ហាទាំងនោះ បញ្ហាគួរឱ្យកត់សម្គាល់រួមមាន ១) លទ្ធភាពទទួលបានទិន្នន័យរដ្ឋាភិបាល និង ២) លទ្ធភាពចូលរួមក្នុងវដ្តនៃការតាក់តែងគោលនយោបាយ[83]។ បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ដែលត្រូវបានធ្វើឡើងសម្រាប់ការសិក្សានេះបញ្ជាក់ថា មួយភាគធំគឺនៅតែមានបញ្ហាប្រឈមទាំង២ នេះ។ អ្នកស្រាវជ្រាវដែលអាចកសាងទំនាក់ទំនង និងទំនុកចិត្តជាមួយជាមួយទីភ្នាក់ងាររដ្ឋាភិបាល នៅតែអាចទទួលបានទិន្នន័យដែលចាំបាច់ និងច្បាមយកទស្សនៈយល់ឃើញរបស់ទីភ្នាក់ងារទាំងនោះដោយផ្ទាល់ ក្នុងការជជែកដេញដោលគោលនយោបាយ ប៉ុន្តែអ្នកស្រាវជ្រាវដែលមិនមានលទ្ធភាព នៅតែមានការលំបាកក្នុងការទទួលបានទិន្នន័យ។

**មានចំណុចគួរឱ្យកត់សម្គាល់ចំនួន២ ក្នុងការកសាងទំនុកចិត្ត។** ទីមួយ គេអាចពង្រឹងទំនុកចិត្តបានដោយផ្អែកលើកត្តាជាច្រើន។ ទីមួយ គឺតាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន និងមិត្តភាព ដែលអាចបណ្តាលមកពីការរៀនជាមួយគ្នា ការស្ថិតក្នុងក្រុមអាយុដូចគ្នា ការធ្លាប់ធ្វើការជាមួយគ្នា។ល។ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះគឺការយល់ឃើញពីសម្ព័ន្ធភាព និងនិន្នាការនយោបាយ (ឧ. ប្រសិនបើមនុស្សម្នាក់ត្រូវបានគេយល់ឃើញថា គាំទ្រ ឬប្រឆាំងរដ្ឋាភិបាល)។ កត្តាមួយទៀតគឺការទទួលស្គាល់ និងការចាត់តាំងផ្លូវការ។ ឧ. ប្រសិនបើអ្នកស្រាវជ្រាវម្នាក់មានលិខិតចាត់តាំងផ្លូវការ គាត់នឹងមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានទិន្នន័យផ្លូវការដែលត្រូវការចាំបាច់ ប៉ុន្តែវាអាចទាមទារទំនាក់ទំនងផ្ទាល់ខ្លួនបន្ថែមទៀតដើម្បីអាចទទួលបានទិន្នន័យយ៉ាងឆាប់រហ័ស។ ទីពីរ ក្នុងវិស័យមិនមែនរដ្ឋាភិបាល ហាក់មានទំនុកចិត្តលើអ្នកធ្វើការក្នុងការិយាល័យ និងអ្នកជំនាញវ័យក្មេង ជាងមន្ត្រីចាស់ៗ ដែលមួយផ្នែកគឺដោយសារតែពួកគេរៀនសាលាជាមួយគ្នា ទទួលបានអាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលដូចគ្នា។ល

[82] WDR (2021), p35

[83] The Asia Foundation (2019) The knowledge sector in Cambodia: Knowledge producers: Situation, Challenges, and Programming Suggestions

ក្រៅពីបញ្ហាប្រឈមទាំងនេះ គេសង្កេតឃើញមាននិន្នាការថ្មីៗមួយចំនួន។ ទីមួយ អ្នកស្រាវជ្រាវនៅកម្ពុជាដើរតួនាទីកាន់តែសំខាន់ក្នុងស្ថាប័នស្រាវជ្រាវ និងវិទ្យាស្ថានស្រាវជ្រាវ និងផ្ដល់យោបល់។ ខុសពីរយៈពេល ៥ ឬ ១០ឆ្នាំមុន បច្ចុប្បន្ន មានអ្នកស្រាវជ្រាវកាន់តែច្រើននៅកម្ពុជា ជាពិសេសអ្នកស្រាវជ្រាវដែលមានអាយុក្រោម៤៥ឆ្នាំ ដែលដើរតួនាទីលេចធ្លោក្នុងវិទ្យាស្ថានស្រាវជ្រាវទាំងអស់។ និន្នាការនេះត្រូវបានសាទរដោយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងបញ្ញវន្តកម្ពុជាផ្ទាល់ និងអ្នកតាក់តែងគោលនយោបាយក្នុងជួររដ្ឋាភិបាល។ ទីពីរ មានក្រុមអ្នកស្រាវជ្រាវវ័យក្មេងកាន់តែច្រើនដែលត្រូវបានបង្កើតឡើង និងគាំទ្រដោយអង្គការសង្គមស៊ីវិលផ្សេងៗ។ ក្នុងក្រុមទាំងនោះ អ្នកស្រាវជ្រាវជាស្ត្រីទទួលបានការលើកទឹកចិត្ត និងការគាំទ្រជាពិសេស (សូមមើលប្រអប់ខាងក្រោមស្ដីពីបណ្ដាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ឬ SheThinks)[84] ។ ក្នុងការសិក្សានេះ មានករណីដ៏គួរឱ្យចាប់អារម្មណ៍មួយ គឺអ្នកស្រាវជ្រាវវ័យក្មេងមួយក្រុមត្រូវបានបង្កើតឡើងក្រោមកម្មវិធីអ្នកស្ម័គ្រចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នោះគឺ "កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ"។ ករណីសិក្សាក្នុងផ្នែកទី៥ នឹងផ្ដល់ព័ត៌មានបន្ថែមទៀតស្ដីពីកម្មវិធីនេះ។

### ប្រអប់ទី៧៖ បណ្ដាញស្ត្រីក្នុងវិស័យស្រាវជ្រាវ (SheThinks) ដែលគាំទ្រដោយអង្គការមូលនិធិអាស៊ី[85]

បណ្ដាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ឬ SheThinks ជាបណ្ដាញស្រាវជ្រាវរបស់ស្ត្រីដែលផ្ដួចផ្ដើមឡើងដោយកម្មវិធីពន្លកចំណេះរបស់អង្គការមូលនិធិអាស៊ី៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា។ ក្រុមនេះត្រូវបានបង្កើតឡើងក្នុងខែកុម្ភៈឆ្នាំ២០២១ ដោយអ្នកស្រាវជ្រាវជាស្ត្រីចំនួន២០ នាក់មកពីស្ថាប័នស្រាវជ្រាវ និងផ្ដល់យោបល់ផ្សេងៗនៅកម្ពុជា និងគាំទ្រដោយក្រុមកម្មវិធីពន្លកចំណេះរបស់អង្គការមូលនិធិអាស៊ី។ ក្រុមស្ត្រីស្រាវជ្រាវនេះមានគោលបំណងលើកឡើងពីវិសមភាពយេនឌ័រក្នុងសហគមន៍ស្រាវជ្រាវនៅកម្ពុជា តាមរយៈការបង្កើនភាពអង់អាច និងការបង្កើនសំឡេងរបស់ស្ត្រីក្នុងការស្រាវជ្រាវ និងការធ្វើឱ្យការងារស្រាវជ្រាវកាន់តែមានបរិយាបន្ន។ ក្រុមនេះបានផ្ដល់ឱកាសដល់អ្នកស្រាវជ្រាវជាស្ត្រីក្នុងការជួយគ្នាទៅវិញទៅមក។ អ្នកស្រាវជ្រាវជាស្ត្រី ទាំងអ្នកស្រាវជ្រាវថ្មី និងអ្នកស្រាវជ្រាវមានបទពិសោធន៍ដែលមកពីស្ថាប័នស្រាវជ្រាវ និងផ្ដល់យោបល់នៅកម្ពុជា ត្រូវបានកៀរគរសម្រាប់ការជួយគ្នាទៅវិញទៅមកប្រកបដោយអត្ថន័យ។

ក្រុមនេះមានគោលបំណងបង្កើតសហគមន៍ស្រាវជ្រាវ ដែលមានភាពអំណោយផលសម្រាប់អ្នកស្រាវជ្រាវជាស្ត្រី។ អង្គការមូលនិធិអាស៊ីសង្ឃឹមថានឹងពង្រីកឱកាសសម្រាប់ឱ្យអ្នកស្រាវជ្រាវជាស្ត្រីជួបប្រជុំគ្នា ចូលរួមជាមួយគ្នា ចែករំលែកបទពិសោធន៍ក្នុងការងារស្រាវជ្រាវ លើកឡើងពីបញ្ហាប្រឈម និងរៀនសូត្រ ក៏ដូចជាចែករំលែកយោបល់ត្រឡប់ និងបំណងប្រាថ្នាជាមួយគ្នា។ សមាជិកក្រុមអាចទទួលបានព័ត៌មាននានា ដូចជា អាហារូបករណ៍ សិក្ខាសាលា ការបណ្ដុះបណ្ដាល និង

[84] ក្រៅពីគំនិតផ្ដួចផ្ដើមក្រោមកម្មវិធីពន្លកចំណេះ មានគំនិតផ្ដួចផ្ដើមផ្សេងទៀតស្ដីពីទឹកស្អាត ឌីជីថល ការអភិវឌ្ឍសហគមន៍។ល។

[85] https://policypulse.org/ponlok-chomnes/shethinks-network/

ព័ត៌មានផ្សេងទៀត។ ក្រៅពីនេះ សមាជិកក្រុមក៏អាចទទួលបានការអភិវឌ្ឍសមត្ថភាពបច្ចេកទេសផងដែរ ដូចជា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ការណែនាំ និងការបង្វឹកបង្ហាត់ដោយសមាជិកដែលមានពិសោធន៍។ ការចូលរួមរបស់ពួកគេក៏ផ្តល់ឱកាសសម្រាប់ការចូលរួមក្នុងសកម្មភាពផ្សេងទៀតដែលគាំទ្រដោយកម្មវិធីពន្លកចំណេះផងដែរ ដូចជា ការសរសេរប្លក (blog) ការចូលរួមក្នុងផតកាស និងការចូលរួមជាមួយវាគ្មិនខាងក្រៅ។

**មានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនផ្សេងទៀតពាក់ព័ន្ធនឹងរបៀបដែលវិទ្យាស្ថានស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ ផលិត និងចែករំលែកការស្រាវជ្រាវ និងទិន្នន័យ។** ទីមួយ អ្នកស្រាវជ្រាវដែលត្រូវបានសម្ភាសន៍ គូសបញ្ជាក់ថា ប្រធានបទស្រាវជ្រាវរបស់ពួកគេនៅតែផ្អែកតាមរបៀបវារៈរបស់ម្ចាស់ជំនួយ ទោះបីជាពួកគេលើកឡើងថា ភាគច្រើនគឺពួកគេឯកភាពតាមរបៀបវារៈទាំងនោះក៏ដោយ។ ឧ. ក្នុងរយៈពេល ២ឆ្នាំកន្លងមកនេះ គម្រោងភាគច្រើនដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ ផ្តោតសំខាន់លើជំងឺកូវីដ-១៩ និងផលប៉ះពាល់របស់ជំងឺនេះ ដែលជាប្រធានបទដ៏ពាក់ព័ន្ធបំផុត។ ទីពីរ មានការចែករំលែកជាប្រព័ន្ធនូវលទ្ធផលរកឃើញពីការស្រាវជ្រាវកាន់តែច្រើននៅក្នុងគេហទំព័រ និងបណ្តាញសង្គម។ ឧទាហរណ៍មួយនៃកិច្ចខិតខំប្រឹងប្រែងនេះគឺការបង្កើតផ្ទាំងបង្ហាញរបាយការណ៍ដោយការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលផ្តល់លទ្ធភាពប្រើប្រាស់ និងព័ត៌មានបច្ចុប្បន្នភាពស្តីពីឯកសារស្រាវជ្រាវដែលទើបបានបោះពុម្ពផ្សាយ និងឯកសារស្រាវជ្រាវដែលនឹងចេញផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត[86]។ ឧទាហរណ៍មួយទៀតគឺសិក្ខាសាលាអនឡាញដែលត្រូវបានរៀបចំឡើងយ៉ាងជាប់លាប់ដោយវិទ្យាស្ថានស្រាវជ្រាវឈានមុខគេ ដែលគ្របដណ្តប់លើប្រធានបទផ្សេងៗ និងចូលរួមដោយបញ្ញវន្តល្បីៗដែលភាគច្រើនជាជនជាតិកម្ពុជា។ ត្រង់ចំណុចនេះ មានការលើកឡើងថា គំនិតផ្តួចផ្តើមឌីជីថលបែបសាមញ្ញទាំងនេះនឹងអាចជួយជំរុញការងារស្រាវជ្រាវនៅកម្ពុជា។

ទោះបីជាសម្រេចបានវឌ្ឍនភាពក្តី ប៉ុន្តែការប្រើប្រាស់ទិន្នន័យបែបបរិមាណជាមួយនឹងសំណាកធំៗនៅតែជាឧបសគ្គសម្រាប់អ្នកស្រាវជ្រាវនៅកម្ពុជា។ ក្នុងផ្នែកបច្ចេកទេស គួរឱ្យតម្លៃដូចគ្នាដល់ការស្រាវជ្រាវ និងទិន្នន័យបែបបរិមាណ និងបែបគុណភាព ប្រសិនបើកិច្ចការទាំងនោះត្រូវបានរៀបចំ និងធ្វើឡើងបានសមស្រប។ ប៉ុន្តែអ្នកតាក់តែងគោលនយោបាយជាច្រើននៅកម្ពុជាដែលត្រូវបានសម្ភាសន៍សម្រាប់ការសិក្សានេះ យល់ថា ហាក់មិនសូវមានការឱ្យតម្លៃលើការស្រាវជ្រាវបែបគុណភាព និងការស្រាវជ្រាវបែបបរិមាណដែលមានទំហំសំណាកតូច។ ទំហំសំណាកជាសំណួរដំបូងមួយក្នុងចំណោមសំណួរដែលត្រូវបានសួរពីអ្នកតាក់តែងគោលនយោបាយពាក់ព័ន្ធ

[86] សូមចូលទៅកាន់៖ https://un-cambodia.exploredata.report/

នឹងការស្រាវជ្រាវដែលត្រូវបានបង្ហាញដល់ពួកគេ។ ដូចការលើកឡើងក្នុងការសិក្សានេះ ការផ្តោតខ្លាំងពេកលើទំហំសំណាក មានន័យថា រដ្ឋាភិបាលមិនឱ្យតម្លៃដល់ការងារស្រាវជ្រាវដែលធ្វើឡើងដោយអ្នកស្រាវជ្រាវនៅកម្ពុជា ខណៈដែលស្នាដៃស្រាវជ្រាវរបស់ពួកគេមានភាពប្រសើរឡើងជាលំដាប់[87]។

**ប៉ុន្តែក្នុងករណីមួយចំនួន លទ្ធផលរកឃើញពីការស្រាវជ្រាវបែបគុណភាព ក៏ត្រូវបានស្វាគមន៍ដោយអ្នកតាក់តែងគោលនយោបាយផងដែរ ប្រសិនបើការស្រាវជ្រាវទាំងនោះពាំនាំចំណេះដឹងកាន់តែច្រើនពីបទពិសោធន៍អន្តរជាតិ និងបទពិសោធន៍ក្នុងតំបន់។** លទ្ធផលរកឃើញនេះផ្អែកលើបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងត្រូវបានបញ្ជាក់ក្នុងសិក្ខាសាលារបស់អង្គការមូលនិធិអាស៊ីដែលបានធ្វើឡើងកាលពីខែវិច្ឆិកាឆ្នាំ២០២១។ ជាទូទៅ អ្នកតាក់តែងគោលនយោបាយយល់ថា ពួកគេមានមតិល្អគួរសមស្តីពីស្ថានភាព និងបញ្ហាក្នុងស្រុក។ អ្វីដែលពួកគេចង់ដឹងបន្ថែមទៀតគឺដំណោះស្រាយ។ ពួកគេយល់ថា ដំណោះស្រាយគោលនយោបាយល្អៗ គួរគាំទ្រដោយទស្សនាទានអន្តរជាតិ និងបទពិសោធន៍ពីប្រទេសផ្សេងទៀត ជាពិសេសប្រទេសដែលមានស្ថានភាពប្រហាក់ប្រហែលនឹងកម្ពុជា។ នេះជាមូលហេតុសំខាន់មួយដែលតាមការលើកឡើងដោយអ្នកតាក់តែងគោលនយោបាយ នាំឱ្យការធ្វើការជាមួយអ្នកជំនាញអន្តរជាតិ និងការចាប់ដៃគូជាមួយស្ថាប័នស្រាវជ្រាវក្នុងតំបន់ និងស្ថាប័នស្រាវជ្រាវអន្តរជាតិ ក្លាយជាកត្តាសំខាន់សម្រាប់ការបង្កើនសមត្ថភាពរបស់ស្ថាប័នស្រាវជ្រាវក្នុងស្រុក និងការធានាភាពពាក់ព័ន្ធនៃលទ្ធផលរកឃើញពីការស្រាវជ្រាវរបស់ពួកគេ។

មានគំនិតផ្តួចផ្តើមគួរឱ្យចាប់អារម្មណ៍មួយចំនួន ដែលមានគោលបំណងប្រមូលទិន្នន័យសាធារណៈ និងផ្សព្វផ្សាយទិន្នន័យទាំងនោះតាមប្រព័ន្ធអ៊ីនធឺណិត។ ឧទាហរណ៍មួយដែលត្រូវបានលើកឡើងក្នុងការសិក្សានេះគឺអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)។ តាមរយៈគេហទំព័ររបស់ខ្លួន អង្គការនេះគឺជាគេហទំព័រ "ទិន្នន័យបើកទូលាយ" ដែលដំណើរការដោយផ្អែកតាមការសន្មតថា ទិន្នន័យដែលប្រមូលបានសម្រាប់ផលប្រយោជន៍សាធារណៈគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយមិនមានការរឹតត្បិត[88]។ គេហទំព័ររបស់របស់អង្គការ ODC មានការបង្ហាញពីទិន្នន័យសាធារណៈស្តីពីប្រធានបទផ្សេងៗ ចាប់ពីជំងឺកូវីដ-១៩ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បរិស្ថាន និងថ្មីៗនេះ ការវិនិយោគផ្ទាល់ពីបរទេស។ អង្គការនេះមានបណ្តុំទិន្នន័យ (datahub) ដែលតាមការគូសបញ្ជាក់ក្នុងគេហទំព័ររបស់អង្គការផ្ទាល់ មានសំណុំទិន្ន័យដែលអាចស្វែងរកបានចំនួន ៤.០១១[89]។

87 ការសង្កេតនេះ ផ្អែកតាមបទពិសោធន៍របស់អ្នកនិពន្ធផ្ទាល់ តាមរយៈការពិនិត្យផលិតផលស្រាវជ្រាវក្នុងរយៈពេល ១៥ឆ្នាំកន្លងមកនេះ និងត្រូវបានបញ្ជាក់ដោយអ្នកផ្តល់ព័ត៌មានសំខាន់។

88 សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ https://opendevelopmentcambodia.net/about/background/

89 https://data.opendevelopmentcambodia.net/en/dataset?organization=cambodia-organization.

## ៤.៣.២ លទ្ធភាពទទួលបានទិន្នន័យ និងការប្រើប្រាស់ទិន្នន័យ

**លទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានទិន្នន័យ ជាគន្លឹះនៃការបង្កើនការងារស្រាវជ្រាវនៅកម្ពុជា សម្រាប់គោលបំណងគោលនយោបាយ**។តាមពិតការចែករំលែកទិន្នន័យជាបញ្ហាទូទៅមួយនៅក្នុងប្រទេសជាច្រើន មិនមែនតែនៅកម្ពុជានោះទេ។ នេះជាមូលហេតុដែលធ្វើឱ្យមានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនលើគំនិតនៃការបង្កើតឱ្យមានអន្តរការីទិន្នន័យក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ (សូមមើលប្រអប់ខាងក្រោម)។ សម្រាប់កម្ពុជា ឯកសារពាក់ព័ន្ធ និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ បានរំលេចចំណុចគួរឱ្យកត់សម្គាល់ចំនួន២។ ទីមួយ វិទ្យាស្ថានស្រាវជ្រាវក្នុងស្រុកត្រូវតែងាយស្រួលទទួលបាននិងប្រើប្រាស់ទិន្នន័យរដ្ឋាភិបាលដែលមានស្រាប់។ ក្នុងរយៈពេលវែង លទ្ធភាពនេះអាចនឹងប្រសើរឡើង នៅពេលមានភាពល្អប្រសើរក្នុងការសម្របសម្រួល និងចែករំលែកទិន្នន័យក្នុងប្រព័ន្ធស្ថិតិជាតិ។ ប៉ុន្តែក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម គេរំពឹងថា អ្នកស្រាវជ្រាវនៅក្រៅរដ្ឋាភិបាល នឹងមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានទិន្នន័យរដ្ឋាភិបាល នៅពេលមានការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ ដែលដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ។ ដូច្នេះ ស្ថាប័នសិក្សា និងស្ថាប័នស្រាវជ្រាវ ត្រូវចូលរួមយ៉ាងសកម្មក្នុងដំណើរការអនុវត្តន៍នេះ។

### ប្រអប់ទី៨៖ ភាពចាំបាច់ និងតួនាទីរបស់អន្តរការីទិន្នន័យ

វិធីមួយដើម្បីជំរុញការប្រើប្រាស់ និងចែករំលែកទិន្នន័យកាន់តែប្រសើរ គឺការបង្កើតឱ្យមានអន្តរការីទិន្នន័យ។ អន្តរការីទិន្នន័យអាចជួយសម្រួលដល់ការប្រមូល ការផ្តល់សុពលភាព និងការបូកសរុបទិន្នន័យពីអ្នករួមផ្តល់ទិន្នន័យ និងធ្វើឱ្យអ្នកប្រើប្រាស់ទិន្នន័យអាចយល់ ប្រើប្រាស់ និងទទួលបានទិន្នន័យ។ អន្តរការីទិន្នន័យអាចសម្រួលដល់ការចែករំលែកទិន្នន័យប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាពខ្ពស់រវាងស្ថាប័នរដ្ឋាភិបាល ឬរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ ការមានអន្តរការីទិន្នន័យគឺជាជម្រើសល្អ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលអាចមានចន្លោះប្រហោងក្នុងក្របខ័ណ្ឌគ្រប់គ្រងទិន្នន័យ ឬកម្សោយក្នុងការពង្រឹងការអនុវត្ត[90]។

អន្តរការីទិន្នន័យក្នុងវិស័យសាធារណៈ ជួយសម្របសម្រួល និងលើកកម្ពស់ការចែករំលែកទិន្នន័យរវាងតួអង្គចម្រុះ តាមរយៈការធានាការអនុលោមតាមវិធានអប្បបរមាស្តីពីការការពារនិងសន្តិសុខទិន្នន័យ ក៏ដូចជាស្តង់ដារគុណភាព និងវិធាននានា ដើម្បីធានាថា ទិន្នន័យអាចដំណើរការជាមួយគ្នាបាន។ ទោះបីជាការប្រើប្រាស់អន្តរការីទិន្នន័យមិនទាន់មានភាពទូលំទូលាយក្នុងវិស័យឯកជនក៏ដោយ ប៉ុន្តែគេអាចរៀនសូត្របានច្រើនពីម៉ូដែលអន្តរការីទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម និងវិស័យសិក្សាស្រាវជ្រាវបច្ចុប្បន្ន។ ខាងក្រោមនេះជាឧទាហរណ៍នៃ

---
[90] WDR (2021), p277-280

ម៉ូដែលទាំងនោះ[91]៖

- អ្នកគ្រប់គ្រងទិន្នន័យ (Data stewards)៖ អ្នកដឹកនាំស្ថាប័នដែលមានតួនាទីជាអ្នកគ្រប់គ្រងទិន្នន័យ ដើម្បីគ្រប់គ្រងសិទ្ធិប្រើប្រាស់ទិន្នន័យ និងការប្រើប្រាស់ទិន្នន័យឡើងវិញ និងកំណត់រកឱកាសសម្រាប់កិច្ចសហការទិន្នន័យឆ្លងវិស័យប្រកបដោយផ្លែផ្កា។
- បរធនបាលកិច្ចទិន្នន័យ (data trust)៖ ក្របខ័ណ្ឌកិច្ចព្រមព្រៀងដែលអាចអនុវត្តដដែលៗ ដោយផ្អែកលើបរធនបាលកិច្ច ឬកិច្ចសន្យា ដែលអាចឱ្យអ្នកដែលមានសិទ្ធិទទួលបានទិន្នន័យផ្ទេរការគ្រប់គ្រងទិន្នន័យរបស់ខ្លួនទៅបរធនបាល (trustee)។
- កិច្ចសហការទិន្នន័យ (data collaborative)៖ ទំនាក់ទំនងមួយក្នុងការចែករំលែកទិន្នន័យដែលអាចមានទម្រង់ចម្រុះ ដូចជា ផ្ទាំងអន្តរកម្មជាសាធារណៈ អន្តរការីដែលទទួលបានទំនុកចិត្ត ការកៀរគរទិន្នន័យ និងភាពជាដៃគូក្នុងការស្រាវជ្រាវ និងវិភាគ។ ក្នុងទំនាក់ទំនងរវាងស្ថាប័នមកពីវិស័យផ្សេងៗ កិច្ចសហការទិន្នន័យអាចឱ្យមានការចែករំលែកទិន្នន័យ ចំណេះដឹង ម៉ូដែល ឬជំនាញរបស់ភាគីមួយ ឬច្រើន។
- កិច្ចសហប្រតិបត្តិការទិន្នន័យ (data cooperative)៖ បណ្តាញកិច្ចព្រមព្រៀងរវាងបុគ្គល/ស្ថាប័នដែលបម្រើប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដែលអាចឱ្យមានការកៀរគរធនធានទិន្នន័យ។ សមាជិកខិតខំពាំនាំទិន្នន័យ និងទទួលខុសត្រូវលើការគ្រប់គ្រងទិន្នន័យ។ ទិន្នន័យត្រូវបានពាំនាំមកនៅពេលសមាជិកចូលរួម និងត្រូវបានលុបចោលនៅពេលសមាជិកចាកចេញ។

អន្តរការីទិន្នន័យអាចជាទីភ្នាក់ងារសាធារណៈ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ អង្គភាពសាធារណៈ ឬទីភ្នាក់ងាររដ្ឋាភិបាលអាចដើរតួនាទីជាអន្តរការី ជាពិសេសដោយសារតែអង្គភាព/ទីភ្នាក់ងារនោះពាក់ព័ន្ធនឹងទិន្នន័យដែលមានប្រភពពីស្ថាប័នសាធារណៈ។ ដូច្នេះ អង្គភាព/ទីភ្នាក់ងារនោះអាចដើរតួនាទីជាអ្នកប្រមូលផ្តុំ ឬច្រកព័ត៌មានទាំងនោះ ក៏ដូចជាធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលកាន់តែខ្លាំងក្នុងការទទួលបាន កំណត់ ស្វែងរក និងប្រើប្រាស់ទិន្នន័យ។ ផ្ទុយទៅវិញ អន្តរការីមិនស្វែងរកប្រាក់ចំណេញ ត្រូវមានផលចំណេញផ្នែកសេដ្ឋកិច្ចដើម្បីអាចឈរជើងបាន និងរ៉ាប់រងចំណាយជាបន្តបន្ទាប់។

ក្រៅពីលទ្ធភាពទទួលបានទិន្នន័យ ការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ ក៏មានសារៈសំខាន់ផងដែរ។ មន្ត្រីរដ្ឋាភិបាលដែលត្រូវបានសម្ភាសន៍ យល់ឃើញថា លទ្ធភាពទទួលបានទិន្នន័យនៅតែជាបញ្ហាចោទ ប៉ុន្តែបានបន្ថែមទៀតថា មកទល់បច្ចុប្បន្ននេះ មានទិន្នន័យយ៉ាងច្រើន ក្នុងបណ្តាញអ៊ីនធឺណិត។ បទសម្ភាសន៍បង្ហាញថាអ្វីដែលជាបញ្ហាចំពោះមុខគឺអ្នកស្រាវជ្រាវ និងអង្គការសង្គមស៊ីវិលមួយចំនួននៅកម្ពុជា ប្រហែលជាមិនមានគំនិតល្អៗស្តីពីទិន្នន័យដែលមានតាមបណ្តាញអ៊ីនធឺណិត និងរបៀបប្រើប្រាស់ទិន្នន័យទាំងនោះឡើយ។ ឧទាហរណ៍នៃទិន្នន័យទាំងនោះ រួម

[91] World Economic Forum (WEF) (2022), Advancing digital agency: The power of data intermediaries, Insight report February 2022.

មានអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ទិន្នន័យដែលពាក់ព័ន្ធនឹងថវិកា ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។ ដូច្នេះ ក្នុងរយៈពេលខ្លី អ្នកស្រាវជ្រាវ និងអង្គការសង្គមស៊ីវិលក្នុងស្រុក អាចផ្តោតសំខាន់លើការវិភាគប្រភពទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនោះ រៀនប្រើប្រាស់ទិន្នន័យទាំងនោះ ក៏ដូចជាកំណត់រកគម្លាត និងតស៊ូមតិឱ្យមានការចែករំលែកទិន្នន័យកាន់តែច្រើន។ ការសិក្សានេះបានធ្វើការវិភាគពីប្រភពទិន្នន័យដែលអាចរកបានតាមបណ្តាញអ៊ីនធឺណិត (សូមមើលឧបសម្ព័ន្ធ) ដែលអាចពង្រីកបន្ថែម និងកែលម្អ។

ដំណោះស្រាយទីពីរគឺការកែលម្អស្ថាប័នស្រាវជ្រាវនិងអង្គការសង្គមស៊ីវិលក្នុងស្រុកដើម្បីប្រើប្រាស់ថ្នាលឌីជីថលកាន់តែប្រសើរសម្រាប់ការប្រមូល និងទទួលបានទិន្នន័យកាន់តែច្រើន។ ចំណុចនេះមានចាប់ពីការប្រើប្រាស់កម្មវិធីបើកទូលាយ ដូចជា Kobo Toolbox ដើម្បីប្រមូល និងវិភាគទិន្នន័យ អង្កេតតាមអនឡាញ ដូចជា SurveyMonkey ឬ Google forms, chatbot ការប្រើប្រាស់ប្រភពទិន្នន័យបើកទូលាយ (ដូចជា ប្រភពទិន្នន័យដែលផ្តល់ដោយធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ។ល។) និងការប្រើប្រាស់ទិន្នន័យដែលផលិតដោយប្រជាពលរដ្ឋ[92]។

ផ្អែកតាមបទសម្ភាសន៍ និងការសង្កេត បច្ចេកទេសជាច្រើនក្នុងចំណោមនេះត្រូវបានប្រើប្រាស់ក្នុងកម្រិតខុសៗគ្នាដោយស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិលនៅកម្ពុជា ដើម្បីប្រមូលទិន្នន័យសម្រាប់ការងារអង្កេតរបស់ខ្លួន ឬទិន្នន័យពីអ្នកទទួលផលរបស់ពួកគេ។ ទោះជាយ៉ាងណា ការអនុវត្តគឺទើបតែចាប់ផ្តើមឡើង និងមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ។ ការសិក្សានេះលើកឡើងថា ការបណ្តុះបណ្តាលស្តីពីបច្ចេកទេសទាំងនេះ នឹងជួយពន្លឿន និងធ្វើឱ្យដំណើរការនេះកាន់តែមានប្រសិទ្ធភាព។

## ៤.៣.៣ ការជំរុញការចូលរួមរបស់វិស័យឯកជន និងទិន្នន័យសម្រាប់គោលបំណងឯកជន

**ភាពជាដៃគូជាមួយវិស័យឯកជន ជាកត្តាសំខាន់ក្នុងការលើកម្ពស់ការប្រើប្រាស់ទិន្នន័យសម្រាប់គោលបំណងឯកជនដើម្បីគោលបំណងសាធារណៈ។** ក្នុងប្រទេសជាច្រើន ទិន្នន័យដែលផលិតដោយវិស័យឯកជន (រួមទាំងទិន្នន័យ Big Data) ត្រូវបានប្រើប្រាស់សម្រាប់ជំរុញការអភិវឌ្ឍ និងបង្កើនកម្រិតជីវភាពរបស់ប្រជាជនក្រីក្រ។ ក្រៅពីជាកត្តាសំខាន់មួយសម្រាប់ផលិតកម្មរបស់ក្រុមហ៊ុនយក្ស ដូចជា Amazon, Google និង Facebook ទិន្នន័យវិស័យឯកជនក៏ត្រូវបានប្រើប្រាស់សម្រាប់ការពង្រីកឱកាសរបស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងការជ្រៀតចូលទីផ្សារផងដែរ (ឧ. ការកម្ម៉ង់ម្ហូបតាមអនឡាញ ការធ្វើទីផ្សារតាមបណ្តាញសង្គម) បង្កើនប្រតិបត្តិការទូទាត់ និងបរិយាបន្នហិរញ្ញវត្ថុ (ឧ. ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ការប្រើប្រាស់ទិន្នន័យរបស់អ្នកប្រើប្រាស់ដើម្បីកែលម្អការដាក់ពិន្ទុឥណទាន) កែលម្អការគ្រប់គ្រងការផ្គត់ផ្គង់ក្នុងវិស័យ

[92] សូមមើល ឧ. ព័ត៌មានក្នុង Global Partnership for Sustainable Development Data ៖ https://www.data4sdgs.org/, https://sustainabledevelopment.un.org/partnership/?p=11910;

សុខាភិបាល និងប្រព័ន្ធភស្តុភារក្នុងមធ្យោបាយដឹកជញ្ជូនសាធារណៈ[93]។

**នៅកម្ពុជា គំនិតនៃការទាញប្រយោជន៍ពីទិន្នន័យដែលផលិតដោយវិស័យឯកជនសម្រាប់គោលបំណងគោលនយោបាយ ទើបតែចាប់ផ្តើមឡើងប៉ុណ្ណោះ។** ជាមួយនឹងការកើនឡើងយ៉ាងរហ័សនៃការប្រើប្រាស់អ៊ីនធឺណិត ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងអាជីវកម្មថ្នាលបច្ចេកវិទ្យាក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនឯកជនជាច្រើន ដូចជា ក្រុមហ៊ុនទូរស័ព្ទចល័ត ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ក្រុមហ៊ុនជានារ៉ាប់រង PassApp, FoodPanda, AgriBuddy, Credit Bureau Cambodia និង Mekong Big Data ប្រាកដជាបានប្រមូល រក្សាទុក និងប្រើប្រាស់ទិន្នន័យស្តីពីអតិថិជនរបស់ខ្លួន។ នៅកម្ពុជា គំនិតនៃការប្រើប្រាស់ទិន្នន័យទាំងនេះសម្រាប់គោលបំណងគោលនយោបាយ ទើបតែចាប់ផ្តើមឡើងប៉ុណ្ណោះ ទោះបីជាមានការលើកឡើងពីចំណុចនេះក្នុងឯកសារគោលនយោបាយសំខាន់ៗ ដូចជា ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥) និងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) ក៏ដោយ។ ក្រៅពីនេះ មិនសូវមានការចូលរួមរបស់វិស័យឯកជនដែលធ្វើការងារពាក់ព័ន្ធនឹង Big Data ដែលទើបលេចចេញជារូបរាងនេះឡើយ លើកលែងតែសម្រាប់តួអង្គមួយចំនួន ដូចជា Mekong Data និង DataU (សូមមើលប្រអប់ខាងក្រោម)។

### ប្រអប់ទី៩៖ Mekong Data និង DataU ក្នុងនាមជាប្រតិបត្តិករថ្មីក្នុងវិទ្យាសាស្ត្រទិន្នន័យនៅកម្ពុជា

Mekong Big Data ជាក្រុមហ៊ុនវិភាគ និងផ្តល់បច្ចេកវិទ្យាសេវា Big Data នៅកម្ពុជា។ យោងតាមសារតារក្រុមហ៊ុនដែលត្រូវបានផ្សព្វផ្សាយ ក្រុមហ៊ុននេះធ្វើការជាមួយស្ថាប័ននានាចាប់ពីក្រុមហ៊ុនជោគជ័យធំៗ រហូតដល់ធុរកិច្ចថ្មីក្នុងឧស្សាហកម្ម ដូចជា ធនាគារ FinTech ទូរគមនាគមន៍ ទីភ្នាក់ងារអភិវឌ្ឍន៍ និងក្រុមហ៊ុនជាច្រើនផ្សេងទៀត ដើម្បីជួយឱ្យក្រុមហ៊ុនទាំងនោះកាន់តែផ្អែកលើទិន្នន័យ និងធ្វើការបង់ប្រាក់សម្រាប់ការប្រើប្រាស់ទិន្នន័យ តាមរយៈដំណោះស្រាយផ្សេងៗសម្រាប់ការវិភាគទិន្នន័យ ការពិគ្រោះយុទ្ធសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ (ស្វែងយល់បន្ថែម៖ https://mekongbigdata.com)។

DataU ជាបណ្ឌិតសភាជំនាញរបស់កម្ពុជាដែលរៀបចំ និងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញឌីជីថលថ្មីៗលើផ្នែកវិទ្យាសាស្ត្រទិន្នន័យ វិស្វកម្មទិន្នន័យ និងការធ្វើទីផ្សារឌីជីថលសម្រាប់សតវត្សរ៍ទី២១។ យោងតាមការផ្សព្វផ្សាយសារតារក្រុមហ៊ុន កម្មវិធីរបស់ DataU

[93] WDR (2021), p35

រួមបញ្ចូលជំនាញទិន្នន័យផ្អែកតាមឧស្សាហកម្ម ដែលគាំទ្រដោយការស្រាវជ្រាវ និងការបណ្តុះបណ្តាលជំនាញទន់ផ្អែកតាមតម្រូវការក្នុងស្រុក ដោយផ្តោតសំខាន់លើការងារ ទាំងក្នុងស្រុក និងក្រៅស្រុក។ អ្នកសិក្សាទទួលបានទាំងជំនាញរឹងដើម្បីប្រឡូកក្នុងការងារដែលទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ ក៏ដូចជាជំនាញទន់ និងឧបករណ៍សម្រាប់ការប្រឡូកក្នុងសង្គមការងារកាន់តែប្រសើរ និងក្លាយខ្លួនជាអ្នកដឹកនាំ និងអ្នកធ្វើឱ្យមានការផ្លាស់ប្តូរនាពេលអនាគត។ DataU Academy បណ្តុះបណ្តាលអ្នកគ្រប់គ្រងទិន្នន័យនាពេលអនាគតសម្រាប់សហគ្រាស ដើម្បីបំពេញតម្រូវការទេពកោសល្យ និងបង្កើនជំនាញបុគ្គលិកក្នុងឧស្សាហកម្មគ្រប់ប្រភេទ ចាប់ពីទូរគមនាគមន៍រហូតដល់ធនាគារ និងក្រុមហ៊ុន Start-Up ផ្នែកបច្ចេកវិទ្យាថ្មីៗ (ស្វែងយល់បន្ថែម៖ https://learn.mydatau.org)។

**ការត្រៀមប្រព័ន្ធស្ថិតិជាតិ ជាគន្លឹះនៃការទាញប្រយោជន៍ពីទិន្នន័យសម្រាប់គោលបំណងឯកជន។** ដូចការពិភាក្សាក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោក ការត្រៀមជាស្រេចនេះអាស្រ័យលើគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ (hardware និង software) សម្រាប់ការរក្សាទុក ការពិនិត្យ និងការប៉ាន់ប្រមាណទិន្នន័យ ក៏ដូចជាសមត្ថភាពរបស់ស្ថិតិវិទូផ្លូវការ និងអ្នកវិទ្យាសាស្ត្រទិន្នន័យ។ ដើម្បីឱ្យស្របតាមទិសដៅនោះ កម្ពុជាគួរចាប់យកបទពិសោធន៍ពីប្រទេសសមាជិកអាស៊ានផ្សេងទៀត ដូចជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន និងធ្វើការដកពិសោធន៍ជាមួយទិន្នន័យ Big Data ដើម្បីផ្តល់ស្ថិតិឱ្យបានញឹកញាប់ និងពិស្តារ។ ទិន្នន័យ Big Data ក៏នឹងក្លាយជាប្រធានបទសំខាន់មួយរបស់ក្រុមការងារបច្ចេកទេសទទួលបន្ទុកស្ថិតិជាតិ នៅកិច្ចប្រជុំកំពូលអាស៊ានដែលកម្ពុជានឹងធ្វើជាប្រធាននៅឆ្នាំ២០២២ ផងដែរ (សម្រាប់ព័ត៌មានលម្អិត សូមមើលផ្នែក៤.៥)[94]។

## ៤.៤ ទិន្នន័យ និងរដ្ឋាភិបាលឌីជីថល

គោលនយោបាយស្តីពីទិន្នន័យ និងរដ្ឋាភិបាលឌីជីថល ត្រូវបានរំលេចក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥)។ ក្របខ័ណ្ឌនេះមានគោលបំណងកសាងរដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈតាមរយៈការប្រើប្រាស់កាន់តែប្រសើរនូវប្រព័ន្ធ ICT និងសមាសភាគដែលផ្អែកលើទិន្នន័យ។ ក្របខ័ណ្ឌនេះចែកជា៣ ផ្នែក ៖ ក) រដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈ ខ) គន្លឹះក្នុងការជំរុញសមិទ្ធកម្មឌីជីថល និង គ) អភិបាលកិច្ចផ្អែកលើទិន្នន័យ។ អភិបាលកិច្ចផ្អែកលើទិន្នន័យមានវិធានការគោលនយោបាយចំនួន១០ ដែលវិធានការជាច្រើនដឹកនាំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ សូមមើលតារាងខាងក្រោម។

[94] បទសម្ភាសន៍ជាមួយវិទ្យាស្ថានជាតិស្ថិតិ (ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០២២)

## តារាងទី៥៖ វិធានការគោលនយោបាយសំខាន់ៗស្តីពីអភិបាលកិច្ចផ្អែកលើទិន្នន័យ ក្នុងក្របខ័ណ្ឌគោលនយោបាយឌីជីថល[95]

| ល.រ | វិធានការគោលនយោបាយផ្នែកអភិបាលកិច្ចផ្អែកលើទិន្នន័យ |
|---|---|
| ១ | ជំរុញការធ្វើឌីជីថលូបនីយកម្មក្នុងក្របខណ្ឌរដ្ឋ និងឯកជន ដើម្បីប្រមូលទិន្នន័យឱ្យបានច្រើនកម្រិត និងពីច្រើនប្រភព រួមមានជាអាទិ៍ ទិន្នន័យគោល ទិន្នន័យដែលកើតឡើងជាប្រចាំ (transactional data) និងទិន្នន័យដែលផ្ទុកលើហេដ្ឋារចនាសម្ព័ន្ធប្លុកឆេន (blockchain) សម្រាប់ជាមូលដ្ឋាននៃការវិភាគ |
| ២ | បង្កើតយន្តការរួមក្នុងការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ និងលើកកម្ពស់សមត្ថភាពស្ថាប័ន |
| ៣ | គាំទ្រនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ប្រមូលទិន្នន័យ និងរៀបចំបច្ចេកវិទ្យាដោយប្រើប្រាស់ទិន្នន័យសម្រាប់ផ្តល់សញ្ញាព្រមាន ចំពោះហេតុការណ៍មិនរំពឹងទុកនានា រួមមានជាអាទិ៍ គ្រោះធម្មជាតិ ទឹកជំនន់ ការកាប់បំផ្លាញព្រៃឈើ ការបម្លាស់ទីរបស់ជនអន្តោប្រវេសន៍ |
| ៤ | ធានាបាននូវសមត្ថភាពក្នុងការប្រមូល និងការវិភាគទិន្នន័យ តាមរយៈការរៀបចំបង្កើតម៉ាស៊ីនវិភាគរួម (shared analytics engine) |
| ៥ | ពង្រឹងមុខងារ និងសមត្ថភាពនៃការប្រមូល និងការប្រើប្រាស់ទិន្នន័យដោយបង្កើតកន្លែងផ្ទុកទិន្នន័យសំខាន់នៅតាមស្ថាប័នពាក់ព័ន្ធ រួមមានជាអាទិ៍ វិទ្យាស្ថានជាតិស្ថិតិ និងបណ្ណាសារឌីជីថលជាតិ (national digital archive) |
| ៦ | វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) នៅក្នុងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ ជាពិសេសការប្រើប្រាស់ ការវិភាគទិន្នន័យ និងយន្តការសម្រាប់ការបង្កើតសេវាឌីជីថលឱ្យមានស្វ័យប្រវត្តិកម្មខ្ពស់ និងងាយស្រួលប្រើប្រាស់ |

[95] RGC (2021) Cambodia digital economy and society policy framework.

| | |
|---|---|
| ៧ | ធានាបាននូវគុណភាពនៃទិន្នន័យ និងព័ត៌មានតាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងឡាយ ទាំងកម្រិតស្ថាប័ន និងអន្តរស្ថាប័ន ដោយផ្អែកលើយន្តការរួមនៃការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ |
| ៨ | ជំរុញការស្រាវជ្រាវលើការធ្វើឌីជីថលូបនីយកម្មភាសាខ្មែរ ដើម្បីផ្តល់លទ្ធភាពសម្គាល់ភាសាខ្មែរក្នុងការស្វែងរក និងការវិភាគទិន្នន័យជាអក្សរខ្មែរ និងលាយអក្សរបរទេស |
| ៩ | ជំរុញ ផ្សព្វផ្សាយ និងចែករំលែកទិន្នន័យមួយចំនួនជាសាធារណៈ |
| ១០ | ចូលរួមក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ដែលគាំទ្រដល់ការប្រព្រឹត្តទៅនៃរដ្ឋាភិបាលឌីជីថល ជាពិសេសការលើកកម្ពស់អភិបាលកិច្ចផ្អែកលើទិន្នន័យ។ |

ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា គ្របដណ្តប់លើវិធានការគោលនយោបាយជាច្រើន ដែលវិធានការមួយក្នុងចំណោមនោះពាក់ព័ន្ធនឹងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ កន្លងមក ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិដែលមានប្រព័ន្ធអ៊ីម៉ែល ប្រព័ន្ធគ្រប់គ្រងមាតិកា និងគេហទំព័ររបស់ក្រសួង និងស្ថាប័នជាច្រើន។ ទោះជាយ៉ាងណា ស្ថាប័នរដ្ឋមួយចំនួនមានមជ្ឈមណ្ឌលទិន្នន័យដាច់ដោយឡែករៀងខ្លួន ដែលមិនត្រូវបានតភ្ជាប់ និងប្រើប្រាស់ជាស្ថាប័នតែមួយដើម្បីធានាសក្តានុពលពេញលេញ។ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ឬ CamDX ជាដំណោះស្រាយមួយសម្រាប់បញ្ហានេះ។ CamDX ជាវេទិកាអនឡាញសម្រាប់លើកកម្ពស់អន្តរប្រតិបត្តិការ និងសមាហរណកម្មប្រព័ន្ធព័ត៌មានរបស់ស្ថាប័នរដ្ឋ និងសម្រាប់ការតភ្ជាប់ជាមួយប្រព័ន្ធវិស័យឯកជន។ សម្រាប់ព័ត៌មានបន្ថែមស្តីពី CamDX សូមមើលប្រអប់ខាងក្រោម។

### ប្រអប់ទី១០៖ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)[96]

ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ត្រូវបានបង្កើតឡើងក្រោមអនុក្រឹត្យលេខ១៦៤ ខែសីហា ឆ្នាំ២០២១[97] ។ CamDX ត្រូវបានបង្កើតឡើងក្រោមមជ្ឈមណ្ឌលទិន្នន័យដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ CamDX ជាវិទិកាអនឡាញសម្រាប់ការផ្លាស់ប្តូរទិន្នន័យពហុភាគី រវាងស្ថាប័នសាធារណៈ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងវិស័យឯកជន។ ឧ. គេអាចចុះបញ្ជីអាជីវកម្ម តាមរយៈកម្មវិធីចុះបញ្ជីអាជីវកម្មអនឡាញក្នុង CamDX ហើយឯកសារពាក់ព័ន្ធនឹងត្រូវបានបញ្ជូនទៅក្រសួងទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម។ CamDX

96 សូមចូលទៅកាន់៖ https://camdx.gov.kh/

97 RGC (2021) Sub-Decree No. 164 on data exchange through Cambodia Data Exchange (CamDX)

មានគោលបំណងកសាងហេដ្ឋារចនាសម្ព័ន្ធមួយដែលសម្រួលដល់ការបង្កភាពងាយស្រួលក្នុងការទទួលបានទិន្នន័យនៅក្នុងមូលដ្ឋានទិន្នន័យរដ្ឋាភិបាល (សេវាសាធារណៈ) ដោយមិនធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងការកាន់កាប់ទិន្នន័យ និងមានការផ្លាស់ប្តូរបច្ចេកទេសតិចតួចបំផុតនៅក្នុងប្រព័ន្ធព័ត៌មានដែលមានស្រាប់។

ដើម្បីផ្លាស់ប្តូរទិន្នន័យតាម CamDX ស្ថាប័ននានាត្រូវចុះឈ្មោះជាសមាជិកនៃវេទិកា CamDX។ តាមបច្ចេកទេស សមាជិករបស់ CamDX នឹងអាចចូលប្រើប្រាស់រាល់ប្រព័ន្ធផ្សេងទៀត ដែលដំណើរការក្នុង CamDX ប៉ុន្តែការទទួលបានទិន្នន័យគឺមានកម្រិតខុសគ្នា និងអាចកំណត់ក្នុង Security Server។

ក្រោយការបង្កើតឡើង សេវាដំបូងដែលត្រូវដំណើរការតាម CamDX គឺការចុះបញ្ជីអាជីវកម្មតាមអនឡាញ។ ក្នុងជំហានដំបូង ការចុះបញ្ជីអាជីវកម្មតាមអនឡាញ គ្របដណ្តប់តែលើទីភ្នាក់ងាររដ្ឋាភិបាលជួរមុខដែលផ្តល់សេវាចុះបញ្ជីអាជីវកម្មប៉ុណ្ណោះ។ តួអង្គសំខាន់ៗទាំងនោះ រួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងពាក់ព័ន្ធផ្សេងទៀតនឹងចូលរួមនៅដំណាក់កាលបន្ទាប់។ ក្នុងជំហាននេះ ក្រសួងមហាផ្ទៃអនុញ្ញាតឱ្យ CamDX ផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណកម្មជាភាសាខ្មែរ ជាមួយប្រព័ន្ធរបស់ពួកគេ ដើម្បីបង្កើនភាពស៊ីសង្វាក់គ្នានៃទិន្នន័យបុគ្គល។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏កំពុងចូលរួមក្នុង CamDX ផងដែរ ដើម្បីដាក់បញ្ចូលទិន្នន័យវិនិយោគជាមួយទិន្នន័យចុះបញ្ជីក្រុមហ៊ុន។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១ ដំណាក់កាលទី២ នៃប្រព័ន្ធចុះបញ្ជីតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ឱ្យដំណើរការ។ ក្នុងដំណាក់កាលនេះ ស្ថាប័នចំនួន៤ ផ្សេងទៀតបានក្លាយជាសមាជិករបស់ CamDX។ ស្ថាប័នទាំងនេះផ្តល់សេវាចំនួន៨ មានជាអាទិ៍ ១) ការចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម ២) ការផ្តល់អាជ្ញាប័ណ្ណដល់ប្រតិបត្តិករទេសចរណ៍ និងភ្នាក់ងារធ្វើដំណើរ ៣) ការផ្តល់អាជ្ញាប័ណ្ណដល់សេវាសណ្ឋាគារ និងការស្នាក់នៅក្នុងវិស័យទេសចរណ៍ ៤) ការផ្តល់អាជ្ញាប័ណ្ណដល់ភោជនីយដ្ឋានក្នុងវិស័យទេសចរណ៍ ៥) អាជ្ញាប័ណ្ណ/លិខិតអនុញ្ញាត/វិញ្ញាបនបត្រសម្រាប់ការធ្វើប្រតិបត្តិការក្នុងវិស័យ ICT ៦) អាជ្ញាប័ណ្ណ/លិខិតអនុញ្ញាត/វិញ្ញាបនបត្រសម្រាប់ការធ្វើប្រតិបត្តិការក្នុងវិស័យប្រៃសណីយ៍ ៧) ការផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មបញ្ចាំ និង ៨) ការផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មផ្ទេរប័ណ្ណកម្មសិទ្ធិ[98]។

[98] Ministry of Economy and Finance (MEF), Press Release: The Official Launch of the Business Registration System on Information Technology Platform Phase II, (Phnom Penh, 1st September 2021). https://www.facebook.com/ministry.economy.finance/photos/pcb.4231226156973490/4231213420308097/

## ៤.៥ អភិបាលកិច្ចទិន្នន័យ និងភាពជាដៃគូនៅកម្រិតអាស៊ាន

**ភាពជាដៃគូនៅកម្រិតអាស៊ាន អាចផ្តល់ឱកាសថ្មីៗសម្រាប់អភិបាលកិច្ចទិន្នន័យនៅកម្ពុជា។** យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) លើកឡើងពីសារៈសំខាន់នៃភាពជាដៃគូនៅកម្រិតអាស៊ានក្នុងការកសាងប្រព័ន្ធស្ថិតិជាតិ។ ក្រៅពីនេះ អ្នកផ្តល់ព័ត៌មានសំខាន់បានលើកឡើងថា កម្ពុជាកំពុងច្បាមយកបទពិសោធន៍ពីតំបន់អាស៊ាន ជាពិសេសពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យ រួមទាំង ទិន្នន័យ Big Data។ ការស្រាវជ្រាវនេះបង្ហាញថា មានការផ្តល់ទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចជាច្រើនក្នុងវេបផតថលស្ថិតិអាស៊ាន[99]។ ប្រសិនបើប្រើប្រាស់បានល្អ សំណុំទិន្នន័យទាំងនោះអាចផ្តល់ប្រយោជន៍ដល់អ្នកស្រាវជ្រាវកម្ពុជាដែលចង់ធ្វើការវិភាគឆ្លងប្រទេសនៅក្នុងតំបន់អាស៊ានស្តីពីបញ្ហាអភិវឌ្ឍន៍ជាក់លាក់។

**យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ផ្តោតអាទិភាពលើភាពជាដៃគូនៅកម្រិតអាស៊ានសម្រាប់បញ្ហាដែលពាក់ព័ន្ធនឹងស្ថិតិជាតិ។** យុទ្ធសាស្ត្រនេះទទួលស្គាល់ថា ប្រព័ន្ធស្ថិតិជាតិត្រូវបំពេញតម្រូវការផ្សេងៗ ទាំងនៅថ្នាក់ជាតិ ថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ ដូចជា អាស៊ាន។ បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាតែងផ្តល់ទិន្នន័យផ្សេងៗដល់ផ្នែកស្ថិតិអាស៊ាន (ASEANstats) ដូចជា ពាណិជ្ជកម្មអន្តរជាតិ និងជញ្ជីងទូទាត់។ ទីភ្នាក់ងារពាក់ព័ន្ធ ដូចជា វិទ្យាស្ថានជាតិស្ថិតិ បានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីធានាគុណភាព ភាពទាន់ពេលវេលា និងភាពអាចប្រៀបធៀបបាននៃស្ថិតិទាំងនេះ ដែលមានសារៈសំខាន់សម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃវិធានការសមាហរណកម្មរបស់អាស៊ាន[100]។

កម្ពុជាបានចូលរួមជាមួយសមភាគីអាស៊ាន ក្នុងការអនុម័តក្រមប្រតិបត្តិប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន (ACSS) នៅឆ្នាំ២០១២ និងបច្ចុប្បន្ន កំពុងអនុវត្តក្រមប្រតិបត្តិនោះ។ ក្រោយការអនុម័តក្របខ័ណ្ឌអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកស្ថិតិ (AFCS) ក្នុងឆ្នាំ២០១០ ប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន (ACSS) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១។ ប្រព័ន្ធនេះរួមបញ្ចូលប្រព័ន្ធស្ថិតិជាតិរបស់រដ្ឋសមាជិកអាស៊ាន និងស្ថាប័នតាមវិស័យពាក់ព័ន្ធក្រោមក្រុមប្រឹក្សាសហគមន៍អាស៊ាន។ តាមការលើកឡើងក្នុងផែនការយុទ្ធសាស្ត្ររបស់ ACSS (២០១៦-២០២៥) ចក្ខុវិស័យរបស់ប្រព័ន្ធនេះគឺការផ្តល់ក្របខ័ណ្ឌសម្រាប់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ការផលិត ការធ្វើឱ្យមានភាពសុខដុម ការផ្សព្វផ្សាយ និងបង្ហាញពីស្ថិតិអាស៊ាន។ ផែនការយុទ្ធសាស្ត្រនេះក៏មានរៀបរាប់ពីយន្តការសម្រាប់ធានាការអភិវឌ្ឍប្រកបដោយចីរភាពក្នុងការផ្សព្វផ្សាយព័ត៌មានស្ថិតិ ការបំពេញតម្រូវការព័ត៌មានស្ថិតិ និងការកសាងសមត្ថភាពផ្នែកស្ថិតិផងដែរ[101]។

---

[99] សម្រាប់ការប្រើប្រាស់ផតថលនេះ សូមចូលទៅកាន់៖ https://www.aseanstats.org/

[100] MOP (2019) NSDS (2019-2023)

[101] https://asean.org/our-communities/economic-community/monitoring-regional-economic-integration/asean-community -statistical-system/

**ផ្នែកស្ថិតិរបស់អាស៊ាន (ASEANstats) ទទួលខុសត្រូវលើការងារពាក់ព័ន្ធនឹងស្ថិតិ និងទិន្នន័យរបស់អាស៊ាន។** នេះជាផ្នែកមួយក្នុងចំណោមផ្នែកនានាដែលចំណុះឱ្យនាយកដ្ឋានលេខាធិការដ្ឋានអាស៊ាននៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលមានតួនាទីផ្តល់សេវាស្ថិតិដល់លេខាធិការដ្ឋានអាស៊ាន ស្ថាប័នអាស៊ាន និងភាគីពាក់ព័ន្ធក្នុងអាស៊ាន។ ASEANstats ខិតខំពង្រឹងការអនុវត្ត ACSS និងអនុម័តគោលការណ៍គ្រឹះរបស់អង្គការសហប្រជាជាតិស្តីពីស្ថិតិផ្លូវការ។ ASEANstats មានគោលបំណងប្រែក្លាយទៅជាប្រភពផ្តាច់មុខនៃស្ថិតិអាស៊ានដែលមានភាពពាក់ព័ន្ធ អាចប្រៀបធៀបបាន និងទាន់ពេលវេលា ដើម្បីសម្រួលដល់ការកសាងចំណេះដឹងក្នុងសហគមន៍អាស៊ានដែលមានភាពរឹងមាំ ប្រកបដោយទំនុកចិត្ត និងទទួលបានការគោរព។ តារាងខាងក្រោមសង្ខេបពីមុខងារ ផលិតផល និងសេវាសំខាន់ៗ យន្តការសម្របសម្រួល និងក្រុមការងាររបស់ ASEANstats។

តារាងទី៦៖ ព័ត៌មានសំខាន់ៗស្តីពី ASEANstats[102]

| ព័ត៌មានសំខាន់ៗ | ការបរិយាយ |
|---|---|
| មុខងារ | - បង្កើតសូចនាករថ្នាក់តំបន់ ក្របខ័ណ្ឌទិន្នន័យ និងប្រព័ន្ធសម្រាប់ពិនិត្យតាមដានគោលដៅ និងគំនិតផ្តួចផ្តើមរបស់សហគមន៍អាស៊ាន<br>- ចងក្រង បូកសរុប និងផ្សព្វផ្សាយព័ត៌មានស្ថិតិស្តីពីតំបន់អាស៊ាន និងរដ្ឋសមាជិកអាស៊ាន<br>- ផ្តល់សេវាស្ថិតិដល់លេខាធិការដ្ឋានអាស៊ាន ស្ថាប័នអាស៊ាន និងភាគីពាក់ព័ន្ធក្នុងអាស៊ាន |

[102] https://www.aseanstats.org/about-aseanstats/

| | |
|---|---|
| | - ធ្វើឱ្យមានភាពសុខដុមសម្រាប់ស្ថិតិអាស៊ាន៖ ការធ្វើឱ្យទស្សនាទាន និយមន័យ ការបែងចែកប្រភេទ និងអភិក្រម មានស្តង់ដារ<br>- អនុវត្ត និងសម្របសម្រួលកម្មវិធីស្ថិតិថ្នាក់តំបន់ និងសកម្មភាពនានា ដូចជា សកម្មភាពរបស់ក្រុមការងារក្នុងក្របខ័ណ្ឌអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកស្ថិតិ ក្រោមការណែនាំពីគណៈកម្មាធិការប្រព័ន្ធស្ថិតិនៃសហគមន៍អាស៊ាន (ACSS) និង<br>- អនុវត្តគោលនយោបាយ និងសម្របសម្រួលភាពជាដៃគូរវាងគណៈកម្មាធិការ ACSS ស្ថាប័នអាស៊ាន និងសហគមន៍ស្ថិតិអន្តរជាតិ/តំបន់។ |
| ផលិតផល/សេវាសំខាន់ៗ | - ឯកសារស្ថិតិ<br>- មូលដ្ឋានទិន្នន័យអនឡាញ<br>- ការស្នើសុំទិន្នន័យ |
| យន្តការសម្របសម្រួល | - គណៈកម្មាធិការប្រព័ន្ធស្ថិតិនៃសហគមន៍អាស៊ាន (ACSS)<br>- អនុគណៈកម្មាធិការ ACSS ទទួលបន្ទុករៀបចំផែនការ និងសម្របសម្រួល (ACSS-SCPC)<br>- អគ្គនាយកដ្ឋានតាមដានសមាហរណកម្មអាស៊ាន (AIMD) |
| ក្រុមការងារ | - ក្រុមការងារស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ (WGIMTS)<br>- ក្រុមការងារស្ថិតិវិនិយោគអន្តរជាតិ (WGIIS)<br>- ក្រុមការងារស្ថិតិពាណិជ្ជកម្មអន្តរជាតិផ្នែកសេវាកម្ម (WGSITS)<br>- ក្រុមការងារចែករំលែកទិន្នន័យ វិភាគ និងផ្សព្វផ្សាយស្ថិតិអាស៊ាន (WGDSA)<br>- ក្រុមការងារសូចនាករគោលដៅអភិវឌ្ឍន៍សង្គម (WGSDGI)<br>- ក្រុមការងារប្រព័ន្ធគណនីជាតិ (WGSNA) |

**ក្រៅពីនេះ អាស៊ានក៏មានគំនិតផ្តួចផ្តើមដែលផ្តោតសំខាន់លើវិស័យឯកជនផងដែរ។** ការស្រាវជ្រាវនេះបានរំលេចឧទាហរណ៍២។ ទីមួយ គឺមូលដ្ឋានទិន្នន័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអាស៊ានដែលជាវេទិកាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមអនឡាញ ដែលអាចឱ្យអ្នកមានចំណាប់អារម្មណ៍ស្វែងរកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីក្នុងតំបន់អាស៊ានបានយ៉ាងងាយស្រួល[103] ប៉ុន្តែបច្ចុប្បន្ននេះ មិនសូវមានការបញ្ចូលទិន្នន័យសម្រាប់កម្ពុជានោះទេ[104]។

**គំនិតផ្តួចផ្តើមមួយទៀតដែលពាក់ព័ន្ធនឹងទិន្នន័យ និងផ្តោតលើវិស័យឯកជន គឺក្របខ័ណ្ឌអាស៊ានស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៨។** ក្របខ័ណ្ឌនេះបង្ហាញពីទំនាក់ទំនងរវាងអភិបាលកិច្ចទិន្នន័យ សេដ្ឋកិច្ចឌីជីថល និងអាជីវកម្មខ្នាតតូច។ ដោយសារមានភាពពាក់ព័ន្ធគ្នាកាន់តែច្រើនឡើងរវាងទិន្នន័យ អ្វីៗដែលនៅជុំវិញខ្លួន និងមនុស្ស ទំនុកចិត្តលើទិន្នន័យបានក្លាយជាបុរេលក្ខខណ្ឌសម្រាប់ការសម្រេចបានផលចំណេញពេញលេញពីបរិវត្តកម្មឌីជីថល។ សហគ្រាសខ្នាតតូច និងមធ្យម កំពុងរំលេចទំនាក់ទំនងរវាងការរក្សាតុល្យភាពគំនិតផ្តួចផ្តើមឌីជីថល និងការគ្រប់គ្រងការការពារទិន្នន័យ និងការធានាសុវត្ថិភាពនៃភាពឯកជនរបស់អតិថិជន ដើម្បីធានាថា វិធានការទាំងនោះមិនបង្អាក់នវានុវត្តន៍។ ដូច្នេះ ចាំបាច់ត្រូវផ្តោតសំខាន់លើអភិបាលកិច្ចទិន្នន័យឌីជីថល ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ច និងការប្រើប្រាស់បច្ចេកវិទ្យានៅគ្រប់វិស័យទាំងអស់ក្នុងរដ្ឋសមាជិកអាស៊ាន[105]។

**ក្របខ័ណ្ឌអាស៊ានស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល បានកំណត់យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមជាក់លាក់មួយចំនួន។** អាទិភាពជាយុទ្ធសាស្ត្រ រួមមាន ១) វដ្តជីវិត និងប្រព័ន្ធអេកូឡូស៊ីទិន្នន័យ ២) លំហូរទិន្នន័យឆ្លងដែន ៣) ឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ និង ៤) ក្របខ័ណ្ឌច្បាប់ និងគតិយុត្តិ។ អាទិភាពទាំង៤ នេះទ្រទ្រង់ដោយគំនិតផ្តួចផ្តើមចំនួន ៤ មានជាអាទិ៍ ១) ក្របខ័ណ្ឌបែងចែកប្រភេទទិន្នន័យអាស៊ាន ២) យន្តការអាស៊ានសម្រាប់លំហូរទិន្នន័យឆ្លងដែន ៣) វេទិកានវានុវត្តន៍ឌីជីថលអាស៊ាន និង ៤) វេទិកាអាស៊ានស្តីពីឯកជនភាព និងការការពារទិន្នន័យ។ ចំណុចសំខាន់ៗមានសង្ខេបក្នុងជ្យាក្រាមខាងក្រោម។

103 សូមចូលទៅកាន់៖ http://www.asean-gidatabase.org/gidatabase/

104 គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ មានម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតែ ៥ ប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជីនៅកម្ពុជា រួមមាន ម្រេចកំពតស្ករត្នោតខេត្តកំពង់ស្ពឺ ស្រាវីស្គី Scotch ក្រូចថ្លុងកោះទ្រង់ និងឃ្មុំព្រៃខេត្តមណ្ឌលគិរី។ សូមចូលទៅកាន់ http://www.asean-gidatabase.org/gidatabase/gi-search-2។

105 ADGSOM (2021) ASEAN data management framework: Data governance and protection throughout the data lifecycle.

### រូបភាពទី៥៖ អាទិភាព និងគំនិតផ្តួចផ្តើមនានា៖ ក្របខ័ណ្ឌអាស៊ានស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល

| អាទិភាពជាយុទ្ធសាស្ត្រ | | | |
|---|---|---|---|
| វដ្តជីវិត និងប្រព័ន្ធអេកូឡូស៊ីទិន្នន័យ | លំហូរទិន្នន័យឆ្លងដែន | ឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ | ក្របខ័ណ្ឌច្បាប់ និងគតិយុត្តិ |
| លទ្ធផលចុងក្រោយ៖<br>• អភិបាលកិច្ចទិន្នន័យទូទាំងវដ្តជីវិតទិន្នន័យ (ឧ. ការប្រមូល ការប្រើប្រាស់ ការទទួលបាន និងការរក្សាទុក)<br>• ការការពារគ្រប់គ្រាន់លើប្រភេទទិន្នន័យផ្សេងៗ | លទ្ធផលចុងក្រោយ៖<br>• ភាពប្រាកដប្រជារបស់អាជីវកម្មចំពោះលំហូរទិន្នន័យឆ្លងដែន<br>• មិនមានការរឹតត្បិតខុសទំនងលើលំហូរទិន្នន័យ | លទ្ធផលចុងក្រោយ ៖<br>• ការអភិវឌ្ឍសមត្ថភាពទិន្នន័យ (ហេដ្ឋារចនាសម្ព័ន្ធ និងជំនាញ)<br>• ការទាញប្រយោជន៍ពបច្ចេកវិទ្យាថ្មីៗ | លទ្ធផលចុងក្រោយ៖<br>• ការធ្វើឱ្យមានភាពសុខដុមក្នុងទិដ្ឋភាពច្បាប់ និងគតិយុត្តិនៅអាស៊ាន (ដូចជាការការពារទិន្នន័យផ្ទាល់ខ្លួន)<br>• ការរៀបចំ និងការយកលំនាំតាមការអនុវត្តល្អបំផុត |
| គំនិតផ្តួចផ្តើមក្របខ័ណ្ឌបែងចែកប្រភេទទិន្នន័យអាស៊ាន | គំនិតផ្តួចផ្តើមយន្តការអាស៊ានសម្រាប់លំហូរទិន្នន័យឆ្លងដែន | គំនិតផ្តួចផ្តើមវេទិកានវានុវត្តន៍ឌីជីថលអាស៊ាន | គំនិតផ្តួចផ្តើមវេទិកាអាស៊ានស្តីពីឯកជនភាព និងការការពារទិន្នន័យ |

**ទិន្នន័យ Big Data និងការជំរុញការចូលរួមរបស់វិស័យឯកជន គឺជាប្រធានបទចម្បងដែលពាក់ព័ន្ធនឹងស្ថិតិក្នុងកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០២២។** យោងតាមមន្ត្រីវិទ្យាស្ថានជាតិស្ថិតិដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំព្រឹត្តិការណ៍នេះ រដ្ឋសមាជិកអាស៊ាននឹងពិភាក្សាពីរបៀបដែលប្រទេសនីមួយៗ និងតំបន់អាស៊ានទាំងមូលអាចពន្លឿនការអនុវត្តទិន្នន័យ Big Data ដើម្បីកែលម្អប្រព័ន្ធស្ថិតិជាតិ។ គំនិតទូលំទូលាយគឺប្រទេសនីមួយៗ នឹងដាក់ស្នើជាយោបល់រៀងៗខ្លួនដែលឆ្លុះបញ្ចាំងពីតម្រូវការ និងកម្រិតអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងនោះ គំនិតមួយចំនួននឹងត្រូវបានសាកល្បង ហើយមេរៀនដែលទទួលបាននឹងត្រូវបានចែករំលែកក្នុងចំណោមរដ្ឋសមាជិក។ កិច្ចការដ៏សំខាន់មួយគឺការជំរុញការចូលរួមជាប្រព័ន្ធរបស់វិស័យឯកជនដែលមានភាពជឿនលឿន និងមានបទពិសោធន៍ច្រើនក្នុងផ្នែកទិន្នន័យ Big Data[106]។

---

106 បទសម្ភាសន៍ជាមួយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ (ថ្ងៃទី៤ ខែមករា ឆ្នាំ២០២២)

## ៥. ករណីសិក្សាចំនួន៤ ស្តីពីការប្រើប្រាស់ទិន្នន័យ និងដំណើរការគោលនយោបាយ

**ដើម្បីបង្ហាញបន្ថែមទៀតពីប្រធានបទស្តីពីដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា ការសិក្សានេះនឹងបង្ហាញករណីសិក្សាចំនួន៤ មានជាអាទិ៍** ១) កិច្ចគាំពារសង្គមក្នុងអំឡុងពេលនៃការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ២) កំណែទម្រង់វិមជ្ឈការ ៣) ការផ្តល់ជំនួយដល់សហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យទេសចរណ៍នៅអំឡុងវិបត្តិកូវីដ-១៩ និង ៤)ការជំរុញការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសហគមន៍។ គោលបំណងចម្បងគឺដើម្បីបង្ហាញថាខណៈដែលមានភាពដូចគ្នាមួយចំនួនលើលក្ខណៈសំខាន់ៗ និងដំណើរការ ដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជាប្រែប្រួលតាមវិស័យ និងបញ្ហា។ មូលហេតុនៃការជ្រើសរើសករណីសិក្សាទាំងនេះ គឺមួយផ្នែកដោយសារតែវាជួយបង្ហាញពីចំណុចខុសគ្នាទាំងនេះ និងមួយផ្នែកទៀតគឺដោយសារតែវាសុទ្ធតែជាផ្នែកសំខាន់ៗក្នុងផែនការស្តារឡើងវិញរបស់កម្ពុជា។ គេរំពឹងថា ការពិភាក្សាពីករណីសិក្សាទាំងនេះនឹងរំលេចសារមួយចំនួនដូចខាងក្រោម៖

- គុណភាពនៃដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា ប្រែប្រួលតាមវិស័យ/បញ្ហានីមួយៗ អាស្រ័យលើកត្តាសំខាន់ៗជាច្រើន ដូចជា កម្រិតនៃចំណាប់អារម្មណ៍ផ្នែកនយោបាយ ការសម្របសម្រួលអន្តរក្រសួងដែលត្រូវការចាំបាច់ គុណភាពនៃការគ្រប់គ្រង និងអ្នកជំនាញក្នុងទីភ្នាក់ងារដឹកនាំ និងគុណភាពនៃក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃរបស់វិស័យ/បញ្ហានោះ។
- ទោះបីជាមានចំណុចខុសគ្នាក៏ដោយ ប៉ុន្តែលក្ខណៈជារួមមួយ គឺមានទិន្នន័យច្រើនបង្គួរដែលត្រូវបានផលិតឡើង ប៉ុន្តែនៅតែមានបញ្ហាប្រឈមក្នុងការចែករំលែក និងប្រើប្រាស់ទិន្នន័យ។ ទោះជាយ៉ាងណា គេរំពឹងថានឹងអាចដោះស្រាយបញ្ហាទាំងនេះបន្តិចម្តងៗ ប្រសិនបើរដ្ឋាភិបាលអនុវត្តផែនការផ្សេងៗដែលមានស្រាប់ និងប្រសិនបើផ្តល់ឱកាសសម្រាប់ការរួមចំណែកពីតួអង្គមិនមែនរដ្ឋ។
- ក្នុងករណីនីមួយៗ កម្ពុជាអាចច្បាមយកចំណេះដឹង និងការរៀនសូត្រយ៉ាងច្រើនពីកម្រិតអាស៊ាន។ ដូច្នេះហើយទើបមានការដាក់បញ្ចូលផ្នែកមួយស្តីពី "ភាពពាក់ព័ន្ធរបស់អាស៊ាន" ក្នុងករណីនីមួយៗ។

## ៥.១ ករណីសិក្សាទី១៖ កិច្ចគាំពារសង្គមក្នុងអំឡុងពេលឆ្លើយតបនឹងវិបត្តិកូវីដ-១៩

**ករណីសិក្សាទី១ ផ្តោតលើការផលិត និងប្រើប្រាស់ទិន្នន័យក្នុងកិច្ចគាំពារសង្គមនៅកម្ពុជា។** ករណីទីមួយនេះបង្ហាញពីមូលហេតុដែលរដ្ឋាភិបាលកម្ពុជាខិតខំលើកកម្ពស់កិច្ចគាំពារសង្គម ជាពិសេសក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ និងក្នុងអំឡុងវិបត្តិកូវីដ-១៩។ ករណីសិក្សានេះលើកឡើងថា ការប្តេជ្ញាចិត្តផ្នែកនយោបាយនេះជាកត្តាសំខាន់មួយដែលអាចឱ្យមានការប្រើប្រាស់ និងចែករំលែកទិន្នន័យប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការគោលនយោបាយ ទោះបីជានៅមានបញ្ហាមួយចំនួនក្នុងការសម្របសម្រួល និងផ្នែកបច្ចេកទេសក្តី។

### ៥.១.១ កិច្ចគាំពារសង្គម និងការប្តេជ្ញាចិត្តផ្នែកនយោបាយ

**កិច្ចគាំពារសង្គមក្នុងនាមជាគោលនយោបាយមួយ ត្រូវបានកំណត់និយមន័យដោយឡែក និងមានវិសាលភាពផ្សេងៗផងដែរ។** សម្រាប់កម្ពុជា កិច្ចគាំពារសង្គមសំដៅលើប្រព័ន្ធមួយដែលមានគោលនយោបាយ កម្មវិធី សកម្មភាព និងក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌស្ថាប័នដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារ និងបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការប្រឈមមុខដោយប្រសិទ្ធភាពទៅនឹងវិបត្តិសេដ្ឋកិច្ច និងភាពងាយរងគ្រោះដែលបណ្តាលមកពីការប្រែប្រួលលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ។ កិច្ចគាំពារសង្គមនៅកម្ពុជាចែកចេញជាជំនួយសង្គម និងការធានារ៉ាប់រងសង្គម[107]។ និយមន័យខាងលើគឺមួយភាគធំស៊ីសង្វាក់គ្នានឹងការអនុវត្តជាអន្តរជាតិ[108]។

**គោលនយោបាយចម្បងស្តីពីកិច្ចគាំពារសង្គមនៅកម្ពុជា គឺក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥)។** ឯកសារគោលនយោបាយនេះរៀបរាប់ពីចក្ខុវិស័យ គោលបំណង លទ្ធផលរំពឹងទុក សកម្មភាព ក៏ដូចជាបញ្ហាឆ្លងវិស័យក្នុងប្រព័ន្ធគាំពារសង្គម។ ឯកសារនេះក៏មានតារាងមួយដែលបង្ហាញពីសកម្មភាពជាក់លាក់ដែលត្រូវធ្វើឡើងដោយទីភ្នាក់ងារមួយចំនួនផងដែរ។ គោលនយោបាយនេះត្រូវបានតាក់តែងឡើងក្រោមការពិគ្រោះយោបល់ និងផ្អែកតាមធាតុចូលពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ទោះជាយ៉ាងណា គម្លាតធំៗក្នុងឯកសារនេះរួមមានព័ត៌មានស្តីពីតម្រូវការហិរញ្ញប្បទាន និងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ។

**កិច្ចគាំពារសង្គមជាគោលនយោបាយមួយដ៏ស្មុគស្មាញ និងចំណាយថវិកាច្រើនដែលស្ថិតក្រោមការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល។** ការប្តេជ្ញាចិត្តខ្ពស់កម្រិតនេះ (ជាពិសេសនៅពេលពាក់ព័ន្ធនឹងចំណាយយ៉ាងច្រើនរបស់រដ្ឋាភិបាល) គឺមិនធម្មតាឡើយសម្រាប់កម្ពុជា។ មុនវិបត្តិកូវីដ-១៩ កម្មវិធី

[107] RGC (2016) NSPPF (2016-2025)
[108] សម្រាប់ព័ត៌មានបន្ថែម សូមមើល Schuring, E and Loewe, M (2021) Handbook on social protection systems.

ជំនួយសង្គមរបស់កម្ពុជាគ្របដណ្ដប់លើបញ្ចាភាគប្រជាជនក្រីក្របំផុតមិនដល់ ២% ផងទេ[109]។ ក្នុងឆ្នាំ២០១៥ ចំណែកនៃវិភាជថវិការបស់រដ្ឋាភិបាលសម្រាប់កម្មវិធីទាំងនេះគឺប្រមាណ ០,៩% ដែលជាចំនួនទាបខ្លាំងជាងមធ្យមភាគជាសកល[110] ប៉ុន្តែក្នុងពេលមានវិបត្តិកូវីដ-១៩ រដ្ឋាភិបាលបានចាត់វិធានការរហ័សដើម្បីជួយដល់ប្រជាជនងាយរងគ្រោះ និងរងផលប៉ះពាល់។ យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គិតត្រឹមខែសីហា ឆ្នាំ២០២១ រដ្ឋាភិបាលបានចំណាយថវិកាជាង ៤១០លានដុល្លារលើប្រជាជនចំនួន ២,៦លាននាក់[111]។ របាយការណ៍នេះលើកឡើងថារដ្ឋាភិបាលប្ដេជ្ញាអនុវត្តកិច្ចគាំពារសង្គម ព្រោះវិធានការនេះស៊ីសង្វាក់គ្នានឹងគោលនយោបាយផ្លូវការ និងសំខាន់បំផុតគឺបន្សុីគ្នានឹងយុទ្ធសាស្រ្តចតុកោណរបស់រដ្ឋាភិបាល។

## ៥.១.២ ការប្រើប្រាស់ទិន្នន័យ និងកំណែទម្រង់បន្ថែម

ការរៀបចំ និងការអនុវត្តកម្មវិធីគាំពារសង្គម ជាដំណើរការមួយដែលប្រើប្រាស់ទិន្នន័យយ៉ាងច្រើន និងទាមទារការសម្របសម្រួលច្រើនផងដែរ។ តាមនិយមន័យ កិច្ចគាំពារសង្គមជាគោលនយោបាយឆ្លងវិស័យដែលពាក់ព័ន្ធនឹងភាគីផ្សេងៗដែលផ្ដល់ធាតុចូល និងទិន្នន័យ នៅពេលរៀបចំឧបករណ៍គាំពារសង្គម។ ក្រៅពីនេះ តម្រូវការទិន្នន័យកើនឡើងជាលំដាប់ក្នុងដំណាក់កាលអនុវត្តន៍ ដូចជា ទិន្នន័យស្ដីពីការគ្របដណ្ដប់ និងការចុះបញ្ជី តម្រូវការ និងស្ថានភាព លក្ខណៈសម្បត្តិ និងការចុះឈ្មោះ ការទូទាត់ ការផ្ដល់សេវា។ល។ ដូច្នេះ ការគ្រប់គ្រងទិន្នន័យត្រូវបានចាត់ទុកជាចំណុចស្នូលនៃប្រព័ន្ធគាំពារសង្គមរបស់ប្រទេសមួយ[112]។

**ការផលិត ការប្រើប្រាស់ និងការចែករំលែកទិន្នន័យក្នុងកិច្ចគាំពារសង្គម គឺជាការអនុវត្តល្អ។** ដើម្បីកំណត់អ្នកទទួលផលគោលដៅ មានការបង្កើត និងកែលម្អសំណុំទិន្នន័យផ្សេងៗដោយរដ្ឋាភិបាលក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍។ មូលដ្ឋានទិន្នន័យចម្បងគឺអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬ IDPoor។ តាំងពីឆ្នាំ២០០៨ មក កម្មវិធី IDPoor ត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារទាល់ក្រនៅទូទាំងប្រទេស ដោយចាប់ផ្ដើមពីប្រជាជនជនបទ និងពង្រីកទៅប្រជាជនទីក្រុងចាប់តាំងពីឆ្នាំ២០១៨ មក។ កម្មវិធី IDPoor ស្ថិតក្នុងចំណោមមូលដ្ឋានទិន្នន័យរដ្ឋាភិបាលមួយចំនួនតូច ដែលត្រូវបានផ្សព្វផ្សាយតាមគេហទំព័រ ធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ និងងាយស្រួលប្រើប្រាស់[113]។

---
[109] World Bank Group. 2017. Cambodia: Sustaining Strong Growth for the Benefit of All. Washington, DC.
[110] UNDP ( 2020 ) Meeting the costs and maximizing the impact of social protection in Cambodia.
[111] https://www.amro-asia.org/lifting-cambodia-out-of-the-COVID-19-rut-with-support-from-the-cash-transfer-program/
[112] Schuring, E and Loewe, M ( 2021 ) Handbook on social protection systems.

ទោះបីជាមានព្រំដែនកំណត់ខ្លះក៏ដោយ ប៉ុន្តែកម្មវិធី IDPoor ត្រូវបានចាត់ទុកថាមានប្រសិទ្ធផល។ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រទាំងអស់សុទ្ធតែប្រឈមនឹងបញ្ហាសមិទ្ធកម្ម ជាពិសេសដោយសារតែជាទូទៅមានភាពក្រៅផ្លូវការច្រើនពេក[114]។ យោងតាមការពិនិត្យឡើងវិញដោយ OECD ក្នុងឆ្នាំ២០១៧ កម្មវិធី IDPoor បានប្រឈមនឹងបញ្ហាជាច្រើនដែលកើតមានជាទូទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កំហុសក្នុងការដាក់បញ្ចូល និងការផាត់ចេញ។ ទោះជាយ៉ាងណា ប្រព័ន្ធនេះត្រូវបានគេចាត់ទុកថាមានប្រសិទ្ធផល[115]។ ផ្អែកតាមបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ដែលត្រូវបានធ្វើឡើងសម្រាប់ការសិក្សានេះ ក្រសួងផែនការរួមជាមួយនឹងដៃគូអភិវឌ្ឍន៍ បាន និងកំពុងខិតខំដោះស្រាយបញ្ហាទាំងនេះ តាមរយៈការកែលម្អកម្រងសំណួរ ការពិចារណាដាក់បញ្ចូលក្រុមងាយរងគ្រោះថ្មីៗ (ឧ. ជនមានពិការភាព អ្នកផ្ទុកមេរោគអេដស៍) និងការបង្កើនការផ្សព្វផ្សាយទិន្នន័យ[116]។

វឌ្ឍនភាពដ៏ធំមួយទៀតដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទិន្នន័យក្នុងកិច្ចគាំពារសង្គម គឺការអនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកាន់តែគ្រប់ជ្រុងជ្រោយ។ ដូចការលើកឡើងពីខាងដើម ដំណើរការគោលនយោបាយរបស់រដ្ឋាភិបាល ច្រើនតែខ្វះចន្លោះនៅដំណាក់កាលពិនិត្យតាមដាន និងវាយតម្លៃ។ ដូច្នេះ ការអនុម័តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃក្នុងឆ្នាំ២០២០ ដោយក្រុមប្រឹក្សាជាតិគាំពារសង្គម គឺជាសមិទ្ធផលគួរឱ្យកត់សម្គាល់មួយ (សូមមើលតារាងខាងក្រោម)។ ទោះជាយ៉ាងណា បញ្ហាប្រឈមដែលនៅសេសសល់គឺការសម្របសម្រួល និងការប្រើប្រាស់ទិន្នន័យពីទីភ្នាក់ងារផ្សេងៗ។

113 សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ https://mop.idpoor.gov.kh/

114 Brown, C et al (2018) A poor means test? Econometric targeting in Africa, Journal of Development Economics, Elsevier, vol. 134(C), p. 109-124.

115 OECD (2017) Social protection system review of Cambodia, OECD Development Pathways, OECD Publishing, Paris.

116 បទសម្ភាសន៍ជាមួយក្រសួងផែនការ

## តារាងទី៧៖ ស្ថាប័ន និងប្រភពទិន្នន័យក្នុងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកិច្ចគាំពារសង្គម[117]

| ល.រ | ស្ថាប័ន | ប្រភពទិន្នន័យ |
|---|---|---|
| ១ | ក្រសួងសុខាភិបាល (MoH) | - ស្ថិតិសេវា<br>- មូលដ្ឋានទិន្នន័យស្តីពីការចុះបញ្ជី<br>- ការប៉ាន់ស្មានចំនួនប្រជាជន<br>- មូលនិធិសមធម៌សុខាភិបាល<br>- កំណត់ត្រាវិក្កយបត្រ<br>- កំណត់ត្រាការទូទាត់ |
| ២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) | - របាយការណ៍ចំណាយ<br>- មូលដ្ឋានទិន្នន័យស្តីពីការចុះបញ្ជី<br>- ស្ថិតិសេវា<br>- កំណត់ត្រាវិក្កយបត្រ<br>- កំណត់ត្រាការទូទាត់ |
| ៣ | ក្រសួងផែនការ | - ប្រព័ន្ធចុះបញ្ជី ID Poor<br>- អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| ៤ | ក្រសួងអប់រំ យុវជន និងកីឡា (អយក) | - របាយការណ៍ចំណាយ<br>- របាយការណ៍របស់ អយក<br>- មូលដ្ឋានទិន្នន័យស្តីពីការចុះបញ្ជី<br>- បញ្ជីសាលារៀនសាធារណៈ<br>- ការប៉ាន់ស្មានចំនួនប្រជាជន<br>- ស្ថិតិសេវា<br>- កំណត់ត្រាវិក្កយបត្រ<br>- កំណត់ត្រាការទូទាត់ |
| ៥ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - តារាងផែនការថវិកា<br>- របាយការណ៍ចំណាយ |

117 NSPC (2021) M&E framework for social protection in Cambodia

| | | |
|---|---|---|
| ៦ | បេឡាជាតិសន្តិសុខសង្គម (បសស) | - របាយការណ៍ចំណាយ<br>- របាយការណ៍ហិរញ្ញវត្ថុ<br>- របាយការណ៍វិភាគហិរញ្ញវត្ថុ<br>- មូលដ្ឋានទិន្នន័យស្តីពីការចុះបញ្ជី<br>- ការប៉ាន់ស្មានចំនួនប្រជាជន<br>- ស្ថិតិសេវា<br>- កំណត់ត្រាវិក្កយបត្រ<br>- កំណត់ត្រាការទូទាត់<br>- ផែនការថវិកា |
| ៧ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | - របាយការណ៍ចំណាយ<br>- ការប៉ាន់ស្មានចំនួនប្រជាជន<br>- ស្ថិតិសេវា<br>- កំណត់ត្រាវិក្កយបត្រ<br>- កំណត់ត្រាការទូទាត់ |
| ៨ | វិទ្យាស្ថានជាតិសុខភាពសាធារណៈ | - អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា<br>- ស្ថិតិសេវា<br>- លទ្ធផលនៃការវិភាគដោយប្រើប្រាស់ម៉ូដែល |
| ៩ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | - លទ្ធផលនៃការវិភាគដោយប្រើប្រាស់ម៉ូដែល<br>- ប្រព័ន្ធត្រួតពិនិត្យសវនកម្ម<br>- របាយការណ៍ចុះវាល<br>- ផ្ទាំងបង្ហាញព័ត៌មានស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ<br>- សន្ទស្សន៍ Live Rice |

ក្រុមប្រឹក្សាជាតិគាំពារសង្គម កត់សម្គាល់ពីភាពចាំបាច់ក្នុងការកែលម្អការគ្រប់គ្រងទិន្នន័យ។ អាទិភាពមួយក្នុងចំណោមអាទិភាពកំណែទម្រង់ដែលបានគ្រោងឡើង គឺការបង្កើតប្រព័ន្ធផ្តល់សេវាផ្អែកតាម ICT ដែលទ្រទ្រង់កម្មវិធីគាំពារសង្គមផ្សេងៗ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី មានផែនការជាស្រេចសម្រាប់គាំទ្រដល់ផ្នែកនេះ។ គម្រោងជំនួយបច្ចេកទេសត្រូវបានរំពឹងថានឹងបង្កើតជាថ្នាលឌីជីថលរួមមួយសម្រាប់ផ្តល់កម្មវិធីគាំពារសង្គមដែលគ្របដណ្តប់

គ្រប់ជ្រុងជ្រោយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងគ្របដណ្តប់លើផ្នែកទិន្នន័យសំខាន់ៗនៃកិច្ចគាំពារសង្គម ដូចជា ការចុះបញ្ជី ការកំណត់អត្តសញ្ញាណ ការចុះឈ្មោះអ្នកទទួលផល ការផ្តល់សេវាសង្គម និងការពិនិត្យតាមដាន[118]។

### ៥.១.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន

សេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម បូករួមនឹងក្របខ័ណ្ឌថ្នាក់តំបន់ និងផែនការសកម្មភាពអាស៊ាន ត្រូវបានអនុម័តក្នុងឆ្នាំ២០១៨។ អាស៊ានមានចក្ខុវិស័យក្នុងការលើកកម្ពស់ជីវិតរស់នៅរបស់ប្រជាជនអាស៊ាននៅឆ្នាំ២០២៥ ក្រោមគោលដៅបង្កើនសុខុមាលភាព ភាពសុខដុម និងជីវភាពរស់នៅរបស់ប្រជាជនក្នុងវដ្តជីវិតរបស់ពួកគេ។ អាស៊ានមានសកម្មភាពជាច្រើន ក្នុងនោះ សកម្មភាពមួយផ្តោតសំខាន់លើ "ការសហការគ្នាពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល (UHC) ក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ តាមរយៈការពង្រឹងសមត្ថភាពប៉ាន់ប្រមាណ និងគ្រប់គ្រងប្រព័ន្ធសុខាភិបាលដើម្បីទ្រទ្រង់ការគ្របដណ្តប់សុខភាពជាសកល ដោយផ្អែកលើការចែករំលែកបទពិសោធន៍ ព័ត៌មាន និងជំនាញ"[119]។

## ៥.២ ករណីសិក្សាទី២៖ កំណែទម្រង់វិមជ្ឈការ

**វិមជ្ឈការជាករណីមួយទៀតនៃកំណែទម្រង់ឆ្លងវិស័យ។** ស្រដៀងគ្នានឹងកិច្ចគាំពារសង្គមដែរ វិមជ្ឈការដើរតួនាទីសំខាន់សម្រាប់ការផ្តល់សេវានៅថ្នាក់ក្រោមជាតិ។ ប៉ុន្តែក្នុងការអនុវត្ត វិមជ្ឈការទាមទារការសម្របសម្រួលឆ្លងក្រសួងជាច្រើន។ ការលើកយកករណីនេះមកគឺដើម្បីបង្ហាញពីរបៀបដែលកត្តាទាំងនេះរួមចំណែកដល់ការប្រើប្រាស់ និងចែករំលែកទិន្នន័យមានស្រាប់ដោយមិនមានប្រសិទ្ធភាព។ អាចនិយាយបានថា ការចែករំលែក និងប្រើប្រាស់ទិន្នន័យនឹងមានភាពប្រសើរឡើងនាពេលអនាគត ដោយសារតែការសម្របសម្រួលល្អជាងមុនរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់កាន់តែច្រើនឡើងនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងឌីជីថល និងការផ្តោតកាន់តែខ្លាំងលើការពិនិត្យតាមដាន និងវាយតម្លៃនៅថ្នាក់ក្រោមជាតិ។

### ៥.២.១ វិមជ្ឈការ និងបញ្ហាប្រឈមក្នុងការសម្របសម្រួល

**កំណែទម្រង់វិមជ្ឈការនៅកម្ពុជាធ្វើឡើងដោយសន្សឹមៗ និងមិនមានរបាយដូចគ្នានោះទេ** ដោយកំណែទម្រង់ដំបូងចាប់ផ្តើមនៅឆ្នាំ២០០២ តាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់។ ក្នុងឆ្នាំ២០០៨ កំណែទម្រង់នេះត្រូវបានអនុវត្តនៅថ្នាក់ស្រុក ក្រុង និងខណ្ឌ និងថ្នាក់រាជធានី ខេត្ត។ ក្នុងចំណោមព័ត៌មានលម្អិតទាំងអស់ យើងសូមលើកយក ២ចំណុចដែលពាក់ព័ន្ធ។ ទីមួយ កំណែទម្រង់វិមជ្ឈការត្រូវបានដាក់ចេញ ក្រោយពេលដែលកម្ពុជាបានអនុវត្តគោលការណ៍មជ្ឈការ

[118] ADB (2020) Kingdom of Cambodia: Supporting digital Cambodia for inclusive development project.
[119] ASEAN (2018) ASEAN Declaration on Strengthening Social Protection

ជាយូរមកហើយ ពោលគឺតាំងពីកម្ពុជាទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣[120]។ ទីពីរ ពាក់ព័ន្ធនឹងការសម្របសម្រួលឆ្លងក្រសួង វិមជ្ឈការនៅថ្នាក់ឃុំ/សង្កាត់ ដែលបានដាក់ចេញក្នុងឆ្នាំ២០០២ មានលក្ខណៈសាមញ្ញជាងកំណែទម្រង់នៅថ្នាក់ស្រុក ក្រុង ខណ្ឌ ព្រោះវាមិនពាក់ព័ន្ធនឹងការបែងចែកសមត្ថកិច្ច និងធនធានឡើងវិញពីរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ[121]។

ពាក់ព័ន្ធនឹងគោលនយោបាយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ផ្អែកតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលកម្មវិធីលើកទីមួយគឺចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០។ កម្មវិធីនេះមានសមាសភាគ ដូចតទៅ ៖ ១) ការគ្រប់គ្រងកំណែទម្រង់ ២) មុខងារ និងរចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ៣) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤) វិមជ្ឈការសារពើពន្ធ និងការរៀបចំផែនការ និងថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ៥) ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ថ្មីៗនេះ រដ្ឋាភិបាលកម្ពុជាបានអនុម័តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិលើកទី២ (២០២១-២០៣០) ដែលគ្របដណ្ដប់លើសមាសភាគ៥ ដូចខាងលើ និងរួមបញ្ចូលផ្នែកឆ្លងវិស័យសំខាន់ៗ ដូចជា សមភាពយេនឌ័រ សមធម៌ និងបរិយាបន្នសង្គម ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ និងអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក។

**ទោះបីជាមានយន្តការសម្របសម្រួលកម្រិតខ្ពស់ក៏ដោយ ប៉ុន្តែការសម្របសម្រួលក្នុងចំណោមក្រសួងនានានៅតែជាបញ្ហាចោទសម្រាប់កំណែទម្រង់នេះ។** បច្ចុប្បន្ន ការសម្របសម្រួលកម្រិតខ្ពស់គឺគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ ដោយមានក្រសួងមហាផ្ទៃជាប្រធាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន។ កិច្ចការមួយរបស់គណៈកម្មាធិការនេះគឺការជំរុញឱ្យមានការផ្ទេរមុខងារ និងថវិកាទៅរដ្ឋបាលស្រុក ក្រុង ខណ្ឌ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៨ មក គឺមិនសូវមានវឌ្ឍនភាពនោះទេ ជាពិសេសពាក់ព័ន្ធនឹងការផ្ទេរថវិកា។ ក្នុងឆ្នាំ២០២០ ថវិកាស្រុក ក្រុង ខណ្ឌ មានប្រមាណតែ ០,៧% ប៉ុណ្ណោះនៃថវិកាជាតិសរុប[122]។

ការសម្របសម្រួលរវាងកំណែទម្រង់នានា (វិមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) និងក្នុងចំណោមក្រសួងសំខាន់ៗ គឺជាកិច្ចការដ៏លំបាក។ ទោះបីកំណែទម្រង់វិមជ្ឈការ ជាកំណែទម្រង់ទូទាំងរដ្ឋាភិបាលក៏ដោយ ប៉ុន្តែជារឿយៗ កំណែទម្រង់នេះដឹកនាំដោយក្រសួងមហាផ្ទៃ ខណៈដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដឹកនាំដោយក្រសួង

[120] ADB (2011) D&D in Cambodia.
[121] NCDD (2010) NP-SNDD
[122] WB (2021) Intergovernmental transfer in Cambodia

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការសិក្សាកន្លងមកលើកឡើងថា កំណែទម្រង់ទាំង២ នេះមិនមានការសម្របសម្រួលល្អប្រសើរនោះទេ ដោយក្នុងរយៈពេល ១ទសវត្សរ៍កន្លងមកនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានចូលរួមពេញលេញក្នុងកំណែទម្រង់វិមជ្ឈការនោះទេ។ ក្រៅពីនេះ ក្រសួងសាម៉ីមានភាពយឺតយ៉ាវក្នុងការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ[123]។ ប៉ុន្តែចាប់ពីឆ្នាំ២០១៩ មក ស្ថានភាពនេះត្រូវបានរំពឹងថានឹងមានភាពប្រសើរឡើង ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទើបតែបានអនុម័តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ដើម្បីផ្ទេរអំណាចថវិកាកាន់តែច្រើនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ[124]។

## ៥.២.២ បញ្ហាប្រឈមសម្រាប់ការប្រើប្រាស់ទិន្នន័យក្នុងវិមជ្ឈការ

**ការប្រមូល និងគ្រប់គ្រងទិន្នន័យជាឧបករណ៍សំខាន់មួយក្នុងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា។** ក្នុងឆ្នាំ២០២០ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ បានបង្កើត និងដំណើរការមូលដ្ឋានទិន្នន័យយ៉ាងតិច ១៥ ខុសៗគ្នា ដែលចែកចេញជា ៣ក្រុមៈ ១) មូលដ្ឋានទិន្នន័យដែលត្រូវបានប្រើប្រាស់ជាប្រចាំដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ២) មូលដ្ឋានទិន្នន័យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ និង ៣) មូលដ្ឋានទិន្នន័យដែលត្រូវបានធ្វើបច្ចុប្បន្នភាពតាមដំណាក់កាល។ សូមមើលឧបសម្ព័ន្ធដែលបង្ហាញពីមូលដ្ឋានទិន្នន័យទាំង១៥។ ក្នុងចំណោមមូលដ្ឋានទិន្នន័យទាំងនេះ មូលដ្ឋានទិន្នន័យយ៉ាងតិចចំនួន៨ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ រួមទាំងមូលដ្ឋានទិន្នន័យឃុំ[125]។

មូលដ្ឋានទិន្នន័យឃុំ (ជាទូទៅ ហៅកាត់ថា CDB) ជាឧទាហរណ៍ល្អមួយនៃសំណុំទិន្នន័យដ៏មានប្រយោជន៍ ប៉ុន្តែមិនត្រូវបានចែករំលែក និងប្រើប្រាស់បានល្អ។ ដោយបានចាប់ផ្តើមឡើងក្នុងឆ្នាំ២០០២ និងគ្រប់គ្រងដោយក្រសួងផែនការ ដំបូងឡើយ មូលដ្ឋានទិន្នន័យឃុំមានតែ ១៧ សំណួរប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលនោះមក មានការបន្ថែមសំណួរកាន់តែច្រើនឡើង។ គិតត្រឹមឆ្នាំ ២០១៦ មូលដ្ឋានទិន្នន័យនេះមានសូចនាករចំនួន១.២០០ ដែលចែកចេញជាថ្នាក់ភូមិ (២៩ មូលបទ/ប្រធានបទ) ថ្នាក់ឃុំ/សង្កាត់ (៩ មូលបទ/ប្រធានបទ) និងថ្នាក់ស្រុក ក្រុង ខណ្ឌ (៤ មូលបទ/ប្រធានបទ)។ មូលដ្ឋានទិន្នន័យឃុំត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដោយថ្នាក់ភូមិ ឃុំ និងស្រុក ក្រុង ខណ្ឌ ជាអ្នកប្រមូលទិន្នន័យ។ ច្បាស់ណាស់ថា ការធ្វើបច្ចុប្បន្នភាព មូលដ្ឋានទិន្នន័យឃុំត្រូវចំណាយពេលយូរ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិមិនបានទទួលគ្រឿងលើកទឹកចិត្តសម្រាប់ការបំពេញកិច្ចការទាំងនេះឡើយ។

[123] WB (2021) Intergovernmental transfer in Cambodia
[124] MEF (2019) SNA-BSRS (2019-2025)
[125] សូមមើល db.ncdd.gov.kh

**ទិន្នន័យពីមូលដ្ឋានទិន្នន័យឃុំ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងគោលនយោបាយផ្សេងៗ** មានជាអាទិ៍ការរៀបចំផែនការរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ និងការរៀបចំប័ណ្ណពិន្ទុរដ្ឋបាលថ្នាក់ក្រោមជាតិ[126]។ ក្រៅពីនេះ ទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំត្រូវបានប្រើប្រាស់សម្រាប់ការគណនាអត្រាភាពក្រីក្រតាមឃុំ ដែលបន្ទាប់មកត្រូវបានប្រើប្រាស់សម្រាប់ការគណនាមូលនិធិឃុំ/សង្កាត់[127]។ ត្រឡប់ទៅឆ្នាំ២០១២ វិញ សំណុំទិន្នន័យនេះក៏ត្រូវបានប្រើប្រាស់ដើម្បីរៀបចំរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា នៅថ្នាក់ក្រោមជាតិផងដែរ (រាជធានី ខេត្ត និងស្រុក ក្រុង ខណ្ឌ)[128]។

**ក្រៅពីការប្រើប្រាស់ខាងលើ មូលដ្ឋានទិន្នន័យឃុំមិនត្រូវបានប្រើប្រាស់ និងចែករំលែកទូលំទូលាយនោះទេ។** ផ្អែកតាមលទ្ធផលរកឃើញពីការស្រាវជ្រាវនេះ សំណុំទិន្នន័យ និងផលិតផលផ្សេងៗដែលទទួលបានពីមូលដ្ឋានទិន្នន័យឃុំមិនត្រូវបានចែករំលែកទូលំទូលាយនោះទេ លើកលែងតែសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រួលដល់ការរៀបចំរបាយការណ៍ស្ថានភាពប្រចាំឆ្នាំ និងប័ណ្ណពិន្ទុ។ មូលដ្ឋានទិន្នន័យឃុំថ្មីបំផុតដែលអាចរកបាន ក្នុងគេហទំព័ររបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យគឺចាប់ពីឆ្នាំ២០១០។ ក្រៅពីនេះ សំណុំទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំមិនត្រូវប្រើប្រាស់យ៉ាងទូលំទូលាយឡើយ។ បើមិនរាប់បញ្ចូលការប្រើប្រាស់ដែលបានលើកឡើងខាងលើ ក្រសួងសាមីុ និងនាយកដ្ឋានពាក់ព័ន្ធតាមវិស័យ មិនសូវបានដឹងពីមូលដ្ឋានទិន្នន័យឃុំនោះទេ ទោះបីជាអថេរជាច្រើនក្នុងមូលដ្ឋានទិន្នន័យឃុំ គ្របដណ្តប់លើបញ្ហាក្នុងវិស័យទាំងនោះក៏ដោយ។ ដោយសារតែមិនមានការផ្តល់មូលដ្ឋានទិន្នន័យនេះនៅក្រៅរដ្ឋាភិបាល មូលដ្ឋានទិន្នន័យឃុំមិនត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយដៃគូអភិវឌ្ឍន៍ ឬអង្គការមិនមែនរដ្ឋាភិបាលនោះទេ។

**យូរៗទៅ មានមន្ទិលសង្ស័យកាន់តែច្រើនចំពោះភាពអាចជឿជាក់បាន និងគុណភាពនៃមូលដ្ឋានទិន្នន័យឃុំ។** មួយភាគធំគឺមូលដ្ឋានទិន្នន័យឃុំពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការតែម្តង។ ដូចការលើកឡើងពីខាងដើម ការគាំទ្រតិចតួចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាមីុផ្សេងៗ ធ្វើឱ្យមិនសូវមានការទទួលយកមូលដ្ឋានទិន្នន័យឃុំ។ ក្រៅពីនេះ នៅពេលដែលមានការលំបាកក្នុងការទទួលបានមូលដ្ឋានទិន្នន័យឃុំ ដៃគូអភិវឌ្ឍន៍បានដកការគាំទ្ររបស់ខ្លួន ដែលធ្វើឱ្យមានការលំបាកបន្ថែមទៀតក្នុងការប្រមូល និងវិភាគទិន្នន័យ។ ស្ថានភាពនេះបានបង្កើតជាវដ្តនៃកង្វះលទ្ធភាព កង្វះគុណភាព និងកង្វះទំនុកចិត្តលើសំណុំទិន្នន័យនេះ។

---

126 ប័ណ្ណពិន្ទុនេះតំណាងឱ្យស្ថានភាពបច្ចុប្បន្នភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ (រហូតដល់ថ្នាក់ឃុំ/សង្កាត់) ពាក់ព័ន្ធនឹងសូចនាករអភិវឌ្ឍន៍ចំនួន៩ ដូចជា សេដ្ឋកិច្ច សង្គម បរិស្ថាន និងយេនឌ័រ។

127 មូលនិធិឃុំ/សង្កាត់ជាជាវិភាជថវិកាប្រចាំឆ្នាំពីរដ្ឋាភិបាលទៅឃុំ/សង្កាត់ទាំងអស់នៅក្នុងប្រទេសកម្ពុជា។

128 MOP (2012) Scorecard of the implementation of Cambodia Millennium Development Goals (CMDG) at sub-national levels by Capital, Provinces, Municipalities, District, Khans in Year 2012 (Based on the Commune Database (CDB) in December 2011 Selected and Presented by Maps and Graphics)

ទោះបីជាមានបញ្ហាប្រឈមក្តី ប៉ុន្តែមូលដ្ឋានទិន្នន័យឃុំនៅតែសំណុំទិន្នន័យតែមួយគត់ដែលមានទ្រង់ទ្រាយធំ និងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ស្តីពីការអភិវឌ្ឍតាមមូលដ្ឋាននៅកម្ពុជា។ មូលដ្ឋានទិន្នន័យឃុំមានអថេរសំខាន់ៗស្តីពីប្រជាជន ទំហំផ្ទៃដី ស្ថានភាពគ្រួសារ និងវិស័យសំខាន់ៗ។

អ្នកតបសម្ភាសន៍មកពីក្រសួងផែនការ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យបានគូសបញ្ជាក់ថាខណៈដែលមូលដ្ឋានទិន្នន័យឃុំមានព្រំដែនកំណត់មួយចំនួន គួរមានការកែលម្អ និងការពិចារណាបន្ថែមទៀតថាតើអាចប្រែក្លាយមូលដ្ឋានទិន្នន័យនេះទៅជាប្រភពទិន្នន័យ ដែលផលិតដោយប្រជាពលរដ្ឋបានដែរ ឬទេ។ មួយវិញទៀត គឺគេអាចប្រើប្រាស់មូលដ្ឋានទិន្នន័យឃុំសម្រាប់វាស់វែងប្រសិទ្ធភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅតាមមូលដ្ឋាន[129]។

ផែនការកំណែទម្រង់ថ្មីៗចំនួន៣ ត្រូវបានរំពឹងថានឹងធ្វើឱ្យមានភាពប្រសើរឡើងលើការចែករំលែក និងប្រើប្រាស់ទិន្នន័យដែលមានស្រាប់ក្រោមកំណែទម្រង់វិមជ្ឈការ រួមទាំងមូលដ្ឋានទិន្នន័យឃុំ។ ទីមួយ ផ្អែកតាមការពិនិត្យឯកសារ និងបទសម្ភាសន៍ ការសម្របសម្រួលរវាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ/ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាទូទៅមានភាពប្រសើរឡើងតាំងពីឆ្នាំ២០១៩ ជាមួយនឹងការអនុម័តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ[130]។ យុទ្ធសាស្ត្រនេះតំណាងឱ្យកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញវិមជ្ឈការ ស្របតាមទិសដៅដែលបានកំណត់ក្នុងរបៀបវារៈកំណែទម្រង់នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ទីពីរគឺការផ្តោតកាន់តែខ្លាំងលើការពិនិត្យតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។** ជាថ្មីម្តងទៀត និន្នាការនេះក៏ត្រូវបានជំរុញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោមយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) ផងដែរ។ ដូចការលើកឡើងក្នុងឯកសារនេះ ការផ្តោតការយកចិត្តទុកដាក់លើទិន្នន័យហាក់កើនឡើងទៅតាមការផ្តោតការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និងវាយតម្លៃ។ យោងតាមបទសម្ភាសន៍ជាមួយមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគោលការណ៍ណែនាំថ្មីមួយស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ កំពុងត្រូវបានព្រាងឡើង និងរៀបចំបញ្ចប់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីថ្នាក់រាជធានី ខេត្ត។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែល

[129] បទសម្ភាសន៍ជាមួយក្រសួងផែនការ (កាលបរិច្ឆេទ) បទសម្ភាសន៍ជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (កាលបរិច្ឆេទ)

[130] MEF (2019) SNA-BSRS

ទទួលបានជំនួយបច្ចេកទេសពីធនាគារពិភពលោក បាន និងកំពុងពិនិត្យឡើងវិញលើចំណាយសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការពិនិត្យឡើងវិញលើចំណាយសាធារណៈ ជាទម្រង់មួយនៃការវាយតម្លៃលើប្រសិទ្ធផលផ្នែកប្រតិបត្តិការ និងប្រសិទ្ធផលផ្នែកវិភាជថវិកាតាមរដ្ឋបាលថ្នាក់ក្រោមជាតិ[131]។

ទីបី គឺភាពប្រសើរឡើងជារួមនៃឌីជីថលូបនីយកម្ម និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្រាប់ការចែករំលែកព័ត៌មាន និងការរាយការណ៍ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីថ្នាក់ជាតិថ្មីសម្រាប់កំណែទម្រង់វិមជ្ឈការ (២០២១-២០៣០) កំណត់យករដ្ឋាភិបាលអេឡិចត្រូនិកជាចំណុចផ្ដោតសំខាន់។ ដើម្បីឱ្យរដ្ឋាភិ-បាលអេឡិចត្រូនិកដំណើរការទៅបាន ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់បន្ថែមទៀតលើអភិបាលកិច្ចទិន្នន័យ ដូចជា ការអភិវឌ្ឍ និងការដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងទូទាំងប្រទេស ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ និងទីភ្នាក់ងារថ្នាក់ជាតិអាចបញ្ចូល និងចែករំលែកទិន្នន័យបានទាន់ពេលវេលា និងស៊ីសង្វាក់គ្នា[132]។

### ៥.២.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន

ខុសពីកិច្ចគាំពារសង្គម (ដែលលើកមកពិភាក្សាក្នុងផ្នែកខាងលើ) ឬការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម និងការអភិវឌ្ឍយុវជន (ដែលលើកមកពិភាក្សាក្នុងផ្នែកខាងក្រោម) មិនមានក្របខ័ណ្ឌគោលនយោបាយថ្នាក់តំបន់អាស៊ានស្ដីពីវិមជ្ឈការនោះទេ។ ផ្អែកតាមការសិក្សាមួយរបស់ធនាគារពិភពលោកកាលពីពេលថ្មីៗនេះ ប្រទេសជាសមាជិកអាស៊ានមានភាពខុសគ្នាខ្លាំងនៅពេលនិយាយពីវិមជ្ឈការ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ[133]។ ទោះជាយ៉ាងណា ផ្អែកតាមបទសម្ភាសន៍ដែលបានធ្វើឡើងសម្រាប់ការសិក្សានេះ[134] នៅតែមានចំណាប់អារម្មណ៍លើការប្រៀបធៀបករណីរបស់កម្ពុជាទៅនឹងករណីរបស់បណ្ដាប្រទេសអាស៊ានផ្សេងទៀត ជាពិសេសវៀតណាម និងប្រទេសមួយចំនួនផ្សេងទៀត ដូចជា ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។

## ៥.៣ ករណីសិក្សាទី៣៖ ការជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍នៅអំឡុងវិបត្តិកូវីដ-១៩

ទោះបីជាការប្រើប្រាស់ទិន្នន័យមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចក៏ដោយ ប៉ុន្តែការប្រើប្រាស់ទិន្នន័យក្នុងដំណើរការគោលនយោបាយដែលពាក់ព័ន្ធនឹងសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ គឺមិនទាន់មានភាពរីកចម្រើននោះទេ។ ករណីសិក្សានេះពិភាក្សាពីគម្លាត

[131] បទសម្ភាសន៍ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កាលបរិច្ឆេទ) បទសម្ភាសន៍ជាមួយធនាគារពិភពលោក (កាលបរិច្ឆេទ)
[132] NCDD (2021) National Program on Sub-National Democratic Development (NP-SNDD) for 2021-2030.
[133] World Bank (2020) Deepening decentralization within centrally led states: The direction of local governance reforms in Southeast Asia.
[134] បទសម្ភាសន៍ជាមួយមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (GDSNAF) (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១)

មួយចំនួន និងបង្ហាញពីរបៀបដែលគម្លាតទាំងនោះពាក់ព័ន្ធនឹងគោលនយោបាយជាក់លាក់ និងឧបសគ្គផ្នែកស្ថាប័នដែលពាក់ព័ន្ធនឹងការចុះបញ្ជី និងការជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម។ ប្រេវ៉ាឡង់នៃភាពមិនផ្លូវការ ធ្វើឱ្យមានការលំបាកក្នុងការច្បាមយកទិដ្ឋភាពពេញលេញនៃសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម ក្នុងអំឡុងពេលមានវិបត្តិ ដូចជា វិបត្តិកូវីដ-១៩។ រដ្ឋាភិបាលកម្ពុជាបានកត់សម្គាល់បញ្ហាទាំងនេះ និងបានចាត់វិធានការជាក់ស្តែងដើម្បីដោះស្រាយ។ ក្រៅពីនេះ មានចំណេះដឹង និងកម្មវិធីល្អៗដែលរដ្ឋាភិបាលកម្ពុជាអាចរៀនសូត្រពីកម្រិតអាស៊ាន។

### ៥.៣.១ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ និងជំនួយរបស់រដ្ឋាភិបាលក្នុងអំឡុងវិបត្តិកូវីដ-១៩

ស្ថិតិស្តីពីសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា គឺលែងមានសុពលភាព និងមានបញ្ហាពាក់ព័ន្ធនឹងការកំណត់និយមន័យ។ ពោលគឺនិយមន័យត្រូវបានកំណត់ទៅតាមចំនួននិយោជិត និងតម្លៃទ្រព្យសម្បត្តិ។ មុនឆ្នាំ២០២០ កម្រិតដូចគ្នាត្រូវបានប្រើប្រាស់សម្រាប់ប្រភេទសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមទាំងអស់ ប៉ុន្តែក្រោយឆ្នាំ២០២០ មានការប្រើប្រាស់កម្រិតខុសគ្នាសម្រាប់វិស័យផ្សេងៗ (សូមមើលតារាងខាងក្រោម)។ ទិន្នន័យថ្នាក់ជាតិដែលមានថ្មីបំផុតស្តីពីសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមគឺទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រឹមឆ្នាំ២០១៤ មក។ ទិន្នន័យនោះបង្ហាញថា នៅកម្ពុជា មានសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមចំនួន៥១២.៨៧០ សហគ្រាស (ឬប្រមាណ ៩៩,៨% នៃចំនួនសហគ្រាសសរុប)។ ភាពផ្លូវការនៃសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា ត្រូវបានកំណត់ដោយស្ថានភាពនៃការចុះបញ្ជីរបស់សហគ្រាសទាំងនោះ។ ក្នុងឆ្នាំ២០១៨ ចំនួនសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមសរុបដែលបានចុះបញ្ជីមានប្រមាណ១៥៦.០០០ សហគ្រាស។ រដ្ឋាភិបាលកម្ពុជាខិតខំជានាការចុះបញ្ជីសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមឱ្យបានយ៉ាងតិច ៨០% នៅឆ្នាំ២០២៥[135] ប៉ុន្តែទំហំធំនៃវិស័យក្រៅផ្លូវការ និងលក្ខខណ្ឌតម្រូវមិនច្បាស់លាស់សម្រាប់ការចុះបញ្ជីបានធ្វើឱ្យមានមន្ទិលពាក់ព័ន្ធនឹងកម្រិត ៨០% នេះ ថាតើវាជាតួលេខផ្លូវការ ឬយ៉ាងណា។

[135] RGC (2015) "Cambodia Industrial Development Policy 2015 – 2025"

### តារាងទី៨៖ ការកំណត់និយមន័យសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា

| និយមន័យរហូតដល់ឆ្នាំ២០១៩ | | | | |
|---|---|---|---|---|
| | កត្តាកំណត់ | ខ្នាតមីក្រូ | ខ្នាតតូច | ខ្នាតមធ្យម |
| ទ្រព្យសកម្ម<br>ចំនួននិយោជិត | | មិនលើស<br>៥០.០០០ ដុល្លារ<br>តិចជាង ១០ នាក់ | ៥០.០០០-<br>២៥០.០០០<br>ដុល្លារ<br>១០-៥០ នាក់ | ២៥០.០០០-<br>៥០០.០០០<br>ដុល្លារ<br>៥១-១០០ នាក់ |
| ប្រភព៖ មូលដ្ឋានទិន្នន័យ ADB ឆ្នាំ២០២០ ស្តីពីការត្រួតពិនិត្យសហគ្រាសខ្នាតតូច និងមធ្យមនៅអាស៊ី។ ទិន្នន័យពីក្រុមប្រឹក្សា... ទិន្នន័យពីក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ឆ្នាំ២០០៥។ | | | | |
| **និយមន័យក្រោយឆ្នាំ២០២០** | | | | |
| វិស័យ | វិស័យ | ខ្នាតមីក្រូ | ខ្នាតតូច | ខ្នាតមធ្យម |
| កម្មន្តសាល | ចំនួនកម្លាំងពលកម្មសមមូលនៃរយៈពេលពេញម៉ោង | ១-២ នាក់ | ៣-៤៩ នាក់ | ៥០-៤៩៩ នាក់ |
| | ទ្រព្យសកម្ម (មិនគិតដីធ្លី) | មិនលើស<br>៥០.០០០ ដុល្លារ | ៥០.០០០-<br>៥០០.០០០<br>ដុល្លារ | ៥០០.០០០-<br>១.០០០.០០០<br>ដុល្លារ |
| កសិកម្ម ព្រៃឈើ និងនេសាទ | ចំនួនកម្លាំងពលកម្មសមមូលនៃរយៈពេលពេញម៉ោង | ១-២ នាក់ | ៣-៤៩ នាក់ | ៥០-១៩៩ នាក់ |
| | ទ្រព្យសកម្ម | មិនលើស<br>៥០.០០០ ដុល្លារ | ៥០.០០០-<br>៥០០.០០០<br>ដុល្លារ | ៥០០.០០០-<br>១.០០០.០០០<br>ដុល្លារ |

| | | | | |
|---|---|---|---|---|
| ពាណិជ្ជកម្ម លក់ដុំ និង លក់រាយ | ចំនួនកម្លាំងពលកម្មសមមូលនៃរយៈពេលពេញម៉ោង | ១-២ នាក់ | ៣-៤៩ នាក់ | ៥០-១៩៩ នាក់ |
| | ទ្រព្យសកម្ម (មិនគិតដីធ្លី និងអគារ) | មិនលើស ៥០.០០០ ដុល្លារ | ៥០.០០០-៥០០.០០០ ដុល្លារ | ៥០០.០០០-១.០០០.០០០ ដុល្លារ |
| សេវាផ្សេងទៀត | ចំនួនកម្លាំងពលកម្មសមមូលនៃរយៈពេលពេញម៉ោង | ១-៤ នាក់ | ៥-៤៩ នាក់ | ៥០-៩៩ នាក់ |
| | ទ្រព្យសកម្ម (មិនគិតដីធ្លី) | មិនលើស ៥០.០០០ ដុល្លារ | ៥០.០០០-៥០០.០០០ ដុល្លារ | ៥០០.០០០-១.០០០.០០០ ដុល្លារ |
| សកម្មភាពផ្សេងទៀត | ចំនួនកម្លាំងពលកម្មសមមូលនៃរយៈពេលពេញម៉ោង | ១-៩ នាក់ | ១០-៤៩ នាក់ | ៥០-១៩៩ នាក់ |
| | ទ្រព្យសកម្ម | មិនលើស ៥០.០០០ ដុល្លារ | ៥០.០០០-៥០០.០០០ ដុល្លារ | ៥០០.០០០-១.០០០.០០០ ដុល្លារ |

ចំណាំ៖ សមមូលនៃរយៈពេលពេញម៉ោង សំដៅលើផលធៀបនៃចំនួនម៉ោងធ្វើការសរុបដែលទទួលបានប្រាក់ឈ្នួលនៅក្នុងអំឡុងពេលមួយ (ការងារក្រៅម៉ោង ការងារពេញម៉ោង ការងារក្រោមកិច្ចសន្យា) និងចំនួនម៉ោងធ្វើការសរុបក្នុងអំឡុងពេលដដែលនោះ។ និយមន័យនៃសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម ប្រើប្រាស់ប្រាក់ដុល្លារអាមេរិកសម្រាប់ការកំណត់កម្រិតទ្រព្យសកម្ម។

ប្រភព ៖ មូលដ្ឋានទិន្នន័យ ADB ឆ្នាំ២០២០ ស្តីពីការត្រួតពិនិត្យសហគ្រាសខ្នាតតូច និងមធ្យមនៅអាស៊ី។ ទិន្នន័យពី គោលនយោបាយអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម និងផែនការអនុវត្តន៍រយៈពេល ៥ឆ្នាំ (២០២០-២០២៤) (ចេញផ្សាយឆាប់ៗនេះ)

**ក្នុងចំណោមអាជីវកម្មដែលបានចុះបញ្ជីក្នុងវិស័យទេសចរណ៍នៅកម្ពុជា អាជីវកម្មជាច្រើនប្រមូលផ្តុំក្នុងរាជធានីភ្នំពេញ និងបន្ទាប់មកគឺក្នុងខេត្តសៀមរាប។** ក្នុងរាជធានីភ្នំពេញ មានអាជីវកម្មប្រភេទនោះជាច្រើន (ដូចមានរៀបរាប់ខាងក្រោម) លើកលែងតែមគ្គុទេសក៍ទេសចរណ៍ដែលច្រើនតែជាបុគ្គលស្វ័យនិយោជន៍។ ១. ក្នុងរាជធានីភ្នំពេញ ភ្នាក់ងារទេសចរណ៍ដែលបានចុះបញ្ជី

មានចំនួនជាង ៥០% ខារ៉ាអូខេមាន ៣៣% ក្លឹបរាត្រីមាន ៦៧% សណ្ឋាគារមាន ៣៣% និងហាងម៉ាស្សាមាន ៣៣%។ ខេត្តសៀមរាបជាតំបន់ទី២ ដែលមានការប្រមូលផ្តុំអាជីវកម្មច្រើនជាងគេ[136]។ ទោះជាយ៉ាងណា គួរចាត់ទុកទិន្នន័យផ្លូវការទាំងនោះជាសូចនាករ ព្រោះថាអាជីវកម្មជាច្រើនដែលគួរតែបានចុះបញ្ជី អាចមិនអនុលោមតាមលក្ខខណ្ឌនេះ។

**វិស័យទេសចរណ៍របស់កម្ពុជារងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិកូវីដ-១៩។** វិស័យនេះធ្លាប់មានកំណើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១ទសវត្សរ៍កន្លងមក ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃចំនួនភ្ញៀវទេសចរណ៍អន្តរជាតិប្រមាណ ១២% និងបានបង្កើតឱ្យមានគ្រឹះស្ថានទេសចរណ៍ដែលបានចុះបញ្ជីចំនួន៦៣០.០០០ និងបង្កើតការងារដោយផ្ទាល់ក្នុងវិស័យទេសចរណ៍ចំនួន ៦៣០.០០០ការងារ។ ប៉ុន្តែក្នុងឆ្នាំ២០២០ ដែលកម្ពុជាត្រូវបានវាយប្រហារដោយវិបត្តិកូវីដ-១៩ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសនេះ ថយចុះ ៨០% ធៀបនឹងឆ្នាំ២០១៩។ ដូច្នេះ ចំនួនភ្ញៀវទេសចរណ៍ក្នុងស្រុកថយមកត្រឹម ៧,២៣ លាននាក់ ស្មើនឹងការធ្លាក់ចុះ ៣៦,១% ធៀបនឹងឆ្នាំ២០១៩។ គេរំពឹងថា វិស័យនេះនឹងបន្តសម្រេចបានកំណើនអវិជ្ជមាននៅឆ្នាំ២០២១ ប៉ុន្តែនឹងងើបឡើងវិញចាប់ពីឆ្នាំ២០២២ ទៅ[137]។

**វិស័យទេសចរណ៍គឺជាអាទិភាពមួយក្នុងផែនការស្តារសេដ្ឋកិច្ចរបស់រដ្ឋាភិបាលកម្ពុជា។** ក្នុងឆ្នាំ២០២១ ក្រសួងទេសចរណ៍បានរៀបចំផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាល និងក្រោយវិបត្តិជំងឺឆ្លងសកលកូវីដ (២០២១-២០២៥) ដើម្បីបង្កើនចំនួនភ្ញៀវទេសចរណ៍ឱ្យដល់កម្រិតមុនវិបត្តិកូវីដ-១៩ (ពោលគឺភ្ញៀវទេសចរណ៍អន្តរជាតិប្រមាណ ៧លាននាក់ និងភ្ញៀវទេសចរណ៍ក្នុងស្រុកប្រមាណ ១១លាននាក់)។ ក្រៅពីនេះ ចាប់ពីខែកុម្ភៈ ឆ្នាំ២០២០ មក រដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការផ្តល់ជំនួយចំនួន៨លើក ដែលវិធានការចុងក្រោយបានបញ្ចប់នៅខែមិថុនា ឆ្នាំ២០២១។ វិធានការមួយលើកៗ មានភាពខុសគ្នាតិចតួចពាក់ព័ន្ធនឹងប្រភេទនៃការផ្តល់ជំនួយ។ ប៉ុន្តែបើនិយាយជារួម វិធានការទាំងនោះមានដូចជា ការលើកលែងពន្ធ ថ្លៃអាជ្ញាប័ណ្ណ និងភាគទានសន្តិសុខសង្គមសម្រាប់អាជីវកម្មដែលបានចុះបញ្ជីក្នុងវិស័យទេសចរណ៍ និងការផ្តល់ប្រាក់ឧបត្ថម្ភ និងការបណ្តុះបណ្តាលបង្កើនជំនាញសម្រាប់កម្មករដែលត្រូវបានរំសាយក្នុងវិស័យទេសចរណ៍[138]។

សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមជាច្រើនដែលបានចុះបញ្ជីក្នុងវិស័យទេសចរណ៍ សុទ្ធតែបានដឹងពីការផ្តល់ជំនួយរបស់រដ្ឋាភិបាល ប៉ុន្តែមានសហគ្រាសតិចតួចប៉ុណ្ណោះដែលបានទទួលជំនួយទាំងនោះ។ផ្អែកតាមការស្ទង់មតិដែលធ្វើឡើងដោយអង្គការមូលនិធិអាស៊ី គិតត្រឹមខែមេសា ឆ្នាំ២០២១ មានអាជីវកម្មប្រមាណ ៧០% ដែលបានដឹងកម្មវិធីទាំងនេះ។ ទោះជាយ៉ាងណា

[136] MOT (2020) Statistics on the number and types of tourism sector business in 2019

[137] MOT (2021) Key statistics of tourism sector and prediction

[138] The Asia Foundation (2021) Revisiting the Pandemic: Rapid survey on the impact of COVID-19 on MSMEs in the tourism sector and households in Cambodia

មានអាជីវកម្មដែលបានចុះបញ្ជីប្រមាណតែ ៤៥% ប៉ុណ្ណោះដែលលើកឡើងថាបានទទួលការលើកលែងពន្ធ ខណៈដែលអាជីវកម្មដែលបានចុះបញ្ជីតែប្រមាណ ១០% ប៉ុណ្ណោះដែលលើកឡើងថាបានទទួលកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស ការឧបត្ថម្ភសាច់ប្រាក់ដល់កម្មករដែលត្រូវបានរំសាយ និង/ឬការរៀបចំបំណុលឡើងវិញដោយធនាគារ/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ក្នុងចំណោមមូលហេតុធំៗនៃការមិនប្រើប្រាស់កម្មវិធីទាំងនេះដែលគូសបញ្ជាក់ដោយអ្នកតបសម្ភាសន៍ រួមមានកង្វះព័ត៌មានស្តីពីកម្មវិធី កង្វះការយល់ដឹងពីរបៀបចូលរួមក្នុងកម្មវិធី (និងថាតើពួកគេមានលក្ខណៈសម្បត្តិចូលរួម ឬទេ) និងការយល់ថា នីតិវិធីដាក់ពាក្យចូលរួមបច្ចុប្បន្នមានភាពច្របូកច្របល់ និងស្មុគស្មាញពេក[139]។

## ៥.៣.២ គោលនយោបាយ និងការប្រើប្រាស់ទិន្នន័យដើម្បីជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍

**ការតាក់តែងគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យដើម្បីជួយដល់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា ទើបតែចាប់ផ្តើមឡើងប៉ុណ្ណោះ។** ពាក់ព័ន្ធនឹងគោលនយោបាយ យោងតាមសន្ទស្សន៍គោលនយោបាយសហគ្រាសខ្នាតតូច និងមធ្យមអាស៊ាន ឆ្នាំ២០១៨ កម្ពុជាមានពិន្ទុ ២,៥៥ សម្រាប់ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ (ធៀបនឹងពិន្ទុមធ្យម ៣,៤៣)។ ពាក់ព័ន្ធនឹងទិន្នន័យ របាយការណ៍នេះរកឃើញថាមានការពិនិត្យតាមដាន និងវាយតម្លៃតិចតួចលើក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ឆ្នាំ២០០៥ ខណៈដែលទិន្នន័យស្តីពីសហគ្រាសខ្នាតតូច និងមធ្យម មិនត្រូវបានប្រមូលជាប់លាប់នោះទេ[140]។

ពាក់ព័ន្ធនឹងសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ បញ្ហាទិន្នន័យកាន់តែមានភាពជ្រាលជ្រៅលើសពីការប្រមូលទិន្នន័យកាន់តែច្រើន និងការប្រើប្រាស់ទិន្នន័យទាំងនោះ។ បញ្ហាដំបូងបណ្តាលមកពីការមិនមាននិយមន័យស៊ីសង្វាក់គ្នាសម្រាប់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមដែលត្រូវបានប្រើប្រាស់ដោយក្រសួង និងទីភ្នាក់ងារនានា និងការមិនមានលក្ខខណ្ឌគតិយុត្តិដែលស៊ីសង្វាក់គ្នាពាក់ព័ន្ធនឹងការចុះបញ្ជីសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម។ សន្ទស្សន៍គោលនយោបាយអាស៊ានស្តីពីសហគ្រាសខ្នាតតូច និងមធ្យមឆ្នាំ២០១៨ រកឃើញថា មានអាជ្ញាប័ណ្ណជាង៧៥ ដែលអាចអនុវត្តបានចំពោះសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា ហើយអាជ្ញាប័ណ្ណទាំងនោះត្រូវបានចេញដោយក្រសួងជាច្រើន[141]។ ស្ថានភាពនេះក៏អាចកើតឡើងចំពោះសហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យទេសចរណ៍ផងដែរ។

---

[139] The Asia Foundation (2021) Revisiting the Pandemic: Rapid survey on the impact of COVID-19 on MSMEs in the tourism sector and households in Cambodia

[140] OECD, ERIA, and ASEAN (2018) ASEAN SME Policy Index

[141] OECD, ERIA, and ASEAN (2018) ASEAN SME Policy Index

**យោងតាមច្បាប់ស្តីពីទេសចរណ៍ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យទេសចរណ៍ ត្រូវចុះបញ្ជីជាមួយក្រសួងទេសចរណ៍។** នេះជាលក្ខខណ្ឌតម្រូវបន្ថែមលើលក្ខខណ្ឌចុះបញ្ជីជាមួយក្រសួងផ្សេងទៀត ដូចជា ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ។ ទោះបីជាមានបទបញ្ញត្តិក្នុងច្បាប់ស្តីពីទេសចរណ៍ក៏ដោយ ប៉ុន្តែក្នុងការអនុវត្តអ្វីដែលជាចំណុចមិនច្បាស់លាស់គឺទំហំអាជីវកម្មដែលត្រូវចុះបញ្ជី។ យោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ (មាត្រា ៣) មានការលើកឡើងពីអាជីវកម្មគ្រួសារដែលមិនតម្រូវឱ្យចុះបញ្ជី។ ប៉ុន្តែយោងតាមអនុក្រឹត្យលេខ១៨(២០១៧)នៅពេលដែលមុខងារចុះបញ្ជីអាជីវកម្មខ្នាតមីក្រូនិងខ្នាតតូច ត្រូវបានផ្ទេរទៅអង្គភាពច្រកចេញចូលតែមួយ នៅថ្នាក់រាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ស្រុក ក្រុង ខណ្ឌ វាហាក់ដូចជាអាជីវកម្មគ្រប់ទំហំ ដូចជាផ្ទះសំណាក់ ភោជនីយដ្ឋាន ហាងម៉ាស្សា និងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរណ៍ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ[142]។

ដើម្បីបង្កើនការចុះបញ្ជីអាជីវកម្ម ទាំងក្រសួងទេសចរណ៍ ក៏ដូចជាអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ ត្រូវអនុវត្ត និងខិតខំពង្រីកការចុះបញ្ជីអាជីវកម្មតាមអនឡាញ។ គេហទំព័រនេះត្រូវបានដាក់ឱ្យប្រើប្រាស់ដោយក្រសួងទេសចរណ៍ ក្នុងខែ មេសា ឆ្នាំ២០១៥[143] ។ គេហទំព័រនេះគឺសម្រាប់ឱ្យអាជីវកម្ម និងមគ្គុទេសក៍ទេសចរណ៍ដែលពាក់ព័ន្ធនឹងទេសចរណ៍ ចុះបញ្ជីអាជ្ញាប័ណ្ណរបស់ខ្លួនតាមអនឡាញ និងកាត់បន្ថយរយៈពេលស្នើសុំរបស់ប្រតិបត្តិករដើម្បីពន្លឿនដំណើរការដាក់ពាក្យសុំ ក៏ដូចជាកាត់បន្ថយការប្រមូលផ្តុំគ្នាដើម្បីកាត់បន្ថយការចម្លងជំងឺកូវីដ-១៩។ នៅកម្រិតអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ រដ្ឋាភិបាលកំពុងជំរុញការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានការផ្តល់សេវា (SD-MIs) ដើម្បីអាចឱ្យមានការសាកសួរតាមអនឡាញ ការតាមដានវឌ្ឍនភាពសេវា ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងការដាក់ពាក្យសុំតាមអនឡាញ។

គំនិតផ្តួចផ្តើមមួយទៀតរបស់រដ្ឋាភិបាលគឺការប្រើប្រាស់គេហទំព័រចុះបញ្ជីអាជីវកម្មដើម្បីឱ្យការចុះបញ្ជីអាជីវកម្មកាន់តែមានប្រសិទ្ធភាព[144]។ ក្រោមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ឧស្សាហកម្ម ៤.0 ដំណើរការចុះបញ្ជីអាជីវកម្មនឹងចំណាយពេលត្រឹមតែ ៨ថ្ងៃប៉ុណ្ណោះ។ គំនិតផ្តួចផ្តើមនេះនឹងជួយទាក់ទាញអាជីវកម្មថ្មីៗទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាជួយឱ្យមានភាពផ្លូវការសម្រាប់វិស័យក្រៅផ្លូវការដ៏ធំនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

[142] The Asia Foundation (2021) Revisiting the Pandemic: Rapid survey on the impact of COVID-19 on MSMEs in the tourism sector and households in Cambodia

[143] សូមចូលទៅកាន់៖ www.cambodiatourismindustry.org

[144] សូមចូលទៅកាន់៖ https://www.registrationservices.gov.kh/en/home

### ៥.៣.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន

កម្ពុជាអាចរៀនសូត្រពីចំណេះដឹងប្រហាក់ប្រហែលគ្នាពីកម្រិតអាស៊ាន ពាក់ព័ន្ធនឹងសហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យទេសចរណ៍។ ចំណេះដឹងទាំងនោះអាចរកបានពីការសិក្សាស្រាវជ្រាវថ្នាក់តំបន់ ដូចជាសន្ទស្សន៍គោលនយោបាយសហគ្រាសខ្នាតតូច និងមធ្យមដែលបានធ្វើឡើងក្នុងឆ្នាំ២០១៨។ ការសិក្សានេះពិនិត្យមើលទិដ្ឋភាពគោលនយោបាយនៃការអភិវឌ្ឍនសហគ្រាខ្នាតតូច និងមធ្យមក្នុងតំបន់អាស៊ាន តាមរយៈការកំណត់រកគម្លាត និងផ្តល់អនុសាសន៍សម្រាប់ជាគន្លឹះឆ្ពោះទៅមុខ។ ការសិក្សានេះមានប្រយោជន៍សម្រាប់ការស្រាវជ្រាវស្តីពីសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជាដោយសារមូលហេតុដូចតទៅ។

ទីមួយ គេអាចរៀនសូត្រពីវិធីសាស្ត្រនៃការសិក្សានេះ ដែលផ្អែកលើវិធីសាស្ត្រសន្ទស្សន៍គោលនយោបាយសហគ្រាសខ្នាតតូច និងមធ្យមរបស់ OECD និងដាក់បញ្ចូលគោលដៅនៃផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមរបស់អាស៊ាន (SAP SMEF) ២០១៦-២០២៥។ ទីពីរ ការប៉ាន់ប្រមាណនេះប្រើប្រាស់លក្ខណៈវិនិច្ឆ័យចំនួន ៨ ចំណុចដូចគ្នា (លក្ខណៈវិនិច្ឆ័យបន្ទាប់បន្សំ ២៥ចំណុច) ដើម្បីប៉ាន់ប្រមាណគោល-នយោបាយស្តីពីសហគ្រាសខ្នាតតូច និងមធ្យម និងស្ថានភាពក្នុងរដ្ឋសមាជិកអាស៊ាន ដោយផ្តល់ ១ពិន្ទុសម្រាប់ប្រទេសនីមួយៗ និងពិន្ទុមេដ្យ៉ានសម្រាប់តំបន់ទាំងមូល។ ចក្ខុវិស័យប្រហាក់ប្រហែលគ្នានេះ ផ្តល់មូលដ្ឋានព័ត៌មានដល់អ្នកតាក់តែងគោលនយោបាយក្នុងប្រទេសនីមួយៗ។ ទីបី ការសិក្សានេះត្រូវបានរំពឹងថានឹងធ្វើឡើងដដែលៗក្នុងអំឡុងពេលមួយ ដូច្នេះវានឹងផ្តល់ទិន្នន័យឆ្លងប្រទេស ក៏ដូចជាទិន្នន័យនៅអំឡុងពេលផ្សេងៗដែលអាចប្រៀបធៀបគ្នាបាន។

តារាងទី៩៖ ពិន្ទុឆ្នាំ២០១៨ របស់កម្ពុជា ក្នុងសន្ទស្សន៍គោលនយោបាយស្តីពីសហគ្រាសខ្នាតតូច និងមធ្យម ធៀបនឹងពិន្ទុសម្រាប់តំបន់អាស៊ាន

| ល.រ | ទិដ្ឋភាព | ពិន្ទុសម្រាប់កម្ពុជា | ពិន្ទុមេដ្យ៉ានសម្រាប់តំបន់ អាស៊ាន |
|---|---|---|---|
| ១ | ផលិតភាព បច្ចេកវិទ្យា និងនវានុវត្តន៍ | ២.៦២ | ៣.៧៨ |
| ២ | គោលនយោបាយបរិស្ថាន និងសហគ្រាសខ្នាតតូច និងមធ្យម | ១.៨៨ | ៣.៤៥ |
| ៣ | លទ្ធភាពទទួលបានហិរញ្ញវត្ថុ | ២.៨៩ | ៤.១៥ |
| ៤ | លទ្ធភាពទទួលបានទីផ្សារ និងអន្តរជាតូបនីយកម្ម | ២.៦៩ | ៤.៥៥ |
| ៥ | ក្របខ័ណ្ឌស្ថាប័ន | ២.៥៥ | ៤.២០ |
| ៦ | ច្បាប់ បទបញ្ញត្តិ និងពន្ធ | ២.៣១ | ៣.៤៣ |
| ៧ | ការអប់រំ និងជំនាញសហគ្រិនភាព | ២.៥៤ | ៤.២៧ |
| ៨ | សហគ្រាសសង្គម និងសហគ្រិនភាពបែបបរិយាបន្ន | ២.៣៥ | ២.៧៧ |

ក្នុងវិស័យទេសចរណ៍ អាស៊ានក៏មានផ្ដល់គំនិតផ្ដួចផ្ដើម និងកម្មវិធីជាក់លាក់ ជាពិសេសក្នុងបរិបទនៃការស្ដារសេដ្ឋកិច្ចឡើងវិញនៅក្នុងតំបន់ផងដែរ។ យោងតាមក្របខ័ណ្ឌស្ដារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន សហគ្រាសខ្នាតតូច និងមធ្យម មានភាពពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រទាំង ៥។ ទោះជាយ៉ាងណាក្រោមយុទ្ធសាស្ត្រទី ៣ (ការបង្កើនសក្ដានុពលទីផ្សារក្នុងតំបន់អាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ចកាន់តែធំទូលាយ) អាទិភាពចម្បងមួយគឺវិស័យទេសចរណ៍៖ អាទិភាព "៣g" (ការពន្លឿនការស្ដារវិស័យឡើងវិញ (ទេសចរណ៍ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម) និងការធានាសុវត្ថិភាពការងារក្នុងវិស័យដែលរងផលប៉ះពាល់)។ ក្នុងអាទិភាពនេះ មានការផ្ដល់គំនិតផ្ដួចផ្ដើម និងកម្មវិធីមួយចំនួន[145]។

ក្រៅពីនេះ ស្ថាប័នអភិវឌ្ឍន៍មួយចំនួនផ្សេងទៀតក៏មានទិន្នន័យបច្ចុប្បន្នភាពស្ដីពីសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងតំបន់អាស៊ាន រួមទាំងនៅកម្ពុជាផងដែរ។ ឧទាហរណ៍មួយគឺបណ្ណាល័យទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសំណុំទិន្នន័យក្នុងប្រព័ន្ធត្រួតពិនិត្យសហគ្រាសខ្នាតតូច និងមធ្យមនៅអាស៊ី ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងផ្ដល់ឱ្យប្រើប្រាស់ក្នុងទម្រង់ Excel។ មូលដ្ឋានទិន្នន័យ (យ៉ាងហោចណាស់សម្រាប់ករណីកម្ពុជា) មានភាពគ្រប់ជ្រុងជ្រោយ និងផ្អែកតាមទិន្នន័យថ្មីបំផុតពីក្រសួង និងទីភ្នាក់ងារសំខាន់ៗក្នុងរដ្ឋាភិបាលកម្ពុជា ដូចជា វិទ្យាស្ថានជាតិស្ថិតិ ធនាគារជាតិនៃកម្ពុជា ផ្សារមូលបត្រកម្ពុជា និងប្រភពផ្សេងទៀត [146]។ ឧទាហរណ៍មួយទៀតគឺសូចនាករសហគ្រាសខ្នាតតូច និងមធ្យមរបស់ OECD ស្ដីពីអាស៊ាន ដែលមានព័ត៌មានល្អៗជាច្រើនស្ដីពីប្រធានបទក្នុងគេហទំព័ររបស់ខ្លួន ប៉ុន្តែមិនទាន់មានទិន្នន័យក្នុងទម្រង់ Excel សម្រាប់ការផ្សព្វផ្សាយជាសាធារណៈតាមអនឡាញនោះទេ[146]។

## ៥.៤ ករណីសិក្សាទី៤៖ ការជំរុញការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសហគមន៍

### ៥.៤.១ គោលនយោបាយ និងការប្រើប្រាស់ទិន្នន័យស្ដីពីការអភិវឌ្ឍ

**គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា (២០១១) គឺជាគោលនយោបាយចម្បងស្ដីពីការអភិវឌ្ឍយុវជននៅកម្ពុជា។** គោលនយោបាយនេះខិតខំបំពាក់បំប៉នយុវជនឱ្យមានរាងកាយរឹងមាំ ប្រាជ្ញាឈ្លាសវៃ និងជំនាញចាំបាច់ ក៏ដូចជាមនសិការ ក្រមសីលធម៌ និងគុណតម្លៃដើម្បីឱ្យពួកគេខ្លួនជាពលរដ្ឋល្អ។

គោលនយោបាយនេះមានចំណុចយុទ្ធសាស្ត្រជាច្រើន ដូចជា ការអប់រំ និងជំនាញយុវជន សុខភាព ការងារ និងការស្ម័គ្រចិត្ត និងការចូលរួម។ ស្ថាប័នចម្បងដែលសម្របសម្រួល និងត្រួត

[145] នឹងបញ្ចូលតារាងមួយនៅពេលក្រោយ។
[146] សូមចូលទៅកាន់៖ https://data.adb.org/dataset/asia-small-and-medium-sized-enterprise-monitor-2021-volume-1-country-and-regional-reviews
[147] សូមចូលទៅកាន់៖ https://www.oecd.org/southeast-asia/data/sme.htm

ពិនិត្យការអនុវត្តគោលនយោបាយនេះគឺក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនកម្ពុជាដោយក្រសួងអប់រំ យុវជន និងកីឡា (អយក) ជាស្ថាប័នដឹកនាំកិច្ចការនេះ[148]។

**តាមពិត ការសម្របសម្រួល និងការពិនិត្យតាមដានការអភិវឌ្ឍយុវជនគឺទាបជាងការរំពឹងទុក។** ការអនុវត្តផ្នែកមួយចំនួននៃការអភិវឌ្ឍយុវជន ជាសមត្ថកិច្ចរបស់ក្រសួងផ្សេងៗ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា (សម្រាប់ការអប់រំ) ក្រសួងសុខាភិបាល (សម្រាប់សុខភាព) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សម្រាប់ជំនាញ និងការងារ)។ ចាប់តាំងពីការអនុវត្តនៅដើមឆ្នាំ២០០០ ក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនមានការលំបាកក្នុងការសម្របសម្រួលក្រសួងទាំងនេះ និងការប្រមូលទិន្នន័យដែលត្រូវការចាំបាច់ដើម្បីពិនិត្យតាមដានវឌ្ឍនភាព។ ក្រៅពីនេះ ការសម្របសម្រួលក៏ជាកិច្ចការលំបាកសម្រាប់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារពាក់ព័ន្ធនឹងយុវជនផងដែរ ហើយការជំរុញការចូលរួមរបស់ក្រុមគណបក្សដែលមាននិន្នាការជាអង្គការមិនមែនរដ្ឋាភិបាលផង និងនិន្នាការនយោបាយផង បានធ្វើឱ្យមានភាពចម្រុះ និងភាពរប៉ាត់រប៉ាយក្នុងសមាសភាគភាគីពាក់ព័ន្ធ[149]។

**ការផលិត និងប្រើប្រាស់ទិន្នន័យស្តីពីការអភិវឌ្ឍយុវជន ឆ្លុះបញ្ចាំងពីការលំបាកក្នុងការសម្របសម្រួលដែលបានលើកមកបង្ហាញខាងលើ។** ទីមួយ គឺគោលនយោបាយអភិវឌ្ឍន៍យុវជនឆ្នាំ២០១១ មិនមានក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃច្បាស់លាស់ ដូច្នេះ មិនមានការកំណត់ច្បាស់ពីទិន្នន័យដែលត្រូវការចាំបាច់ពីភាគីពាក់ព័ន្ធផ្សេងៗនោះទេ។ ទីពីរ គឺភាពមានកម្រិតនៃសមត្ថភាពរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនក្នុងការបំពេញតួនាទីចម្បងមួយរបស់ខ្លួន ពោលគឺការប្រមូលទិន្នន័យពីក្រសួង និងទីភ្នាក់ងារផ្សេងៗ ការរក្សាទុកទិន្នន័យក្នុងមូលដ្ឋានទិន្នន័យ និងការផលិតលទ្ធផលបច្ចុប្បន្នភាពនៃការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ។ កន្លងមក មិនមានការបំពេញកិច្ចការទាំងនេះឡើយ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនទើបតែបានអភិវឌ្ឍប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលអាចជឿជាក់ជាងមុន។

បញ្ហាប្រឈមក្នុងការផលិត និងប្រើប្រាស់ទិន្នន័យស្តីពីការអភិវឌ្ឍយុវជននៅកម្ពុជា លេចឡើងនៅពេលដែលរដ្ឋាភិបាលកម្ពុជាខិតខំបង្កើតសន្ទស្សន៍អភិវឌ្ឍន៍យុវជនជាលើកដំបូង ក្នុងឆ្នាំ២០១៨។ សន្ទស្សន៍អភិវឌ្ឍន៍យុវជន ជាគំនិតផ្តួចផ្តើមថ្នាក់តំបន់ដែលមានគោលបំណងប៉ាន់ប្រមាណ និងតាមដានវឌ្ឍនភាពនៃការអភិវឌ្ឍយុវជនក្នុងតំបន់អាស៊ាន (សម្រាប់ខ្លឹមសារបន្ថែម សូមមើលផ្នែកខាងក្រោម)។ សន្ទស្សន៍នេះផ្តោតសំខាន់លើវិស័យចំនួន៤ រួមមាន ការអប់រំ សុខភាព និងសុខុមាលភាព ការងារ និងឱកាស និងការចូលរួម និងការជំរុញការចូលរួម។ សម្រាប់វិស័យនីមួយៗ មានការប្រើប្រាស់កម្រងសូចនាករស្តង់ដារ។ យោងតាមមន្ត្រី អយក ដែលចូលរួមក្នុងលំហាត់

148 RGC (2011) National Youth Development Policy in Cambodia
149 Pak (2019) Assessment of youth development policy in Cambodia.

សន្ទស្សន៍អភិវឌ្ឍន៍យុវជន មានបញ្ហាជាច្រើននៅពេលប្រមូលទិន្នន័យសម្រាប់កិច្ចការនេះ ដូចជាការលំបាកក្នុងការទទួលបានទិន្នន័យពីក្រសួងផ្សេងទៀត កង្វះភាពច្បាស់លាស់ និងភាពមិនស៊ីសង្វាក់គ្នាក្នុងការកំណត់និយមន័យទិន្នន័យ។ល។

មកទល់បច្ចុប្បន្នគេនៅតែពឹងផ្អែកលើអង្កេតដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍ និងស្ថាប័នស្រាវជ្រាវដើម្បីស្វែងយល់ពីស្ថានភាពរបស់យុវជននៅកម្ពុជា។ ដោយសារតែប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃកាន់តែគ្រប់ជ្រុងជ្រោយសម្រាប់ការអភិវឌ្ឍយុវជនមិនទាន់ត្រូវបានរៀបចំឡើងឱ្យបានរួចរាល់ ទិន្នន័យថ្មីបំផុតស្ដីពីស្ថានភាពយុវជននៅកម្ពុជាទទួលបានពីការសិក្សាដែលធ្វើឡើងដោយតួអង្គមិនមែនរដ្ឋ ដូចជា ការសិក្សាស្ដីពីអក្ខរកម្ម និងជំនាញឌីជីថលរបស់យុវជន ការងាររបស់យុវជន ស្ថានភាពរបស់មនុស្សវ័យជំទង់។ល។

## ៥.៤.២ កម្មវិធីថ្មីមួយស្ដីពីការស្ម័គ្រចិត្តរបស់យុវជន និងការអភិវឌ្ឍសហគមន៍

កម្មវិធី "ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ" ត្រូវបានផ្ដួចផ្ដើមឡើងដោយអគ្គនាយកដ្ឋានយុវជន ក្នុងឆ្នាំ២០១៩ ក្រោមជំនួយបច្ចេកទេសពីកម្មវិធីអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ (UNV)។ ចាប់ពីឆ្នាំ២០២០ រហូតមកទល់បច្ចុប្បន្ន កម្មវិធី "ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ" មិនទទួលបានមូលនិធិពីម្ចាស់ជំនួយនោះទេ ប៉ុន្តែកម្មវិធីនេះនៅតែអាចពង្រីកការគ្របដណ្ដប់ពីចំនួន ១២ខេត្តក្នុងឆ្នាំ២០១៩ ដល់១៨ ខេត្តក្នុងឆ្នាំ២០២០ និងទូទាំងផ្ទៃប្រទេសក្នុងឆ្នាំ២០២១។ ក្នុងកម្មវិធីនេះ យុវជនចំនួន ១៥នាក់ត្រូវបានជ្រើសរើសពីខេត្តនីមួយៗ និងបង្កើតជា ៣ក្រុម ដែលក្រុមនីមួយៗទទួលការបណ្ដុះបណ្ដាលស្ដីពីរបៀបជ្រើសរើស បង្កើត និងអនុវត្តគម្រោងអភិវឌ្ឍន៍សហគមន៍ ដែលបន្ទាប់មកនឹងត្រូវបានវាយតម្លៃ និងសម្រេចយកជាជើងឯកនៅចុងឆ្នាំ។ ក្នុងឆ្នាំ ២០១៩ មានគម្រោងចំនួន៣៦ ត្រូវបានអនុវត្តដោយយុវជនចំនួន ១៦០នាក់។ ក្នុងឆ្នាំ២០២១ ចំនួនគម្រោងកើនដល់៨៥ និងអនុវត្តដោយយុវជនចំនួន ៤៥០នាក់នៅទូទាំងផ្ទៃប្រទេស។

គម្រោងដែលដឹកនាំដោយយុវជនក្នុងកម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ គ្របដណ្ដប់លើប្រធានបទចំនួន៨ ដូចជា ការអប់រំ កសិកម្ម និងបរិស្ថាន (ជាពិសេសការប្រមូលសំណល់)។ យុវជនដែលចូលរួមក្នុងកម្មវិធីនេះ បានទទួលការបណ្ដុះបណ្ដាលស្ដីពីជំនាញវិភាគ ការប្រមូលទិន្នន័យ ការងារជាក្រុម ទំនាក់ទំនង ការកៀរគរធនធាន និងជំនាញធ្វើបទបង្ហាញ។

ថ្មីៗនេះ ដោយសារវិបត្តិកូវីដ-១៩ យុវជនត្រូវបានតម្រូវឱ្យរៀនសូត្រជំនាញឌីជីថលថ្មីៗ ដូចជាការស្វែងរកទិន្នន័យតាមអ៊ីនធឺណិត កិច្ចប្រជុំអនឡាញ និងការរាយការណ៍តាមប្រព័ន្ធអ៊ីនធឺណិត។ បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាល ក្រុមយុវជនត្រូវសរសេរសំណើគម្រោងដែលមានស្តង់ដារសម្រាប់ក្រុមនីមួយ ដោយប្រើប្រាស់ទិន្នន័យពីមូលដ្ឋានទិន្នន័យឃុំ និងប្រភពផ្សេងទៀត។ ក្នុង

ពេលអនុវត្តគម្រោង យុវជនដែលចូលរួមក្នុងកម្មវិធីនេះត្រូវបានលើកទឹកចិត្តឱ្យធ្វើការ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងមន្ទីរពាក់ព័ន្ធ។

### ៥.៤.៣ ភាពពាក់ព័ន្ធរបស់អាស៊ាន

**ពាក់ព័ន្ធនឹងគោលនយោបាយទូទៅ អាស៊ានផ្តោតអាទិភាពខ្ពស់លើការអភិវឌ្ឍយុវជន ទាំងនៅកម្រិតតំបន់ និងកម្រិតរដ្ឋសមាជិក។** ដើម្បីសម្រួលដល់ដំណើរការគោលនយោបាយដែលមានប្រសិទ្ធភាពសម្រាប់ប្រធានបទនេះ អាស៊ានបានផ្តួចផ្តើមលំហាត់សន្ទស្សន៍អភិវឌ្ឍន៍យុវជន (YDI) ដើម្បីជានានូវគោលនយោបាយស្តីពីយុវជនដែលកាន់តែផ្អែកលើភស្តុតាង។ លំហាត់សន្ទស្សន៍អភិវឌ្ឍន៍យុវជនដំបូងរបស់អាស៊ានចាប់ផ្តើមក្នុងឆ្នាំ២០១៦ និងមានការផ្តល់របាយការណ៍ក្នុងឆ្នាំ២០១៧។

អាស៊ានបានកំណត់និយមន័យយុវជនជាមនុស្សដែលមានអាយុ ១៥-៣៥ ឆ្នាំ និងផ្តោតលើវិស័យចំនួន៥ រួមមាន ១) ការអប់រំ ២) សុខភាព និងសុខុមាលភាព ៣) ការងារ និងឱកាស ៤) ការចូលរួម និងការជំរុញការចូលរួម និង ៥) ការយល់ដឹងពីអាស៊ាន គុណតម្លៃ និងអត្តសញ្ញាណអាស៊ាន។ ដូចការលើកឡើងពីខាងដើម កម្ពុជាបានចូលរួមក្នុងលំហាត់សន្ទស្សន៍អភិវឌ្ឍន៍យុវជននៅឆ្នាំ ២០១៧ និងផ្តោតសំខាន់លើវិស័យចំនួន ៤ដំបូង។ នៅចុងឆ្នាំ២០២១ កម្ពុជាបានចាប់ផ្តើមដំណាក់កាលទី២ តែលើកឡើងនេះកម្ពុជាផ្តោតសំខាន់លើវិស័យទី៥[150]។

**ក្នុងក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន មានការផ្តោតការយកចិត្តទុកដាក់លើយុវជននៅក្នុងយុទ្ធសាស្ត្រទាំង៥។** ឧទាហរណ៍នៃគំនិតផ្តួចផ្តើម និងកម្មវិធីសំខាន់ៗ ដែលមានរៀបរាប់ក្នុងផែនការអនុវត្តន៍ រួមមានការលើកកម្ពស់ជំនាញរបស់យុវជន ជាពិសេសជំនាញបច្ចេកវិទ្យាឌីជីថល ការបំពេញតម្រូវការរបស់ពលករទេសន្តរប្រវេសក៍ ការលើកកម្ពស់ការវាយតម្លៃ និងការទទួលស្គាល់ជំនាញដែលកាន់តែមានស្តង់ដារនៅទូទាំងតំបន់អាស៊ានអាហារូបករណ៍សម្រាប់សិស្សនិស្សិតវ័យក្មេងលើជំនាញថ្មីៗដែលពាក់ព័ន្ធនឹងស្ថានភាពក្រោយវិបត្តិកូវីដ-១៩ និងការផ្តោតការយកចិត្តទុកដាក់លើសុខភាពផ្លូវចិត្តរបស់យុវជន ជាពិសេសក្នុងអំឡុងពេលបិទខ្ទប់ និងក្នុងពេលមានការលំបាកផ្នែកសេដ្ឋកិច្ច[151]។

---

[150] https://borneobulletin.com.bn/asean-report-focusses-on-youth-awareness-values-and-identity/

[151] ASEAN's ACRF

## ៦. សេចក្ដីសន្និដ្ឋានសំខាន់ៗ និងអនុសាសន៍សម្រាប់កម្មវិធី

### ៦.១ សេចក្ដីសន្និដ្ឋានសំខាន់ៗ

ផ្អែកតាមលទ្ធផលរកឃើញកន្លងមក របាយការណ៍នេះបានរំលេចសេចក្ដីសន្និដ្ឋានសំខាន់ៗមួយចំនួន។ សេចក្ដីសន្និដ្ឋានគឺផ្អែកតាមចម្លើយទៅនឹងសំណួរក្នុងការស្រាវជ្រាវ និងពាក់ព័ន្ធនឹងអនុសាសន៍ដែលមានបង្ហាញក្នុងផ្នែកបន្ទាប់។

**ពាក់ព័ន្ធនឹងនិន្នាការអភិវឌ្ឍ និងការស្ដារឡើងវិញក្រោយវិបត្តិកូវីដ-១៩ រដ្ឋាភិបាលកម្ពុជាបានអនុម័តផែនការគ្រប់ជ្រុងជ្រោយមួយ។** ផែនការនោះគូសបញ្ជាក់ពីវិស័យអាទិភាពមួយចំនួនដូចជា កសិកម្ម កសិ-ឧស្សាហកម្ម ទេសចរណ៍ កាត់ដេរ និងឧស្សាហកម្មមិនមែនកាត់ដេរ។ ក្រៅពីនេះ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចថ្នាក់តំបន់ សេដ្ឋកិច្ចឌីជីថល ការទ្រទ្រង់សហគ្រាសខ្នាតតូច និងមធ្យម ការអភិវឌ្ឍជំនាញ និងកិច្ចគាំពារសង្គមក៏ជាអាទិភាពសំខាន់ៗក្នុងរបៀបវារៈរបស់កម្ពុជាផងដែរ។ អាទិភាពទាំងនេះបន្សុីគ្នានឹងអាទិភាពដែលបានកំណត់នៅកម្រិតអាស៊ាន ដែលកម្ពុជាអាចគូសបញ្ជាក់បន្ថែមទៀត នៅពេលធ្វើជាប្រធានកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០២២។ អាទិភាពទាំងនេះក៏ពិចារណាពីនិន្នាការធំៗនៅកម្រិតសកល និងកម្រិតតំបន់ផងដែរ ជាពិសេសពាក់ព័ន្ធនឹងការវិនិយោគពីបរទេស សេដ្ឋកិច្ចឌីជីថល អភិបាលកិច្ចទិន្នន័យ កិច្ចគាំពារសង្គម និងការងារ និងការប្រែប្រួលអាកាសធាតុ។

**ពាក់ព័ន្ធនឹងដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជា កិច្ចការដំបូងដែលធ្វើឡើងដោយការសិក្សានេះគឺការកំណត់និយមន័យ និងការបែងចែកប្រភេទនៃដំណើរការនេះ។** ការសិក្សានេះកំណត់គោលនយោបាយសាធារណៈនៅកម្ពុជាជាគោលនយោបាយរយៈពេលវែង (៣-៥ ឆ្នាំ) និងគោលនយោបាយរយៈពេលមធ្យម (៣ឆ្នាំ)។ គោលនយោបាយមួយផ្ដល់ទិសដៅ និងអាទិភាពសម្រាប់រដ្ឋាភិបាល និងទីភ្នាក់ងាររបស់ខ្លួនសម្រាប់បញ្ហាមួយចំនួន តាមរយៈការបញ្ជាក់ពីចក្ខុវិស័យ គោលដៅ គោលបំណង យុទ្ធសាស្ត្រ ភាគីពាក់ព័ន្ធ វិធានការសំខាន់ៗ ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងធនធានហិរញ្ញវត្ថុ។ ការអនុវត្តគោលនយោបាយមួយត្រូវអមជាមួយឧបករណ៍ច្បាប់សមស្រប និងកញ្ចប់ថវិកា។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសកម្មក្នុងការរៀបចំ និងពង្រឹងការអនុវត្តដំណើរការស្តង់ដារសម្រាប់ការរៀបចំកញ្ចប់ថវិកា ការអនុវត្តគោលនយោបាយ (ភាគច្រើនស្ដីពីការអនុវត្តថវិកា) និងការពិនិត្យតាមដាន និងវាយតម្លៃ។

មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួនប៉ុន្តែនៅតែមានបញ្ហាប្រឈមក្នុងដំណើរការគោលនយោបាយសាធារណៈនៅកម្ពុជា។ មានការបង្កើត និងអនុវត្តគោលការណ៍ និងនីតិវិធីដែលកាន់តែមានស្តង់ដារ នៅគ្រប់ដំណាក់កាលគោលនយោបាយដើម្បីធានាប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព

គណនេយ្យភាព និងការចូលរួម។ សមត្ថភាពរបស់ភាគីពាក់ព័ន្ធក៏មានភាពប្រសើរឡើងផងដែរ ជាពិសេសដោយសារការផ្តល់តួនាទីគ្រប់គ្រងដល់អ្នកជំនាញការវ័យក្មេងកាន់តែច្រើន។បញ្ហាប្រឈមធំៗ រួមមានការសម្របសម្រួលឆ្លងក្រសួង (ជាពិសេសសម្រាប់គោលនយោបាយឆ្លងវិស័យ) កង្វះភាពពាក់ព័ន្ធគ្នារវាងគោលនយោបាយ និងវិភាជថវិកា និងភាពមានកម្រិតនៃការពិនិត្យតាមដាន និងវាយតម្លៃ ជាពិសេសនៅកម្រិតផលប៉ះពាល់។ ការជំរុញការចូលរួមរបស់តួអង្គមិនមែនរដ្ឋគឺមិនមានកម្រិតដូចគ្នានោះទេ ពោលគឺអាស្រ័យលើកម្រិតទំនុកចិត្ត និងសមត្ថភាពបច្ចេកទេសរបស់ភាគីពាក់ព័ន្ធ។

**រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការប្រើប្រាស់ទិន្នន័យ ក្នុងដំណើរការគោលនយោបាយសាធារណៈ។** ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃដំណើរការនេះអាស្រ័យលើគុណភាពនៃប្រព័ន្ធអភិបាលកិច្ចទិន្នន័យជារួម។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍គឺជាអ្នកផលិត និងប្រើប្រាស់ទិន្នន័យច្រើនជាងគេ។ ខណៈដែលមានការផលិតទិន្នន័យផ្លូវការកាន់តែច្រើន ចាំបាច់ត្រូវបង្កើនគុណភាព និងភាពអាចជឿជាក់បាននៃទិន្នន័យទាំងនោះ។ ឧ. មានការព្រួយបារម្ភជុំវិញភាពចាំបាច់ក្នុងការពិនិត្យមើលភាពពេញលេញ និងភាពអាចជឿជាក់បាននៃសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ (ឧ. ផសស និងអត្រាភាពក្រីក្រ) និងតម្រូវការទិន្នន័យកាន់តែច្រើនស្តីពីក្រុមងាយរងគ្រោះ ជាពិសេសពាក់ព័ន្ធនឹងផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។ អ្វីដែលជាបញ្ហាចោទជាងនេះគឺការចែករំលែកទិន្នន័យ និងការប្រើប្រាស់ទិន្នន័យ ទាំងក្នុងរដ្ឋាភិបាល និងរវាងរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋ។ រដ្ឋាភិបាលបានទទួលស្គាល់បញ្ហានេះ និងបានរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ និងកែលម្អវេទិកាចែករំលែកទិន្នន័យរបស់ខ្លួន (ដូចជា CamStat)។ ក្នុងប្រទេសមួយចំនួនដំណោះស្រាយសម្រាប់បញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការចែករំលែក និងប្រើប្រាស់ទិន្នន័យគឺការបង្កើតឱ្យមាន "អន្តរការីទិន្នន័យ" ដែលដើរតួនាទីជាអ្នកសម្របសម្រួល។

**កន្លងមក មិនសូវមានការចូលរួមពីតួអង្គមិនមែនរដ្ឋឡើយ។ មួយផ្នែក គឺដោយសារតែបញ្ហាប្រឈមក្នុងការកសាងទំនាក់ទំនង ប៉ុន្តែហាក់មានទំនុកចិត្តកាន់តែច្រើនក្នុងចំណោមក្រុមអ្នកធ្វើការការិយាល័យ និងអ្នកជំនាញវ័យក្មេងក្នុងវិស័យមិនមែនរដ្ឋាភិបាល។** គួរកត់សម្គាល់ផងដែរថា អ្នកស្រាវជ្រាវនៅកម្ពុជា ជាពិសេសអ្នកស្រាវជ្រាវវ័យក្មេង (រួមទាំងស្ត្រី) បានដើរតួនាទីកាន់តែសំខាន់ក្នុងស្ថាប័នស្រាវជ្រាវ និងស្ថាប័នផ្តល់យោបល់នៅកម្ពុជា។ ទោះជាយ៉ាងណា នៅតែមិនទាន់មានឱកាស និងការណែនាំគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងការកើនឡើងនៃចំនួនអ្នកស្រាវជ្រាវវ័យក្មេងនៅកម្ពុជានោះទេ។

បញ្ហាផ្នែកបច្ចេកទេសចំនួន៣ ប្រហែលជាបានរឹតត្បិតភាពអាចជឿជាក់បាននៃការងារស្រាវជ្រាវដែលផលិតដោយតួអង្គមិនមែនរដ្ឋ ក្នុងក្រសែភ្នែកអ្នកតាក់តែងគោលនយោបាយ។ បញ្ហាទីមួយ

គឺកង្វះ "ភាពជាតំណាងក្នុងការធ្វើសំណាក" នៃការងារស្រាវជ្រាវទាំងនោះ។ បញ្ហានេះពាក់ព័ន្ធនឹងកង្វះលទ្ធភាពរបស់អ្នកស្រាវជ្រាវក្នុងការទទួលបានទិន្នន័យសំណាកធំពីរដ្ឋាភិបាល និងភាពមានកម្រិតនៃការប្រើប្រាស់ថ្នាលឌីជីថលដែលចំណាយតិចសម្រាប់ការប្រមូលទិន្នន័យ (សូមមើលខាងក្រោម)។ បញ្ហាទីពីរគឺកង្វះលទ្ធភាពរបស់អ្នកស្រាវជ្រាវក្នុងការទទួលបានទិន្នន័យផ្លូវការដែលផលិតដោយរដ្ឋាភិបាល (ដូចការលើកឡើងពីខាងដើម)។ ពាក់ព័ន្ធនឹងចំណុចនេះ គួរកត់សម្គាល់ថា ក្នុងករណីដែលមានទិន្នន័យ (ភាគច្រើនគឺក្នុងគេហទំព័រផ្លូវការ) ការប្រើប្រាស់ទិន្នន័យទាំងនេះក៏នៅមានកម្រិតផងដែរ។ បញ្ហាទីបីគឺកង្វះចក្ខុវិស័យប្រហាក់ប្រហែលគ្នាក្នុងតំបន់ជាពិសេសចក្ខុវិស័យស្ដីពីអនុសាសន៍គោលនយោបាយដែលលើកឡើងដោយការងារស្រាវជ្រាវទាំងនោះ។

ស្ថាប័នស្រាវជ្រាវក្នុងស្រុក និងអង្គការសង្គមស៊ីវិល មិនបានទាញប្រយោជន៍ពេញលេញពីសក្ដានុពលនៃថ្នាលឌីជីថលសម្រាប់ការប្រមូល និងទទួលបានទិន្នន័យនោះទេ។ ចំណុចនេះរួមមានការប្រើប្រាស់កម្មវិធីប្រភពបើកទូលាយ ដូចជា Kobo Toolbox ដើម្បីប្រមូល និងវិភាគទិន្នន័យអង្កេតអនឡាញ ដូចជា SurveyMonkey ឬ Google forms, chatbot ការប្រើប្រាស់ប្រភពទិន្នន័យបើកទូលាយ (ដូចជា ប្រភពទិន្នន័យដែលផ្ដល់ដោយធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ។ល។) និងការប្រើប្រាស់ទិន្នន័យដែលផលិតដោយប្រជាពលរដ្ឋ។ មួយផ្នែកគឺស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិលនៅកម្ពុជា បាន និងកំពុងប្រើប្រាស់បច្ចេកទេសទាំងនេះ។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានការបណ្ដុះបណ្ដាលបន្ថែមទៀតដើម្បីពន្លឿន និងធ្វើឱ្យដំណើរការនេះកាន់តែមានប្រសិទ្ធភាព។

ស្ថាប័នស្រាវជ្រាវ និងអង្គការសង្គមស៊ីវិលក្នុងស្រុក មិនបានបង្កើនកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធក្នុងការប្រើប្រាស់ចំណេះដឹងពីកម្រិតអាស៊ានដើម្បីដាក់បញ្ចូលក្នុងការវិភាគស្ដីពីប្រទេសកម្ពុជានោះទេ។ ក្នុងគេហទំព័រផ្លូវការរបស់ខ្លួន អាស៊ាន ជាពិសេសផ្នែកស្ថិតិអាស៊ាន (ASEANstats) បានផ្ដល់ព័ត៌មានយ៉ាងច្រើន។ ទន្ទឹមនឹងនេះ ទីភ្នាក់ងារពហុភាគីផ្សេងទៀត ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានចងក្រងសំណុំទិន្នន័យល្អៗជាច្រើន និងផ្សព្វផ្សាយតាមអ៊ីនធឺណិតផងដែរ។ អ្នកស្រាវជ្រាវកម្ពុជាអាចប្រើប្រាស់ធនធានទាំងនេះដើម្បីគូសបញ្ជាក់ពីស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា និងមាគ៌ាឆ្ពោះទៅមុខ។ ការប្រៀបធៀបថ្នាក់តំបន់បានផ្ដល់ទាំងចក្ខុវិស័យស្ដីពីបញ្ហានានា ក៏ដូចជាដំណោះស្រាយ ពោលគឺដំណោះស្រាយដែលមានការបញ្ជាក់ដោយផ្អែកតាមបទពិសោធន៍ក្នុងបណ្ដាប្រទេសផ្សេងទៀតនៅក្នុងតំបន់។ នៅពេលទទួលបានចំណេះដឹងកាន់តែច្រើនពីកម្រិតអន្តរជាតិ និងកម្រិតតំបន់ ស្នាដៃស្រាវជ្រាវដែលផលិតឡើងដោយអ្នកស្រាវជ្រាវកម្ពុជា ពិតជាអាចទាក់ទាញចំណាប់អារម្មណ៍របស់អ្នកតាក់តែងគោលនយោបាយ។

**ផ្នែកសំខាន់មួយដែលមិនត្រូវបានលើកមកពិភាក្សាឱ្យបានគ្រប់គ្រាន់ក្នុងការសិក្សានេះគឺការជំរុញការចូលរួមរបស់វិស័យឯកជន និងសក្តានុពលនៃទិន្នន័យ** Big Data។ បច្ចុប្បន្ន បញ្ហានេះបានទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់រដ្ឋាភិបាលកម្ពុជា និងអាស៊ាន។ នឹងមានចំណាប់អារម្មណ៍ និងភាពចាំបាច់កាន់តែខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដោយសារល្បឿននៃឌីជីថលូបនីយកម្ម។ ប៉ុន្តែមិនទាន់មានការសិក្សាស្តីពីប្រធានបទសំខាន់នេះសម្រាប់ករណីប្រទេសកម្ពុជា ដោយប្រើប្រាស់ការប្រៀបធៀប និងបទពិសោធន៍ពីអាស៊ាន និងប្រទេសផ្សេងទៀតនោះទេ។

## ៦.២ អនុសាសន៍សម្រាប់ការពិចារណាក្នុងការរៀបចំកម្មវិធី

**អនុសាសន៍ទាំងនេះគឺសម្រាប់កម្មវិធីពន្លកចំណេះ និងកម្មវិធីស្រដៀងគ្នាផ្សេងទៀតដែលខិតខំផ្តល់ការគាំទ្រដល់សមត្ថភាពស្រាវជ្រាវគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា។** កម្មវិធីពន្លកចំណេះ មានគោលបំណងគាំទ្រ និងពង្រឹងសមត្ថភាពនៃវិស័យស្រាវជ្រាវ និងផ្តល់មូលដ្ឋានព័ត៌មានដល់ការវិភាគគោលនយោបាយសាធារណៈនៅកម្ពុជា។ ដៃគូចម្បង និងដៃគូស្រាវជ្រាវថ្មីៗរបស់កម្មវិធីនេះបានធ្វើការស្រាវជ្រាវផ្សេងៗស្តីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យចម្រុះ ដូចជា ការអប់រំ ទេសចរណ៍ ការអភិវឌ្ឍទីក្រុង វិស័យកាត់ដេរ កសិកម្ម សហគ្រាសគ្រិនភាព ទេសន្តរប្រវេសន៍ឆ្លងដែន យេនឌ័រ និងបរិយាបន្នសង្គម។ល។ កម្មវិធីពន្លកចំណេះផ្តោតការយកចិត្តទុកដាក់ជាពិសេសលើអ្នកស្រាវជ្រាវជាស្ត្រី។ ក្រៅពីនេះ កម្មវិធីពន្លកចំណេះបានចាប់ដៃគូជាមួយស្ថាប័នរដ្ឋាភិបាលសំខាន់ៗ ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រសួងផែនការ។ល។

គោលបំណងនៃកម្មវិធីពន្លកចំណេះដែលទ្រទ្រង់ដល់ភាពប្រសើរឡើងនៃការប្រើប្រាស់ទិន្នន័យ និងភស្តុតាងក្នុងការតាក់តែងគោលនយោបាយសាធារណៈ កាន់តែមានភាពពាក់ព័ន្ធនឹងផែនការស្តារឡើងវិញពីវិបត្តិកូវីដ-១៩ របស់រដ្ឋាភិបាលកម្ពុជា។ នៅពេលដែលនិន្នាការអភិវឌ្ឍន៍មានភាពស្មុគស្មាញកាន់តែខ្លាំងឡើង លំហរសារពើពន្ធកាន់តែតូចចង្អៀត ហើយការលេចឡើងនៃភាពងាយរងគ្រោះមានលក្ខណៈខុសពីមុន រដ្ឋាភិបាលកម្ពុជាត្រូវការទិន្នន័យប្រសើរជាងមុនដើម្បីកែលម្អការកំណត់ចំណុចដៅនៃការអភិវឌ្ឍ និងការត្រួតពិនិត្យការប្រើប្រាស់ធនធានសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។ ស្ថាប័នរដ្ឋាភិបាលដែលកំពុងចូលរួមជាមួយកម្មវិធីពន្លកចំណេះ (ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ល។) ក៏ជាភាគីពាក់ព័ន្ធសំខាន់ៗក្នុងគោលនយោបាយសាធារណៈ និងការប្រើប្រាស់ទិន្នន័យផងដែរ។ ក្រៅពីនេះ មានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការលើកស្ទួយអ្នកស្រាវជ្រាវវ័យក្មេង។

សម្រាប់ជាជំហានបន្ទាប់ក្នុងការបង្កើនប្រសិទ្ធភាព និងផលប៉ះពាល់របស់ខ្លួន កម្មវិធីពន្លកចំណេះគួរអនុវត្តតាមអនុសាសន៍ជាយុទ្ធសាស្ត្រ និងអនុសាសន៍ផ្នែកប្រតិបត្តិការ។ ជាយុទ្ធសាស្ត្រ កម្មវិធីពន្លកចំណេះគួរអភិវឌ្ឍខ្លួនឱ្យក្លាយជា "អន្តរការីទិន្នន័យ" រវាងរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋ ក្នុងចំណោមតួអង្គមិនមែនរដ្ឋ និងរវាងអ្នកស្រាវជ្រាវកម្ពុជា និងភាគីពាក់ព័ន្ធនៅកម្រិតតំបន់ ដូចជា ស្ថាប័នសិក្សាស្រាវជ្រាវក្នុងអាស៊ាន និងក្នុងប្រទេសអូស្ត្រាលី។ គោលបំណងចម្បងគឺដើម្បីលើកកម្ពស់ ១) ទំនុកចិត្ត និងកិច្ចសហការក្នុងការរៀបចំ និងការអនុវត្តការស្រាវជ្រាវ ការចែករំលែកទិន្នន័យ ការប្រើប្រាស់ទិន្នន័យ និងការផ្សព្វផ្សាយការស្រាវជ្រាវក្នុងចំណោមតួអង្គទាំងនេះ និង ២) ចក្ខុវិស័យក្នុងតំបន់ស្តីពីការវិភាគទិន្នន័យ និងការអនុវត្តគំនិតផ្តួចផ្តើមទិន្នន័យថ្មីៗ ដូចជា Big Data និងការប្រើប្រាស់ទិន្នន័យសម្រាប់គោលបំណងឯកជនដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ។

ផ្អែកតាមទិសដៅយុទ្ធសាស្ត្រខាងលើ កម្មវិធីពន្លកចំណេះអាចពិចារណាពីគំនិតប្រតិបត្តិការមួយចំនួន ដូចខាងក្រោម៖

- **ផ្តោតសំខាន់លើបញ្ហាអភិវឌ្ឍន៍សំខាន់ៗ និងគម្លាតគោលនយោបាយសាធារណៈ៖** កម្មវិធីពន្លកចំណេះគួរជំរុញការស្រាវជ្រាវប្រធានបទ ដែលពាក់ព័ន្ធនឹងការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើ ១) ការប្រែប្រួលលក្ខណៈនៃភាពងាយរងគ្រោះ និងតម្រូវការរបស់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី យុវជន វិស័យក្រៅផ្លូវការ សហគ្រាសខ្នាតតូច និងមធ្យម។ល។ ២) ផលប៉ះពាល់នៃវិធានការគោលនយោបាយផ្សេងៗដែលរដ្ឋាភិបាលបានអនុវត្ត និងរបៀបកែលម្អវិធានការទាំងនោះដើម្បីធានាភាពពាក់ព័ន្ធគ្នាកាន់តែប្រសើររវាងគោលនយោបាយ និងថវិកាក្នុងអន្តរាគមន៍គោលនយោបាយ។
- **ការឆ្លុះបញ្ចាំងលើនិន្នាការធំៗ និងចំណេះដឹងក្នុងតំបន់៖** ក្នុងករណីដែលអាចអនុវត្តបាន ការងារស្រាវជ្រាវដែលធ្វើឡើងដោយដៃគូរបស់កម្មវិធី គួរពិចារណាពីនិន្នាការធំៗ និងរួមបញ្ចូលចំណេះដឹងពីអាស៊ាន និងតំបន់ផ្សេងទៀត។ ក្នុងចំណោមនិន្នាការធំៗដែលលើកមកពិភាក្សាក្នុងផ្នែកទី ២ នៃរបាយការណ៍នេះ និន្នាការមួយចំនួនតូចទាមទារការផ្តោតការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់កម្មវិធី និងដៃគូរបស់កម្មវិធី។ និន្នាការទាំងនោះមានដូចជា ការស្តារឡើងវិញពីវិបត្តិកូវីដ-១៩ នៅកម្រិតសកល និងកម្រិតតំបន់អាស៊ាន ជាពិសេសសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងការវិនិយោគពីបរទេស សេដ្ឋកិច្ចឌីជីថល រដ្ឋាភិបាលឌីជីថល និងអភិបាលកិច្ចទិន្នន័យ។ និន្នាការដែលមានសារៈសំខាន់ដូចគ្នានេះដែររួមមាន ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម កិច្ចគាំពារសង្គម ទេសន្តរប្រវេសន៍ឆ្លងដែន និងការអភិវឌ្ឍយុវជន។
- **ការកសាងទំនុកចិត្ត និងភាពជាដៃគូក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ៖** គួរពង្រឹងភាពជាដៃគូដែលមានស្រាប់រវាងកម្មវិធីពន្លកចំណេះ និងស្ថាប័នរដ្ឋាភិបាល តាមរយៈ ១) ការកំណត់រក

អគ្គនាយកដ្ឋាន និងនាយកដ្ឋានជាក់លាក់ដែលកម្មវិធីគួរសហការជាមួយ (ឧ. អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពគោលនយោបាយនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ អគ្គនាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា។ល។) និង ២) ការគាំទ្រដល់គម្រោងស្រាវជ្រាវមួយចំនួនដែលមានភាពជាដៃគូរវាងតួអង្គមិនមែនរដ្ឋ និងអគ្គនាយកដ្ឋាន និងនាយកដ្ឋានមួយចំនួន។

- **ការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវ៖** កម្មវិធីពន្លកចំណេះគួរកសាងសមត្ថភាពស្រាវជ្រាវសម្រាប់ដៃគូរបស់ខ្លួន និងអ្នកស្រាវជ្រាវមកពីទីភ្នាក់ងាររដ្ឋាភិបាលដែលចូលរួមជាមួយកម្មវិធីតាមរយៈការស្រាវជ្រាវដែលគាំទ្រដោយកម្មវិធីផ្ទាល់។ ពាក់ព័ន្ធនឹងប្រធានបទសម្រាប់ការកសាងសមត្ថភាព ក្រៅពីចំណេះដឹងទូទៅស្តីពីដំណើរការស្រាវជ្រាវ ការបណ្តុះបណ្តាលគួរផ្តោតលើជំនាញថ្មីៗជុំវិញការប្រមូលទិន្នន័យ (ឧ. កម្មវិធីតាមអនឡាញ ប្រភពទិន្នន័យបើកទូលាយ ទិន្នន័យដែលផលិតដោយប្រជាពលរដ្ឋ) និងរបៀបទាញប្រយោជន៍ពីទិន្នន័យដែលមានស្រាប់ទាំងក្នុងប្រទេស និងក្នុងតំបន់។
- **ការសម្របសម្រួលការប្រមូលការចែករំលែកនិងការប្រើប្រាស់ទិន្នន័យ៖** កម្មវិធីពន្លកចំណេះគួរដើរតួនាទីជាមជ្ឈមណ្ឌលសម្រាប់សម្រាប់ការប្រមូល រក្សាទុក និងធ្វើបច្ចុប្បន្នភាពទិន្នន័យពីទីភ្នាក់-ងាររដ្ឋាភិបាល និងប្រភពផ្សេងៗ ទាំងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ គួរផ្សព្វផ្សាយទិន្នន័យដែលប្រមូលបានដល់ដៃគូស្រាវជ្រាវរបស់កម្មវិធី និងសាធារណជន ក៏ដូចជាអនុវត្តតាមវិធាន និងនីតិវិធីសមស្រប។ ក្នុងករណីអាចអនុវត្តបាន កម្មវិធីគួរផ្តល់ការណែនាំស្តីពីការយល់ដឹង និងការប្រើប្រាស់ទិន្នន័យ។
- **ការតស៊ូមតិឱ្យមានការចែករំលែកទិន្នន័យកាន់តែច្រើន៖** អនុលោមតាមគោលនយោបាយរបស់រដ្ឋាភិបាល និងផ្អែកលើបណ្តាញដែលមានស្រាប់ កម្មវិធីពន្លកចំណេះគួរដើរតួនាទីយ៉ាងសកម្មក្នុងការតស៊ូមតិឱ្យមានការចែករំលែកទិន្នន័យកាន់តែច្រើនពីរដ្ឋាភិបាល ទៅអ្នកស្រាវជ្រាវនៅក្រៅរដ្ឋាភិបាល។ ការតស៊ូមតិនេះអាចធ្វើឡើង ក្នុងបរិបទនៃយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យដែលក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិនឹងអនុវត្តនៅពេលឆាប់ៗនេះ និងយុទ្ធសាស្ត្រផ្សេងទៀត ដូចជា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ កម្មវិធីអាចផ្តោតគោលដៅលើសំណុំទិន្នន័យជាក់លាក់ ដូចជា អង្កេតថ្នាក់ជាតិនាពេលថ្មីៗនេះដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (អង្កេតការងារ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា អង្កេតកសិកម្ម អង្កេតសហគ្រាសដែលនឹងធ្វើឡើងនាពេលឆាប់ៗនេះ ប្រភពទិន្នន័យនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដូចជា ទិន្នន័យវិភាជថវិកាលម្អិតរបស់ក្រសួង និងរដ្ឋបាល

ថ្នាក់ក្រោមជាតិ ទិន្នន័យរដ្ឋបាល) ទិន្នន័យពីលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (ដូចជា មូលដ្ឋានទិន្នន័យឃុំ) និងទិន្នន័យដែលពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម។

- **ការលើកស្ទួយអ្នកស្រាវជ្រាវវ័យក្មេង៖** តាមការលើកឡើងក្នុងការសិក្សានេះ អ្នកស្រាវជ្រាវវ័យក្មេងមានសក្តានុពលជាច្រើន ប៉ុន្តែពួកគេត្រូវការការណែនាំ និងការតម្រឹមតម្រង់បន្ថែមទៀត។ កម្មវិធីពន្លកចំណេះគួរលើកទឹកចិត្តឱ្យដៃគូរបស់ខ្លួនជំរុញការចូលរួមរបស់អ្នកស្រាវជ្រាវនិងអ្នកហាត់ការវ័យក្មេង ក្នុងគម្រោងស្រាវជ្រាវដែលទទួលបានការឧបត្ថម្ភ និងរៀបចំកម្មវិធីបណ្តុះបណ្តាលការស្រាវជ្រាវដែលកែសម្រួលទៅតាមតម្រូវការរបស់អ្នកស្រាវជ្រាវវ័យក្មេង ជាពិសេសអ្នកស្រាវជ្រាវជាស្ត្រី និងអ្នកស្រាវជ្រាវដែលមកពីតាមបណ្តាខេត្ត។ ក្រៅពីនេះ កម្មវិធីពន្លកចំណេះគួរពិចារណាផ្តល់ការណែនាំ/ការបង្វឹកបង្ហាត់ដល់គំនិតផ្តួចផ្តើម និងកម្មវិធីយុវជនថ្មីៗ ដូចជា កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំជាដើម។
- **ផ្តួចផ្តើមប្រធានបទស្រាវជ្រាវដែលថ្មី និងសំឡឹងឆ្ពោះទៅមុខ៖** ទន្ទឹមនឹងការផ្តោតលើបញ្ហាចំពោះមុខ និងតម្រូវការផ្នែកបច្ចេកទេស កម្មវិធីពន្លកចំណេះគួរផ្តួចផ្តើមប្រធានបទស្រាវជ្រាវថ្មីៗស្តីពីអភិបាលកិច្ចទិន្នន័យ និងគោលនយោបាយសាធារណៈ។ ប្រធានបទជាឧទាហរណ៍រួមមាន ការឆ្ពោះទៅរកទិន្នន័យ Big Data និងការជំរុញចូលរួមរបស់វិស័យឯកជនក្នុងវិស័យសំខាន់ៗ ដូចជា ទេសចរណ៍ កសិកម្ម និងសហគ្រាសខ្នាតតូច និងមធ្យម។ ក្នុងការផ្តួចផ្តើមប្រធានបទថ្មីៗ កម្មវិធីពន្លកចំណេះគួរពាំនាំចក្ខុវិស័យកាន់តែច្រើនពីកម្រិតតំបន់ ជាពិសេសកម្រិតអាស៊ាន។
- **ការបង្កើតភាពជាដៃគូជាមួយស្ថាប័នស្រាវជ្រាវក្នុងតំបន់៖** ការកសាងភាពជាដៃគូជាមួយស្ថាប័នស្រាវជ្រាវថ្នាក់តំបន់ (ក្នុងអាស៊ាន និងប្រទេសអូស្ត្រាលី) មានសារៈសំខាន់ណាស់សម្រាប់ការកសាងសមត្ថភាពបច្ចេកទេស និងការជំរុញលើកទឹកចិត្ត ការបង្កើនភាពអាចជឿជាក់បាន និងការកសាងទំនុកចិត្ត ជាពិសេសទំនុកចិត្តរវាងស្ថាប័នក្នុងស្រុក និងទីភ្នាក់ងាររដ្ឋាភិបាល។ អង្គការមូលនិធិអាស៊ី និងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី រួមជាមួយនឹងបណ្តាញយ៉ាងច្រើនរបស់ខ្លួននៅកម្រិតអាស៊ាន និងក្រៅពីនេះ គួរតភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នស្រាវជ្រាវក្នុងស្រុកទៅនឹងកម្រិតតំបន់ និងផ្តួចផ្តើមគម្រោងស្រាវជ្រាវថ្នាក់តំបន់ ជាពិសេសប្រធានបទស្រាវជ្រាវថ្មីៗដូចបានលើកឡើងខាងលើ។

# ឯកសារយោង


ADB (2011) Decentralization and de-concentration in Cambodia.

ADB (2020) Kingdom of Cambodia: Supporting digital Cambodia for inclusive de velopment project.

ADGSOM (2021) ASEAN data management framework: Data governance and pro tection throughout the data lifecycle.

Allen, R. et al (2013) The international handbook of public financial management

Allen, R., and P. Kohnert. 2012. "Anatomy of a Finance Minister," Mimeo. Washing ton, DC: IMF.

AMRO (2021) AMRO annual consultation report – Cambodia 2021.

ASEAN (2018) ASEAN Declaration on Strengthening Social Protection

ASEAN (2020) ASEAN Comprehensive Recovery Framework (ACRF) – Implemen tation Plan.

ASEAN and UNCTAD (2021) ASEAN investment report (2020-2021): Investing in Industry 4.0. Jarkata, Indonesia.

Australian Government (2021) Australia with its Australia's Long-Term Emissions Reducation Plan adopted in 2021, Canberra.

Brown, C et al (2018) A poor means test? Econometric targeting in Africa, Journal of Development Economics, Elsevier, vol. 134(C), p. 109-124.

CADT, CDRI, et al (2021) Demand for and supply of digital skills in Cambodia

CICP (2021) Cambodia's Chairmanship of ASEAN: Challenging Perceptions, Con cretizing Consolidations

CoM (2011) Notification on the preparation of policy, strategy, and workplan doc- ument.

EU (2020) Assessment of the Budget Strategic Plan (BSP) of selected ministries

Google, Temasek and Bain & Company (2021) E-Conomy SEA 2021: Roaring 20s: The SEA digital decade. USA.

Hang, C. (2015) Cambodia's economy: Toward a brighter future – Progress, chall enges, and future prospects.

ILO (2021) World employment and social outlook trends (2022). Geneva.

ILO (2021) World Social Protection Report (2020-2022). Geneva.

INASP (2016) Evidence-informed policy making toolkit,

KAS and AVI (2021) Cambodia's ASEAN Chairmanship 2021: Priorities and Chal lenges

Lim H, (2021) ASEAN's contribution to regional peace and stability: A Cambodian perspective in Cambodia's ASEAN Chairmanship in 2022: Priorities and chal- lenges.

Luo, Jing Jing, and Kheang Un. "China's Role in the Cambodian People's Party's Quest for Legitimacy." Contemporary Southeast Asia 43, no. 2 (2021): 395- 419.

MEF (2011) Guideline on preparing Budget Strategic Plan (BSP)
MEF (2015) Guideline on preparing program-based budgets
MEF (2019) SNA-BSRS (2019-2025)
MEF (2020) Circular on preparing BSP for 2021.
MEF (2020) Circular on preparing Budget Strategic Plan (BSP) for 2021.
MOP (2012) Scorecard of the implementation of Cambodia Millennium Development Goals (CMDG) at sub-national levels
MOP (2015) Monitoring and evaluation for NSDP implementation system (MENI) orientation guideline.
MOP (2015) Summary assessment of the M&E system for NSDP implementation.
MOT (2020) Statistics on the number and types of tourism sector business in 2019
MOT (2021) Key statistics of tourism sector and prediction
NCDD (2021) National Program on Sub-National Democratic Development (NP-SNDD) for 2021-2030.
NSPC (2021) M&E framework for social protection in Cambodia
OECD (2017) Social protection system review of Cambodia, OECD Development Pathways, OECD Publishing, Paris.
OECD, ERIA, and ASEAN (2018) ASEAN SME Policy Index
Pak (2010) A dominant party in a weak state: How the ruling party in Cambodia has managed to stay in power. ANU University, PhD thesis.
Pak (2019) Assessment of youth policy in Cambodia.
RGC (2011) National Youth Development Policy in Cambodia
RGC (2013) Guideline on preparing the NSDP (2014-2018)
RGC (2013) Guideline on the Procedures and Measures for Developing Legal Documents.
RGC (2013) Sub-decree #488 on the organizational structure and functioning of MEF.
RGC (2015) "Cambodia Industrial Development Policy 2015 – 2025"
RGC (2016) National Social Protection Policy Framework (2016-2025)
RGC (2018) National Strategy for the Development of Statistics (NSDS) (2019-2023)
RGC (2019) Development Cooperation and Partnership Strategy (2019-2023)
RGC (2020) CSDG progress report
RGC (2020) Progress report for 2019 on the CSDGs (2016-2030).
RGC (2021) Cambodia digital economy and society policy framework.
RGC (2021) Report on the assessment of the Implemetnation of National Strategy for the Development of Statistics 2019-2023 and Statistics 2030: Towards Reform Agenda.
RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023)

RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023), World Bank (2020) Cambodia Economic Update: Restrained recovery, AMRO (2021) AMRO annual consultation report – Cambodia 2021.

RGC (2021) Strategic Framework and Program for Cambodia's Economic Recovery (2021-2023)

RGC (2021) Sub-Decree No. 164 on data exchange through Cambodia Data Ex change (CamDX)

Schuring, E and Loewe, M (2021) Handbook on social protection systems.

The Asia Foundation (2019) The knowledge sector in Cambodia: Knowledge pro ducers: Situation, Challenges, and Programming Suggestions

The Asia Foundation (2021) Enduring the Pandemic: Rapid survey on the impact of COVID-19 on MSMEs in the tourism sector in Cambodia

The Asia Foundation (2021) Ponlok Chomnes National Policy Forum Booklet, Phnom Penh, Cambodia.

The Economist (2021) Instant economics – A real time revolution will up-end the practice macro-economics (23rd Oct 2021 Edition).

Un, Kheang (2019) Cambodia: Return to Authoritarianism. Cambridge University Press, 2019.

UNCTAD (2021) Digital economy report 2021: Cross-border data flows and develop ment: For whom the data flow. New York, USA.

UNCTAD (2021) World Investment Report 2021: Investing in sustainable recovery. New York, USA.

UNDP (2020) Meeting the costs and maximizing the impact of social protection in Cambodia

UNDP (2021) How Industry 4.0 can boost Cambodia's economy after COVID-19: Opportunities for industrial upgrading and equiតាភងទី development

UOB (2021) ASEAN SME transformation study 2020. Singapore.

World Bank (2016) Program budgeting in Cambodia

World Bank (2017) Cambodia: Sustaining Strong Growth for the Benefit of All. Washington, DC.

World Bank (2020) Cambodia Economic Update: Restrained recovery,

World Bank (2020) Deepening decentralization within centrally led states: The direction of local governance reforms in Southeast Asia.

World Bank (2021) Intergovernmental fiscal architecture.

World Bank (2021) WDR on Data for Better Lives

World Economic Forum (WEF) (2022) Advancing digital agency: The power of data intermediaries, Insight report February 2022,

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ ស្ថាប័នរបស់អ្នកផ្តល់ព័ត៌មានសំខាន់

១. វិទ្យាស្ថានចក្ខុវិស័យអាស៊ី
២. វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
៣. មជ្ឈមណ្ឌលខេមរសិក្សា
៤. មជ្ឈមណ្ឌលសិក្សាគោលនយោបាយ
៥. មជ្ឈមណ្ឌលបណ្តុះបណ្តាល DataU
៦. ស្ថាប័នស្រាវជ្រាវវេទិកាអនាគត
៧. ក្រុមហ៊ុន Mekong Big Data
៨. ក្រសួងផែនការ
៩. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១០. លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
១១. វិទ្យាស្ថានជាតិស្ថិតិ
១២. កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ
១៣. វិទ្យាស្ថាន Yusof Ishak

# ឧបសម្ព័ន្ធ២៖ ឧទាហរណ៍នៃគេហទំព័រផ្លូវការដែលមានទិន្នន័យ និង/ឬ មូលដ្ឋានទិន្នន័យល្អៗ

| ក្រសួង/ស្ថាប័ន | គេហទំព័រ DBMS ឬ MIS | តំណភ្ជាប់ | ចំណាំ |
|---|---|---|---|
| ទីភ្នាក់ងាររដ្ឋាភិបាល | | | |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) | CamStat | http://camstat.nis.gov.kh/ | វេទិកាអនឡាញសម្រាប់ការចែករំលែកទិន្នន័យទូទាំងរដ្ឋាភិបាលលើវិស័យ/មូលបទចំនួន ១២ |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) | គេហទំព័រផ្លូវការ | https://www.nis.gov.kh/index.php/km/ | ទិន្នន័យថ្នាក់ជាតិផ្សេងៗក្នុងទម្រង់ PDF និង Excel |
| ក្រសួងផែនការ | IDPoor | https://www.idpoor.gov.kh/ | វេទិកាអនឡាញដែលមានទិន្នន័យដើមជាច្រើនដែលអាចទាញយកក្នុងទម្រង់ Excel |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) | សូចនាករម៉ាក្រូសេដ្ឋកិច្ច និងសូចនាករសារពើពន្ធ | https://mef.gov.kh/documents-category/publication/ | ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំស្តីពីសូចនាករម៉ាក្រូសេដ្ឋកិច្ច និងសូចនាករសារពើពន្ធក្នុងទម្រង់ PDF |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) | ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) | https://fmis.mef.gov.kh/ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុទូទាំងរដ្ឋាភិបាលដែលមានទិន្នន័យយ៉ាងច្រើនសម្រាប់ការផលិតព័ត៌មានបច្ចុប្បន្នភាពថវិកាជាប្រចាំ |
| ធនាគារជាតិនៃកម្ពុជា (NBC) | ស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុ | https://www.nbc.org.kh/english/publications/economic_and_monetary_statistics.php | ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំស្តីពីស្ថិតិសេដ្ឋកិច្ច និងស្ថិតិរូបិយវត្ថុ ក្នុងទម្រង់ PDF |
| គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប | មូលដ្ឋានទិន្នន័យ ផ.ស.ថ ជាតិ (NAD) | http://db.ncdd.gov.kh/ | ផ្សារភ្ជាប់នឹងមូលដ្ឋានទិន្នន័យចំនួន ៩ ដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិមជ្ឈការ |
| គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | | | |
| គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CRDB) | មូលដ្ឋានទិន្នន័យ ODA របស់កម្ពុជា | http://odacambodia.com/ | តារាងគម្រោងរបស់ម្ចាស់ជំនួយ និងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអាចទាញយកបានក្នុងទម្រង់ Excel |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ព័ត៌មានស្តីពីការអភិវឌ្ឍកម្ពុជា | http://www.cambodiainvestment.gov.kh | មូលដ្ឋានទិន្នន័យស្តីពីការវិនិយោគរបស់កម្ពុជា ប៉ុន្តែគឺសម្រាប់តែអ្នកប្រើប្រាស់ដែលបានចុះឈ្មោះប៉ុណ្ណោះ |
| ក្រសួងមុខងារសាធារណៈ (MCS) | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិល | http://www.mcs.gov.kh/?p=6444 | ទើបនឹងត្រូវបានដាក់ចេញ មិនទាន់អាចចូលប្រើប្រាស់ជាសាធារណៈ |
| ក្រសួងអប់រំ យុវជន និងកីឡា | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) | https://www.moeys.gov.kh/index.php/en/emis.html | ទិន្នន័យស្ថិតិសំបូរបែបទម្រង់ជាតារាង ប៉ុន្តែមានតែក្នុងទម្រង់ PDF |
| ក្រសួងសុខាភិបាល | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលកម្ពុជា | (មិនមាន) | មិនមានតាមអនឡាញ |

| | | | |
|---|---|---|---|
| ក្រសួងបរិស្ថាន | E-MoE | http://e-moe.moe.gov.kh/ | អះអាងថាមានស្ថិតិស្តីពីវិស័យបរិស្ថាននៅកម្ពុជា ប៉ុន្តែត្រូវបញ្ចូលឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់ |
| អគ្គនាយកដ្ឋានពន្ធដារ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានពន្ធ | https://www.tax.gov.kh/u6rhf7ogbi6/gdt-stream/9c0d924f-df4c-4c76-9d4c-a6d88383ea8f | ប្រព័ន្ធ MIS ផ្ទៃក្នុងដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងពន្ធ |
| ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល | | | |
| ការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា | ផ្ទាំងបង្ហាញរបាយការណ៍ | https://un-cambodia.exploredata.report/?view=-Published | បណ្ណាល័យអនឡាញដែលមានបញ្ជីបច្ចុប្បន្នភាពនៃរបាយការណ៍ផ្សេងៗស្តីពីការអភិវឌ្ឍរបស់កម្ពុជា |
| UNDP | ទិន្នន័យសម្រាប់កម្ពុជា | https://www.dataforcam-bodia.org/ | ទ្រទ្រង់ដោយ UNDP acceletaor lab ជាមួយនឹងផ្ទាំងបង្ហាញព័ត៌មានសំបូរបែបស្តីពីបញ្ហាអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងវិបត្តិកូវីដ-១៩ |
| អង្គការមូលនិធិអាស៊ី | Policy pulse | https://policypulse.org/ | ព័ត៌មានបច្ចុប្បន្នភាពអនឡាញស្តីពីបញ្ជីសារពើភណ្ឌគោលនយោបាយ ព្រឹត្តិការណ៍ ឯកសារបោះពុម្ពផ្សាយ និងកំណែទម្រង់នាពេលថ្មីៗនេះ |
| អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) | ODC | https://opendevelopment-cambodia.net/ | បណ្តុំទិន្នន័យអនឡាញ និងការចែករំលែកប្រធានបទផ្សេងៗ |
| មជ្ឈមណ្ឌលខេមរសិក្សា | មូលដ្ឋានទិន្នន័យតំបន់ប្រជុំជននៅកម្ពុជា | https://urbandatabase.khmerstudies.org/ | ការចងក្រងឯកសារ និងទិន្នន័យដែលមានគុណភាពខ្ពស់ស្តីពីការសិក្សាតំបន់ប្រជុំជននៅកម្ពុជា |
| វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា | មូលដ្ឋានទិន្នន័យថវិកាប្រចាំឆ្នាំ | http://www.cambodi-anbudget.org/index.php?page=00124 | ថវិកាជាតិក្នុងទម្រង់ Excel សម្រាប់ឆ្នាំមួយចំនួន |
| គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា | មូលដ្ឋានទិន្នន័យតម្លាភាព | https://betterfactories.org/transparency/ | មូលដ្ឋានទិន្នន័យដែលត្រួតពិនិត្យស្ថានភាពរោងចក្រនៅកម្ពុជា |
| អាស៊ាន អាស៊ី | | | |
| នាយកដ្ឋានសហគមន៍សេដ្ឋកិច្ចអាស៊ាននៃលេខាធិការដ្ឋានអាស៊ាន | ផ្នែកស្ថិតិអាស៊ាន (ASEAN_stats) | https://www.aseanstats.org/ | មានរបាយការណ៍ជាទម្រង់ pdf ឯកសារដើម និងផ្ទាំងបង្ហាញព័ត៌មាន |
| មជ្ឈមណ្ឌលថាមពលអាស៊ាន | ស្ថិតិថាមពលអាស៊ាន | https://aeds.aseanenergy.org/statistics/ | មូលដ្ឋានទិន្នន័យដែលអាចចូលប្រើប្រាស់ដោយស្ថាប័នរដ្ឋាភិបាលនៃរដ្ឋសមាជិកតែប៉ុណ្ណោះ (រំពឹងថានឹងមានភាពទូលំទូលាយជាងនេះនាពេលអនាគត) |
| ការិយាល័យ IP អាស៊ាន | មូលដ្ឋានទិន្នន័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអាស៊ាន | http://www.asean-gidata-base.org/gidatabase/ | មានរបាយការណ៍ជាទម្រង់ pdf និងឯកសារដើម |

| | | | |
|---|---|---|---|
| មូលនិធិកិច្ចសហប្រតិបត្តិការអាស៊ាន-កូរ៉េ | ការបង្កើតវចនានុក្រមទិន្នន័យបើកចំហអាស៊ានសម្រាប់ការតភ្ជាប់ទំនាក់ទំនងក្នុងអាស៊ាន | https://www.aseanrokfund.com/our-works/development-of-asean-open-data-dictionary-for-asean-connectivity | |
| Think Asia/ADB/TTCSP | Think Asia | https://think-asia.org/ | ផ្តល់ចំណេះដឹងពីស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់កំពូលៗនៅអាស៊ី |
| DBMS/MIS កម្រិតសកល | | | |
| អង្គការអន្តរជាតិខាងការងារ | ILOstat | https://ilostat.ilo.org/ | មានរបាយការណ៍ជាទម្រង់ pdf និងឯកសារដើម |
| ធនាគារអភិវឌ្ឍន៍អាស៊ី | ទិន្នន័យ និងស្ថិតិ | https://www.adb.org/what-we-do/data/main | មានរបាយការណ៍ជាទម្រង់ pdf ឯកសារដើម និងផ្ទាំងបង្ហាញព័ត៌មាន |
| អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ | FAOStat | https://www.fao.org/faostat/en/#home | |
| សន្ទស្សន៍ទិន្នន័យបើកចំហជាសកល | សំណុំទិន្នន័យ GODI | https://index.okfn.org/dataset/ | |
| Google | ការស្វែងរកសំណុំទិន្នន័យ | https://datasetsearch.research.google.com/ | |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | ទិន្នន័យរបស់ IMF | https://www.imf.org/en/Data | |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | ផ្ទាំងផ្សព្វផ្សាយព័ត៌មានស្តង់ដារ (DSBB) | https://dsbb.imf.org/dqrs | |
| Knoema | ទិន្នន័យជាសកល | https://business.knoema.com/global-data-by-knoema/ | |
| Open Data Watch | បញ្ជីសារពើភ័ណ្ឌទិន្នន័យបើកទូលាយ | https://odin.opendatawatch.com/Data/download | |
| OpenGov Asia | ព័ត៌មានស្តីពីអាស៊ី | https://opengovasia.com/about-us/ | របាយការណ៍ជាទម្រង់ PDF |
| អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច | ទិន្នន័យបើកចំហរបស់រដ្ឋាភិបាល | https://www.oecd.org/gov/digital-government/open-government-data.htm | |
| The Open Data Impact Map | បណ្តាញទិន្នន័យបើកទូលាយសម្រាប់ការអភិវឌ្ឍ (OD4D) | https://opendataimpactmap.org/index | |
| ធនាគារពិភពលោក | ទិន្នន័យបើកចំហរបស់ធនាគារពិភពលោក | https://data.worldbank.org/ | |

| | | | |
|---|---|---|---|
| អង្គការតម្លាភាពអន្តរជាតិ | GLOBAL CORRUPTION BAROMETER | https://www.transparency.org/en/gcb | |
| ទិន្នន័យរបស់អង្គការសហប្រជាជាតិ ៖ ពិភពព័ត៌មាន | តារាងស្ថិតិប្រជាជន សារតារប្រទេស (ផ្ទៃក្រឡា) និងសារតារតំបន់ | http://data.un.org/ | |
| ទិន្នន័យរបស់អង្គការសហប្រជាជាតិ ៖ ពិភពព័ត៌មាន | ព្រឹត្តិបត្រស្ថិតិប្រចាំខែ (អនឡាញ) | https://unstats.un.org/unsd/mbs/app/DataSearchTable.aspx | |
| ស្ថិតិពាណិជ្ជកម្មរបស់អង្គការសហប្រជាជាតិ | មូលដ្ឋានទិន្នន័យ UN Comtrade | https://comtrade.un.org/ | |
| អង្គការសហប្រជាជាតិ ៖ នាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម | មូលដ្ឋានទិន្នន័យសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | https://unstats.un.org/sdgs/UNSDG/ | |
| អង្គការសហប្រជាជាតិ ៖ ផ្នែកស្ថាប័នសាធារណៈ និងរដ្ឋាភិបាលឌីជីថល | ទិន្នន័យស្ដីពីទីក្រុង | https://publicadministration.un.org/egovkb/en-us/Data/City/id/16-Phnom-Penh/dataYear/2020 | |
| UNESCO | វិទ្យាស្ថានស្ថិតិ (UIS) របស់ UNESCO | http://data.uis.unesco.org/ | |
| UNICEF | សំណុំទិន្នន័យរបស់ UNICEF | https://data.unicef.org/resources/resource-type/datasets/ | |
| សហភាពសមាគមអន្តរជាតិ | មូលដ្ឋានទិន្នន័យសង្គមស៊ីវិលទូទាំងពិភពលោក | https://uia.org/ybio/ | |
| អង្គការសហប្រជាជាតិ ៖ នាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម | ផ្នែកស្ថិតិ | https://unstats.un.org/home/ | |
| សាកលវិទ្យាល័យ California | ទិន្នន័យ និងស្ថិតិរដ្ឋាភិបាលអន្តរជាតិ | https://guides.lib.berkeley.edu/c. | តភ្ជាប់នឹងមូលដ្ឋានទិន្នន័យបើកទូលាយផ្សេងទៀត |
| World Data Lab | សំណុំទិន្នន័យគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | https://worlddata.io/products | |
| វេទិកាសេដ្ឋកិច្ចពិភពលោក | របាយការណ៍ និងសៀវភៅស | https://www.weforum.org/whitepapers | របាយការណ៍ជាទម្រង់ PDF |
| អង្គការសុខភាពពិភពលោក | ទិន្នន័យរបស់ WHO | https://www.who.int/data | |
| អង្គការកម្មសិទ្ធិបញ្ញាពិភពលោក | មូលដ្ឋានទិន្នន័យ IP | https://www.wipo.int/reference/en/ | |
| អង្គការពាណិជ្ជកម្មពិភពលោក | WTO Stat | https://stats.wto.org/ | |
| មូលនិធិ World Wide Web | The Open Data Barometer | https://opendatabarometer.org/4thedition/?_year=2016&indicator=ODB | |

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី ក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។


**អង្គការមូលនិធិអាស៊ី**

ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ponlokchomnes@asiafoundation.org
(+៨៥៥) ០២៣ ២១០ ៤៣១
https://policypulse.org/


Australian Aid

ពន្លក ចំណេះ

The Asia Foundation